# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ កន តំណាងរាស្ត្រ

## កណ្ឌទី ៩

### ចារឹកឡើងវិញដោយៈ ឈុល ដារ៉ា

*(តាំងពី**តៀវឃី**សម្លាប់**ចូកូ** ហើយ**អេងតៀវ**នាំទាហានរត់ទៅនៅនឹង**អួនសៀវ** ចៅហ្វាយស្រុកគីជីវ លុះដល់**លីប៉ោ**ចាត់ប្រើ**កូស៊ុន, ជុនសុក** និង**ហៅសេង** លើកទាហានទៅរក្សាបន្ទាយទិសខាងលិចយ៉ាងមាំមួន)។*

**កាល**ដែល**ចូឆូ**បានបញ្ចុះបញ្ចូលមនុស្សជាពួកក្រុមសេនាទាហាន បានមនុស្សចុះចូលជាច្រើនព្រមទាំងទីប្រឹក្សា **ចូឆូ**មានសេចក្ដីត្រេកអរពន់ប្រមាណណាស់ ឱ្យ**អេងតៀវ**កាន់សំបុត្រលើកទាហានទៅទទួល**ចូកូ**ជាបិតា ដែលនៅស្រុកតាន់លីវឱ្យមកនៅជាមួយនឹងខ្លួន។ កាល**អេងតៀវ**ទៅដល់ហើយ ក៏ជូនសំបុត្រទៅ**ចូកូ** ៗឃើញសេចក្ដីសំបុត្រសម្គាល់ប្រាកដថាជាពាក្យបុត្ររបស់ខ្លួនមិនមានសង្ស័យ ទើបរៀបប្រមូលទ្រព្យរបស់ធូន់ស្រាល បបួល**ចូតេក**និងបងប្អូនសាច់ញាតិប្រហែលពីររយប្លាយ លើកទ្រព្យរបស់ទាំងអស់ផ្ទុករទេះមួយរយលើកទៅនៅស្រុកគុនជីវ។

លុះទៅដល់ជិតស្រុកគុនជីវហើយ ចៅហ្វាយស្រុកឈីជីវឈ្មោះ**តូកៀម**ជាមនុស្សចិត្តល្អ ធូរទូលាយរួសរាយរាប់អានអ្នកទាំងពួង គិតឃើញថានឹងចូលទៅនៅនឹង**ចូឆូ** លុះដឹងថា**ចូឆូ**ឱ្យទៅទទួល**ចូកូ**ជាបិតាមកដល់ជិតស្រុកឈីជីវហើយ ក៏មានសេចក្ដីត្រេកអរចេញទៅគំនាប់**ចូកូ** ហើយអញ្ជើញឱ្យចូលទៅសំណាក់ក្នុងស្រុកនោះ រួចឱ្យរៀបបាយទឹកចំណីអាហារឱ្យ**ចូកូ**និងក្រុមគ្រួសារបរិភោគ។ **ចូកូ**ឈប់

សម្រាកនៅស្រុកនោះពីរថ្ងៃ រួច**តូកៀម**ចាត់ប្រើ**តៀវយី**និងទាហានប្រាំរយឲ្យជូនដំណើរ**ចូកូ**ទៅស្រុកគុនជីវ។ លុះទៅដល់តំបន់វត្តហែហ៊ុយ ទទួលពេលយប់ធ្លាក់ភ្លៀងធំ **ចូកូ**ឲ្យឈប់សំណាក់អាស្រ័យក្នុងទីនោះ ហើយឲ្យ**តៀវយី**ដែលឃុំទាហានជូនទៅនោះ រាយទាហានព័ទ្ធឡោមយាមល្បាតជុំវិញពីក្រៅ លុះពេលកណ្ដាលអាធ្រាត្រស្ងាត់ **តៀវយី**ប្រឹក្សានឹងទាហានទាំងពួងថា កាលពីដើមយើងជាពួកចោរជូតក្បាលលឿង លុះមានគេមកប្រាបប្រាមយើងលើកលះព្យុហៈអាក្រក់ចេញចូលមកនៅនឹង**តូកៀម** ៗមិនមានឲ្យរបស់អ្វីសោះ ដែលយើងនឹងធ្វើរាជការជាមួយតទៅនោះ ឃើញថាមិនបានប្រយោជន៍អ្វី ឥឡូវ**តូកៀម**ឲ្យយើងជូនដំណើរ**ចូកូ**មក **ចូកូ**មានទ្រព្យសម្បត្តិមាសប្រាក់ផ្ទុកពេញរទេះច្រើនណាស់ យើងត្រូវតែលបសម្លាប់**ចូកូ**ចេញ ហើយយកទ្រព្យរបស់ទាំងអស់ នាំគ្នារត់ទៅនៅច្រកភ្នំស្រួលជាង។ ទាហានទាំងអស់យល់ព្រមផង ភ្លៀងសោតក៏នៅមិនព្រមរាំង **តៀវយី**លើកទាហានចូលទៅនឹងសម្លាប់**ចូកូ** ៗបានឮសូរទាហានគឹកកងចូលមក ស្ទុះឡើងដឹកដៃភរិយាតូចរត់ទៅ។ ទទួល**តៀវយី**ចោមព័ទ្ធពីក្រៅជាប់ សម្លាប់**ចូកូ**ស្លាប់នៅទីនោះ កាប់ទាំងបក្សពួក**ចូកូ**ស្លាប់ដេរដាស ហើយក៏ជញ្ជូនទ្រព្យរបស់អស់គ្មានសល់ យកទាំងភ្លើងដុតកុដិអារាមនៅទីនោះឆេះអស់ទៅទៀត ហើយក៏នាំបក្សពួកទៅជ្រកពួននៅព្រៃកៀនភ្នំ។

ឯ**អេងតៀវ**កាលឃើញ**ចូកូ**ស្លាប់ហើយ ក៏គិតបារម្ភខ្លាច**ចូឆូ** ទើបរត់ទៅនៅនឹង**អ្នូនសៀវ**ចៅហ្វាយស្រុកគីជីវ។ ពួកទាហានដែលទៅជាមួយនឹង**អេងតៀវ** ក៏នាំគ្នារត់ត្រឡប់ទៅប្រាប់**ចូឆូ**តាមដំណើរដែលមានមកពីដើម ហើយថា**ចូកូ**បិតាលោកដែលស្លាប់នោះ យើងខ្ញុំយល់ឃើញថា**តូកៀម**ប្រើឧបាយកលឲ្យ**តៀវយី**នាំទាហាន

ជូនដំណើរមក ហើយក្លែងលបសម្លាប់បិតាលោក យកទ្រព្យរបស់ទៅឲ្យ**តូកៀម**ជាប្រយោជន៍ជាមួយគ្នា។ **ចូឆ្វ**បានឮថាបិតាស្លាប់ក៏ទួញយំដំឱរាអាល័យបិតា ទាល់តែដួលផ្ដាក់ពីលើកៅអីបាត់ស្មារតីក្នុងទីនោះ។ ពួកទាហានកាលឃើញដូច្នោះ ក៏ស្ទុះទៅគ្រាហ៍ត្រកងឡើងវិញ។ **ចូឆ្វ**លុះដឹងស្មារតីហើយ មានសេចក្ដីខឹងខ្លាំងណាស់ថា "ដែល**តូកៀម**ធ្វើកលឧបាយសម្លាប់បិតាយើង និងក្រុមញាតិរបស់យើង វេលានេះយើងនឹងលើកពួកពលទាហានទៅសង្កត់យកស្រុកឈីជីវឲ្យរាបដូចផែនដី ទើបអស់សេចក្ដីក្ដៅ" ថាហើយក៏កេណ្ឌប្រមូលពលទាហានបានចំនួនបីម៉ឺនប្រគល់ឲ្យ**ស៊ុនហុក** និង**ធៀយ៉ុក** នៅរក្សាស្រុកគុនជីវ។ ឯខ្លួន**ចូឆ្វ**ក៏កេណ្ឌទាហានជាច្រើនលើកជាក្បួនទ័ពទៅជិតស្រុកឈីជីវ ហើយឲ្យតាំងបន្ទាយរាយព័ទ្ធជុំវិញ ចាត់ប្រើ**ហែហ្គូទុន** និង**អ៊ីគឹម**, **តៀនអ៊ុយ**ឲ្យលើកទាហានជាកងមុខ បើវាយបានស្រុកឈីជីវហើយ ឲ្យសម្លាប់ឲ្យអស់ទាំងប្រុសទាំងស្រីកុំឲ្យសល់ទើបអស់កំហឹង។

ខណៈនោះ**ពៀនយៀង** ចៅហ្វាយស្រុកគីវតាំង ដែលជាមិត្តស្និទ្ធស្នាលនឹង**តូកៀម**លុះបានដំណឹងថា **ចូឆ្វ**លើកទ័ពមកនឹងវាយយកស្រុកឈីជីវដូច្នេះ ក៏កេណ្ឌទាហានប្រាំពាន់លើកទៅជួយ**តូកៀម**។ **ចូឆ្វ**បានដឹងដូច្នោះ ចាត់ប្រើ**ហែហ្គូទុន**ឲ្យលើកទាហានទៅស្កាត់វាយទ័ព**ពៀនយៀង** បានតទល់គ្នា **ហែហ្គូទុន**ក៏ច្បាំងកាប់សម្លាប់**ពៀនយៀង**និងពលទាហានស្លាប់អស់។

ឯ**តាន់កុង**ដែលលបរត់ចោល**ចូឆ្វ**ពីគ្រាមុននោះ បានទៅសុំនៅធ្វើរាជការជាមួយនឹងចៅហ្វាយស្រុកតងគុន ខ្លួន**តាន់កុង**ជាមិត្តស្និទ្ធស្នាលនឹង**តូកៀម**ដែរ កាលបើឮដំណឹងថា**ចូឆ្វ**លើកទ័ពទៅវាយស្រុកបានហើយ ឲ្យទាហានកាប់សម្លាប់មនុស្សទាំងប្រុសទាំងស្រីឲ្យអស់ **តាន់កុង**ក៏ឡើងសេះតែម្នាក់ឯងស្រូតទៅទាំងយប់ទាំងថ្ងៃ

ដើម្បីនឹងហាមឃាត់**ចូឆ្វ**កុំឲ្យធ្វើអន្តរាយ**តូកៀម** លុះទៅដល់មុខបន្ទាយនិយាយប្រាប់ទាហាន**ចូឆ្វ**ថា យើងសុំទៅជួបនឹង**ចូឆ្វ** ទាហានក៏ចូលទៅជម្រាប**ចូឆ្វ** ៗដឹងហើយនឹកក្នុងចិត្តថា "ដែល**តាន់កុង**មករកយើងនៅគ្រានេះ មិនគឺអ្វី ប្រហែលមានការនិយាយពីរឿង**តូកៀម**ជាប្រាកដ។ បើយើងមិនឲ្យចូលមកក៏បាន តែថាគេមានគុណូបការនឹងយើង កាលយើងរត់ពី**តាំងតុះ**។ **តាន់កុង**នេះចាប់បានហើយមិនបញ្ជូនខ្លួនយើងទៅ បានជាយើងរស់រួចជីវិត" គិតហើយឲ្យទាហានហៅខ្លួន**តាន់កុង**ចូលមក។ **ចូឆ្វ**គំនាប់ហើយសួរថា អ្នកមករកយើងនេះមានត្រូវការរឿងអ្វី? **តាន់កុង**ជម្រាបថា ខ្ញុំដឹងថាលោកលើកទ័ពមកច្បាំងនឹង**តូកៀម** ប្រយោជន៍នឹងសងសឹកព្រោះបិតាលោកស្លាប់ ឯ**តូកៀម**ចៅហ្វាយស្រុកឈើជីវនោះ ខ្ញុំបានស្គាល់ចិត្តនិងគំនិតមារយាទជាមនុស្សសុចរិតពិតត្រង់ណាស់ បានប្រើ**តៀវឃី**នាំទាហានជូនដំណើរបិតាលោកទៅដល់តំបន់ហៃហ៊ុយ ដែលកើតហេតុឡើងក្នុងទីនោះ ព្រោះ**តៀវឃី**ជាមនុស្សទុច្ចរិតចិត្តលោភសម្លាប់បិតាលោក យកទ្រព្យរបស់អស់ហើយរត់ទៅពួនក្នុងព្រៃទាល់តែសម័យនេះ។ **តូកៀម**នឹងបានរួមគំនិតឧបាយក្លាយក្លែងឲ្យធ្វើដូច្នេះក៏ទេ ដែលលោកបង្គាប់ទាហានថាបើវាយបានស្រុកឈើជីវហើយ ឲ្យសម្លាប់ទាំងប្រុសទាំងស្រីឲ្យអស់នោះ ខ្ញុំឃើញថាអ្នកស្រុកនោះគ្មានទោសខុសអ្វីសោះ លោកនឹងឲ្យសម្លាប់នោះមិនគួរ ដែលខ្ញុំជម្រាបទាំងនេះសូមលោកត្រិះរិះមើលសិនចុះ។

**ចូឆ្វ**ឮហើយខឹងច្រឡោតឡើងទៀតថា កាលយើងរត់ពី**តាំងតុះ**មកនោះ អ្នកគិតព្រមលួមនៅជាមួយយើង ហេតុម្ដេចក៏រត់ចោលយើងកណ្ដាលផ្លូវ ឥឡូវត្រឡប់មករកយើងវិញ ឯ**តូកៀម**ប្រាកដជាប្រើឧបាយឲ្យជូនបិតាយើងទៅ ហើយក្លែងឲ្យ

សម្លាប់យកទ្រព្យរបស់ជាពិត ហេតុនេះ ទើបយើងឈឺចិត្តលើកទ័ពមកសងសឹក**តូកៀម**វិញ ដែលអ្នកនឹងបែរមុខឃាត់ហាមយើងនោះ យើងមិនស្ដាប់អ្នកទេ។ **តាន់កុង**ឃើញ**ចូឆ្វ**ខឹងខ្លាំងណាស់ ក៏នៅស្ងៀម ហើយលា**ចូឆ្វ**ចេញពីបន្ទាយមកវិញ ហើយនឹកគិតតែក្នុងចិត្តថា “អញមកហាមឃាត់**ចូឆ្វ**មិនសមដូចសេចក្ដីប្រាថ្នា បើនឹងទៅរក**តូកៀម**ក៏ចៀមចិត្តគួរគិតឲ្យអៀនខ្មាស” គិតហើយក៏ដើររូតរះទៅរក**តៀវម៉ៅ**នៅស្រុកតាន់លីវ។

ឯ**ចូឆ្វ**លើកទាហានទន្ទ្រានចូលទៅជិតស្រុកឈីជីវ ប្រទះនឹងមនុស្សប្រុសស្រីត្រង់កន្លែងណា ក៏ឲ្យប្រហារឥតញញើតដៃសោះ ហើយឲ្យរើរិបយកទ្រព្យរបស់មកទុកជាច្រើន។

ខណៈនោះ**តូកៀម**ចៅហ្វាយស្រុកឈីជីវ ដែលដឹងថា**ចូឆ្វ**លើកទ័ពមកកាប់សម្លាប់អស់អ្នកស្រុកដូច្នោះ ក៏មានសេចក្ដីបរិវិតក្កកើតទុក្ខវេទនាសោកាទួញយំអាណិតអាណាប្រជានុរាស្ត្រពន់ប្រមាណ បានប្រជុំទីប្រឹក្សាពិចារណាយល់ឃើញថា ការណ៍ដែលកើតហេតុទាំងនេះ ព្រោះអកុសលកម្មរបស់យើងតាមមកទាន់ហើយ បានជាត្រូវអន្តរាយស្លាប់គ្រប់គ្នា។ **ចូប៉ា**ឆ្លើយថាខ្លួនលោកគ្មានសេចក្ដីខុសអ្វីសោះ ឥឡូវនេះ**ចូឆ្វ**លើកទ័ពមកធ្វើអន្តាយដូច្នេះ លោកចេះតែនៅស្ងៀមក៏ពុំកើត សត្រូវកាន់តែរំជួលឡើងទៀត ត្រូវយើងរកកេណ្ឌកងទ័ពត្រឡប់ទៅតាំងច្បាំងគ្នាវិញទើបាន។ **តូកៀម**ឃើញត្រូវផង ក៏តាំងកេណ្ឌទាហានបានក្នុងខណៈនោះ ដល់ព្រឹកឡើងឲ្យបើកទ្វារស្រុកលើកទាហានចេញទៅក្រឡោកទៅឃើញកងទ័ព**ចូឆ្វ**ច្រើនលើសលុប ឧបមាដូចរលកសមុទ្រ។

ឯ**ចូឆ្វ**ឃើញ**តូកៀម**លើកទាហានចេញមក ក៏ឡើងសេះជិះត្រឡប់ទៅមុខទាហាន ឲ្យទាហានទាំងអស់វាយគ្នាជាប៉ែកឆ្វេងស្ដាំ។ **តូកៀម**ក៏ឡើងសេះជិះតម្រង់ទៅបញ្ចេញខ្លួនឱនគំនាប់**ចូឆ្វ**ហើយនិយាយថា ពីដើមខ្ញុំបម្រុងខ្លួននឹងចូលទៅធ្វើរាជការជាមួយនឹងលោកជាប្រាកដ លុះឃើញបិតាលោកលើកគ្រប់គ្រួមកដល់ខេត្តខ្ញុំៗក៏បានគួរសមទទួលនាំទៅឈប់ស្នាក់លើទីគ្រឹហាស្ថាន បានតាំងរៀបភោជនាហារដ៏ប្រសើរឲ្យពិសាជាទីរាប់អាន ហើយខ្ញុំបានចាត់ប្រើ**តៀវឃើ**ឲ្យនាំទាហានជូនដំណើរបិតាលោកទៅទៀត ប្រាថ្នានឹងជួយការពារអន្តរាយ ហើយប្រាថ្នានឹងឲ្យបានសេចក្ដីគាប់ប្រសើរពីលោកផង។ តែថា**តៀវឃើ**ជាមនុស្សទុច្ចរិត ប្រែចិត្តចេញពីខ្ញុំនាំបិតាលោកនិងបក្សពួកទៅសម្លាប់យកទ្រព្យ។ ខ្ញុំនឹងបានបង្គាប់ឲ្យធ្វើដូច្នោះក៏ទេ ដែលលោកមកខឹងនឹងខ្ញុំជាគំនុំគុំគួនខ្លាំង ហើយលើកទាហានមកច្បាំងសម្លាប់អ្នកស្រុក ដែលមិនមានទោសខុសផងនោះ ខ្ញុំឃើញថាមិនគួរណាស់។ សូមលោកត្រិះរិះមើលដោយគួរសិនចុះ។ **ចូឆ្វ**ឮដូច្នោះខឹងច្រឡោតជេរប្រមាថ**តូកៀម**ជាពាក្យអាស្រូវភាសផ្សេងៗ ហើយស្រែកថា "អាឯងប្រើឧបាយកលពន្យល់ឲ្យទាហានសម្លាប់បិតាអញ និងបក្សពួកអស់ជាប្រាកដ ហើយមកបើកមាត់និយាយកែខ្លួន សុទ្ធតែពាក្យសំនួនគួរសមល្អណាស់" ហើយស្រែកប្រកាសថា នរណានឹងទទួលយកអាសាទៅចាប់ខ្លួន**តូកៀម**ឲ្យយើងបាន? **ហែហ្គូទុន**ឆ្លើយទទួលយកអាសាឡើងជិះសេះចេញទៅនឹងចាប់**តូកៀម**។ **ចូប៉ា**ឃើញហើយបរសេះចេញមកតយុទ្ធគ្នានឹង**ហែហ្គូទុន**បានប្រាំភ្លែង ទទួលកើតខ្យល់ព្យុះធ្លាក់រំលាជាខ្លាំង ពួកពលដែលកំពុងច្បាំងក៏ថយទៅឈប់តែសព្វខ្លួន។ ឯ**តូកៀម**កាលត្រឡប់ចូលទៅស្រុកហើយ ក៏ប្រឹក្សានឹងសេនាទាហានទាំងពួងថា ទាហានរបស់យើងនឹងតស៊ូទ័ព**ចូឆ្វ**មិនបានទេ

បើប្រឹងច្បាំងទៅកាលណា បណ្ដាទាហាននិងអាណាប្រជានុរាស្ត្រក្នុងស្រុកនឹងស្លាប់អស់ហើយ បើដូច្នេះគួរតែអ្នករាល់គ្នានាំយកខ្លួនយើងទៅចងចំណងឲ្យជាប់ ហើយនាំទៅឲ្យ**ចូឆូ**តែម្ដងចុះ ទើបបានរួចជីវិតទាំងអស់គ្នា។

ក្នុងពេលនោះ មានឈ្មោះ**ប៊ឹតុក**ពួកអ្នកស្រុកតងហៃ កាលពីដើមធ្វើដង្ខៅលក់ដូរ មានទ្រព្យសម្បត្តិច្រើនណាស់ គ្រានោះគ្នាទៅលលក់ឯស្រុកឡុកអៀងនោះ លុះលលក់អស់ហើយក៏បររទេះត្រឡប់មកវិញ។ មានស្រីម្នាក់រូបល្អស្រស់អាយុដប់ប្រាំមួយឆ្នាំ សុំដោយសាររទេះ**ប៊ឹតុក**មកស្រុកតងហៃផង។ **ប៊ឹតុក**យោគយល់អាណិតដ្បិតជាស្រី ក៏ប្រណីឲ្យឡើងជិះរទេះ ឯខ្លួនឯងក៏ចុះដើរទៅ។ ស្រីនោះនិយាយថា ខ្លួនខ្ញុំជាអ្នកដោយសារ នឹងអង្គុយលើរទេះឲ្យម្ចាស់ចុះដើរមិនគួរសោះ បើដូច្នេះអ្នកឡើងមកជិះវិញចុះ។ **ប៊ឹតុក**ក៏ឡើងបរអង្គុយពីមុខ ស្រីនោះអង្គុយពីក្រោយ។ ខ្លួន**ប៊ឹតុក**នឹងបានក្រឡេកមើលឲ្យស្គាល់ស្រីនោះជាយ៉ាងម្ដេចក៏ទេសោះ។ លុះបរទៅដល់ស្រុកតងហៃ ស្រីនោះនិយាយថា “ខ្លួនយើងមិនមែនជាមនុស្សទេ គឺជាស្រីទេពអប្សរ ទេវតាជាធំប្រើឲ្យយើងយកភ្លើងមកដុតផ្ទះអ្នកឯង ទើបយើងក្លែងសុំជិះរទេះដោយលចិត្តមើល ឃើញថាអ្នកឯងមិនធ្វើអន្តរាយដល់ខ្លួនយើងនោះ គឺចិត្តអ្នកសុចរិតល្អត្រង់មែន ប្រសិនជាយើងនឹងមិនយកភ្លើងទៅដុតផ្ទះអ្នកក៏ឃើញថាខុសនឹងបង្គាប់ទេវតាជាធំ បើដូច្នេះអ្នកចូរជញ្ជូនទ្រព្យរបស់ពីក្នុងផ្ទះចេញឲ្យអស់ក្នុងវេលាយប់នេះ ស្រីនោះក៏អន្តរធានបាត់ទៅ។ **ប៊ឹតុក**បានឃើញដូច្នោះ ក៏មានសេចក្ដីអស្ចារ្យក្នុងចិត្តណាស់ ទើបរវៀសរវៃទៅដល់ផ្ទះហើយ ចាត់ឲ្យជញ្ជូនរើយកទ្រព្យរបស់អស់ពីក្នុងផ្ទះ។ ដល់ពេលអាធ្រាត្រស្ងាត់ ស្រាប់តែបណ្ដាលភ្លើងឆេះផ្ទះ**ប៊ឹតុក**អស់រលីង ឯទ្រព្យរបស់ដែលជញ្ជូនចេញទៅនោះ **ប៊ឹតុក**លើកឲ្យទៅជាទាន

ស្មូមយាចកអស់គ្មានសល់។ កិត្តិស័ព្ទនោះក៏ឮខ្ចរខ្ចាយទៅដល់**តូកៀម** ៗចាត់ឲ្យមនុស្សទៅយកខ្លួន**ប៊ឹតុក**មកទុកជាទីប្រឹក្សា។

កាល**ប៊ឹតុក**បានឮ**តូកៀម**ព្រមឲ្យគេចាប់ខ្លួនទៅជូន**ចូឆ្វ**ដូច្នោះ **ប៊ឹតុក**ក៏ឆ្លើយទាស់ថា លោកជាទីចៅហ្វាយស្រុកឈីជីវ សន្តានចិត្តរបស់លោកប្រកបដោយសុចរិតពិតត្រង់ ទាំងមានមេត្តាករុណាដល់ប្រជានុរាស្ត្រជាជ្រៅទូលាយណាស់ ដែលលោកនឹងឲ្យចងខ្លួនលោកទៅឲ្យ**ចូឆ្វ**នោះមិនសមគួរទេ។ បណ្ដារាស្ត្រទាំងពួងនឹងអស់ទីពឹងពំនាក់សោះ។ លោកត្រូវតែគិតកេណ្ឌកងសេនាទាហានឲ្យបានគ្រប់គ្រាន់ហើយឲ្យឡើងរក្សាសើនបន្ទាយឲ្យមាំមួនចុះ។ បើធ្វើដូច្នោះឃើញថា **ចូឆ្វ**នឹងពុះពារទម្លាយដោយងាយមិនបាន មួយទៀតសុំឲ្យលោកធ្វើសំបុត្រឲ្យខ្ញុំកាន់ទៅសុំកងទ័ព**ខុងយ៉ុង**ចៅហ្វាយស្រុកប៉ាក់ហៃ យកមកជួយតតាំងច្បាំងនឹង**ចូឆ្វ**មួយច្បាប់ មួយច្បាប់ទៀត ឲ្យចាត់ប្រើទាហានកាន់សំបុត្រទៅសុំកងទ័ព**តេងកៃ**ចៅហ្វាយស្រុកឈៀងជីវមកជួយផង ទុកជាកងទ័ពសន្ទប់ខ្ទប់វាយទ័ព**ចូឆ្វ**ក៏គង់តែនឹងបែកមិនខាន។ **តូកៀម**បានស្ដាប់ហើយយល់ឃើញត្រូវ ទើបសួរទៅ**ប៊ឹតុក**ថា នរណានឹងទទួលយកអាសារកាន់សំបុត្រទៅឲ្យ**តេងកៃ**? **តាន់កេង**ឆ្លើយថា ខ្ញុំបាទសូមទទួលអាសា។ **តូកៀម**ក៏ឲ្យធ្វើសំបុត្របោះត្រាប្រគល់ឲ្យ**ប៊ឹតុក** និង**តាន់កេង**កាន់យកទៅខណៈនោះ។

ឯ**ខុងយ៉ុង**ចៅហ្វាយស្រុកប៉ាក់ហៃ ជាមនុស្សមានចិត្តធូរទូលាយរួសរាយគប់ប្រសព្វពួកម៉ាកជាច្រើននាក់ បណ្ដារាស្ត្រក្នុងស្រុកមានសេចក្ដីមេត្រីរាប់អាន។ **ខុងយ៉ុង**នោះមានទាហានមកទទួលទានអាហារលើផ្ទះ លុះឃើញ**ប៊ឹតុក**យកសំបុត្រទៅដល់ ក៏មើលដឹងសេចក្ដីហើយថា **តូកៀម**និងយើងជាមនុស្សស្រឡាញ់រាប់អាន

គ្នាមកយូរ ខាង**ចូឆ្វ**មិនដែលមានរឿងអ្វីនឹងយើងដូចគ្នា បើយើងនឹងធ្វើសំបុត្រទៅហាមឃាត់ **ចូឆ្វ**ក៏ប្រហែលនឹងស្ដាប់ពុំបាន បើត្រឡប់ជាមិនស្ដាប់យើងវិញ សុំយើងលើកទ័ពទៅជួយ**តូកៀម**ជាក្រោយ។ **ប៊ីតុក**ថា **ចូឆ្វ**នោះខឹងគុំគួននឹង**តូកៀម** ថាប្រើឧបាយសម្លាប់**ចូក្វ**ជាបិតា បើលោកនឹងឲ្យសំបុត្រទៅឃាត់វេលាណា ខ្ញុំឃើញថា **ចូឆ្វ**គង់មិនស្ដាប់ ខាងនេះចង់ប្រញាប់ក៏នឹងនាំឲ្យយូរការ។ **ខុងយ៉ុង**ឆ្លើយថា អ្នកនិយាយដូច្នេះត្រូវណាស់ យើងនឹងប្រើបម្រើយ៉ាងរហ័សឲ្យកាន់សំបុត្រទៅ ឯទាហានខាងនេះក៏យើងត្រូវកេណ្ឌបញ្ជូនឲ្យចេញទៅព្រមជាមួយគ្នាតែម្ដង។

កាលកំពុងនិយាយគ្នានោះ មានបម្រើសេះមកជម្រាប**ខុងយ៉ុង**ថា **ក្វនហៃ**ឃុំនាំពួកចោរជូតក្បាលលឿងប្រហែលបួនប្រាំម៉ឺន លើកចូលមកជិតដល់ស្រុកយើងហើយ។ **ខុងយ៉ុង**ឮច្បាស់ក៏មានសេចក្ដីភ័យណាស់រលះរលាំង តាំងតែឲ្យកេណ្ឌទាហានលើកទៅតទល់នឹងពួកចោរ។ **ក្វនហៃ**ឡើងជិះសេះបរចេញមកមុខទាហានហើយស្រែកហៅ**ខុងយ៉ុង**ថា ដែលយើងលើកទ័ពមកនេះប្រាថ្នានឹងរកស្បៀងអាហារ បើអ្នកព្រមឲ្យស្បៀងយើងមួយម៉ឺនថាំង យើងនឹងលើកកងទ័ពត្រឡប់ទៅវិញ បើអ្នកមិនព្រមឲ្យយើងទេ យើងនឹងលើកកងទ័ពខ្ទប់វាយយកស្រុកនេះឲ្យបានហើយឲ្យសម្លាប់ភរិយាបុត្រនិងញាតិសន្ដានមិនឲ្យមានសល់។

**ខុងយ៉ុង**ស្រែកតបថា ខ្លួនយើងជាមន្ត្រីមានបណ្ដាស័ក្ដិរក្សាខបខណ្ឌសីមារបស់ព្រះមហាក្សត្រ ខ្លួនឯងជាចោរកំណាចទុច្ចរិត ដែលឯងមកគិតកំហែងឲ្យយើងជូនស្បៀងទៅឲ្យនោះ យើងមិនត្រូវការឲ្យទេ បើឯងខ្លាំងពូកែនឹងចង់វាយទម្លាយយកស្រុកយើង ក៏តាមចិត្តឯងចុះ យើងមិនខ្លាចទេ។

**កួនហៃ**ខឹងណាស់ ជិះសេះរាំងាវចូលប្រយុទ្ធនឹង**ខុងយ៉ុង**។ **ចុងប៉ោ**ទាហាន**ខុងយ៉ុង**ក៏ឡើងសេះចេញទៅតទល់នឹង**កួនហៃ**បានប្រាំស្នៀត **កួនហៃ**យកដាវកាប់**ចុងប៉ោ**ធ្លាក់ពីលើសេះស្លាប់ ។ **ខុងយ៉ុង**ឃើញថានឹងទប់ទល់ពុំឈ្នះ ក៏រួតរះថយទាហានចូលទៅក្នុងស្រុកវិញ។ **កួនហៃ**លើកពលទាហានចោរឡោមព័ទ្ធជុំវិញស្រុកនោះច្រើនថ្ងៃ ឯ**ប៊ីតុក**ដែល**តួកៀម**ឱ្យនាំសំបុត្រមកសុំកងទ័ព ក៏ជាប់នៅក្នុងស្រុក**ប៉ាក់ហៃ** ដោយសេចក្ដីព្រួយទុក្ខជាមួយនឹង**ខុងយ៉ុង**។

លុះព្រឹកព្រាងឡើង **ខុងយ៉ុង**ឡើងមើលលើសើនបន្ទាយ ឃើញពួកចោរព័ទ្ធជុំវិញ **ខុងយ៉ុង**ក៏ប្រៀបប្រុងទាហានយាមល្បាតប្រយ័ត្នការជាមាំមួនណាស់។

ពេលនោះមានទាហានម្នាក់ជិះសេះពុំពារទម្លាយកងទ័ពចោរ ចូលមកដល់ទ្វារស្រុកស្រែកឱ្យបើកទ្វារទទួល។ **ខុងយ៉ុង**ក្រឡេកឃើញមិនទាន់ហ៊ានបើកព្រោះមិនស្គាល់ច្បាស់ ឯពួកចោរក៏តាមស្រចូលមក។ ទាហានម្នាក់នោះក៏ប្រែមុខត្រឡប់ទៅវិញ ដេញកាប់ពួកចោរស្លាប់ជាច្រើន។ **ខុងយ៉ុង**ឃើញច្បាស់បង្គាប់ឱ្យបើកទ្វារទទួល ទាហាននោះក៏ចូលមក។ **ខុងយ៉ុង**សួរថា អ្នកឈ្មោះអ្វី? មកពីណាបានជាពុះពារទម្លាយពួកចោរចូលមកបាន? **ថៃស៊ូជូ**លោតចុះពីលើសេះបោះទួនចេញពីដៃចេញ ហើយឱនគំនាប់ថា ខ្ញុំបាទឈ្មោះ**ថៃស៊ូជូ** នៅស្រុកអ៊ុយគួន មាតាខ្ញុំបាទបានសរសើរដល់គុណលោកថា បានឱ្យអាវសំពត់និងបាយទឹក ត្រីសាច់ដល់មាតាខ្ញុំមកពីដើម ឥឡូវនេះមាតាខ្ញុំបានដឹងឮថា ពួកចោរមកចោមព័ទ្ធស្រុកទើបគាត់ប្រើខ្ញុំបាទឱ្យមកជួយច្បាំង ប្រាថ្នានឹងតបស្នងសងគុណ បានជាខ្ញុំបាទខំពុះពារទម្លាយពួកចោរចូលមកនេះ។ ខ្ញុំបាទសម្លាប់អស់ចោរជាច្រើន។ **ខុងយ៉ុង**បានឮច្បាស់ ក៏នឹករឭកឃើញបាន ហើយតបថា “កាលអ្នកនៅពីតូចនោះ យើងសម្គាល់ថានឹងមាន

សតិបញ្ញាគួរជាទាហានបាន បានជាយើងយករបស់ទៅឲ្យដើម្បីចងជាមេត្រីទុកនឹងមាតារបស់អ្នក ដែលមាតាប្រើអ្នកមកជួយធុរៈយើងគ្រានេះ យើងមានសេចក្ដីសោមនស្សត្រេកអរណាស់" និយាយហើយក៏យកក្រឹសនិងអាវឲ្យ។ **ថៃស៊ូជួ**ទទួលយកក្រឹសនិងអាវដោយអំណរ ហើយគំនាប់ជម្រាបថា ខ្ញុំបាទនឹងសុំទាហានមួយពាន់លើកចេញទៅវាយពួកចោរត្រាតែបែកឲ្យបាន។

**ខុងយ៉ុង**ឃាត់ហាមថា ខ្លួនអ្នកមានថ្វីដៃខ្លាំងពូកែមែនហើយ តែថាវេលានេះ ពួកចោរច្រើនខ្លាំងពូកែណាស់ ក្រែងអ្នកតទល់ពុំបាន។ **ថៃស៊ូជួ**តបថា លោកមានគុណនឹងមាតាខ្ញុំជាច្រើន ទោះបីខ្ញុំបាទនឹងស្លាប់ក្នុងកងទ័ពក៏ពុំស្ដាយជីវិត ខ្ញុំបាទគិតឲ្យបានតែតបគុណលោកដែលមានឧបការៈនឹងមាតាខ្ញុំបាទប៉ុណ្ណោះ។ បើខ្ញុំបាទត្រឡប់ទៅវិញហើយមាតាដឹងថាខ្ញុំបាទពុំបានធ្វើការអ្វីសោះ ទោសខ្ញុំបាទក៏មានច្រើន។ **ខុងយ៉ុង**តបថា ត្រូវហើយយើងចង់បានអ្នកទុកជាទីប្រឹក្សាទើបហាមឃាត់ដូច្នេះ ព្រោះទាហានអ្នកស្រុកយើងតិចណាស់ ឯ**ឡៅពី**គេមានសតិបញ្ញាបាន**គួនអ៊ូ, តៀវហ៊ុយ**ទុកជាកម្លាំង បើបាន**ឡៅពី**មកជួយច្បាំងជាទ័ពសន្ទប់ ពួកទ័ពចោរក៏គង់នឹងបែកពុំខាន។ តែថានឹងរកអ្នកណាកាន់សំបុត្រពុះពារទម្លាយទៅគ្មាន។ **ថៃស៊ូជួ**តបថា បើលោកមិនឲ្យខ្ញុំបាទចេញទៅច្បាំងទេ នឹងឲ្យខ្ញុំបាទនាំសំបុត្រទៅវិញ ខ្ញុំបាទនឹងនាំចេញទៅឲ្យ**ឡៅពី**។

**ខុងយ៉ុង**ក៏តាំងធ្វើសំបុត្រជាសេចក្ដីថា "**ខុងយ៉ុង**ចៅហ្វាយស្រុកប៉ាក់ហៃឲ្យពរមកដល់**ឡៅពី**ចៅហ្វាយស្រុកផេងងួនគួន ដ្បិតវេលានេះ**ក្វនហៃ** នាំពួកចោរកំណាចប្រហែលបួនប្រាំម៉ឺនមកឡោមព័ទ្ធខេត្តខ្ញុំជុំវិញ អ្នកចូរមានចិត្តគិតមេត្តាដល់ខ្ញុំ លើកទ័ពមកច្បាំងសម្លាប់ពួកចោរជាទ័ពខ្ទប់ពីក្រៅឲ្យបាន ខ្ញុំនឹងអ្នកក៏មានផ្លូវ

មេត្រីនឹងគ្នាតទៅ” លុះធ្វើសំបុត្រហើយក៏ប្រគល់ឲ្យ**ថៃស៊ូជូ** ៗទទួលសំបុត្រភ្លាម ក៏ត្រៀមខ្លួនពាក់ក្រឹសជិះសេះកាន់ទួនបរចេញតាមទ្វារស្រុក ទៅដល់មុខបន្ទាយទ័ពចោរ។ **គួនហៃ**ឃើញក៏លើកទាហានស្រចេញមកដេញចាប់**ថៃស៊ូជូ** ៗក៏បង្រុះពុះពារទ័ពចោរតនឹងអាវុធឥតរួញរា ពួកចោរពិការស្លាប់និងគណនារាប់ពុំបាន។ **ថៃស៊ូជូ**ចេះតែកាប់ឆ្ការបំពារធ្លុះធ្លាយទៅ លុះទៅដល់ស្រុកផេងងួនគួន ចូលទៅគំនាប់**ឡៅពី**ហើយជូនសំបុត្រទៅ**ឡៅពី**មើល។ **ឡៅពី**ដឹងក្នុងសេចក្តីសំបុត្រនោះនៅមិនទាន់ឆ្លើយថាម្តេច ក៏លួចសម្លឹងមើលរូបភាព**ថៃស៊ូជូ** ឃើញមាំមួនសួនសមជាទាហានហើយសួរថា អ្នកឈ្មោះអ្វី? **ថៃស៊ូជូ**ឆ្លើយថា ខ្ញុំបាទឈ្មោះ**ថៃស៊ូជូ** នឹងបានជាញាតិសាលោហិតនឹង**ខុងយ៉ុង**ក៏ទេ ដែលខ្ញុំបាទទទួលយកអាសាមកនេះ ព្រោះ**ខុងយ៉ុង**មានគុណនឹងមាតាខ្ញុំបាទពីដើម។ **ឡៅពី**បានស្តាប់ក៏ចាប់ចិត្តស្រឡាញ់ហើយសរសើរ**ថៃស៊ូជូ**ថា ជាអ្នកមានចិត្តកតញ្ញូនឹងមាតា ហើយប្រាប់ថាដែល**ខុងយ៉ុង**រាប់អានឲ្យមកសុំកងទ័ពយើងទៅជួយនោះ យើងមុខជានឹងលើកទៅតាមត្រូវការ។ ពេលនោះ**ឡៅពី**ក៏ឲ្យ**គួនអ៊ូ, តៀវហ៊ុយ** ប្រមូលសេនាទាហានបីពាន់ហើយនាំ**ថៃស៊ូជូ**លើកចេញទៅស្រុកប៉ាក់ហៃ។

ឯ**គួនហៃ**នាយចោរ លុះឃើញកងទ័ពលើកមកពីក្រោយដឹងថាជាទ័ពលើកមកជួយ**ខុងយ៉ុង** ក៏ប្រៀបប្រុងទាហានងាកទៅតទល់។ **ឡៅពី**បរពលចូលទៅជិតហើយ ឲ្យ**គួនអ៊ូ, តៀវហ៊ុយ** និង**ថៃស៊ូជូ** បរសេះស្រូតទៅមុខទាហាន។ **គួនហៃ**ក្រឡេកឃើញកងទ័ពដែលលើកមកនោះតិច ក៏ប្រមាថមើលងាយមិនសូវនឹងប្រើងសង្វាតប្រយ័ត្នការ បរសេះចេញទៅសង្វាតពីមុខទាហាន។ **ថៃស៊ូជូ**បរសេះបំពានចេញទៅទទួល ឃើញ**គួនអ៊ូ**បរសេះស្ទុះលឿនទៅមុខក៏ទាញសេះទប់ ឯ**គួនអ៊ូ**ចូល

ទៅស៊ប់តគ្នានឹង**គួនហៃ**បាន ៣០ស្ទៀត **គួនអ៊ូ**យកដាវវែងកាប់ត្រូវ**គួនហៃ**ដាច់ពាក់កណ្ដាលខ្លួនធ្លាក់ពីលើសេះស្លាប់។ **គួនអ៊ូ, ថៃស៊ូជូ** ក៏ដេញកាប់ទ័ពចោរជាកោលាហល **ឡៅពី**និង**តៀវហ៊ុយ**ចូលច្របល់ពីក្រោយទៀត។ ឯ**ខុងយ៉ុង**បានឮសំឡេងកងទ័ពគឹកកងក៏ឡើងមើលសើនបន្ទាយ យើញកងទ័ព**ឡៅពី**ដេញកាប់សម្លាប់ពួកចោរបែកបាក់ខ្ចាត់ខ្ចាយ ឧបមាដូចខ្លាដេញខាំហ្វូងប្រើសទ្រាយកណ្ដាលត្រាញ់ **ខុងយ៉ុង**ក៏មានសេចក្ដីត្រេកអរពន់ប្រមាណស្ទុះទៅបរពលខ្ទប់ពីក្រោយ ពួកចោរបែកបាក់ស្លាប់ពិការ ខ្លះរត់រួច ខ្លះមកនៅនឹង**ឡៅពី**។

**ខុងយ៉ុង**ឲ្យអញ្ជើញ**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** និង**ថៃស៊ូជូ**ចូលមកក្នុងស្រុក ហើយរៀបតែងតុលៀងភោជនាហារ។ កាលកំពុងបរិភោគ **ខុងយ៉ុង**ឲ្យ**ប៊ីតុក**ក្រោកឡើងគំនាប់**ឡៅពី** ហើយ**ខុងយ៉ុង**ពណ៌នារឿងដែល**តូកៀម**ប្រើ**ប៊ីតុក**កាន់សំបុត្រមកសុំកងទ័ពទៅជួយច្បាំងនឹង**ចូឆូ** ទទួលកងទ័ព**គួនហៃ**ចោរមកឡោមព័ទ្ធចេញទៅពុំបាន បានជា**ប៊ីតុក**ក៏ខកនៅក្នុងទីនេះ។

**ឡៅពី**តបថា **តូកៀម**ជាមនុស្សពិតត្រង់ល្អណាស់ ដែលនឹងក្លែងកលឲ្យកើតហេតុទាំងនេះ ក៏គឺតែកម្មរបស់**តូកៀម**សង។ **ខុងយ៉ុង**ឆ្លើយថា ឥឡូវនេះ**ចូឆូ**ស្មានថា**តូកៀម**ប្រើឧបាយបានជានៅគុំគួន នឹងសងសឹក**តូកៀម**វិញ។ ឯកងទ័ព**ចូឆូ**លើកមកនោះច្រើនអនេកណាស់ ប្រទូសរ៉ាយដល់ពួកអ្នកស្រុកសឹងវិនាសអស់ទាំងប្រុសស្រីខ្លួនអ្នកជាពូជព្រះរាជវង្សព្រះចៅ**ហៀនតេ** គួរយើងនឹងទំនុកបម្រុងឲ្យបណ្ដារាស្ត្រទាំងពួងមានសេចក្ដីសុខក្សេមក្សាន្ត ខ្ញុំសូមអញ្ជើញអ្នកលើកទ័ពទៅជាមួយនឹងខ្ញុំដើម្បីនឹងជួយ**តូកៀម** ដែល**ចូឆូ**លើកទ័ពមកប្រទូសរ៉ាយនោះ។ **ឡៅពី**បានស្ដាប់ឆ្លើយតបថា ដែលអ្នកនិយាយមកនេះគួរសមហើយ តែថាយើងខ្លាចក្រែងមិនធួនការ

ព្រោះទាហានយើងតិចណាស់ បើនឹងលើកទៅតតាំងគង់នឹងចាញ់**ចូឆ្វ**។ **ខុងយ៉ុង**ឆ្លើយថា ដែលខ្ញុំប៉ងនឹងលើកទ័ពទៅជួយ**តូកៀម**នោះ មិនមែនឃើញលាភសក្ការៈ ឬព្រោះគាប់ចិត្តអ្នកនោះក៏ទេ ចំពោះឃើញថា**តូកៀម**ជាមនុស្សចរិតពិតត្រង់នឹងផែនដីមានសេចក្ដីមេត្តាអាណិតអាណាប្រជានុរាស្ត្រឲ្យនៅជាសុខ ដូចខ្លួនអ្នកជាពូជព្រះរាជវង្សព្រះចៅ**ហៀនតេ** យល់ឃើញថានរណាជាមនុស្សកតញ្ញូនឹងផែនដីហើយមានទុក្ខធុរៈពិត គួរនឹងជួយអាណិត ឬលះចិត្តមិនរវល់វិញ?

**ឡៅពី**តបថា ចិត្តរបស់ខ្ញុំដែលបានដឹងឮដូច្នេះនឹងបានព្រងើយកន្តើយក៏ទេ តែវេលានេះសុំឲ្យអ្នកលើកទាហានទៅមុនចុះ ខ្ញុំនឹងវិលទៅខ្ចីទាហាន**កងស៊ុនចាន**ឲ្យបានពីរបីពាន់ផ្សំគ្នា ហើយលើកតាមអ្នកទៅជាក្រោយ។ **ខុងយ៉ុង**ឆ្លើយថា ដែលអ្នកនឹងលើកទៅតាមក្រោយនោះ កុំឲ្យបញ្ឆោតយើង។ **ឡៅពី**តបថា "អ្នកដែលដឹងឮគេនិយាយថាខ្ញុំធ្លាប់បញ្ឆោតភូតភរអ្នកណាខ្លះ? បើយើងទៅខ្ចីទាហានគេបានក្ដី មិនបានក្ដី យើងក៏លើកទៅតាមអ្នកជាប្រាកដ" ហើយក៏លា**ខុងយ៉ុង**ទៅរក**កងស៊ុនចាន**នៅស្រុកប៉ាក់បេង។ **ខុងយ៉ុង**ក៏ឲ្យ**ប៊ីតុក**ស្រូតទៅប្រាប់**តូកៀម**ថា នឹងលើកទ័ពទៅជួយ។ **ប៊ីតុក**ទទួលពាក្យហើយ លា**ខុងយ៉ុង**ត្រឡប់ទៅ។

ខណៈនោះមានមនុស្សមកប្រាប់**ថៃស៊ូជូ**ថា **ឡៅពី**ឲ្យហៅទៅជួប។ **ថៃស៊ូជូ**ចូលទៅជម្រាប**ខុងយ៉ុង**ថា ដែលមាតាខ្ញុំបាទប្រើឲ្យមកតបស្នងសងគុណលោក ខ្ញុំបាទក៏ធ្វើការសម្រេចហើយ។ ឥឡូវនេះ**ឡៅពី**ចៅហ្វាយស្រុកអៀវជីវ ប្រើបម្រើឲ្យនាំសំបុត្រមកហៅខ្ញុំបាទថាឲ្យទៅដើម្បីនឹងប្រឹក្សាការរាជការ បើខ្ញុំបាទមិនទៅទេនឹងខូចផ្លូវមេត្រីរាប់អានគ្នា។ ហេតុនេះខ្ញុំបាទសូមលាលោកសិន។ **ខុងយ៉ុង**បានស្ដាប់ក៏ចាប់ចិត្តអាល័យ**ថៃស៊ូជូ**ណាស់ ទើបចូលទៅយកមាសប្រាក់ និងសំពត់អាវ

ឲ្យជាគំនាប់**ថៃស៊ូជូ** ៗថារបស់ទាំងនេះសូមលោកទុកចែកចាយឲ្យទាហានចុះ ហើយលា**ខុងយ៉ុង**ទៅរកមាតា ពណ៌នាប្រាប់សេចក្តីឲ្យមាតាស្តាប់គ្រប់ប្រការ។ មាតាបានស្តាប់មានសេចក្តីសោមនស្សណាស់ទើបថា ដែល**ឡៅពី**ចៅហ្វាយស្រុកអៀវជីវ ឲ្យមករកកូននោះចូរទៅជាប្រញាប់ចុះ។ **ថៃស៊ូជូ**លាមាតាចេញទៅដល់ស្រុកអៀវជីវ។

ឯ**ឡៅពី**កាលទៅដល់ស្រុកប៉ាក់បេង ចូលទៅរក**កងស៊ុនចាន** បានជួបហើយនិយាយថា ឥឡូវនេះ**ចូឆូ**លើកទ័ពទៅច្បាំងនឹង**តូកៀម**ចៅហ្វាយស្រុកឈីជីវ ខ្ញុំមកសុំខ្ចីទាហានអ្នកពីរបីពាន់ ដើម្បីលើកទៅជួយ**តូកៀម**ធ្វើសង្គ្រាមតនឹង**ចូឆូ**។ **កងស៊ុនចាន**បានស្តាប់ឆ្លើយតបថា **ចូឆូ**ហើយនិងអ្នកមិនមានទោសទាស់គ្នាពីអ្វីសោះ អ្នកនឹងលើកទៅជួយខាង**តូកៀម**នោះ ខ្ញុំមិនយល់ព្រមផងទេ។ **ឡៅពី**តបថា ខ្ញុំបានទទួលពាក្យនឹង**ខុងយ៉ុង**ទៅហើយ បើត្រឡប់ជាមិនទៅវិញ **ខុងយ៉ុង**នឹងថាខ្ញុំចរចាមិនពិត។ **កងស៊ុនចាន**ឆ្លើយថា បើអ្នកបានជាទទួលពាក្យគេមកហើយ ខ្ញុំនឹងឲ្យទាហានសេះតែត្រឹមពីរពាន់ចុះ។ **ឡៅពី**តបថា ខ្ញុំនឹងសុំ**ជូឡុង**ទៅផង។ **កុងស៊ុនចាន**ក៏ព្រមឲ្យ។ **ឡៅពី**មានសេចក្តីត្រេកអរណាស់ ទើបនាំយក**ជូឡុង**និងទាហាន**កងស៊ុនចាន**ចំនួនពីរពាន់ ឲ្យ**ជូឡុង**ជាកងទ័ពក្រោយ។

**ឡៅពី, គួនអ៊ូ** និង**តៀវហ៊ុយ**នាំទាហានបីពាន់ប្តាយជាទ័ពមុខស្រូតរូតទៅដល់ស្រុកឈីជីវ។ **តូកៀម**បានឮដូច្នោះ ក៏បានធូរស្បើយក្នុងចិត្ត។ ឯ**ខុងយ៉ុង**ចៅហ្វាយស្រុកប៉ាក់ហៃ និង**តេងកៃ**ចៅហ្វាយស្រុកឈៀងជីវ ក៏នាំទាហានលើកទៅដល់ស្រុកឈីជីវ ឃើញកងទ័ព**ចូឆូ**តាមរាយប្រកិតជិតជាប់គ្នា។ **ខុងយ៉ុង**និង**តេងកៃ**ក៏ឲ្យតាំងបន្ទាយពីក្រោយទ័ព**ចូឆូ**ទាំងពីរប៉ែក ប៉ងនឹងមើលកលសឹក។ **ចូឆូ**ឃើញដូច្នោះគិត

ថា "ឥឡូវមានកងទ័ពមកតាំងនៅពីក្រោយជា ២ប៉ែក បើនឹងលើកវាយបំបែកទៅមុខ ក្រែងពីក្រោយលើកគំហុកខ្ទប់មកទៀត" គិតហើយក៏បែងទាហានឲ្យមានពួកបែរទៅមុខផង បែរមកក្រោយផងទាំងសងខាង។

កាល**ឡៅពី**លើកទាហានទៅដល់ស្រុកឈឺជីវហើយ ឃើញកងទ័ព**ខុងយ៉ុង**និង**តេងកៃ**តាំងបន្ទាយរាយប្រកិតគ្នានឹងទ័ព**ចូឆូ**ជាពីរប៉ែកដូច្នោះ ក៏ចូលទៅជួបនឹង**ខុងយ៉ុង**ៗមានអំណរណាស់ និយាយនឹង**ឡៅពី**ថា **ចូឆូ**លើកទាហានមកធ្វើសង្គ្រាមជាច្រើនហួសប្រមាណ ខ្លួន**ចូឆូ**ក៏ជាមនុស្សមានសតិបញ្ញាជំនាញស្ទាត់ក្នុងការពិជ័យសង្គ្រាម ដែលយើងនឹងលើកទាហានចូលកាច់យកដោយឆាប់ទាន់ចិត្តនោះ ឃើញនឹងបង់ការ ត្រូវតែរារង់បង្អង់មើលកលការណ៍សិន បើឃើញបានចំណាប់ហើយសឹមយើងលើកចូលទៅច្បាំងនឹង**ចូឆូ**។

**ឡៅពី**តបថា អ្នកដែលនិយាយនោះត្រូវណាស់ តែខ្ញុំក្រែងនឹងតាំងនៅយូរមិនបានព្រោះស្បៀងអាហារក្នុងស្រុកឈឺជីវតិចពេក ពួកអ្នកស្រុកក៏អត់ឃ្លាន បើដូច្នេះខ្ញុំឲ្យ**គួនអ៊ូ** និង**ជូឡុង**នាំទាហានបួនពាន់មករួមនឹងអ្នក ឯខ្លួនខ្ញុំ និង**តៀវហ៊ុយ**នាំទាហានជាងមួយពាន់ ពារទម្លាយកង**ចូឆូ**ចូលទៅឲ្យដល់ស្រុកឈឺជីវតែម្តង ប្រយោជន៍នឹងបាននិយាយប្រឹក្សាការនឹង**តូកៀម** ហើយនឹងប្រមាណមើលស្បៀងអាហារក្នុងស្រុកដែលមាននៅនោះច្រើន ឬតិច នឹងបានសម្រេចគិតគ្នាតទៅទៀត។ **ខុងយ៉ុង**ក៏យល់ព្រមផង។ ខណៈនោះ**ឡៅពី**និង**តៀវហ៊ុយ** នាំទាហានចូលទៅដល់មុខបន្ទាយ**ចូឆូ**។ ទាហាន**ចូឆូ**ឃើញក៏លើកគ្នាតាមមករារាំងពីមុខ។ កងទ័ពទាំងសងខាងក៏តាំងតែចូលលុកតប្រយុទ្ធទៅវិញទៅមក បីដូចរលកក្នុងមហាសមុទ្រ។

ឯ**អ៊ីគឹម**ទាហានឯកនោះបរសេះចេញមកមុខទាហាន ហើយស្រែកសួរ**ឡៅពី**និង**តៀវហ៊ុយ**ថា ឯងមកនេះនឹងទៅណា? ទាហានឯងជាងមួយពាន់ប៉ុននេះនឹងស្កាំដៃទាហានយើងឬ? **តៀវហ៊ុយ**បានឮឈឺចិត្តណាស់ មិនបានឆ្លើយឆ្លងថាដូចម្ដេច បរសេះស្ទុះផ្លែចទៅប្រយុទ្ធនឹង**អ៊ីគឹម**បានដប់ស្នៀត។ **ឡៅពី**កាន់ដាវបរសេះចូលទៅជួយ**តៀវហ៊ុយ**ពីក្រោយ។ **អ៊ីគឹម**កម្លាំងខ្សោយក៏ថយត្រឡប់ **តៀវហ៊ុយ**ដេញជាប់កាប់ទាហាន**ចូឆូ**ស្លាប់ជាច្រើននាក់។ **ឡៅពី** និង**តៀវហ៊ុយ**នាំទាហានទៅដល់មាត់ទ្វារស្រុក។

ឯ**តូកៀម**ឡើងពិនិត្យមើលលើសើនបន្ទាយ ឃើញកងទ័ពដេញគ្នាទម្លាយចូលមកដល់មាត់ទ្វារ ក៏ឃើញទង់ជ័យក្រហមជាសម្គាល់មានអក្សរជាទង់ថា "**ឡៅពី**ចៅហ្វាយស្រុកផេងងួនគួន" **តូកៀម**មានអំណរពន់ប្រមាណ បង្គាប់ឲ្យទាហានស្ទុះទៅបើកទ្វារទទួល**ឡៅពី**ចូលទៅក្នុងស្រុក ទើបអញ្ជើញឲ្យអង្គុយហើយរៀបតុលៀងអាហារ។ **ឡៅពី** និង**តៀវហ៊ុយ**នូវអស់ពលសេនា បរិភោគរួចហើយ **ឡៅពី**ជម្រាប**តូកៀម**ថា ដែលយើងចូលមកនេះ បានកាប់ឆ្ការពារទម្លាយកងទ័ព**ចូឆូ**វិនាសអស់ជាច្រើន។ **តូកៀម**បានស្ដាប់ក៏មានសេចក្ដីត្រេកអរណាស់ តាំងតែគយគន់មើលរូបរាង**ឡៅពី**ឃើញសមគួរជាពូជព្រះរាជវង្ស ទាំងវោហារសម្ដីដែលចរចារួសរាយសុភាពបែបជាអ្នកចិត្តល្អ **តូកៀម**ចាត់ប្រើ**ប៊ីតុក**ឲ្យចូលទៅយកត្រាសម្រាប់ស្រុកឈីជីវចេញមកជាប្រញាប់ ហើយប្រគល់ឲ្យ**ឡៅពី**ៗឃើញដូច្នោះ ក៏នឹកភ័យស្រដីតបទៅថា ដែលលោកយកត្រាសម្រាប់ខេត្តមកឲ្យខ្ញុំនេះ ដោយហេតុភេទប្រការម្ដេច? **តូកៀម**តបថា សព្វថ្ងៃនេះព្រះចៅ**ឡេនតេ**បានគ្រងរាជសម្បត្តិ ព្រះជន្មវស្សាក៏ទ្រង់នៅជាព្រះរាជកុមារណាស់ នាហ្មឺនមុខមន្ត្រីដែលគ្មានចិត្តជាសុចរិតទៀងត្រង់

នោះ ក៏រមែងធ្វើការជាចលាចលផ្សេងៗ ផែនដីមានតែសេចក្ដីក្ដៅក្រហាយមកជារឿយៗ ខ្លួនខ្ញុំក៏ចាស់ជរា នឹងធ្វើការបម្រុងផែនដីតទៅទៀតពុំបាន ខ្ញុំឃើញថាអ្នកជាពូជព្រះរាជវង្សខ្ពង់ខ្ពស់មានកេរ្តិ៍ឈ្មោះជាអ្នកមានសតិបញ្ញា ហើយមេត្តារាប់អានបណ្ដារាស្ត្រទាសករទាំងពួង ឲ្យមានសេចក្ដីសុខក្សេមក្សាន្ត។ ខ្ញុំបានតាំងចិត្តគិតជាស្រេច ទើបលើកត្រានេះជូនផ្ទេរឲ្យលោកទទួលធ្វើជាចៅហ្វាយស្រុកឈើជីវតទៅ ដើម្បីនឹងបានគិតកម្ចាត់សត្រូវរាជសម្បត្តិឲ្យខ្ចាត់ខ្ចាយចេញ បើអ្នកពេញចិត្តជាប្រាកដ ខ្ញុំនឹងធ្វើសំបុត្រចូលទៅក្រាបទូលព្រះចៅ**ឡូនតេ** សូមឲ្យទ្រង់បានជ្រាប។

**ឡៅពី**បានស្ដាប់ក៏ឱនគំនាប់**តូកៀម** ហើយថា ខ្លួនខ្ញុំជាពូជព្រះរាជវង្សពិតមែន តែថាគំនិតនិងសតិបញ្ញាតិចណាស់ តាំងពីចូលធ្វើរាជការមិនទាន់បានគុណគាប់ប្រសើរយ៉ាងណាទេ។ សព្វថ្ងៃធ្វើត្រឹមតែចៅហ្វាយស្រុកចត្វា គិតជាចំណេះរបស់ខ្លួនមិនធូននៅឡើយ ដែលខ្ញុំលើកទាហានមកនេះ ព្រោះចិត្តប្រាថ្នានឹងជួយលោកដែលច្បាំងនឹង**ចូឆ្នូ**ប៉ុណ្ណោះ ឬលោកនៅមិនជឿស្មោះថា ខ្ញុំមកដណ្ដើមយកស្រុកឈើជីវនោះមិនមែនទេ បើខ្ញុំគិតដូច្នោះ ក៏សូមឲ្យទេវតាប្រហារជីវិតខ្ញុំចុះ។

**តូកៀម**តបថា ដែលខ្ញុំនឹងលើកស្រុកឲ្យអ្នកនេះ ជាសេចក្ដីសុចរិត មិនមែននឹងគិតសង្ស័យអាល័យស្ដាយ ឬឧបាយបញ្ឆោតដូចម្ដេចក៏ទេ។ **តូកៀម**លួងលោមអង្វរប្រគល់ស្រុកឈើជីវឲ្យ**ឡៅពី**ដូច្នេះ ជាច្រើនដងច្រើនគ្រាណាស់ **ឡៅពី**នៅមិនព្រមទទួលសោះ។ **ប៊ីតុក**និយាយនឹង**តូកៀម**ថា ទ័ព**ចូឆ្នូ**លើកមកទល់ជិតនឹងកំពែងស្រុកហើយ។ **ឡៅពី**បានជួយធ្វើការសឹក ហើយលោកគិតទៅប្រគល់ស្រុកឲ្យយូរការដូច្នេះមិនស្រួលទេ ឲ្យលោកខំរិះគិតគ្នាធ្វើការសង្គ្រាមឲ្យសម្រេចសិន សឹមគិតប្រគល់ស្រុកទេសឲ្យ**ឡៅពី**ជាក្រោយចុះ។

**ឡៅពី**និយាយនឹង**តូកៀម**ថា ខ្ញុំសុំសរសេរសំបុត្រទៅឃាត់ហាម**ចូឆូ**ឲ្យលើកទ័ពត្រឡប់ទៅវិញ បើ**ចូឆូ**មិនស្ដាប់សឹមគិតលើកកងទ័ពចេញទៅច្បាំងខាងក្រោយ។ **តូកៀម**ក៏យល់ព្រមផង **ឡៅពី**ក៏សរសេរសំបុត្រចាត់ឲ្យទាហានកាន់យកទៅឲ្យ**ចូឆូ**ជាច្រើនគ្នា ហើយឲ្យលបយកទៅឲ្យ**ខុងយ៉ុង** និង**តេងកៃ**ថា ឲ្យត្រៀមទាហានទុកឲ្យមាំមួនកុំអាលចេញច្បាំង ទាហានក៏នាំសំបុត្រនោះចេញទៅ។ ពួកទាហាន**ចូឆូ**នាំបម្រើចូលទៅដល់**ចូឆូ**ក្នុងបន្ទាយ **ចូឆូ**ទទួលសំបុត្រមើលឃើញសេចក្ដីថា “**ឡៅពី**សុំឲ្យពរមកដល់**ចូឆូ** ឲ្យគិតដល់គ្រាដែលធ្វើការជាមួយគ្នានៅគយហៅលោគួន ហើយយើងទាំងសងខាងក៏និរាសគ្នាទៅ មិនបានភពប្រទះគ្នាមកទល់នឹងសម័យនេះ។ ខ្ញុំក៏មានចិត្តគិតដល់អ្នកមិនភ្លេចសោះ ដែលបិតាអ្នកអនិច្ចកម្មនោះ ព្រោះ**តៀវឃី**ប្រទូសរ៉ាយពីខ្លួនវា **តូកៀម**មិនមែនទៅចូលរួមគំនិតជាមួយនឹងវាក៏ទេ ដែលអ្នកមកខឹងនឹង**តូកៀម** ហើយថែមលើកកងទ័ពមកសម្លាប់អស់អ្នកស្រុកដែលនៅទំនេរនោះជាសេចក្ដីក្ដៅក្រហាយខុសឆ្ងាយផ្លូវយុត្តិធម៌ អ្នកក៏ជាមន្ត្រីក្នុងរាជការមានតម្រិះប្រាជ្ញាស្រាប់ហើយ គួរឲ្យគិតមើលចុះ សព្វថ្ងៃនេះ**លីឈុយ**, **គុយគី**បានជានាហ្មឺនធំនៅក្នុងស្រុកទៀងហាន់ ព្រះចៅ**ឡៀនតេ** និងនាហ្មឺនមុខមន្ត្រីខ្ញុំរាជការ នូវអស់បណ្ដារាស្ត្រមានតែសេចក្ដីក្ដៅក្រហាយជាច្រើន ចំណែកខាងអាណាខេត្តក្រៅក៏នៅកើតពួកចោរជូតក្បាលលឿង តែងតែធ្វើទុក្ខបុកម្នេញបណ្ដារាស្ត្រជារឿយៗ ដោយហេតុមន្ត្រីធំពុំប្រព្រឹត្តសុចរិតធម៌ អ្នកចូរគិតអាណិតដល់បណ្ដារាស្ត្រជាខ្ញុំផែនដីដែលព្រួយទុក្ខ គួរណាស់តែនឹងជួយឧបត្ថម្ភលើកកងទ័ពទៅបង្ក្រាបពួកអាចោរកំណាចឲ្យខ្ចបខ្ចាច តបះតេជៈរបស់អ្នក មិនគួរលើកយកធុរៈជាកិច្ចផ្ទាល់ខ្លួនមកគួនខឹងនឹង**តូកៀម** ដែលជាមនុស្សស្លូតត្រង់សោះ ពីព្រោះតែបិតារបស់អ្នកសូន្យបង់ជីវិត អ្នក

ត្រូវគិតឲ្យជាក់ច្បាស់ដោយបញ្ញា បើឃើញថា**តូកៀម**ប្រព្រឹត្តទុច្ចរិតពុំពិតដូចខ្ញុំថាទេ សុំឲ្យអ្នកលើកទ័ពមកចាប់**តូកៀម**សម្លាប់ចុះ ដែលខ្ញុំនាំសេចក្តីមកជម្រាបប៉ុណ្ណេះ សុំឲ្យអ្នកឈ្វេងយល់ដល់ទៅខ្ញុំផង”។

ឯ**ចូឆ្វូ**កាលឃើញសេចក្តីសំបុត្រដូច្នោះ ក៏បណ្តាលនូវសេចក្តីក្រោធពិរោធជាពន្លឹក ហើយបែរទៅប្រឹក្សានឹង**គុយកែ**ថា “យើ! អា**ឡៅពី**ចំជាចិត្តព្រហើនណាស់ ហ៊ានឲ្យសំបុត្រមកហាមឃាត់យើង បើយើងរកទៅហើយឃើញថា វាប្រើឧបាយកលល្បួងបញ្ឆោតយើងមែន នោះគួរឲ្យកាត់ក្បាលបម្រើដែលកាន់សំបុត្រនោះចេញ ហើយរៀបទ័ពជាប្រញាប់ទៅវាយយកស្រុកឈីជីវឲ្យខាងតែបាន”។ **គុយកែ**ឆ្លើយថា **ឡៅពី**ជាមនុស្សស្លូតត្រង់ជាទីបំផុត ដែលនឹងទៅសម្លាប់បម្រើកាន់សំបុត្រនោះមិនគួរសោះ សុំឲ្យលោកឆ្លើយតបសំបុត្រទៅយកចិត្ត**ឡៅពី**សិន តទៅមុខសឹមលើកទ័ពទៅវាយយកស្រុកឈីជីវ នឹងបានដោយស្រួល។ **ចូឆ្វូ**ក៏យល់ព្រមផងទើបឲ្យឃាត់អ្នកបម្រើនោះទុក ហើយត្រិះរិះរកសេចក្តីដែលនឹងធ្វើសំបុត្រតបទៅ**ឡៅពី**វិញ។

ចំណែកខាង**លីប៉ោ** កាលរត់ចេញអំពី**លីឈុយ, គុយគី**ពីក្រុងតៀងហាន់ទៅដល់ស្រុកឡាំយ៉ុង បានចូលទៅអាស្រ័យនឹងអ្នកស្រុកៗមិនទទួល **លីប៉ោ**ក៏ចូលទៅនៅនឹង**អ្នួនសៀវ** ថៅហ្វាយស្រុកគីជីវ។ **លីប៉ោ** បានធ្វើសេចក្តីគាប់ប្រសើរទុកដល់**អ្នួនសៀវ**មួយគ្រា តែ**លីប៉ោ**ធ្វើអាក្រក់ដល់ពួកទាហានស្និទ្ធរបស់**អ្នួនសៀវ** ៗខឹងណាស់ គិតនឹងសម្លាប់**លីប៉ោ** ៗក៏រត់ទៅនៅនឹង**តៀវអៀន**ថៅហ្វាយស្រុកសៀងតុង។

ឯ**បាំងស៊ី**ជានាហ្មឺននៅក្នុងក្រុងទៀងហាន់ ជាមិត្តស្និទ្ធស្នាលនឹង**លីប៉ោ** លុះឮ**លីប៉ោ**ទៅនៅស្រុកសៀងតុង ក៏លបនាំភរិយាបុត្រ និងស្និទ្ធគ្រួបក្សពួករបស់**លីប៉ោ**

ទៅឲ្យ**លីប៉ោ**នៅឯស្រុកសៀងតុង។ **លីឈុយ, គុយគី** ដឹងការបង្គាប់ឲ្យចាប់**បាំងស៊ី**សម្លាប់បង់ ហើយធ្វើសំបុត្រទៅដល់**តៀវអៀន**ឲ្យចាប់**លីប៉ោ**សម្លាប់។ **លីប៉ោ**ដឹងខ្លួនក៏រត់ទៅនៅនឹង**តៀវម៉ៅ**ចៅហ្វាយស្រុកតាន់លីវ។

ចំណែក**តាន់កុង**ដែលទៅហាមឃាត់**ចូឆូ**ៗមិនស្តាប់ **តាន់កុង**ទៅនៅនឹង**តៀវចៀវ**ជាប្អូន**តៀវម៉ៅ**នៅស្រុកតាន់លីវនោះ **តៀវចៀវ**ក៏នាំ**តាន់កុង**ទៅរក**តៀវម៉ៅ**ជាបង។ **តាន់កុង**ជម្រាប**តៀវម៉ៅ**ថា **ចូឆូ**បានជាធំនៅខាងប្រជុំខេត្តទិសឯកើតមានសេនាទាហានជាច្រើន ឥឡូវចោលស្រុកគុនជីវ លើកទៅវាយយកស្រុកឈីជីវ។ ខ្ញុំយល់ឃើញថា ស្រុកគុនជីវនោះគ្មាននរណាមានថ្វីដៃនៅរក្សាគ្រប់គ្រងទេ សុំឲ្យលោកចាត់**លីប៉ោ**ឲ្យលើកទ័ពទៅវាយយកស្រុកគុនជីវ ក៏នឹងបែកបានដោយងាយ បើបានស្រុកគុនជីវហើយ ស្រុកទៅមុខក៏ស្រួលមិនលំបាក។ **តៀវម៉ៅ**បានស្តាប់ក៏ពេញចិត្ត ទើបចាត់សេនាទាហានឲ្យ**លីប៉ោ**ជាមេទ័ព ហើយឲ្យយក**តាន់កុង**ទៅជាមួយ។ **លីប៉ោ**លើកកងទ័ពជាប្រញាប់ទៅវាយស្រុកគុនជីវបានហើយ លើកទាហានទន្ទ្រានវាយយកខេត្តខណ្ឌក្បែរផ្លូវទៅដល់ស្រុកប៉ាក់អៀង នៅសល់តែស្រុកអៀនសៀ១ ស្រុកតងហៃ១ ស្រុកហួនគួន១ ទាំងបីស្រុកនេះ **ធៀយ៉ុក**និង**ស៊ុនហុក**រក្សាគ្រប់ទុកបាន។ ឯ**ចោយិន**ជាទាហាន**ចូឆូ**ដែលនៅស្រុកគុនជីវនោះ បែករត់ទៅនឹងទៅរក**ចូឆូ**។ មានបម្រើសេះស្រួតទៅដល់**ចូឆូ**មុន យកសេចក្តីទាំងពួងជម្រាប**ចូឆូ**បានដឹងសព្វគ្រប់។ **ចូឆូ**ដឹងហើយក៏មានចិត្តបរិវិតក្កណាស់ប្រឹក្សានឹងទាហានទាំងពួងថា ដែល**លីប៉ោ**លើកទ័ពទៅវាយយកស្រុកគុនជីវនោះឃើញថា គ្រប់គ្រួរបស់យើងប្រហែលនឹងវិនាសខ្ចាត់ខ្ចាយអស់ហើយ បើដូច្នោះត្រូវតែយើងលើកកងទ័ពត្រឡប់ទៅច្បាំងនឹង**លីប៉ោ**វិញ។

**គុយកែ**ឆ្លើយថា ដែលលោកនឹងលើកទ័ពត្រឡប់ទៅវិញនោះគួរណាស់ ព្រោះ**ឡៅពី**ក៏មានសំបុត្រមកឃាត់ហាមលោកផង លោកត្រូវមានសំបុត្រតបទៅវិញ ដើម្បីចងមេត្រីទុកតទៅ សេចក្ដីដែល**ឡៅពី**ឃាត់ហាមទាំងប៉ុន្មាន លោកក៏បានទទួលស្ដាប់គ្រប់ប្រការ រួចសឹមលើកពលសេនាទៅស្រុកគុនជីវ។ **ចូឆ្វូ**បានស្ដាប់ឃើញត្រូវ ក៏ទៅធ្វើសំបុត្រតាមពាក្យ**គុយកែ**និយាយ ហើយប្រគល់ឲ្យទាហាន**ឡៅពី**នាំទៅ **ចូឆ្វូ**ក៏លើកទ័ពត្រឡប់ទៅស្រុកគុនជីវ។

បម្រើនាំសំបុត្រវិលទៅដល់ស្រុកឈីជីវវិញ ក៏ជូនសំបុត្រនោះឲ្យ**ឡៅពី**នៅមុខ**តូកៀម**។ **ឡៅពី** និង**តូកៀម** មើលដឹងសេចក្ដីហើយ ក៏មានអំណរក្នុងចិត្តណាស់។ **តូកៀម**ឲ្យបម្រើទៅអញ្ជើញ**ខុងយ៉ុង១, តេងកៃ១, គួនអ៊ូ១, ជូឡុង១** ឲ្យចូលមក ហើយចាត់ឲ្យរៀបតុលៀងអាហារ អញ្ជើញ**ឡៅពី**ឲ្យអង្គុយក្នុងទីសមគួរ ហើយឱនគំនាប់ជម្រាប**ឡៅពី**ថា ខ្លួនខ្ញុំចាស់ជរាហើយ បើនឹងផ្ទេរផ្ទុករាជការឲ្យបុត្រទាំងពីរក៏ពុំបាន ព្រោះវាគ្មានសតិបញ្ញាសោះ ខ្ញុំសូមឲ្យអ្នកទទួលធ្វើជាចៅហ្វាយស្រុកឈីជីវចុះ ឯចំណែកខ្លួនខ្ញុំសុំនៅក្រៅរាជការជួយចាត់ការទំនុកបម្រុងតទៅ។ **ឡៅពី**បានស្ដាប់**តូកៀម**និយាយដូច្នោះ ទើបពិគ្រោះនឹងសេនាទាហានទាំងពួងថា ពីថ្ងៃមុន**ខុងយ៉ុង**បបួលយើងឲ្យមកជួយការពារ**តូកៀម** យើងឃើញផ្លូវមេត្រីរាប់អានបានលើកទ័ពមកជួយ ឥឡូវនេះ**តូកៀម**នឹងលើកស្រុកឈីជីវឲ្យដល់យើង បណ្ដារាស្ត្រទាំងអស់បានដឹងក៏នឹងគរហានិន្ទាថា យើងជាមនុស្សលោភចង់បានទ្រព្យ និងយសសក្តិ។

**ប៊ីតុក**ជម្រាប**ឡៅពី**ថា សព្វថ្ងៃនេះកើតចលាចលផ្សេងៗ ស្រុកទៀងហាន់កាន់តែរៀវរោយ នឹងសាបសូន្យអស់ហើយ។ បើអ្នកឯណាមានសតិបញ្ញាចូរឧស្សាហ៍

ខំរិះគិតក្នុងគ្រានេះចុះ ឥឡូវនេះ**តូកៀម**ព្រមចិត្តស្រុះស្រួលលើកស្រុកជូនលោក ហេតុម្តេចលោកធ្វើព្រងើយកន្តើយដូច្នេះ ឯស្រុកឈើជីវនេះមានខណ្ឌឡើងក៏ច្រើន បើនឹងប្រមាណអ្នកដែលមានទ្រព្យសម្បត្តិគ្រប់តំបន់ ក៏មានដល់ម៉ឺនរយប្លាយ លោកចូរទទួលយកចុះនឹងបានគិតការតទៅ។ **ឡៅពី**ឆ្លើយថា អ្នកកុំបង្ខំឡើយ យើងមិនទទួលយកទេ។

**តាន់តេង**និយាយនឹង**ឡៅពី**ថា **តូកៀម**ជាមនុស្សជរាមានរោគមែន លោកចូរអាណិតដល់រាស្ត្រទាំងពួង ព្រមទទួលយកស្រុកឈើជីវទៅ។ **ឡៅពី**ឆ្លើយថា **អ្នួនសៀវ**ចៅហ្វាយស្រុកឈើជីវនោះ ជាពូជនាហ្មឺនមកបួនដំណាមនុស្សហើយ ៗមានស្រុកឡើងជាច្រើន ហេតុម្តេចអ្នកមិនលើកស្រុកនោះឲ្យ។

**ខុងយ៉ុង**ឆ្លើយថា **អ្នួនសៀវ**នោះឧបមាដូចសពនៅក្នុងស្មប រាប់តែថ្ងៃខែដែលនឹងទ្រោមទៅវិញ ទាំងសតិបញ្ញាក៏មិនសូវមាន នឹងរាប់អានឲ្យធ្វើជាធំតទៅដូចម្តេចបាន។ ឥឡូវបុណ្យមកដល់ហើយ ហេតុម្តេចលោកមិនព្រមទទួល។ **ឡៅពី**ក៏នៅតែមិនព្រមទទួលសោះ។

**តូកៀម**បានឮ**ឡៅពី**ចេះតែប្រកែក ក៏ស្រែកទួញយំថា បើអ្នកមិនទទួលធ្វើចៅហ្វាយស្រុកនេះទេ ហាក់បីដូចជាអ្នកគ្មានមេត្តាខ្ញុំសោះឡើយ បើកាលណាខ្ញុំនឹងស្លាប់ក៏មិនបានស្លាប់ទៅដោយស្រួល ព្រោះរំជួលកង្វល់នឹងរឿងនេះ។

**គួនអ៊ូ, តៀវហ៊ុយ** និយាយនឹង**ឡៅពី**ទៀតថា **តូកៀម**ព្រមប្រគល់ស្រុកឲ្យលោកដោយសុចរិត ហេតុម្តេចលោកមិនអាណិត ទាល់តែកើតទោមនស្សយ៉ាងនេះ? **ឡៅពី**ក៏នៅតែមិនព្រមទៀត។

**តូកៀម**និយាយថែមទៀតថា បើអ្នកមិនព្រមទទួលធ្វើជាចៅហ្វាយស្រុកនេះ ចូរត្រិះរិះអាណិតទៅនៅរក្សាស្រុកសៀវផាយចុះ ស្រុកនោះក៏ឡើងស្ដាប់បង្គាប់ស្រុកឈីជីវនេះ បើខ្ញុំមានទុក្ខក្ដៅក្រហាយវេលាណា នឹងបានពឹងពាក់អាស្រ័យនឹងអ្នកផង។ មនុស្សទាំងពួងដែលនៅជួបជុំក្នុងទីនោះ បាននាំគ្នាជួយនិយាយអង្វរឲ្យ**ឡៅពី**ទទួលយកស្រុកសៀវផាយ។ **តូកៀម**មានសេចក្ដីត្រេកអរណាស់ ទើបយកមាសប្រាក់សំពត់អាវមកចែកឲ្យ**ឡៅពី** និងទាហាន**ខុងយ៉ុង, តេងកៃ** ជាច្រើន។

ក្នុងពេលនោះ **ជូឡុង** និយាយនឹង**ឡៅពី**ថា លោកមកជួយទុក្ខធុរៈ**តូកៀម**ឃើញថា សម្រេចហើយ ខ្ញុំនឹងសុំលាលោកទៅរក**កងស៊ុនចាន**វិញ។ **ឡៅពី**ឮហើយចាប់ដៃ**ជូឡុង**ជាប់ ហើយយំនិយាយផ្ដែផ្ដាំគ្នាជាអនេកប្រការ។ **ជូឡុង**ក៏លា**ឡៅពី**ប្រមូលទាហានពីរពាន់លើកចេញទៅស្រុកប៉ាក់បេង។

ឯ**ខុងយ៉ុង** និង**តេងកៃ** ក៏លា**ឡៅពី** និង**តូកៀម**លើកទាហានចេញទៅកាន់ស្រុករៀងខ្លួន។ **តូកៀម**ធ្វើសំបុត្របើកខេត្តចាត់ឲ្យជូនដំណើរ**ឡៅពី**ទៅឈររក្សាស្រុកសៀវផាយ។ កាល**ឡៅពី**ទៅឈររក្សាស្រុកនោះ បណ្ដារាស្ត្រទាំងឡាយរួសរាយស្រឡាញ់**ឡៅពី**ជាច្រើន។

កាល**ចូឆូ** លើកទ័ពទៅដល់កណ្ដាលផ្លូវ បានប្រទះនឹង**ចោឃិន** ១ជម្រាបឲ្យការណ៍ថា **លីប៉ោ**ដែលជាមេទ័ពលើកមកនោះ រូបរាងធំដំបងទ្រង់ទ្រាយជាអ្នកមានកម្លាំងខ្លាំងពូកែ បាន**តាន់កុង**តាំងទុកជាទីប្រឹក្សា លុះវាយបានស្រុកគុនជីវហើយ ក៏លើកឆ្លងទៅវាយស្រុកក្បែរផ្លូវរៀងទៅដល់ស្រុកប៉ាក់អៀង ។ ឯ**ស៊ុនហុក**និង**ផៀយ៉ុក**ត្រូវ**លីប៉ោ**ចាត់ឲ្យនៅរក្សាស្រុកទុកទាំងបីតំបន់។ **ចូឆូ**បានស្ដាប់ហើយឆ្លើយតបថា "**លីប៉ោ**នោះជាអ្នកមានថ្វីដៃខ្លាំងពូកែពិតមែនហើយ តែមិនជាអ្នកស្ទាត់ក្នុងការទាំង

ពួងទេ អ្នកកុំបីជាទុក្ខឡើយ”។ លុះនិយាយគ្នាហើយ ក៏ឲ្យស្រួតលើកទាហានទៅដល់ស្រុកតេងកួន ហើយឲ្យឈប់តាំងបន្ទាយជាមាំមួនក្នុងទីនោះ។

ឯ**លីប៉ោ**កាលឮកិត្តិស័ព្ទថា **ចូឆ្វ**លើកទ័ពទៅតាំងបន្ទាយនៅស្រុកតេងកួន ដូច្នោះ ទើបចាត់ឲ្យ**លីហង** និង**ស៊ីឡាន់**យុំនាំទាហានមួយម៉ឺននាក់ទៅនៅរក្សាស្រុកគុនជីវ។ **តាន់កុង**បានឮដូច្នោះ ក៏សួរ**លីប៉ោ**ថា ស្រុកគួនជីវនោះជាទីសំខាន់ លោកនឹងឲ្យ**លីហង** និង**ស៊ីឡាន់**ទៅនៅរក្សានោះ តើខ្លួនលោកនឹងទៅនៅឯណា? **លីប៉ោ** ឆ្លើយថា យើងនឹងលើកទៅតាំងទល់ទ័ព**ចូឆ្វ**ឯស្រុកប៉ាក់អៀង ប្រយោជន៍នឹងបានការពារស្រុកទុកឲ្យបានធំទូលាយ។ **តាន់កុង**ថា លោកនឹងទុកចិត្តឲ្យ**ស៊ីហង** និង **ស៊ីឡាន់**នៅរក្សាស្រុកគុនជីវ ខ្ញុំយល់ឃើញថាមុខជាចាញ់ប្រៀបតែម្តង ព្រោះភ្នំថៃសាន់នៅទិសឯត្បូងស្រុកគុនជីវនោះ ចម្ងាយប្រហែលប្រាំបីរយសិន (៣២ គ.ម) មានច្រកចំពោះចុះតែជើងអ្នកមួយ ដើរតាមចន្លោះភ្នំជាផ្លូវកាត់ឲ្យត្រង់ គង់តែ**ចូឆ្វ**នឹងស្រួតលើកតម្រង់តាមផ្លូវនោះមក សុំឲ្យលោកចាត់ទាហានមួយម៉ឺនទៅបង្កប់ចាំនៅសងខាងច្រកភ្នំនោះ បើកងទ័ពមុខ**ចូឆ្វ**លើកមកដល់ទីនោះ ត្រូវឲ្យអស់ទាហានសំងំសម្ងាត់ បើកាលណា**ចូឆ្វ**លើកមកដល់ សឹមឲ្យលើកចេញស្កាត់ខ្ទប់ទាំងសងខាង កងទ័ពមុខនៃ**ចូឆ្វ**នឹងត្រឡប់វិលទៅជួយក៏មិនទាន់ ដូច្នោះឃើញថានឹងចាប់**ចូឆ្វ**បានដោយងាយ។

**លីប៉ោ**បានស្តាប់ឆ្លើយថា “ដែលយើងនឹងតាំងរាំងទ័ព**ចូឆ្វ**នៅស្រុកប៉ាក់អៀងនោះ សេចក្តីគិតរបស់យើងឃើញថា មានផ្លូវនឹងតតាំងច្បាំងគ្នាជាច្រើនកន្លែង មិនបាច់នឹងបែងទាហានទៅបង្កប់ក្នុងទីនោះនាំឲ្យតែរវល់ទេ” ថាហើយ**លីប៉ោ**ក៏ចាត់ចែងទាហានត្រៀមទុកតទ័ពផ្ទាល់ស្រុកប៉ាក់អៀង។

**ចូឆ្ន**ដឹងដំណឹងច្បាស់ ក៏គិតស្រឡះលើកទាហានទៅតាមច្រកផ្លូវភ្នំថៃសាន់។ **គុយកែ**គិតទាន់ឃាត់ហាម**ចូឆ្ន**ថា ទីភ្នំថៃសាន់នោះមានចំពោះតែផ្លូវដើរ ខ្លាច**លីប៉ោ**ទៅបង្កប់ទាហាននៅទីនោះហេតុនេះសូមឲ្យលោកឈប់បង្អង់សិន ចាំឲ្យបម្រើសេះទៅស៊ើបល្បាតមើល។

**ចូឆ្ន**បានឮក៏សើចហើយតបថា “**លីប៉ោ**នោះជាមនុស្សមិនចេះគិត កាលណាឡើយនឹងយកទាហានទៅបង្កប់នៅទីនោះ យើងដឹងថាឥឡូវនេះ**លីប៉ោ**ឲ្យ**លីហាង** នឹង **ស៊ីឡាន់**ភ្ជុំទាហានទៅរក្សាស្រុកគុនជីវ ខ្លួន**លីប៉ោ**ឯងទទួលទ័ពនៅរក្សាស្រុកប៉ាក់អៀង ដូច្នេះយើងត្រូវបញ្ជូន**ចោយិន**ឲ្យលើកទាហានជាច្រើន ទៅឡោមព័ទ្ធស្រុកគុនជីវជាមុន” ថាហើយក៏លើកទាហានទន្ទ្រានទៅតាមច្រកភ្នំថៃសាន់។

**តាន់កុង**ដឹងដូច្នោះក៏និយាយនឹង**លីប៉ោ**ថា **ចូឆ្ន**ស្រូតលើកទាហានតមកដោយកម្លាំងក្រោធខឹង ខ្ញុំដឹងថាទាហានទាំងនោះ មុខជានឿយហត់ខ្លាំងណាស់ សុំឲ្យលោកបង្ខំលើកទាហានខាងយើងចេញទៅទទួលតទល់ជាឆាប់ យើងគង់នឹងបានចំណាប់ឈ្នះ**ចូឆ្ន**ជាប្រាកដ បើបង្អង់ឲ្យយូរទាហានបាត់នឿយហត់ទៅវិញ យើងនឹងផ្ចាញ់បានដោយកម្រណាស់។ **លីប៉ោ**តបថា មុនយើងនឹងតាំងខ្លួន យើងមានត្រឹមតែខ្លួនមួយ ហើយនឹងសេះប៉ុណ្ណោះ លុះបានធ្វើការសង្គ្រាមតាមលំដាប់រៀងមក ទាល់តែបានសេនាទាហានប៉ុណ្ណេះហើយ មិនត្រូវគិតក្រោធញញើត**ចូឆ្ន**នោះសោះឡើយ ទោះបី**ចូឆ្ន**នឹងមកតាំងបន្ទាយឲ្យមាំមួនយ៉ាងណា យើងក៏ត្រូវតែពុះពារទម្លាយវាយយកឲ្យបាន។

ខណៈនោះ **ចូឆ្ន**បានលើកទ័ពមកដល់ស្រុកប៉ាក់អៀង ហើយឲ្យតាំងបន្ទាយវាយសេនាទាហានជាមាំមួនបានស្រេចទាំងអស់។ លុះព្រឹកឡើងពួកទាហានចេញ

ទៅតម្រៀបនៅមុខបន្ទាយ **ចូឆ្វ**ជានាយជិះសេះចេញទៅឈរនៅមុខទាហាន បានក្រឡេកឃើញ**លីប៉ោ** និងទាហានឯកប្រាំបីនាយឈរអមទាំងឆ្វេងស្តាំ គឺឈ្មោះ **តៀវលៀវ១, ចុងប៉ា១, ឡាន់ប៉េង១, សោស៊ុន១, សេងលៀម១, ប៊ុយសុក១, សុងហៀន១, ហោសេង១** និងទាហានឡេវជាច្រើនហ៊ោកញ្ជៀវគឹកកងចេញមក។ **ចូឆ្វ**យករំពាត់សេះចង្អុលមុខ**លីប៉ោ**ហើយថា ខ្លួនហើយនិងយើងនឹងបានមានទោសទាស់ព្រោះអ្វីក៏ទេ ហេតុម្តេចខ្លួនក៏លើកទាហានមកវាយយកស្រុករបស់យើងដូច្នេះ?

**លីប៉ោ**ឆ្លើយថា “ស្រុកទាំងអម្បាលនេះជារបស់ព្រះមហាក្សត្រ ក៏ទុកដូចជារបស់មនុស្សប្រុសស្រីទាំងពួងដែលនៅលើផែនដី បើអ្នកឯណាមានបុណ្យឫទ្ធីខ្លាំងពូកែជាងគេ ត្រូវតែគ្រប់គ្រងស្រុកនីមួយៗបានដូចគ្នា ហេតុម្តេចអ្នកមកថាស្រុកនេះជារបស់អ្នក អ្នកគ្មានសេចក្តីអៀនខ្មាសទេឬ?” ថាហើយក៏ប្រើ**ចុងប៉ា**ឲ្យចេញទៅចាប់**ចូឆ្វ**។ **ចូឆ្វ**ឲ្យ**ង៉ាក់ជិន**ចេញមកតយុទ្ធគ្នានឹង**ចុងប៉ា**បានសាមសិបស្នៀត។ **ហែហ្គូទុន**បរសេះចេញទៅជួយ**ង៉ាក់ជិន, តៀវលៀវ**ក៏ចេញមកតយុទ្ធនឹង**ហែហ្គូទុន**។ ទាហានបួននាយប្រយុទ្ធគ្នាជាអង់អាចមិនបានចាញ់ឈ្នះ **លីប៉ោ**ឃើញដូច្នោះខឹងណាស់ បរសេះវាំទួនទៅតនឹង**ហែហ្គូទុន, ង៉ាក់ជិន** ឯ**ហែហ្គូទុន** និង**ង៉ាក់ជិន**តស៊ូនឹង**លីប៉ោ**មិនបាន ក៏ញាក់សេះថយរត់ **លីប៉ោ**ស្ទុះដេញប្រយុទ្ធពីក្រោយ ទាហាន**ចូឆ្វ**បែកខ្ចាត់ខ្ចាយអស់ទៅ **លីប៉ោ**ញាក់សេះត្រឡប់មកវិញ។ **ចូឆ្វ**សៀបប្រៀបនឹង**លីប៉ោ**ក៏ថយទ័ពត្រឡប់ចូលបន្ទាយ ហើយប្រឹក្សានឹងសេនាទាហានទាំងពួងថា **លីប៉ោ**កម្លាំងខ្លាំងពូកែណាស់ នឹងរកអ្នកឯណាតស៊ូមិនបាន។

**អ៊ីគឹម**ឆ្លើយថា ខ្ញុំបាទឡើងទៅលើភ្នំឃើញបន្ទាយ**លីប៉ោ**ទិសខាងលិចមានទាហានស្តើងណាស់ ដែល**លីប៉ោ**ច្បាំងឈ្នះចូលទៅគ្រានេះ មុខជានឹងមានចិត្តកម្រើប

មើលងាយ ទាហាន**លីប៉ោ**គង់នឹងប្រមាទមិនបានរក្សាបន្ទាយឲ្យមាំមួនទេ វេលាយប់នេះ សុំឲ្យលោកលើកទាហានចូលប្លន់យកបន្ទាយ**លីប៉ោ** គង់នឹងបានដោយងាយ។ **ចូឆ្វ**ក៏យល់ព្រមផង ទើបចាត់**ចោហេង១, លីតៀន១, អ៊ុគីម១, តៀនអ៊ុយ១** និងទាហានឡេវប្រហែលពីរម៉ឺនត្រៀមទុកជាស្រេច។

ឯ**លីប៉ោ**កាលត្រឡប់ទៅក្នុងបន្ទាយ បង្គាប់ឲ្យរៀបចំលៀងសេនាទាហាននិងឲ្យបំណាច់រង្វាន់ទាំងពួងតាមសមគួរ។ **តាន់កុង**និយាយនឹង**លីប៉ោ**ថា ដែល**ចូឆ្វ**បែកទ័ពទៅនោះ មុខជានឹងមានសេចក្ដីគិតត្រឡប់មកធ្វើការសងសឹកវិញជាប្រាកដ ខ្ញុំឃើញថាបន្ទាយទិសខាងលិចមានទាហាននៅស្ដួចស្ដើងណាស់ សុំឲ្យប្រមូលទាហានទៅបំពេញឲ្យមាំមួនឡើងវិញ។ **លីប៉ោ**តបថា **ចូឆ្វ**បែកទ័ពទៅពីព្រោះចាញ់ប្រៀបយើង ប្រហែលមិនគិតមកប្លន់បន្ទាយយើងវិញទេ។ **តាន់កុង**ថា លោកកុំអាលទុកចិត្ត ដ្បិត**ចូឆ្វ**ជាមនុស្សមានសតិបញ្ញាឆ្លៀវឆ្លាតក្នុងការសង្គ្រាមណាស់ ខ្ញុំឃើញថាមុខជានឹងលើកទ័ពមកប្លន់បន្ទាយជាប្រាកដ។ **លីប៉ោ**ឃើញត្រូវផង ទើបចាត់ឲ្យ**កោស៊ុន១, ងុយសុក១, ហោសេង១** នាំយកទាហានជាច្រើនទៅរក្សាបន្ទាយទិសខាងលិចជាយ៉ាងមាំមួន។

លុះដល់ពេលកណ្ដាលយប់ប្រហែលយាមពីរប្លាយ **ចូឆ្វ**ក៏លើកទាហានដែលត្រៀមទុកនោះទៅព័ទ្ធផ្លូវពីទិសខាងត្បូង ចូលទៅជិតដល់បន្ទាយហើយក៏ឲ្យរាយទ័ពជុំវិញ ហើយហ៊ោរត់ត្រសុកទៅលុកកាច់យកបន្ទាយនោះបាន។ ទាហានដែលនៅក្នុងបន្ទាយក៏បែកធ្លាយរត់ចេញទៅ។ ឯ**ងុយសុក១, ហោសេង១, កោស៊ុន១** ដែល**លីប៉ោ**ឲ្យនាំទាហានទៅរក្សាបន្ទាយនោះ បានលើកទៅជិតបន្ទាយក្នុងពេលនោះ លុះឃើញទាហាន**ចូឆ្វ**ប្លន់យកបន្ទាយបាន ក៏នឹកភ័យខ្លាច**លីប៉ោ**នឹងយកទោសខុស ទើប

ខំបង្រុះពុះពារច្បាំងយកបន្ទាយបានវិញ។ **ចូឆ្វ**ឃើញដូច្នោះ ក៏លើកទាហានគ្នាខាងក្រៅ សន្ធឹកទាហានទាំងសងខាងដែលប្រឡូកច្បាំងគ្នាក្នុងពេលយប់នោះ ហាក់បីដូចខ្យល់ព្យុះសង្ឃរាកក្រើកទាំងដែនពសុធាគឹកកងរំពងទាល់តែភ្លឺស្វាង។

**លីប៉ោ**ដឹងហើយ ក៏តាំងលើកទាហានស្រូតតម្រង់ទៅបន្ទាយខាងត្បូងទៀត។ បម្រើសេះនាំសេចក្តីនោះទៅប្រាប់**ចូឆ្វ**ថា បានឃើញ**លីប៉ោ**លើកទាហានមកជិតនឹងដល់ហើយ។ **ចូឆ្វ**បានឮជាក់ក៏តក់ស្លុតក្នុងចិត្ត គិតនឹងលើកទាហានត្រឡប់បែរមុខទៅក្រោយរត់បណ្តោយទៅ។ **កោស៊ុន, ងុយសុក, ហោសេង** ឃើញដូច្នោះក៏លើកទាហានបង្រុះតាមពីក្រោយដូចគេខ្ទប់ប្រសព្វគ្នានឹងទ័ព**លីប៉ោ**ពីមុខ តាំងតែគ្រលុកប្រកាប់គ្នាទៅវិញទៅមក។ **ចូឆ្វ**ប្រើ**អ៊ីគឹម** និង**ង៉ាក់ជិន**ចេញតនឹងទ័ព**លីប៉ោ**ដែលអង់អាច តែ**អ៊ីគឹម** និង**ង៉ាក់ជិន**កម្លាំងតិច តស៊ូនឹង**លីប៉ោ**ពុំបាន ក៏ញាក់សេះស្ទុះរត់ត្រឡប់ក្រោយនាំ**ចូឆ្វ**គេចបណ្តោយទៅទិសខាងជើង។ **លីប៉ោ**ស្ទុះឡើងតាមចាក់កាប់សម្លាប់ទាហាន**ចូឆ្វ**ស្លាប់គរលើគ្នា ឯ**ចូឆ្វ**, **អ៊ីគឹម** និង**ង៉ាក់ជិន** ក៏លើកទាហានរត់ទៅដល់ជើងភ្នំមួយ ទទួលជួបនឹង**តៀវលៀវ**, **ចោប៉ា** លើកទ័ពពីរកងមករងស្ទាក់ពីមុខ។ **ចូឆ្វ**ក៏ឲ្យ**ចោហង** និង**លីយ៉យ**ចេញតយុទ្ធគ្នានឹង**តៀវលៀវ**, **ចោប៉ា** យ៉ាងមាំមួន។ **ចោហង**, **លីយ៉យ**តស៊ូមិនឈ្នះក៏ញាក់សេះប្រាសថយក្រោយនាំ**ចូឆ្វ**និងទាហានរត់វិលបណ្តោយទៅទិសខាងត្បូង ទទួលប្រទះនឹង**ឡាន់ប៉េង**, **ចោសេង**, **សេងលៀម**, **សុងហៀន**ទាំងបួននាក់លើកទាហានជាពីរកងរងស្ទាក់ជាប់ **ចូឆ្វ**ក៏បង្ខំកងទ័ពចូលប្រកាប់គ្នាជាច្រឡំបល់ **ចូឆ្វ**យល់ថាកម្លាំងថយអន់ណាស់ ទ័ព**លីប៉ោ**ព័ទ្ធស្ទាក់ជុំវិញចេញពុំបាន **ចូឆ្វ**ក៏ខំស្ទុះបំពានរួចជាមួយនឹងទាហានប្រាំនាក់ លុះដល់ទៅជើងភ្នំមួយឮសូរសំឡេងផាវលើភ្នំ **ចូឆ្វ**ក្រឡេកមើលទៅឃើញទាហានបាញ់ធ្នូតម្រង់មក ព្រួញ

ហាក់ដូចគេបាចសាច **ចូឆ្វូ**រឹតតែខ្លាចញញើត ក៏ញាក់សេះត្រឡប់មកវិញ ពួកទាហាន**លីប៉ោ**តាមដេញឡោមព័ទ្ធជុំវិញ**ចូឆ្វូ** ៗភ័យណាស់ក៏ស្រែកថា នរណាមានកម្លាំងចូរជួយប្រឹងយកអាយុយើងផង។ **តៀនអ៊ុយ**ឮហើយក៏ថា “លោកកុំភ័យបារម្ភខ្ញុំសុំជួយ” ហើយក៏លោតចុះពីលើសេះ យកទួនផ្គែពីរគៀតក្នុងក្លៀក ហើយកន្ត្រាក់យកលំពែងពួយកាន់ទុកប្រហែលដប់ប្រាំផ្លែ ទើបបង្គាប់ទាហានប្រាំនាក់ដែលមកជាមួយផងគ្នានោះថា “បើឃើញពួកសត្រូវមកជិតប្រហែលប្រាំព្យាម ចូរប្រាប់យើង” ហើយក៏នាំមុខសេះ**ចូឆ្វូ**បាញ់ធ្នូតទៅវិញ។ ទាហាន**លីប៉ោ**លើកតាមមកពីក្រោយប្រហែលម្ភៃនាក់ ពួក**ចូឆ្វូ**ក៏ស្រែកប្រាប់**តៀនអ៊ុយ**ថា សត្រូវតាមមកជិតប្រហែលប្រាំព្យាមហើយ។ **តៀនអ៊ុយ**បានឮ ក៏រាបង្អង់ ហើយយកព្រួញបាញ់ទៅត្រូវទាហានសត្រូវធ្លាក់ពីលើសេះស្លាប់។ **តៀនអ៊ុយ**ក៏ចេះតែបាញ់ទាល់តែអស់ព្រួញពីដៃត្រូវសត្រូវគ្រប់ព្រួញ ទាហានដែលលើកតាមពីក្រោយនៅសល់ប្រហែលបួនប្រាំនាក់ក៏រត់ត្រឡប់ថយក្រោយទៅវិញ។ **តៀនអ៊ុយ**ក៏តឿនសេះនាំ**ចូឆ្វូ**នឹងរត់ចូលទៅក្នុងបន្ទាយ លុះទៅដល់កណ្តាលផ្លូវជួនពេលថ្ងៃល្ងាច បានឮសំឡេងទាហានស្រែកហ៊ោតាមមកទៀតជាច្រើន។ **ចូឆ្វូ**ក្រឡេកទៅក្រោយឃើញ**លីប៉ោ**បរសេះមកមុខទាហានក៏មានសេចក្តីភិតភ័យខ្លាំងណាស់។ ឯទាហានដែលតាមមកប្រាំនាក់នោះ នឿយហត់អស់កម្លាំងទាំងមនុស្សទាំងសេះ ក៏នាំគ្នាស្ទុះរត់ព្រាត់បែកគ្នាអស់ទៅ នៅតែ**តៀនអ៊ុយ** និង**ចូឆ្វូ**ពីរនាក់ ទទួលក្រឡេកទៅឃើញ**ហែហ្គូទុន**លើកទាហានចេញមកពីម្ខាងជួបនឹង**ចូឆ្វូ**។ **ហែហ្គូទុន**ក៏ចូលច្បាំងរាំងរាតនឹង**លីប៉ោ**ទាល់តែព្រលប់។ យប់នោះមានបណ្តាលព្យុះខ្យល់រល់ធ្លាក់ភ្លៀងធំ **លីប៉ោ**លើកទាហានត្រឡប់ទៅវិញ។

ឯ**ចូឆ្នូ**នាំហែហួទុននិង**តៀនអ៊ុយ**ចូលបន្ទាយ ហើយយកប្រាក់មាសឲ្យជាបំណាច់រង្វាន់**តៀនអ៊ុយ**ជាច្រើន។ លុះព្រឹកឡើង **តាន់កុង**និយាយនឹង**លីប៉ោ**ថា ចៅហ្វាយស្រុកប៉ាក់អៀងនោះរត់បាត់ទៅហើយ។ ក្នុងស្រុកនោះមានសេដ្ឋីម្នាក់ឈ្មោះ**តៀនស៊ី**ជាមនុស្សស្លូតត្រង់ និងជាទីរាប់អានដល់បណ្ដាអ្នកស្រុកទាំងពួង បើ**តៀនស៊ី**នឹងនិយាយការអ្វី អ្នកស្រុកក៏ជឿស្ដាប់គ្រប់គ្នាទាំងអស់ សុំឲ្យលោកហៅយកខ្លួន**តៀនស៊ី**មកនិយាយហើយឲ្យមានសំបុត្រទៅដល់**ចូឆ្នូ**ថា លោកមានជ័យជម្នះដោយយកបានស្រុកប៉ាក់អៀង ឥឡូវនេះ**កោស៊ុន**នៅរក្សាស្រុកនោះ ឯខ្លួនលោកនឹងលើកទ័ពទៅវាយយកស្រុកលីយ៉ុងវិញ ឲ្យ**ចូឆ្នូ**លើកទាហានទៅប្ដូន់យកស្រុកប៉ាក់អៀងចុះ លោកត្រូវឲ្យ**តៀនស៊ី**ទៅឃុំរក្សាបណ្ដាអ្នកស្រុកជាកងទ័ពសន្ទប់ ឯខ្លួនយើងត្រូវលបលើកទាហានចូលទៅក្នុងស្រុកប៉ាក់អៀង ហើយយកឧសទៅគរទុកនៅមុខទ្វារទាំងបួនទិសឲ្យស្រេច បើឃើញ**ចូឆ្នូ**លើកទ័ពមកដល់ យើងត្រូវដុតភ្លើងឲ្យឆេះឡើងកណ្ដាលស្រុក ដុតទាំងគំនរឧសទាំងបួនទិសឲ្យឆេះស្មើគ្នា ទោះបី**ចូឆ្នូ**នឹងមានសេចក្ដីគិតយ៉ាងណា ក៏ឃើញថាគង់នឹងមិនរួចពីដៃយើង។ **លីប៉ោ**បានស្ដាប់ក៏ចាប់ចិត្តគិតឃើញត្រូវ ក៏ហៅ**តៀនស៊ី**ចេញមក ហើយនិយាយល្បួងលួងលោមយកចិត្តតាមគំនិត**តាន់កុង**ពន្យល់នោះ។ **តៀនស៊ី**ក៏ព្រមធ្វើតាម **លីប៉ោ**និង**តៀនស៊ី**ក៏នាំគ្នាត្រឡប់ចូលទៅក្នុងស្រុក ហើយធ្វើសំបុត្រចាត់អ្នកបម្រើស្និទ្ធយកទៅឲ្យ**ចូឆ្នូ**ក្នុងបន្ទាយ។

**ចូឆ្នូ**ទទួលយកសំបុត្រទៅឃើញសេចក្ដីថា ខ្ញុំបាទឈ្មោះ**តៀនស៊ី**ជម្រាបមកលោក**ចូឆ្នូ**បានជ្រាប ដែល**លីប៉ោ**ជាមនុស្សអាក្រក់ លើកទាហានទៅវាយស្រុកប៉ាក់អៀងធ្វើអន្តរាយដល់បណ្ដារាស្ត្រក្នុងស្រុក ឲ្យបានសេចក្ដីទុក្ខក្ដៅក្រហាយនោះ

ឥឡូវនេះ**លីប៉ោ**មានសេចក្តីកំរើបលើកទាហានទៅវាយស្រុកលីយ៉ុង ហើយឲ្យ**កោស៊ុន, ហោសេង**នៅគ្រប់គ្រងរក្សាស្រុកនោះ សូមឲ្យលោកលើកទាហានចូលទៅប្លន់យកស្រុកនេះជាប្រញាប់ចុះ ខ្ញុំបាទនឹងដោតទង់សទុកជាសម្គាល់ ហើយនឹងលើកពួកអ្នកស្រុកចូលគ្រលុកជាទ័ពផ្ទុំពីម្ខាង ឃើញនឹងបានស្រុកប៉ាក់អៀងដោយងាយ។

**ចូឆ្វ**បានឃើញសេចក្តីសំបុត្រដូច្នោះ ក៏មានសេចក្តីស្មោះសរមិនមានសន្ទិះសង្ស័យ ទើបយកសំពត់មានតម្លៃឲ្យជាបំណាច់រង្វាន់អ្នកាន់សំបុត្រ ហើយឲ្យទៅប្រាប់**តៀនស៊ី**វិញថាយើងនឹងធ្វើតាម។ អ្នកបម្រើក៏លាវិលត្រឡប់ទៅវិញ។ **ចូឆ្វ**ឃើញថា "យើងខូចទាហានគ្រានេះក៏ទាល់គំនិតសោះ លុះឃើញ**តៀនស៊ី**ឲ្យសំបុត្រមកយើងដូច្នេះ ឧបមាបីដូចភ្នែកងងឹត ហើយមានគេនាំបង្ហាញផ្លូវឲ្យដើរទៅបាន" និយាយហើយក៏ឲ្យចាត់ចែងទាហានត្រៀមទុក។

**ឡៅហ៊ូ**និយាយថា **លីប៉ោ**នោះមិនជាអ្នកចេះគិតគូរក៏មែនហើយ តែថាបានធ្វើជាមេទ័ពមានទីប្រឹក្សាច្រើន ទាំង**តាន់កុង**ក៏មានសតិបញ្ញា ដែលលោកនឹងជឿស្តាប់ពាក្យ**តៀនស៊ី** ហើយលើកទាហានទៅធ្វើការនោះ បើគួរទៅក៏ទៅចុះ តែឲ្យមានតម្រិះគិតប្រយ័ត្នការឲ្យមាំមួន បើនឹងលើកទាហានទៅត្រូវចែកជាបីកង ឯពីរកងឲ្យបម្រុងទុកក្រៅស្រុកជាទ័ពសន្ទប់ មួយកងទៀតឲ្យលើកចូលទៅធ្វើការជាមួយនឹងខ្លួន ហើយឲ្យរវាំងស្តាប់ដំណឹងល្អអាក្រក់សិន បើឃើញមិនពិតដល់លោក ក៏ឲ្យទាហានមួយកងនោះចេញមកវិញ។ **ចូឆ្វ**បានស្តាប់ហើយ ក៏យល់ព្រមផង ទើបចាត់ទាហានចែកជាបីកង ហើយលើកចេញទៅដល់ស្រុកប៉ាក់អៀង ក្រឡេកទៅឃើញទង់សដោយនៅមាត់ទ្វារខាងលិច ជាសម្គាល់ដូចពាក្យ**តៀនស៊ី**ថា។

លុះដល់ពេលពាក់កណ្ដាលអាធ្រាត្រ **ហោសេង**ក៏លើកទាហានចេញមកជាកងមុខ **កោស៊ុន**ជាកងក្រោយ បើកទ្វារទិសឯកើតចេញទៅតច្បាំងនឹងកងទ័ព**ចូឆ្វ** ៗឲ្យ**តៀនអ៊ុយ**ចេញមកតទល់គ្នានឹង**ហោសេង**ជាពន្លឹក **ហោសេង**បែកទ័ពត្រឡប់ថយក្រោយ **កោស៊ុន**ក៏នាំគ្នាថយបណ្ដោយចូលបន្ទាយវិញ **តៀនអ៊ុយ**បរបណ្ដេញសេះតាមទៅទល់នឹងជើងកំពែង ទទួលអ្នកបម្រើ**តៀនស៊ី**កាន់សំបុត្រចេញទៅខាងទ្វារទិសខាងលិចយកទៅឲ្យ**ចូឆ្វ**ៗលាមើលឃើញសេចក្ដីថា ពេលអាធ្រាត្រយប់នេះ ខ្ញុំបាទ**តៀនស៊ី**នឹងបើកទ្វារទិសឯលិចចេញច្បាំង បើបានឮសំឡេងគងឃ្មោះ ឲ្យលើកទាហានប្រុះចូលទៅជាប្រញាប់។ **ចូឆ្វ**ត្រេកអរណាស់ ក៏ចាត់ឲ្យ**ហែហ្ហួទុន**នាំទាហានបង្ការខាងស្ដាំ ឲ្យ**ចោហាង**រៀបបញ្ចាំជួយខាងឆ្វេង។ **ចូឆ្វ** និង**ហែហ្ហួទុន**, **លីតៀន**, **ង៉ាក់ជិន**, **តៀនអ៊ុយ** លើកទាហានជាកងកណ្ដាល។ ដល់ពេញអាធ្រាត្រខែងងឹង ស្រាប់តែឮសំឡេងគងឃ្មោះខាងក្នុង ឃើញទ្វារឯលិចបើកចំហ។ **ចូឆ្វ**គិតនឹងឲ្យលើកទាហានចូលទៅ **លីតៀន**ឃាត់**ចូឆ្វ**ថា លោកជាមេទ័ពធំ មិនត្រូវបង្ខំលើកទាហានចូលទៅខ្លួនឯងតែម្ដងទេ ត្រូវតែឲ្យខ្ញុំបាទទទួលអាសាចូលទៅបានហើយបើឃើញការណ៍ល្អសឹមលោកលើកចូលទៅចុះ។ **ចូឆ្វ**តបថា ដែលមិនឲ្យយើងចូលទៅជាមួយផងនោះ ឃើញថាទាហានទាំងអស់មិនស្រុះចិត្តគ្នាធ្វើការទេ។ **ចូឆ្វ**បរសេះបង្រុះចូលទៅមុខទាហាន រហូតដល់ពាក់កណ្ដាលស្រុក មិនឃើញមានមនុស្សដើរទៅមកសោះ ក៏តក់ស្លុតរន្ធត់មហិមា ឃើញថាជាការណ៍កលឧបាយ ទើបស្រែកហៅទាហានទាំងឡាយឲ្យស្រូតរត់ចេញទៅក្រៅវិញ ស្រាប់តែឮសំឡេងផាវនិងគងឃ្មោះស្រែកហ៊ោរំពងអឺងកងជុំវិញ ភ្លើងឆេះឡើងគ្រប់ទ្វារទាំងបួនទិស រាលឆេះផ្ទះសម្បែងអ្នកស្រុកពេញទីបរិវេណភ្លឺដូចថ្ងៃ។

**ចោប៉ោ**ក៏បរសេះស្ទុះទៅដេញតាមកងទ័ព**ចូឆូ**ពីទិសខាងកើត **តៀវលៀវ**បរសេះស្ទុះទៅដេញកាប់កងទ័ព**ចូឆូ**ពីទិសឯលិចប្រសព្វគ្នា។ **ចូឆូ**ឃើញភ័យណាស់បរសេះរត់តម្រង់ទៅទិសឯជើង ប្រទះទ័ព**ឡាន់ប៉េង, ចោសេង** បរសេះដេញទាហានបំពានមកស្ទាក់ពីមុខ **ចូឆូ**បរសេះត្រឡប់រត់តម្រង់ទៅទិសឯត្បូង ប្រទះទ័ព**កោស៊ុន, ហោសេង**ចេញមកស្ទាក់ពីមុខទៀត។ **តៀនអ៊ុយ**តាម**ចូឆូ**ទៅ ឃើញដូច្នោះក៏បរសេះទម្លុះទៅប្រយុទ្ធគ្នានឹងទាហាន**កោស៊ុន, ហោសេង** ចេញទៅខាងក្រៅស្រុកបាន លុះក្រឡេកមើលមកក្រោយមិនឃើញ**ចូឆូ** ក៏ភ័យស្ទុះវិលត្រឡប់ចូលទៅដល់មាត់ទ្វារជួបនឹង**លីតៀន**សួរថា អ្នកបានឃើញ**ចូឆូ**ដែរឬទេ? **លីតៀន**ឆ្លើយថា ខ្ញុំក៏តាមរកដែរតែមិនដឹង**ចូឆូ**នៅត្រង់កន្លែងណា។

**តៀនអ៊ុយ**ថា "អ្នកត្រូវខំប្រឹងស្កាត់ប្រមូលទាហានរបស់យើង ដែលរត់ចេញទៅបាននោះកុំឲ្យបែកខ្ញែកគ្នា ខ្ញុំនឹងវិលទៅរក**ចូឆូ**" ថាហើយក៏ស្ទុះបង្រុះទាហាន**លីប៉ោ**ចូលទៅស្វែងរក**ចូឆូ**ក្នុងស្រុក លុះមិនជួបប្រទះក៏ពុះពារទាហានចេញទៅដល់ស្ពានភ្លោះកំពែងស្រុក ជួបនឹង**ង៉ាក់ជិន**ៗសួរ**តៀនអ៊ុយ**ថា ជួបប្រទះនឹង**ចូឆូ**ឬទេ? **តៀនអ៊ុយ**ឆ្លើយថា ខ្ញុំស្វែងរកពីរបីត្រឡប់ហើយ មិនជួបប្រទះសោះ។ **ង៉ាក់ជិន**បបួល**តៀនអ៊ុយ**ត្រឡប់វិលទៅដល់ទ្វារស្រុក ទាហាន**លីប៉ោ**ដែលនៅលើសើនយកភ្លើងគប់អុជឈ្នួនទម្លាក់ចុះមក **ង៉ាក់ជិន**ភ័យស្លុតក៏ញាក់សេះថយចេញមកវិញ ឯ**តៀនអ៊ុយ**បរសេះស្ទុះទម្លាយភ្លើងចូលទៅបានស្វែងរក**ចូឆូ**ក្នុងស្រុក។

ឯ**ចូឆូ**កាលភ្លាត់បែកចាកគ្នាពី**តៀនអ៊ុយ**នោះ ក៏បរសេះពុះទម្លាយភ្លើងរត់ទៅផ្លូវទិសឯជើង ជួបប្រទះនឹង**លីប៉ោ**កាន់ទួនបរសេះមក **ចូឆូ**ខ្លាចក៏លើកដៃឆ្វេងឡើងបាំងមុខ ដៃស្តាំកាន់បង្ហៀរសេះបរពុះទម្លុះភ្លើងទៅដល់មុខ**លីប៉ោ** ៗឃើញមិនច្បាស់

ស្មានថាទាហានរបស់ខ្លួន ក៏យកទួនគោះក្បាល**ចូឆូ**ហើយសួរថា ឃើញ**ចូឆូ**នៅខាងណា?

**ចូឆូ**បែរមុខចេញហើយលើកដៃចង្អុលប្រាប់ថា **ចូឆូ**ជិះលឿនរត់ទៅខាងនោះ។ **លីប៉ោ**មិនបានសង្កេត គ្មានសង្ស័យគិតថាពិត ក៏បរសេះត្រឡប់ទៅខាងក្រោយ។ **ចូឆូ**ត្រេកអរណាស់បរសេះវេះចេញទៅទិសខាងកើត ទើបជួបប្រទះនឹង**តៀនអ៊ុយ** ៗត្រេកអរក៏នាំ**ចូឆូ**ក្តារទាហានចេញទៅដល់មាត់ទ្វារ ឃើញគំនរឧសដែលភ្លើងឆេះនោះនៅទទឹងផ្លូវ ភ្លើងក៏នៅរាលឆេះប៉មកំពែងល្វែងហោណាំងខ្លាំងណាស់។ **តៀនអ៊ុយ**ក៏យកទួនចាក់ភ្លើងដែលឆេះគំនរឧសនោះចេញអស់ពីផ្លូវ ហើយនាំ**ចូឆូ**ស្ទុះទៅដល់មាត់ទ្វារ។ កាល**ចូឆូ**ទៅដល់មាត់ទ្វារនោះ ទទួលភ្លើងឆេះរបេះធ្នឹមខ្លោងទ្វារបាក់មកត្រូវជើងសេះដែល**ចូឆូ**ជិះ ដួលទៅលើគំនរភ្លើងស្លាប់។ **ចូឆូ**ស្ទុះលោតប្រញាប់ផុតពីគំនរភ្លើង តែអាវនិងសក់ ពុកមាត់**ចូឆូ**ត្រូវអណ្តាតភ្លើងឆាបឆេះពេញអស់ទាំងខ្លួនប្រាណ។ **ចូឆូ**ទាញកន្ត្រាក់ហែកអាវនោះបោះចោលទៅ ហើយយកដៃទាំងឆ្វេងស្ដាំបង្ខំបោសលត់ភ្លើងដែលឆេះសក់ និងពុកមាត់នោះទាល់តែរលត់ទើបរត់ចេញទៅផុតមាត់ទ្វារ។

**តៀនអ៊ុយ**មើលមកក្រោយឃើញដូច្នោះ ក៏ស្ទុះលោតពីលើសេះចុះមក ទទួល**ហែហួអៀន**ទៅទាន់ក៏ជួយគ្រាហ៍នាំ**ចូឆូ**ឲ្យឡើងជិះសេះរបស់**ហែហួអៀន**ទៅ។

ខណៈនោះ ទាហាន**លីប៉ោ**តាមទៅជាច្រើនណាស់ **តៀនអ៊ុយ**និង**ហែហួអៀន**រាមកការពារតទល់ទាល់តែដល់មុខបន្ទាយ លុះព្រឹកឡើងក្រឡេកឃើញទាហានតូចធំដែលបាក់បែករត់ដែកមកបាន ក៏បបួលគ្នាទៅសួរ**ចូឆូ**ៗអស់សំណើចសើចក្អាក

ក្អាយ ហើយថា គ្រានេះយើងខូចសេចក្ដីចេះអស់ បានថ្លោះខូចខាតសេនាទាហានជាច្រើន បើខ្លួនយើងនៅមិនទាន់ស្លាប់ទេ យើងត្រូវតែគិតសងសឹក**លីប៉ោ**វិញឲ្យបាន។

**គុយកែ**ឆ្លើយថា បើលោកនឹងគិតសងសឹក**លីប៉ោ**ត្រូវខំគិតឲ្យឆាប់។ **ចូវឆ្វ**ឆ្លើយតបថា ដែលលោកដាស់តឿនខ្លួនយើងដូច្នេះ ត្រូវណាស់ ឯភ្នំម៉ាឡេងនោះមានចំពោះតែផ្លូវដើរ យើងនឹងលើកទាហានទៅបង្កប់តាមច្រកភ្នំ ហើយនឹងឲ្យទាហានទាំងពួងដែលនៅក្នុងបន្ទាយនោះ ស្លៀកសពាក់សធ្វើជាយំសោករឭកអាល័យយើងថា ភ្លើងឆេះរោលជាទម្ងន់ទុរន់ទុរាណាស់ នាំមកដល់បន្ទាយវេលាណាក៏អនិច្ចកម្មទៅ បើកិត្តិស័ព្ទទាំងនេះដឹងទៅដល់**លីប៉ោ** ៗនឹងកំរើបលើកទាហានមកវាយបន្ទាយយើងតាមផ្លូវភ្នំម៉ាឡេង នោះយើងត្រូវសំងំឲ្យស្ងៀម បើឃើញកងទ័ពមុខលើករំលងហួសទៅដល់មាត់ផ្លូវវេលាណា សឹមយើងលើកសេនាទាហានចេញវាយកាត់កងទ័ព**លីប៉ោ** យើងមុខជានឹងចាប់ខ្លួន**លីប៉ោ**បានដោយងាយ។ **គុយកែ**ឆ្លើយថា ដែលលោកគិតនោះល្អណាស់ គ្មាននរណាស្មើបាន ។ ខណៈនោះ **ចូវឆ្វ**បង្គាប់ទាហានទាំងឡាយឲ្យស្លៀកសពាក់ស ហើយឲ្យនាំគ្នាយំសោកអាណិតថា **ចូវឆ្វ**ភ្លើងឆេះលំបាកវេទនាលុះគ្រាប់មកដល់បន្ទាយពេលយប់ ក៏ទទួលអនិច្ចកម្មដូច្នេះ ដើម្បីឲ្យកិត្តិស័ព្ទនេះឮទៅដល់**លីប៉ោ**។ ទាហានទាំងពួងបាននាំគ្នាធ្វើតាម ។ **ចូវឆ្វ**ក៏រៀបចាត់ចែងទាហានឲ្យលើកទៅបង្កប់នៅភ្នំម៉ាឡេង។

ឯទាហាន**លីប៉ោ**ឮកិត្តិស័ព្ទថា**ចូវឆ្វ**ស្លាប់ ក៏នាំយកដំណឹងនោះទៅប្រាប់**លីប៉ោ** ៗបានស្ដាប់សម្គាល់ក្នុងចិត្តថាពិតប្រាកដ ទើបថា “គ្រានេះមុខជាសមប្រកបតាមគំនិតរបស់យើងហើយ យើងនឹងលើកទៅវាយយកទាហាន**ចូវឆ្វ**ទុកជាកម្លាំង” ថាហើយលើកទ័ពទាំងអស់ទៅឲ្យដល់ភ្នំម៉ាឡេង។ ទាហានកងមុខនោះលើកកន្លង

ចេញទៅដល់មាត់ផ្លូវជិតបន្ទាយ**ចូឆ្វ**។ ឯ**ចូឆ្វ**ឃើញបានការ ក៏ឲ្យអុជផាវជាសញ្ញាឡើង ហើយលើកទាហានចេញវាយស្កាត់ពាក់កណ្ដាលខ្នប់ព័ទ្ធជុំវិញ។ **លីប៉ោ**ចេញទៅតទល់ដោយអង់អាចកណ្ដាលទ័ពទាហានខូចខាតស្លាប់ជាច្រើន។ **លីប៉ោ**ក៏នាំទាហានដែលនៅសល់នោះ លើកពុះពារត្រឡប់ក្រោយចូលដល់ស្រុកប៉ាក់អៀងវិញ ហើយបង្គាប់ឲ្យទាហានទាំងពួងឡើងត្រួតត្រារក្សាសើនបន្ទាយដោយមាំមួន ចំណែក**ចូឆ្វ**លើកទាហានចូលបន្ទាយវិញ។

ក្នុងសម័យនោះ អាណាខេត្តខាងទិសឯកើត កើតមានសត្វដង្កូវជាច្រើនស៊ីអស់ស្រូវក្នុងស្រែ និងស្ទឹមកណ្ដាប់គ្រប់ខេត្តតំបន់ ស្រូវឡើងថ្លៃមួយថាំងប្រាំរៀល។ អស់អាណាប្រជានុរាស្ត្រទាំងពួងក្រខ្សត់អត់ឃ្លានដាច់ពោះស្លាប់ជាច្រើន។ មនុស្សខ្លះកាប់សម្លាប់គ្នា អារយកសាច់មកបរិភោគជាអាហារ។ ឯទាហានក្នុងកងទ័ព**ចូឆ្វ**ដាច់ស្បៀងអាហារយូរថ្ងៃ **ចូឆ្វ**ទើបលើកទ័ពទៅបញ្ឈប់ក្នុងស្រុកអៀនសៀ។ **លីប៉ោ**ឃើញដូច្នោះ ក៏លើកទាហានចេញទៅរក្សាគយប្រទល់ដែនខេត្តប៉ាក់អៀងគ្រប់តំបន់។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ១០

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(ចាប់តាំងពី**តូកៀម**ប្រឹក្សានឹង**ប៊ីតុក**ថា ខេត្តឈីជីវនេះ យើងត្រូវប្រគល់ឲ្យ**ឡៅពី**គ្រប់គ្រង។ លុះដល់**តូកៀម**អនិច្ចកម្មទៅ ខេត្តឈីជីវក៏បានមក**ឡៅពី**គ្រប់គ្រងមែន។ **ចូឆ្វូ**តូចចិត្តខ្លាំង ព្រោះមិនបានសម្លាប់**តូកៀម**ជាការសងសឹក ទាំងឃើញស្រុកឈីជីវបានទៅ**ឡៅពី**កាន់កាប់ ដោយគ្មានស្រក់ឈាម ទើបរៀបកងទ័ពដោយបំណងនឹងទៅវាយ**ឡៅពី**... រៀងរហូតដល់**លីប៉ោ**ច្បាំងចាញ់**ចូឆ្វូ** ហើយ ទៅសុំនៅនឹង**ឡៅពី**)។*

**ពេល**នោះ**តូកៀម**ចៅហ្វាយស្រុកឈីជីវអាយុ៦៣ឆ្នាំ មានជំងឺឈឺធ្ងន់ណាស់ ទើបឲ្យហៅ**ប៊ីតុក**និង**តាន់កេង**មកប្រឹក្សាថា ខ្លួនខ្ញុំជរាហើយថែមទាំងមានជំងឺឈឺធ្ងន់ទៀត បើជាមានសឹកសាមមក មុខជានឹងផុតសង្ឃឹមសោះ។ **ប៊ីតុក**ឆ្លើយថា ដែលលោកគិតដូច្នោះក៏ត្រូវហើយ ព្រោះខ្ញុំដឹងថា ទ័ព**ចូឆ្វូ**ដែលលើកទៅច្បាំងនឹង**លីប៉ោ**លើកនេះជាសេចក្ដីហួងហែង បានជា**លីប៉ោ**លើកទ័ពទៅវាយយកស្រុកគុនជីវ។ **ចូឆ្វូ**និង**លីប៉ោ**ច្បាំងគ្នាដូច្នេះ ទទួលស្រូវក៏ថ្លៃ បានជា**ចូឆ្វូ**នឹងលើកទ័ពតាំងនៅស្រុកអៀនសៀ បើដល់ចូលឆ្នាំថ្មីស្រូវអង្ករបរិបូរហើយ មុខជា**ចូឆ្វូ**នឹងលើកទ័ពមកធ្វើសង្គ្រាមនឹង**លីប៉ោ**ទៀត។ បើដូច្នោះសូមឲ្យលោកអញ្ជើញ**ឡៅពី**មក និយាយអង្វរលន់តួប្រគល់ស្រុកនេះឲ្យ**ឡៅពី**ចុះ ពេលនេះប្រហែល**ឡៅពី**ព្រមទទួលមិនខាន បើបានដូច្នេះអស់បណ្ដារាស្ត្រក៏នឹងបានសេចក្ដីសុខតទៅ។

**តូកៀម**យល់ឃើញត្រូវ ក៏ឲ្យបម្រើចេញទៅអញ្ជើញ**ឡៅពី**ពីស្រុកសៀវផាយឲ្យចូលមក។ **ឡៅពី**ឃើញបម្រើទៅប្រាប់ ក៏ប្រញាប់រៀបខ្លួនចូលមកជាមួយនឹង**គួនអ៊ូ, តៀវហ៊ុយ** ហើយចូលទៅរក**តូកៀម** ៗក៏ឲ្យអញ្ជើញ**ឡៅពី**ចូលទៅក្នុងហើយនិយាយថា សព្វថ្ងៃខ្លួនខ្ញុំកាន់តែចាស់ជរារោគាពាធបង្កើតមានជាទម្ងន់ មិនដឹងជាសេចក្តីស្លាប់នឹងមកដល់វេលាណាទេ ខ្ញុំមានតែសេចក្តីវិបត្តិនឹងស្រុកឈីជីវនេះ ព្រោះមិនមានអ្នកឯណានឹងត្រួតត្រារក្សា បានជាឲ្យអញ្ជើញអ្នកមកប្រាថ្នានឹងប្រគល់ឲ្យអ្នក ៗចូរមានសេចក្តីអាសូរករុណាដល់ខ្ញុំទទួលយកត្រាសម្រាប់ងារចុះដើម្បីនឹងបានជួយទំនុកបម្រុងបណ្តារាស្ត្រអ្នកស្រុកឲ្យបានសេចក្តីសុខតទៅ។ **ឡៅពី**តបថា លោកមានបុត្រាពេញការទាំងពីរនាក់គឺ**តូស៊ុង**ជាបង **តូអេង**ជាប្អូន ហេតុម្តេចមិនប្រគល់ការរាជការក្នុងស្រុកនេះជាជំនួសលោក? **តូកៀម**ឆ្លើយថា បុត្រខ្ញុំទាំងពីរនេះល្ងង់គ្មានសតិបញ្ញាសោះ បើនឹងប្រគល់ឲ្យកាន់ការឃើញថាធ្វើមិនកើតយូរទៅគង់នឹងមានទុក្ខដល់អាណាប្រជានុរាស្ត្រមិនខាន ខ្ញុំឃើញតែអ្នកនឹងទទួលការបាន ៗជាឲ្យអញ្ជើញមក។ បើខ្ញុំអស់ជីវិតវេលាណា កុំឲ្យអ្នកប្រគល់ការឲ្យបុត្រាខ្ញុំទាំងពីរនេះឡើយ។

**ឡៅពី**ឆ្លើយថា ខ្លួនខ្ញុំកម្លាំងតិចណាស់ ដែលនឹងទទួលធ្វើជាចៅហ្វាយស្រុកនេះឃើញថានឹងធុតឥតសង្ឃឹមសោះ។ **តូកៀម**ថា "ទាហានក្នុងស្រុកនេះមានច្រើនខ្ញុំនឹងឲ្យ**ស៊ុនខៀន**ចៅហ្វាយស្រុកបាក់ហៃមកជាទីប្រឹក្សាផង" ដូច្នេះហើយនិយាយនឹង**ប៊ីតុក**ថា បើ**ឡៅពី**ធ្វើជាចៅហ្វាយខេត្តតទៅ ឲ្យអ្នកទៅផ្ញើខ្លួនធ្វើរាជការជាមួយនឹង**ឡៅពី**ចុះ។ ឯ**ឡៅពី**ក៏នៅមិនទាន់ទទួលពាក្យ**តូកៀម**ថាម្តេច។

ខណៈនោះ រោគ**តូកៀម**កាន់តែបណ្ដាលកំរើបឡើង នឹងចរចាពុំបាន យកតែម្រាមដៃចង្អុលត្រង់ខ្លួនហើយដាច់ខ្យល់ស្លាប់។ សេនាទាហាន**តូកៀម**ទាំងប៉ុន្មានក៏លើកយកត្រាសម្រាប់ងារមកប្រគល់ឱ្យ**ឡៅពី** ៗមិនព្រមទទួល។ សម័យនោះបណ្ដាអ្នកស្រុកក្នុងទីចំណុះខេត្តបានដឹង នាំគ្នាចូលមកគំនាប់**ឡៅពី**ហើយនិយាយអង្វរលន់តួថា ដែលលោកមិនព្រមទទួលធ្វើជាចៅហ្វាយខេត្តឈីជីវនេះ អំណើះតទៅយើងខ្ញុំទាំងឡាយនឹងបានសេចក្ដីទុក្ខក្ដៅខ្លាំងណាស់។ **គួនអ៊ូ, តៀវហ៊ុយ** ឃើញដូច្នោះក៏ជួយនិយាយទៀត ដោយហេតុមានចិត្តអាណិតអាសូរអាណាប្រជានុរាស្ត្រពន់ប្រមាណថា សូមឱ្យលោកទទួលយកត្រាធ្វើចៅហ្វាយខេត្តឈីជីវ។ **ឡៅពី**បានស្ដាប់ពាក្យ**គួនអ៊ូ, តៀវហ៊ុយ**ក៏ព្រមទទួលត្រាក្នុងខណៈនោះ ហើយតាំង**ស៊ុនខៀន**និង**ប៊ីតុក**ជាទីប្រឹក្សាឆ្វេងស្ដាំ ឱ្យ**គួនអ៊ូ, តៀវហ៊ុយ**ទៅឈររក្សាស្រុកសៀវផាយហើយនាំយកទាហានចូលមកស្រុកឈីជីវទាំងអស់។ **ឡៅពី**និងសេនាទាហាននូវអស់បណ្ដារាស្ត្រក្នុងស្រុកនោះ ក៏ស្រុះស្រួលបបួលគ្នាស្លៀកពាក់សកាន់ទុក្ខ ហើយឱ្យរៀបតែងការសព**តូកៀម**តាមទំនៀម រួចនាំយកសពនោះដង្ហែទៅបញ្ចុះនៅតំបន់អ៊ុយហោ។ **ឡៅពី**រើយកសំបុត្រដែល**តូកៀម**ធ្វើទុកនោះមកប្ដឹងចូលទៅស្រុកក្រុងឱ្យយកសេចក្ដីក្រាបបង្គំទូលព្រះចៅ**ហៀនតេ**។ ក្នុងសេចក្ដីសំបុត្រនោះថា "**តូកៀម**មានអាការជរាភាព ទើបលើកខេត្តឈីជីវប្រគល់ឱ្យ**ឡៅពី**ធ្វើការជំនួស" ព្រះចៅ**ហៀនតេ**ជ្រាបសេចក្ដីហើយ ក៏មិនបានត្រាស់ថាប្រការម្ដេច។

ឯ**ចូឆូ**នៅស្រុកអៀនសៀឮដំណឹងថា **តូកៀម**ចៅហ្វាយខេត្តឈីជីវអនិច្ចកម្ម**ឡៅពី**បានធ្វើជាចៅហ្វាយខេត្តនោះ ដូច្នេះហើយខឹងណាស់ថា "យើងមានសេចក្ដីក្ដៅក្រហាយនឹង**តូកៀម** ព្រោះមិនទាន់បានសងសឹក**តូកៀម**សោះ ស្រាប់តែវាអស់ជីវិត

ទៅ ឯ**ឡៅពី**នោះសោតក៏មិនបានធ្វើសឹកសង្គ្រាម ឲ្យខូចខាតទាហាននិងព្រួញធ្នូមួយឡើយ ហើយមកបានជាថៅហ្វាយស្រុកស្រណុកដោយងាយ ដូច្នេះយើងនឹងលើកទ័ពទៅសម្លាប់**ឡៅពី**ចេញ ហើយលើកសព**តូកៀម**ឡើងវិញ ចិញ្ច្រាំឲ្យល្អិតសាច់និងឆ្អឹង ទើបនឹងអស់សេចក្ដីក្ដៅ” ថាហើយតាំងចាត់ចែងកេណ្ឌកងសេនាទាហានលើកទៅស្រុកឈីជីវ។

**ស៊ុនហុក**ទីប្រឹក្សាឃើញដូច្នោះ និយាយហាមឃាត់**ចូឆូ**ថា ដែលលោកនឹងលើកទ័ពទៅវាយយកស្រុកឈីជីវនោះ ជាការកម្រណាស់ មួយរយនាក់ទើបគិតការនេះបានម្នាក់ ដូចកាលគ្រាព្រះថៅ**ហាន់កោចោ** និងព្រះរាជវង្សបានសោយរាជ្យជាលំដាប់គ្នាមកដល់ដប់ពីរព្រះអង្គ ទទួល**អងម៉ាំង**គិតក្បត់ បានរាជសម្បត្តិដល់ដប់ប្រាំបីឆ្នាំ **ហាន់កងប៊ូ**ជាក្មួយព្រះមហាក្សត្រដែលខូចរាជសម្បត្តិដល់**អងម៉ាំង**នោះ ក៏សម្លាប់**អងម៉ាំង**ចេញ បានរាជសម្បត្តិមកវិញ បានសោយរាជ្យជាតំណទៀតចំនួនដប់ពីរព្រះអង្គ ទើបដល់ព្រះថៅ**ហៀនតេ** ឯសព្វថ្ងៃនេះបើលោកនឹងគិតការធំទៅមុខក៏ចូររកទំនុកទុកឲ្យមាំដូចព្រះមហាក្សត្រពីដើម ទើបនឹងគិតការតទៅបាន ឥឡូវលោកនឹងលើកទ័ពទៅវាយស្រុកឈីជីវតែម្ដងនោះ ខ្ញុំឃើញថារាស្ត្រទាំងពួងនៅមានចិត្តស្រឡាញ់**ឡៅពី**ច្រើន ឃើញថានឹងវាយយកស្រុកនោះមិនបានដោយងាយទេ ឯស្រុកអៀនសៀ បើលោកឲ្យទាហានទៅរក្សានោះ **លីប៉ោ**ដឹងហើយក៏នឹងលើកទ័ពមកវាយយកទទេសោះ លោកលើកទៅខាងនោះ បើមិនកើតការនឹងត្រឡប់មកខាងណាមានតែចាញ់ប្រៀបទាំងសងខាង ថែមទាំងខូចខាតទាហានគ្មានទីអាង ម្ល៉ោះហើយលោកក៏នឹងតាំងខ្លួនពិបាកណាស់ ទម្រាំនឹងដុះក្រាស់ហើរបានឡើងវិញក៏យូរ

ទៅមុខ ដែលលោកនឹងលះបង់ស្រុកទូលាយហើយទៅរកទីចង្អៀតវិញនោះ សូមឲ្យលោកត្រិះរិះមើលដោយគួរសមសិន។

**ចូឆ្វ**តបថា អាណាខេត្តខាងបូព៌ាទិសសុទ្ធតែមនុស្សទុរភិក្សអត់ឃ្លានដោយស្បៀអាហារ ដែលនឹងឲ្យរង់គិតការតទៅក៏នៅក្នុងព្រួយលំបាក ព្រោះទាហានយើងមុខជាត្រូវអត់ឃ្លានស្បៀងអាហារស្លាប់ពុំខាន។

**ស៊ុនហុក**ឆ្លើយថា ឥឡូវនេះខ្ញុំដឹងដំណឹងថា **ហោងី** និង**អ៊ុយសៀវ** ឃុំនាំពួកចោរជូតក្បាលលឿងទៅនៅស្រុកអេងជីវ រាតត្បាតធ្វើទុក្ខបុកម្នេញដល់អាណាប្រជានុរាស្ត្រខ្លាំងណាស់ បើលោកលើកទ័ពទៅវាយពួកចោរនោះបែក ក៏នឹងបានស្បៀងអាហារមកជប់លៀងសេនាទាហាន រាស្ត្រទាំងពួងក៏នឹងមានអំណរ ចុះចូលមកពឹងពរលោកមិនខាន ហើយបើជ្រាបសេចក្តីនោះទៅដល់ព្រះចៅ**ហៀនតេ**ទៀត ក៏នឹងមានសេចក្តីគាប់ប្រសើរដល់លោក។ **ចូឆ្វ**បានស្តាប់ឃើញត្រូវ ក៏ឲ្យទៅប្រាប់**ហែហ្គូទុន** និង**ចោឃិន**នៅរក្សាស្រុក ឯខ្លួន**ចូឆ្វ**ក៏បបួលសេនាទាហានលើកទៅស្រុកអេងជីវ។

ខណៈនោះ **ហោងី** និង**អ៊ុយសៀវ**ជាមេចោរបានដឹង ក៏លើកពួកចោរទៅបោះទ័ពនៅតំបន់ភ្នំអេងសាន់។ **ចូឆ្វ**ដើរចូលទៅមើលពួកកងទ័ពចោរឃើញរបៀបខុសក្បួនសឹក ក៏ឲ្យ**តៀនអ៊ុយ**លើកទាហានទៅច្បាំងនឹងពួកចោរ។ **ហោងី**ក៏ឲ្យទាហានចេញតទល់នឹង**តៀនអ៊ុយ**បានបីភ្លែង **តៀនអ៊ុយ**យកទួនចាក់ទាហានចោរធ្លាក់ពីលើសេះស្លាប់។ **ចូឆ្វ**ក៏បរពលចូលប្រកាប់ពួកចោរ ទម្លាយបន្ទាយ**នៅ**ទីភ្នំនោះបែកខ្ចាត់ខ្ចាយ ហើយតាំងបោះទ័ពនៅទីនោះ លុះវេលាព្រឹកឡើង **អ៊ុយសៀវ**ក៏លើកទាហានចេញមកដល់បន្ទាយ**ចូឆ្វ**។

**ហោប៉ាន់**ទាហានចោរមានកម្លាំងខ្លាំង កាន់ដំបងដែកចេញមកមុខទាហាន ហើយស្រែកប្រកាសថា នរណានឹងតស៊ូគ្នាឲ្យប្រញាប់ចេញមក។ **ចោហង**បានឮក៏វាំដាវចូលទៅប្រយុទ្ធគ្នានឹង**ហោប៉ាន់**បានប្រាំភ្លែង **ចោហង**ធ្វើជាថយរត់ទៅក្រោយ **ហោប៉ាន់**គ្រវែងដំបង ចោលសំដៅទៅ**ចោហង**ៗគេចផុតស្ទុះចូលមកកាប់**ហោប៉ាន់**ដាច់ពាក់កណ្ដាលខ្លួនស្លាប់នៅទីនោះ។ **លីតៀន**ឃើញដូច្នោះ ក៏បរសេះវាំទួនដេញកាប់ពួកចោរចូលទៅចាប់ខ្លួន**អ៊ុយសៀវ**បាន។ **ចូឆ្វូ**ក៏លើកទាហានតាមចូលទៅដល់បន្ទាយចោរ។ ចោរក៏រត់ព្រាត់ព្រាយខ្ចាត់ខ្ចាយអស់ទៅ ទាហាន**ចូឆ្វូ**ក៏ប្រមូលរើសយកទ្រព្យរបស់ចោរបានជាច្រើន។

**ហោងី**មេចោរនាំពួកភឿនប្រមាណពីរយប្លាយ រត់ចេញពីបន្ទាយទៅដល់ភ្នំមួយ ក្រឡេកឃើញ**ខៅធូ**ជិះសេះកាន់ដាវឈរឃាំងផ្លូវ។ **ហោងី**បំផាយសេះចូលប្រយុទ្ធនឹង**ខៅធូ**បានមួយភ្លែង **ខៅធូ**នាំ**ហោងី**និងពួកចោរចូលទៅក្នុងរូងភ្នំ ដែលធ្លាប់នៅសំណាក់។ **ចូឆ្វូ**ឃើញ**ហោងី**រត់ទៅដូច្នោះ ក៏ឲ្យ**តៀនអ៊ុយ**តាមទៅចាប់ខ្លួន។ **តៀនអ៊ុយ**បរសេះលើកទាហានទៅដល់ជើងភ្នំ ឃើញ**ខៅធូ**នាំពួកម៉ាកចេញមកឈរស្កាត់ទទឹងផ្លូវ។ **តៀនអ៊ុយ**សួរថា អ្នកនេះជាពួកចោរជូតក្បាលលឿងឬ? **ខៅធូ**តបថា យើងមិនមែនពួកចោរទេ ឯពួកចោរជូតក្បាលលឿងនោះ យើងចាប់បានមេវាម្នាក់មកទុកក្នុងរូងភ្នំ។ **តៀនអ៊ុយ**សួរថា បើដូច្នោះចូរអ្នកទៅយកពួកចោរនោះមកឲ្យយើងជាឆាប់។ **ខៅធូ**ឆ្លើយថា បើអ្នកយកក្បាលរងទទួលដាវយើងនេះបាន ទើបយើងប្រគល់ពួកចោរឲ្យ។ **តៀនអ៊ុយ**ឮសម្ដីដូច្នោះ ក៏ខឹងណាស់ បរសេះវាំដាវចូលទៅ ប្រយុទ្ធនឹង**ខៅធូ**តាំងពីព្រឹកលុះដល់ថ្ងៃត្រង់មិនចាញ់មិនឈ្នះ ទាំងសងខាងក៏ថយឈប់សម្រាកកម្លាំង ហើយក្រោកឡើងបបួលគ្នាប្រយុទ្ធទៀត តាំងពីថ្ងៃត្រង់

ដល់រសៀលល្ងាច សេះក៏អស់កម្លាំង **ខៅធូ**នឿយណាស់វិលចូលទៅក្នុងរូងភ្នំវិញ។ **តៀនអ៊ុយ**ឲ្យទាហាននាំយកសេចក្ដីទាំងនោះទៅប្រាប់**ចូអ្វ** ៗបានដឹងដូច្នោះលើកទាហានចេញទៅទាំងពេលយប់។

លុះពេលព្រឹកព្រហាម **ខៅធូ**នាំបក្សពួកចេញពីក្នុងរូងភ្នំ។ **ចូអ្វ**ឃើញរូបរាង**ខៅធូ**មាឌធំខ្ពស់ប្រហែលប្រាំមួយហត្ថសមជាទាហាន ក៏គិតចង់បាន**ខៅធូ**ទុក។ ទើបបង្គាប់**តៀនអ៊ុយ**ថា អ្នកចូរទៅតយុទ្ធម្ដងទៀត ហើយធ្វើជាថយរត់ត្រឡប់មកក្រោយវិញ។ **តៀនអ៊ុយ**ក៏ធ្វើតាម លុះប្រយុទ្ធគ្នាបានសាមសិបភ្លែង ក៏ថយត្រឡប់មកក្រោយដោយរហ័ស **ខៅធូ**ក៏បំផាយសេះដេញតាម **ចូអ្វ**ឃើញដូច្នោះ បង្គាប់ឲ្យទាហានបាញ់ធ្នូចម្រុះទៅ **ខៅធូ**ឃើញកម្លាំងនឹងតទល់ពុំបាន ញាក់សេះបរត្រឡប់នាំបក្សពួកចូលទៅក្នុងរូងភ្នំវិញ។ លុះដល់ពេលអាធ្រាត្រស្ងាត់ **ចូអ្វ**បង្គាប់ឲ្យជីករំលុង ហើយយកអន្ទាក់ដាក់នៅមាត់រំលុងនោះ ហើយរាយស្មៅដាក់នៅមាត់រណ្ដៅមិនឲ្យស្គាល់បាន។ ដល់ព្រឹកព្រាងឡើង **ចូអ្វ**ក៏ចាត់**តៀយអ៊ុយ**ឲ្យលើកទាហានមួយរយចូលទៅស្រែកជេរដៀមដាមនៅមាត់រូង បើឃើញ**ខៅធូ**ចេញមកឲ្យតទល់បញ្ឆោតថយមកត្រង់រំលុងនោះ។ **តៀនអ៊ុយ**លើកទាហានមួយរយទៅធ្វើតាម**ចូអ្វ**បង្គាប់ **ខៅធូ**បានឮ លើកបក្សពួកចេញមក ឃើញ**តៀនហ៊ុយ**ហើយស្រែកថា “អាទាហានសេះនេះនឹងមកលេងគ្នានឹងអញទៀតឬ?” ហើយក៏បរសេះចូលទៅប្រយុទ្ធនឹង**តៀនអ៊ុយ**បានដប់ភ្លែង **តៀនអ៊ុយ**ធ្វើជាញាក់សេះថយរត់ទៅខាងរំលុងនោះ **ខៅធូ**មិនដឹងកលឧបាយបំផាយសេះដេញតាមទៅ សេះនោះក៏ផុងធ្លាក់ក្នុងរំលុងជាមួយនឹង**ខៅធូ**។ អន្ទាក់នោះជាប់ជើង**ខៅធូ**ជាមួយនឹងពួកម្នាក់ ទាហាន**ចូអ្វ**កន្ត្រាក់ខ្សែទុក ហើយចូលទៅឡោមព័ទ្ធចាប់ជើងដៃ**ខៅធូ**ចងនាំទៅឲ្យ**ចូអ្វ**។ ឃើញដូច្នោះ**ចូអ្វ**ក៏ធ្វើជាភ្ញាក់ខ្លួន

ហើយក្រោកចុះទៅស្រាយចំណងដៃជើង**ខៅធូ**ចេញអស់ ឱ្យយកសម្លៀកបំពាក់យ៉ាងល្អមកឱ្យ**ខៅធូ**ស្លៀកពាក់ ហើយទាញដៃមកឱ្យអង្គុយហើយសួរថា អ្នកឯងឈ្មោះអ្វី? កំណើត និងទីលំនៅនៅស្រុកណា? ហេតុម្ដេចទើបបាននៅនឹងរូងភ្នំ?

**ខៅធូ**ជម្រាបថា ខ្ញុំបាទឈ្មោះ**ខៅធូ**កើតនៅស្រុកចៀវកុក កាលគ្រាកើតពួកចោរជូតក្បាលលឿង ខ្ញុំបាទនាំគ្រប់គ្រួ និងបក្សពួកប្រហែលប្រាំរយនាក់រត់មកលាក់ខ្លួនពួននៅក្នុងរូងភ្នំនេះ ហើយបក្សពួកជញ្ជូនយកដុំថ្មមកគរទុកនៅមាត់រូងជាច្រើន សម្រាប់តស៊ូនឹងពួកចោរ។ លុះមកដល់ថ្ងៃមួយនោះ ពួកចោរលើកគ្នាមកវាយពួកខ្ញុំបាទ ៗបានយកដុំថ្មណាចោលទៅត្រូវពួកចោរស្លាប់គ្រប់ដុំថ្មនោះ ពួកចោរស្លាប់អន្តរាយជាច្រើន ចោរដែលសល់ពីស្លាប់នោះលើកគ្នាថយទៅវិញអស់។ អំណើះពីនោះមក ខ្ញុំបាទនិងបក្សពួកដាច់ស្បៀងអាហារ មានចោរមួយពួកលើកគ្នាមកឃើញគោខ្ញុំបាទ ទើបយកស្បៀងមកដូរយកគោមួយនឹមទៅ ខ្ញុំបាទក៏ព្រមដូរឱ្យ លុះចោរនាំយកគោទៅចម្ងាយ៥០សិន (២ គ.ម) គោផ្អើលបោលចូលទៅក្នុងព្រៃ ខ្ញុំបាទក៏តាមទៅ ហើយចាប់កន្ទុយគោម្ខាងមួយ អូសមកដល់មាត់រូងភ្នំ ពួកចោរឃើញខ្ញុំបាទមានកម្លាំងក៏មិនអាចតាមមក។

**ចូឆូ**តបថា យើងបានឮល្បីឈ្មោះអ្នកយូរមកហើយ ការជួបឃើញមុខគ្នាថ្ងៃនេះ ជាបុណ្យភ័ព្វរបស់យើង ៗនឹងចិញ្ចឹមរក្សាអ្នកទុកជាទាហាន អ្នកក៏ត្រូវមានចិត្តគិតស្រឡាញ់យើង ហើយព្រមធ្វើរាជការជាមួយចុះ។ **ខៅធូ**ឆ្លើយថា “ដែលលោកមានប្រសាសន៍មកដូច្នេះ ព្រះគុណធ្ងន់មិនមានទីបំផុត ខ្ញុំបាទសុខចិត្តព្រមចូលនៅធ្វើការជាមួយនឹងលោកតទៅ” ដូច្នេះហើយក៏ប្រើពួករបស់ខ្លួនម្នាក់វិលទៅនាំយកគ្រប់គ្រួ និងស្ម័គ្របក្សពួក និង**ហោងី** និងបក្សពួកចោរពីររយប្លាយ ចេញមកចូល

នឹង**ចូឆ្វ**ៗឃើញដូច្នោះក៏មានសេចក្ដីត្រេកអរពន់ប្រមាណ ទើបតាំង**ខៅធូ**ជាមេទាហានឯក (ពាក្យចិនហៅថា **តោអ៊ុយ**) ហើយឲ្យមាសប្រាក់គ្រឿងសម្លៀកបំពាក់ដល់បក្សពួក**ខៅធូ**ថែមទៀត។ ឯខ្លួន**ហោងី** និង**អ៊ុយសៀវ**នោះ **ចូឆ្វ**ឲ្យនាំយកទៅសម្លាប់ចេញ ហើយឲ្យកាត់ក្បាលយកមកដោតនៅមុខបន្ទាយ មិនឲ្យអ្នកឯទៀតយកជាបែបយ៉ាង។ រួចហើយ**ចូឆ្វ**ក៏លើកទាហានទៅស្រុកអៀនសៀ។

**ហៃហ្លួទុន** និង**ចោយិន**បានឮដំណឹង ក៏នាំគ្នាចេញមកទទួល**ចូឆ្វ**ចូលទៅក្នុងស្រុក ហើយជម្រាប**ចូឆ្វ**ថា ខ្ញុំបាទឮកិត្តិស័ព្ទថា **លីហាង** និង**ស៊ីឡាន់** ដែល**លីប៉ោ**ឲ្យទៅនៅរក្សាស្រុកគុនជីវនោះ ពេលនេះពួកទាហានអត់ស្បៀងអាហារណាស់ តែងលើកគ្នាចេញទៅរាតត្បាតវាយដណ្ដើមយកទ្រព្យរបស់អាណាប្រជានុរាស្ត្រ ឯពួកទាហានក្នុងស្រុកនោះក៏មានស្លួចស្ដើងទេ ដូច្នេះសុំឲ្យលោកលើកពលរេហ៍ត្រឡប់ទៅវាយយកស្រុកគុនជីវនោះក៏នឹងបានដោយងាយ។ **ចូឆ្វ**យល់ព្រមតាម ក៏លើកទាហានទាំងឡាយទៅវាយយកស្រុកគុនជីវនោះ។

ឯ**លីហាង** និង**ស៊ីឡាន់** បានឃើញកងទ័ព**ចូឆ្វ**លើកទៅព័ទ្ធស្រុក ក៏លើកទាហានចេញមកតទល់នឹងទ័ព**ចូឆ្វ**។ **ខៅធូ**ឃើញដូច្នោះសុំខ្លួនចេញទៅតទល់យកអាសា **ចូឆ្វ**ត្រេកអរណាស់ ចាត់**ខៅធូ**ឲ្យចេញទៅ។ **ខៅធូ**ជិះសេះរាំទួនចេញទៅតយុទ្ធនឹង**លីហាង**បានបីភ្លែងយកទួនចាក់**លីហាង**ធ្លាក់ពីលើសេះស្លាប់។ **ស៊ីឡាន់**ឃើញដូច្នោះមានសេចក្ដីភ័យណាស់ ប្រាសគេចខ្លួននាំពួកទាហានវិលចូលទៅក្នុងកំពែងស្រុកវិញ ទទួលជួបប្រទះនឹង**លីតៀន**លើកទាហានស្កាត់ជាប់ពីមុខត្រង់គូកំពែងស្រុក។ **ស៊ីឡាន់**ក៏ញាក់សេះបែរមុខចូលទៅក្នុងព្រៃ។ ទទួល**លីយ៉យ**ឃើញ ក៏

ជិះសេះស្ទុះមកស្ទាក់ ហើយលើកធ្នូបាញ់ត្រូវ**ស៊ីឡាន់**ធ្លាក់ពីលើសេះស្លាប់។ កងទ័ព**ស៊ីឡាន់**ក៏បែកខ្ចាត់ខ្ចាយអស់ទៅ។

ខណៈនោះ **ចូឆ្វូ**ក៏វាយយកស្រុកគុនជីវបាន ហើយឱ្យ**ខៅធូ**និង**តៀនអ៊ុយ**លើកពលទាហានជាកងមុខ ឱ្យ**ហែហ្វូទុន** និង**ហែហ្វូអៀន**ជាកងស្តាំ ឱ្យ**លីតៀន** និង**ង៉ាក់ជិន**ជាកងឆ្វេង ខ្លួន**ចូឆ្វូ**ឯងជាកងហ្លួង **អ៊ីគឹម** និង**លីយ៉យ**ជាកងក្រោយ លើកទ័ពទៅវាយយកស្រុកប៉ាក់អៀង។

ឯ**លីប៉ោ**បានដឹងដូច្នោះ ក៏លើកទាហានចេញមកតទល់ទ័ព**ចូឆ្វូ**។ **តាន់កុង**ហាម**លីប៉ោ**ថា ដែលលោកនឹងស្រូតលើកទ័ពចេញទៅនោះ ខ្ញុំបាទឃើញការណ៍មិនស្រួល សុំឈប់បង្អង់ចាំពួកទាហានដែលចេញទៅរកស្បៀងអាហារនោះត្រឡប់មកជួបជុំគ្នាសិន សឹមលើកចេញទៅច្បាំងនឹង**ចូឆ្វូ**ចុះ។ **លីប៉ោ**តបថា កើតមកជាជាតិទាហានហើយនឹងត្រូវកោតខ្លាចសឹកសង្គ្រាមធ្វើអ្វី! **លីប៉ោ**មិនព្រមស្តាប់ពាក្យ**តាន់កុង**រំឭក ក៏លើកទាហានចេញពីស្រុកទៅ។ **លីប៉ោ**ជិះសេះនាំខ្លួនទៅដល់មុខកងទ័ព**ចូឆ្វូ**ហើយស្រែកប្រកាសថា នរណាមានឫទ្ធិដៃខ្លាំងពូកែតស៊ូនឹងយើងបាន ក៏ឱ្យរៀបខ្លួនចេញមកចុះ។ **ខៅធូ**បានឮដូច្នោះខឹងណាស់ បរសេះនាំខ្លួនចេញមកប្រយុទ្ធគ្នានឹង**លីប៉ោ**បានម្ភៃភ្លែង មិនបានចាញ់ឈ្នះ។ **ចូឆ្វូ**ឃើញថា**ខៅធូ**ម្នាក់ឯងយកជ័យជម្នះពី**លីប៉ោ**មិនបាន ក៏ប្រើ**តៀនអ៊ុយ**ចេញទៅជួយ**ខៅធូ**ប្រយុទ្ធនឹង**លីប៉ោ**ទៀត។ ឯ**ហែហ្វូទុន**, **ហែហ្វូអៀន**, **ង៉ាក់ជិន** និង**លីតៀន**ដែលជាកងឆ្វេងស្តាំនាំគ្នាបរសេះចេញទៅចោមព័ទ្ធ**លីប៉ោ**ជុំវិញ។ **លីប៉ោ**កាប់ឆ្ការពារទម្លាយក្នុងចំណោមទ័ពមេគ្រប់ទាំងប្រាំមួយ លុះឃើញថាកម្លាំងខ្លួននឹងទប់ទល់ពុំឈ្នះ ក៏ពានបង្រុះស្ទុះចេញទៅបាន ហើយវិលចូលទៅដល់កំពែង។ ឯ**តៀនស៊ី**ដែលនៅលើសើនបន្ទាយ ឃើញ

**លីប៉ោ**រត់ត្រឡប់ចូលមក ក៏បង្ខំឲ្យបក្សពួកចេញទៅអូសកន្ត្រាក់ស្ពានឆ្លងកំពែងនោះធ្លាក់អស់ មិនឲ្យ**លីប៉ោ**ស្ទុះចូលទៅបាន។ **លីប៉ោ**បរសេះរន្ធាន់ទៅទើរនឹងមាត់ទ្វារ ក៏ស្រែកឆោឡោឲ្យទាហានខាងក្នុងលើកស្ពានទទួល។ **តៀនស៊ី**ឆ្លើយពីក្នុងកំពែងមកវិញថា យើងចូលទៅខាង**ចូឆ្វ**ហើយ អ្នកកុំចូលមកស្រុកយើងមិនបានទេ។ **លីប៉ោ**បានឮច្បាស់ខឹងណាស់ ស្រែកជេរ**តៀនស៊ី**ជាពាក្យអាស្រូវភាសផ្សេងៗ ហើយបរសេះនាំទាហានស្ទុះកាត់ត្រឡប់ទៅស្រុកតាន់លីវ។ **តាន់កុង**ឃើញដូច្នោះ ក៏នាំគ្រប់គ្រួ**លីប៉ោ**រត់តាមទៅ។

**ចូឆ្វ**ក៏លើកកងទ័ពចូលទៅក្នុងស្រុកប៉ាក់អៀងបាន ហើយឲ្យហៅខ្លួន**តៀនស៊ី**មកនិយាយថា ដែល**តៀនស៊ី**បានសំបុត្រទៅបញ្ឆោតយើងឲ្យលើកទ័ពមកចាញ់ប្រៀប**លីប៉ោ**ពីជាន់មុននោះមានទោសជាទំហំធំណាស់ គ្រានេះ**តៀនស៊ី**បានធ្វើសេចក្ដីគាប់លុបទោសចាស់ ឲ្យមនុស្សអូសកន្ត្រាក់ស្ពានមិនឲ្យ**លីប៉ោ**ឆ្លងទៅបាននេះជាគុណនាំឲ្យរលុបទោសអស់ហើយ។

**ឡៅហ្ស**និយាយនឹង**ចូឆ្វ**ថា ដែល**លីប៉ោ**រត់ទៅគ្រានេះ បើលោកនឹងឲ្យលះចោលយូរ ឃើញថា នឹងមានកម្លាំងគិតការឡើងវិញបាន ឧបមាដូចយកខ្លាទៅលែងក្នុងព្រៃ យូរទៅនឹងចាប់យកមកវិញដោយលំបាក។ **ចូឆ្វ**ស្ដាប់ឃើញត្រូវ ទើបចាត់ឲ្យ**ឡៅហ្ស**ជាមេរក្សាទាហាននៅការពារស្រុកប៉ាក់អៀង។ ខ្លួន**ចូឆ្វ**ឯងប្រមូលសេនាទាហានតូចធំភ្ជុំចាកកងទ័ពលើកតាម**លីប៉ោ**ទៅស្រុកតាន់លីវ។

ឯ**តៀវលៀវ, ចុងប៉ា, ហោសេង, កោស៊ុន** ដែលជាសេនា**លីប៉ោ**ភ្ជុំនាំទាហានទៅរកស្បៀងអាហារនោះមិនបានដឹងថា **លីប៉ោ**បែកទ័ពរត់ត្រឡប់ទៅស្រុកតាន់លីវ

សោះ ក៏នាំគ្នាវាតត្បាតវាយប្លន់ឆក់ដណ្ដើមទ្រព្យរបស់បណ្ដាអ្នកស្រុកក្នុងស្រុកប៉ាក់អៀងជាចលាចល រាស្ត្រមានសេចក្ដីទុក្ខទល់ក្ដៅក្រហាយណាស់។

កាល**លីប៉ោ**រត់ពី**ចូឆ្វ**ទៅដល់ស្រុកតាន់លីវនោះ លុះដឹងថា**ចូឆ្វ**លើកទ័ពមកតាម ក៏មិនបានចេញតតាំង សំងំនៅក្នុងកំពែងស្រុក គ្រាន់តែប្រឹក្សានឹង**តៀវម៉ៅ**ជាចៅហ្វាយស្រុក ហើយឲ្យទាហានឡើងយាមល្បាតលើសើនបន្ទាយរាយប្រយ័ត្នការជុំវិញ។ ឯ**ចូឆ្វ**នោះមិញ ប្រើសេនាទាហានឲ្យលើកចូលទៅបោះទ័ពទល់នឹងជើងកំពែងចំនួនដប់ថ្ងៃ មិនឃើញ**លីប៉ោ**ចេញមកសោះ។ ទ័ព**ចូឆ្វ**នោះ ក៏ដាច់ស្បៀងអាហារ ទទួលទេសកាលស្រូវភាជន៍សាលីទៀបនឹងទុំ **ចូឆ្វ**ក៏ប្រមូលផ្ដុំកងទ័ពលើកត្រឡប់ទៅវិញ នៅចម្ងាយពីស្រុកនោះប្រហែលពីររយសិន (៨ គ.ម) ឲ្យទាហានកាន់កណ្ដៀវចុះច្រូតស្រូវភោជន៍សាលីរបស់អ្នកស្រុកពេញស្រែនីមួយៗ ហើយនាំយកមកបុកជាន់ឲ្យទាហានបរិភោគ។ ខណៈនោះ មានមនុស្សទៅប្រាប់**លីប៉ោ**ថាទាហាន**ចូឆ្វ**ដាច់ស្បៀងអាហារ ថយទ័ពត្រឡប់ទៅច្រូតស្រូវ។ **លីប៉ោ**ក៏នាំទាហានទៅចាប់មនុស្សច្រូតស្រូវ។ ទាហាន**ចូឆ្វ**នោះ លុះឃើញ**លីប៉ោ** នាំគ្នារត់ចូលបន្ទាយ ។ **លីប៉ោ**បរសេះស្ទុះដេញតាមទៅដល់ទល់នឹងបន្ទាយ**ចូឆ្វ** ឃើញខាងឆ្វេងផ្លូវមានព្រៃធំ ក៏គិតបារម្ភក្រែងចូឆ្វបង្កប់ទាហាននៅទីនោះ **លីប៉ោ**ក៏ត្រឡប់សេះនាំទាហានចូលក្នុងកំពែងវិញ។

**ចូឆ្វ**ដឹងដូច្នោះ ក៏ប្រឹក្សានឹងសេនាទាហានថា ដែល**លីប៉ោ**ចេញមកដេញមនុស្សច្រូតស្រូវ ហើយវិលត្រឡប់ទៅជាការប្រញាប់នោះ ប្រហែលគិតក្រែងថាយើងបង្កប់ទាហានទុកក្នុងព្រៃ ឥឡូវនេះយើងឲ្យយកទង់ជ័យទៅដោតរាយក្នុងព្រៃឲ្យច្រើន ឲ្យទាហាននៅក្នុងបន្ទាយតែហាសិបនាក់ យើងនិងទាហានទាំងអស់គ្នាទៅ

បង្កប់ក្នុងអូរក្រោយបន្ទាយវិញ បើ**លីប៉ោ**មកឃើញគង់នឹងយកភ្លើងអុជព្រៃឆេះអស់ ហើយចូលហួសទៅក្បែរបន្ទាយឃើញទាហានទាំងឡាយនៅស្ដើង ក៏នឹងលើកចូលទៅវាយយកបន្ទាយនោះ យើងត្រូវឲ្យទាហានវាយគងឃ្មោះនិងស្គរ ជាសញ្ញាឲ្យឮខ្ទរខ្ទារឡើង ហើយសឹមលើកទាហានដែលបង្កប់ពីក្រោយចេញព័ទ្ធបណ្ដោយមក ឃើញថានឹងចាប់**លីប៉ោ**បានដោយងាយ។ ទាហានក្នុងកងទ័ពស្ដាប់ឃើញត្រូវ លុះពេលយប់ជ្រៅ **ចូឆូ**ក៏ប្រើឲ្យទៅធ្វើតាមដែលគិតទុកនោះគ្រប់ប្រការ។

លុះពេលព្រឹកភ្លឺស្រាង **លីប៉ោ**ប្រឹក្សានឹង**តាន់កុង**ថា ពីម្សិលមិញយើងបានទៅដេញចាប់ទាហាន**ចូឆូ**ដែលលួចច្រូតស្រូវ យើងដឹងថា**ចូឆូ**បង្កប់ទាហាននៅក្នុងព្រៃជាច្រើនជាត្រឡប់មកវិញ ថ្ងៃនេះយើងនឹងលើកទាហានទាំងអស់ទៅដុតព្រៃ ដែលបង្កប់ទាហាននោះឲ្យឆេះអស់ ហើយសឹមលើកទ័ពទៅខ្ទប់វាយយកបន្ទាយ**ចូឆូ**ឲ្យបាន។ **តាន់កុង**ឃាត់ថា **ចូឆូ**នោះមានគំនិតគិតក្នុងកលសង្គ្រាមច្រើនណាស់ ដែលលោកនឹងលើកទ័ពចេញទៅច្បាំង ត្រូវតែរវាំងមើលកលការឲ្យស្រួលបួលសិន។ **លីប៉ោ**មិនព្រមស្ដាប់ពាក្យ**តាន់កុង** ឲ្យ**តាន់កុង**នៅរក្សាស្រុកជាមួយនឹង**តៀវម៉ៅ**។ ខ្លួន**លីប៉ោ**ឯងលើកទាហានចេញទៅពីស្រុកដល់ទៅព្រៃខាងឆ្វេងផ្លូវ ឃើញទង់ជ័យដោតនៅជាច្រើនក៏គិតថា “ប្រហែល**ចូឆូ**ឲ្យទាហាននៅក្នុងព្រៃនោះ” ហើយក៏លើកទ័ពវាយខ្ទប់ជុំវិញពីក្រៅ ហើយឲ្យយកភ្លើងដុតព្រៃនោះឆេះឡើងទាំងបួនទិស មិនឃើញមានមនុស្សម្នាក់សោះ ក្រឡេកមើលទៅក្នុងបន្ទាយស្ងាត់ជ្រងំ ខំលើកទាហានចូលទៅ ស្រាប់តែឮសំឡេងឃ្មោះគងទូងភេរី **លីប៉ោ**តក់ស្លុតឈប់ស្ដាប់នៅទីនោះ ស្រាប់តែឮសន្ធឹកកងទ័ពស្រែកហ៊ោក្រោយបន្ទាយ ហើយវាយទាហានព័ទ្ធមក **លីប៉ោ**គ្រវីទួនបរសេះចូលទៅតយុទ្ធ ស្រាប់តែឮផាវអុជឡើងជុំវិញខ្លួន។ **ហៃហួទុន**,

**ហៃហួអៀន, ខៅធូ, តៀនអ៊ុយ, លីតៀន** និង**ង៉ាក់ជិន** ទាំងប្រាំមួយនាក់នេះក៏លើកទាហានឡើងពីក្នុងអូរឈូឆរ ចេញមកព័ទ្ធជុំវិញ**លីប៉ោ** ៗក៏វាប្រកាប់ជាប់ដៃទាំងសងខាង ឃើញកម្លាំងនឹងតតាំងពុំបាន ក៏បង្រុះចោលទាហានរត់ចេញទៅជាមួយនឹង**សេងគៀម**។ **ង៉ាក់ជិន**ឃើញដូច្នោះ ក៏បរសេះដេញតាមពីក្រោយ ហើយ**យឺត**ធ្នូបាញ់ត្រូវ**សេងគៀម** ធ្លាក់ពីលើសេះស្លាប់។ ឯទាហាន**លីប៉ោ**ក៏របួសពិការស្លាប់ជាច្រើន ដែលសល់នៅប៉ុន្មាន ក៏បំពានរត់យកតែខ្លួនទៅចូលក្នុងកំពែងស្រុកវិញ ហើយយកសេចក្តីនោះប្រាប់**តាន់កុង** គ្រប់ប្រការ។ ឯ**តាន់កុង**ក៏ស្តុតរន្ធត់ចិត្តគិតថា "ទាហានក្នុងស្រុកតាន់លីវនេះនៅតិចណាស់ ឃើញថាតទល់នឹង**ចូឆូ**មិនបាន" ហើយក៏នាំគ្រប់គ្រួ**លីប៉ោ**រត់ដោះខ្លួនចេញពីស្រុកនោះទៅ។

ចំណែក**ចូឆូ** លើកកងទ័ពមកខ្ទប់វាយយកស្រុកតាន់លីវនោះបាន ហើយឲ្យទាហានយកភ្លើងដុតបំផ្លាញផ្ទះសម្បែងអ្នកស្រុកឆេះអស់។ **តៀវចៀវ**នោះស្ទុះរត់ទៅមិនទាន់ក៏ស្លាប់ក្នុងភ្លើង។ ឯ**តៀវម៉ៅ**ចៅហ្វាយស្រុកនោះ ក៏រត់ទៅនៅនឹង**អួនសុត**ចៅហ្វាយស្រុកឡាំយ៉ុង។ អស់បណ្តារាស្ត្រដែលនៅក្នុងស្រុកតាន់លីវទាំងប៉ុន្មាន បាននាំគ្នាចុះចូលទៅនៅជាពួកម៉ាករបស់**ចូឆូ**ទាំងអស់។ ឯ**ចូឆូ**នោះក៏ត្រឡប់បានជាធំក្នុងអាណាខេត្តទិសបូព៌ាជាច្រើនតំបន់ ហើយឲ្យតែងតាំងធ្វើជាបន្ទាយវាយតកំពែងជីកគូអូរស្នាមភ្លោះ ទុកគ្រប់ចន្លោះខេត្តនីមួយៗ ហើយឲហ្វឹកហាត់សេនាទាហានបានជាច្រើន។

ឯ**លីប៉ោ**រត់ទៅដល់កណ្តាលផ្លូវ ទទួលជួបប្រទះនឹង**តៀវលៀវ, ចុងប៉ា, ហោសេង, និងកោស៊ុន** ដែលលើកទៅរកស្បៀងអាហារតាំងពីគ្រាដែលនៅក្នុងស្រុកប៉ាក់អៀងនោះ **លីប៉ោ**ពណ៌នារាយរឿងប្រាប់មិនទាន់ចប់ពាក្យ ងាកទៅឃើញ

**តាន់កុង**នាំគ្រប់គ្រួតាមទៅទាន់ **លីប៉ោ**ក៏បានអន់ស្រាកកំហឹងទុក្ខព្រួយ ហើយនាំគ្រប់គ្រួ និងសេនាទាហានទៅតាំងបន្ទាយនៅក្បែរមាត់ទន្លេដែនស្រុកតាន់លីវ ហើយប្រឹក្សានឹង**តាន់កុង** និងសេនាទាហានទាំងប្អូននាយថា យើងបែកទ័ពនឹង**ចូឆ្វូ**រត់មកគ្រានេះ មិនត្រូវគិតកោតញញើតវាទៅទៀតទេ ត្រូវគិតឆ្លៀតរកឧបាយនឹងលើកទ័ពត្រឡប់ទៅច្បាំងនឹង**ចូឆ្វូ**យកស្រុកយើងវិញឲ្យបាន។

**តាន់កុង**ឃាត់ថា ឥឡូវនេះ**ចូឆ្វូ**មានទាហានរេហ៍ពលជាច្រើនណាស់ ខាងអាណាខេត្តបូព៌ាទិសនៅក្នុងអំណាចត្រួតត្រារាជការរបស់**ចូឆ្វូ**ទាំងអស់ ទាហានរបស់យើងក៏មានតិចណាស់ មិនធ្លូនការ ហើយកំពុងនឿយហត់ ដែលលោកនឹងបង្ខំលើកទៅតតាំងច្បាំងកាច់យកដោយរហ័ស មិនមែនបានដោយងាយទេ ត្រូវតែនាំគ្រប់គ្រួទៅរកទីសំណាក់អាស្រ័យឲ្យមាំមួនសិន រួចសឹមគិតការតទៅ។ **លីប៉ោ**ស្ដាប់ហើយឃើញត្រូវ ក៏សួរ**តាន់កុង**ថា បើយើងនឹងនាំគ្រប់គ្រួទៅពឹងពាក់សំណាក់នឹង**អ៊្លួនសៀវ**ចៅហ្វាយស្រុកគីជីវ អ្នកនឹងឃើញយ៉ាងដូចម្ដេច? **តាន់កុង**ឆ្លើយថា ដែលលោកគិតនោះគួរហើយ តែសុំឲ្យចាត់បម្រើទៅស៊ើបស្ដាប់កិត្តិស័ព្ទអ្នកស្រុកគីជីវឲ្យដឹងសិន ជា**អ៊្លួនសៀវ**នឹងព្រមឲ្យយើងនៅដែរឬទេ? **លីប៉ោ**ក៏យល់ព្រម ទើបចាត់បម្រើឲ្យចេញទៅស្រុកគីជីវ។

ឯ**អ៊្លួនសៀវ**ចៅហ្វាយស្រុកគីជីវតាំងពីកិត្តិស័ព្ទថា **ចូឆ្វូ**និង**លីប៉ោ**ច្បាំងគ្នានៅស្រុកប៉ាក់អៀង ទើបប្រឹក្សានឹង**ស៊ឹមផោយ**ថា **លីប៉ោ** និង**ចូឆ្វូ**ច្បាំងគ្នាគ្រានេះ បើខាង**លីប៉ោ**ឈ្នះ**ចូឆ្វូ** តើអ្នកនឹងយល់ឃើញយ៉ាងដូចម្ដេច? **ស៊ឹមផោយ**ឆ្លើយថា ឯសន្ដានចិត្ត**លីប៉ោ**នោះជាមនុស្សកាចសាហាវដូចខ្លា បើបានស្រុកប៉ាក់អៀងហើយ គង់នឹងកំរើបចិត្តគិតកន្លងមកវាយយកស្រុកយើងទៀតមិនខាន សូមឲ្យលោកកេណ្ឌ

ទាហានប្រាំម៉ឺន លើកទៅជួយ**ចូវឆ្វ**ច្បាំងសម្លាប់**លីប៉ោ**ចេញឲ្យបាន ទើបស្រុកយើងនឹងបានសេចក្ដីសុខ។ **អ៊ួនសៀវ**យល់ត្រូវ ក៏ឲ្យ**ង៉ាន់លៀង**លើកទាហានប្រាំម៉ឺនទៅជួយ**ចូវឆ្វ**។

ខណៈនោះបម្រើ**លីប៉ោ** ដែលទៅស៊ើបស័ព្ទស្ដាប់ដំណឹងឯស្រុកគីជីវនោះ ទើបនឹងទៅដល់ពាក់កណ្ដាលផ្លូវបានដឹងឮដូច្នោះ ក៏នាំសេចក្ដីនោះវិលមកប្រាប់**លីប៉ោ**វិញថា ឥឡូវនេះ **អ៊ួនសៀវ**ឲ្យ**ង៉ាក់លៀង**នាំទាហានទៅជួយ**ចូវឆ្វ**ច្បាំងតនឹងលោកហើយ ។ **លីប៉ោ**ឮដូច្នោះក៏ភ័យណាស់ សួរ**តាន់កុង**ថា បើ**អ៊ួនសៀវ**ជាចិត្តមួយនឹង**ចូវឆ្វ**ហើយ តើយើងនឹងគិតយ៉ាងម្ដេច? **តាន់កុង**ថា ខ្ញុំបានឮដំណឹងច្បាស់ថា**តូកៀម**លើកស្រុកឈីជីវឲ្យ**ឡៅពី**ធ្វើជាចៅហ្វាយស្រុកហើយ **ឡៅពី**នោះជាមនុស្សចិត្តល្អធូរទូលាយរួសរាយរាប់អានអ្នកផងទាំងពួងណាស់ សូមលោកនាំគ្រប់គ្រួទៅអាស្រ័យនៅនឹង**ឡៅពី**ក្នុងស្រុកឈីជីវចុះ មុខជា**ឡៅពី**មិនសូន្យផ្លូវមេត្រីនឹងលោកទេ។ **លីប៉ោ**យល់ត្រូវក៏នាំគ្រប់គ្រួទៅរក**ឡៅពី** លុះចូលទៅដល់ស្រុកឈីជីវហើយ ក៏ឲ្យបម្រើចូលទៅជម្រាប**ឡៅពី**ថា **លីប៉ោ**នឹងសូមមកសំណាក់ពឹងពាក់នៅនឹងលោកតទៅ។

**ឡៅពី**ប្រឹក្សានឹង**ប៊ីតុក**ថា **លីប៉ោ**បរាជ័យនឹងដៃ**ចូវឆ្វ** ឥឡូវនេះរត់មកទីពឹងនៅនឹងយើងៗត្រូវតែចេញទៅទទួលឲ្យចូលមកក្នុងស្រុក។ **ប៊ីតុក**ឆ្លើយថា សន្ដានចិត្ត**លីប៉ោ**នោះទុរយសកំណាចកាចសាហាវដូចខ្លា ឥឡូវនេះខ្លួនវាដូចខ្លាធ្លាក់អណ្ដូង បើលោកនឹងយោងលើកយកមកឲ្យចំណីផ្សាំង លុះវាមានកម្លាំងកាលណានឹងទំពារក្បាលយើងវិញ។ **ឡៅពី**តបថា **ចូវឆ្វ**នោះក៏ជាមនុស្សកាចចិត្តអាក្រក់ ឥឡូវនេះបានជាធំត្រួតលើអាណាខេត្តខាងបូព៌ាទាំងអស់ បើ**លីប៉ោ**វាយយកស្រុកគុនជីវវិញ

ស្រុកយើងក៏គង់នឹងបានសេចក្ដីសុខផង **ចូឆ្វ**ក៏មិនអាចនឹងរំលងមកវាយស្រុកយើងទេ ឥឡូវនេះ**លីប៉ោ**បានជាបែរមុខមករកយើងហើយ បើយើងព្រងើយកណ្ដើយក៏ដូចជាគ្មានមេត្តាសោះ។ **តៀវហ៊ុយ**ឆ្លើយថា ចិត្តរបស់លោករមែងធូទូលាយរួសរាយរាប់អានមនុស្សទាំងវៀចទាំងត្រង់ បើលោកនឹងចង់ទទួលយក**លីប៉ោ**មកទុក ក៏តាមអធ្យាស្រ័យលោកចុះ តែឲ្យគិតរវាំងហេតុផលឲ្យល្អ។

**ឡៅពី**ក៏នាំ**គួនអ៊ូ, តៀវហ៊ុយ** និងទាហានទាំងពួងចេញមកទទួល**លីប៉ោ**ចម្ងាយផ្លូវប្រហែលបីរយសិន (១២ គ.ម) ហើយនាំត្រឡប់ចូលមកក្នុងស្រុក រួចអញ្ជើញ**លីប៉ោ**ឲ្យអង្គុយក្នុងទីសមគួរ។ **លីប៉ោ**ក៏ពណ៌នាប្រាប់រឿងឲ្យ**ឡៅពី**ស្ដាប់គ្រប់ប្រការថា ពីដើម**អងអ៊ុន**និងខ្លួនខ្ញុំគិតគ្នាប្រាថ្នានឹងសម្លាប់**តាំងតុះ** ដែលជាសត្រូវរាជសម្បត្តិ ក៏បានដូចចិត្ត លុះ**លីឈុយ, គុយគី**បានជាធំឡើង ក៏ឲ្យរកឧបាយនឹងសម្លាប់ខ្ញុំវិញ ខ្ញុំបាទដឹងការណ៍ទាន់ក៏រត់ចេញពីទីក្រុងមក បានទៅរកទីពឹងនៅជាច្រើនតំបន់ក៏មិនសម្រេចតាមប្រាថ្នា លុះខ្ញុំបាទទៅនៅនឹង**តៀវម៉ៅ**ចៅហ្វាយស្រុកតាន់លីវវេលាណា **ចូឆ្វ**ក៏លើកទ័ពមកព្យាបាទទៅវាយយកស្រុកនោះបាន ខ្ញុំបាទស៊ើបដឹងថា លោកលើកទ័ពមកជួយ**តូកៀម** ខ្ញុំក៏មានសេចក្ដីត្រេកអរ បានជាលើកទ័ពទៅវាយស្រុកគុនជីវឲ្យជាកង្វល់ ដើម្បីនឹងជួយផ្ដល់កុំឲ្យមានរវល់ដល់ស្រុកបានឡើយ គ្រានោះខ្ញុំក៏បានបែកទ័ពបរាជ័យនឹង**ចូឆ្វ**ម្ដងទៀត ខូចខាតទាហានក៏ច្រើន បានជាចូលមកទីពឹងអាស្រ័យនឹងលោក ដើម្បីនឹងឈប់សំណាក់ កាលណាស្បើយធូរក៏នឹងគិតការធំតទៅទៀត តែថាឥឡូវនេះខ្ញុំមិនទាន់បានដឹងច្បាស់ជាចិត្តលោកព្រមរួមគំនិតមួយនឹងខ្ញុំដែរឬទេ?

**ឡៅពី**តបថា “**តូកៀម**អនិច្ចកម្មទៅ ស្រុកឈីជីវក៏នៅលើដៃខ្ញុំកាន់កាប់រក្សាបណ្ដោះអាសន្ន ព្រោះនឹងរកអ្នកឯណាចេះដឹងគ្រាន់ឲ្យធ្វើធំមិនបាន ឥឡូវនេះអ្នកមកដល់ទីឋាននេះ ក៏សមគួរនឹងធ្វើការរាជការបាន ខ្ញុំក៏មានសេចក្ដីត្រេកអរនឹងលើកស្រុកឈីជីវនេះឲ្យអ្នកធ្វើជាចៅហ្វាយស្រុកចុះ” ថាហើយក៏លើកត្រាសម្រាប់ងារនោះឲ្យ**លីប៉ោ** ៗកម្រើកដៃនឹងទទួលយកត្រា តែចោលភ្នែកទៅឃើញ**គួនអ៊ូ, តៀវហ៊ុយ** ដែលឈរក្រោយ**ឡៅពី**បែបខឹងសម្បារ **លីប៉ោ**ធ្វើជាសើចហើយឆ្លើយថា ខ្លួនខ្ញុំត្រឹមតែទីទាហាន នឹងទទួលនិយាយការខេត្តខណ្ឌតែម្ដង ឃើញលើសសតិបញ្ញាណាស់។

**តាន់កុង**ឮដូច្នោះក៏និយាយថា ធម្មតាជាភ្ញៀវមករកលោកជាម្ចាស់ផ្ទះណាឡើងនឹងបានរូតរះរើសយករបស់ទ្រព្យទៅជាមួយផងនោះ ជាសេចក្ដីមិនគួរទេ ឯខ្លួន**លីប៉ោ**ដែលមកសុំសំណាក់នឹងលោកនេះ នឹងបានតាំងចិត្តគិតដណ្ដើមយកស្រុកក៏ទេ លោកមិនត្រូវសង្ស័យអ្វីឡើយ។ **ឡៅពី**ស្ដាប់ហើយក៏រៀបលៀងអាហារអញ្ជើញ**លីប៉ោ**និងសេនាបរិភោគ ហើយចាត់ចែងលំនៅឲ្យ**លីប៉ោ**សំណាក់។ លុះព្រឹកឡើង**លីប៉ោ**រៀបលៀងអាហារ អញ្ជើញ**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ**ទៅបរិភោគវិញ លុះបរិភោគរួចក៏អញ្ជើញ**ឡៅពី**ទៅខាងក្នុង។ **គួនអ៊ូ, តៀវហ៊ុយ**តាមទៅជាមួយ។ ពេលនោះ**លីប៉ោ**ឲ្យបុត្រភរិយាចេញមកគំនាប់**ឡៅពី** ៗរីងខ្លួនក៏ហាមឃាត់ថា កុំឲ្យគំនាប់ឡើយ។ **លីប៉ោ**និយាយថា លោកប្អូនកុំព្រួយនឹងយើងដែលឲ្យភរិយាបុត្រគំនាប់នេះ។

**តៀវហ៊ុយ**បានឮដូច្នោះក៏ខឹងញ័រ ស្រែកកម្ទរថា ខ្លួនឯងហេតុម្ដេចបានជាហៅបងអញថាប្អូន បងអញពេញជាពូជព្រះរាជវង្ស ឧបមាដូចដើមឈើស្លាកមាស

ដែលខ្លួនអ្នកអាងថាខ្លាំងពូកែនោះ ចូររៀបខ្លួនចេញទៅល្បងថ្វីដៃមើលបានពីរបីរយភ្លេងចុះ។

**ឡៅពី**បែរទៅនិយាយឃាត់**តៀវហ៊ុយ**ជាប្រញាប់ **គួនអ៊ូ**ក៏ចាប់ដឹកដៃ**តៀវហ៊ុយ**ចេញមកក្រៅ។ **ឡៅពី**និយាយនឹង**លីប៉ោ**ថា ដែល**តៀវហ៊ុយ**និយាយទ្រគោះឲ្យអ្នកអម្បាញ់មិញនេះ ព្រោះសេពសុរាស្រវឹងខ្លាំងណាស់ យើងសុំសំពះកុំឲ្យយកទោសឡើយ។ **លីប៉ោ**គ្រវីក្បាលហើយមិនឆ្លើយសោះ។ **ឡៅពី**ក៏លា**លីប៉ោ**ទៅវិញ លុះទៅដល់កណ្ដាលផ្លូវ **តៀវហ៊ុយ**ក៏បរសេះវេះត្រឡប់ទៅដល់មុខផ្ទះ**លីប៉ោ**ហើយស្រែកថា អម្បាញ់មិញអញខ្លាចបងអញទេ ឥឡូវនេះបងអញទៅហើយ ឲ្យ**លីប៉ោ**ចេញមកឆាប់នឹងល្បងថ្វីដៃគ្នាមើលបានពីរបីភ្លេង។ **ឡៅពី**ក្រឡេកមកក្រោយមិនឃើញ**តៀវហ៊ុយ**ក៏ឲ្យ**គួនអ៊ូ**តាមទៅហៅយកខ្លួន**តៀវហ៊ុយ**មកវិញ។

លុះវេលាព្រឹកឡើង **លីប៉ោ**ទៅនិយាយនឹង**ឡៅពី**ថា ពីដើមខ្ញុំមកសុំអាស្រ័យនៅនឹងលោក ៗក៏ព្រមឲ្យនៅហើយ តែឥឡូវនេះ**តៀវហ៊ុយ**ប្អូនលោកនោះទៅនិយាយពាក្យអាក្រក់មើលងាយខ្ញុំខ្លាំងណាស់ ខ្ញុំនឹងនៅតទៅក៏គង់នឹងមានទាស់ចិត្តលោក បើដូច្នោះខ្ញុំនឹងលាលោកទៅរកទីដទៃនៅវិញចុះ។

**ឡៅពី**តបថា អ្នកនឹងទៅនៅទីដទៃនោះ សេចក្ដីគរហានិន្ទានឹងមានដល់យើងដែល**តៀវហ៊ុយ**នៅចិត្តពាលស្រាលសេចក្ដី បានស្ដីទ្រគោះបោះបោកឲ្យអ្នកនោះ ថ្ងៃក្រោយខ្ញុំនឹងនាំខ្លួនទៅសុំខមាលទោសនឹងអ្នក បើអ្នកមិនចូលចិត្តនៅក្នុងទីនេះ ក៏ចូលទៅនៅឯស្រុកសៀវផាយចុះ ព្រោះស្រុកនោះក៏ជាទីស្រុកតូចឡើងដល់ស្រុកនេះ បើខ្វះខាតស្បៀងអាហារវេលាណា សឹមយើងផ្ញើបញ្ជូនទៅឲ្យ។

**លីប៉ោ**បានស្តាប់ក៏មានអំណរសាទរគំនាប់**ឡៀពី** ហើយក៏នាំគ្រប់គ្រួនិងសេនាទាហានទៅនៅស្រុកសៀវផាយ ។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

### កណ្ឌទី ១១

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(ចាប់តាំងពី**ចូឆ្វ**ផ្ញើសំបុត្រទៅក្រាបទូលព្រះចៅ**ហៀនតេ**ថា ខ្លួនបានបង្ក្រាបសឹកសត្រូវនៅអាណាខេត្តទិសបូព៌ាជ្រះស្រឡះហើយ រឿងរហូតដល់ព្រះចៅ**ហៀនតេ** ស្ដេចយាងចូលទៅក្នុងក្រុងឡុកអៀង ហើយទតឃើញព្រះរាជតំណាក់ក្នុងព្រះរាជវាំងត្រូវភ្លើងឆេះអស់ ទើបទ្រង់សោកស្ដាយ)។*

**ឯចូឆ្វ** កាលច្បាំងបានអាណាខេត្តប៉ែកខាងបូព៌ាទិសមកជាចំណុះខ្លួនវិញហើយ ក៏បកសំបុត្រចូលទៅក្រាបទូលព្រះចៅ**ហៀនតេ**ជាសេចក្ដីថា “ទូលព្រះបង្គំជាខ្ញុំ**ចូឆ្វ**បានប្រាបប្រាមសឹកសត្រូវនឹងពួកអាចោរកំណាច ក្នុងអាណាខេត្តបូព៌ាទិសរាបទាបអស់ហើយ”។ សំបុត្របកនោះ **លីឈុយ, គុយគី**ទទួលហើយ ក៏ព្រងើយកន្តើយមិនបានយកទៅថ្វាយសោះ គិតតែអបអែបព្រះតម្រាស់បញ្ជូនទៅឲ្យ**ចូឆ្វ**វិញថា **ចូឆ្វ**មានសេចក្ដីគាប់ប្រសើរ ធ្វើរាជការចម្រើនប្រយោជន៍ សូមទ្រង់ឲ្យឡើងទីជា “**គៀនតិកចុងកុះ**” ប្រែថា “ឧកញ៉ាចម្រើនអាយុ”។ ខណៈនោះ **លីឈុយ**នៅក្នុងស្រុកក្រុងក៏តាំងខ្លួនជាធំ សម្រេចអាណាចក្រខាងទាហាន **គុយគី**ជាធំសម្រេចរាជការខាងភ្នាក់ងាររដ្ឋបាល។ អ្នកទាំងពីរនេះបណ្ដាលឲ្យកំរើបចិត្តប្រព្រឹត្តចាត់ចែងការរាជការជាកម្មសិទ្ធិលើខ្លួនទាំងអស់ មិនមានកោតខ្លាចព្រះចៅ**ហៀនតេ**និងបណ្ដានាហ្មឺនទាំងពួងសោះ រាជការផែនដីក៏វិប្បរិតប្រែប្រួលដូចកាលគ្រា**តាំងតុះ**។

ខណៈនោះ **អៀវពីវ** និង**ជូហ៊ី**ជានាហ្មឺនធំក្នុងស្រុកក្រុង ឃើញ**លីឈុយ**, **គុយគី**តាំងខ្លួនជាធំ ហើយចាត់ចែងការរាជការទុច្ចរិតប្រព្រឹត្តអាក្រក់ ក៏យកសេចក្ដីនេះលបក្រាបទូលព្រះចៅ**ហៀនតេ** ហើយថា ទូលព្រះបង្គំជាខ្ញុំយល់ឃើញ**ចូឆូ**ជាមន្ត្រីមានសតិបញ្ញាក្លាហាន មានសេនាទាហានប្រហែលសាមសិបម៉ឺន ពួកសេនាខ្លាំងពូកែជាច្រើន ឥឡូវនេះបានជាធំខាងអាណាខេត្តបូព៌ាទិសទាំងអស់ បើបាន**ចូឆូ**នោះមកធ្វើរាជការផ្ទាល់ព្រះអង្គក្នុងស្រុកក្រុង នឹងបានបង្ក្រាបពួកសត្រូវរាជសម្បត្តិចេញបាន ទីព្រះរាជឋាន និងអាណាខេត្តក្រុងក្រៅ ក៏នឹងបានជាសុខក្សេមក្សាន្តតទៅ។ ព្រះចៅ**ហៀនតេ**ទ្រង់ព្រះសណ្ដាប់ដូច្នោះ ក៏ទោមនស្សក្នុងព្រះទ័យ ទ្រង់ព្រះកន្សែងសោកាអាណិតព្រះអង្គ ទើបទ្រង់ត្រាស់តបថា សព្វថ្ងៃនេះយើងមានតែសេចក្ដីរុំរ៉ៃក្នុងចិត្តទុក្ខជានិច្ចកាល នឹងបណ្ដាលហាមាត់និយាយមិនបាន បើអ្នកឯណាមានតម្រិះប្រាជ្ញា ចេះគិតរលំាងបច្ចាមិត្តរាជសត្រូវនេះបាន ទើបយើងនឹងមានសេចក្ដីសប្បាយ។

**អៀវពីវ**ទូលថា ទូលព្រះបង្គំជាខ្ញុំនឹងគិតកលឧបាយឲ្យ**លីឈុយ**, **គុយគី**កើតទាស់ទែង ធ្វើចម្បាំងកាប់សម្លាប់គ្នាឲ្យបាន រួចសុំឲ្យមានព្រះតម្រាស់ទៅហៅ**ចូឆូ**ឲ្យលើករេហ៍ពលចូលមក ទើបនឹងបានរំលាងបក្សពួកអាកំណាចឲ្យអស់ចេញ ព្រះអង្គក៏នឹងបានសេចក្ដីសុខវិញពុំខាន។

ព្រះចៅ**ហៀនតេ**ទ្រង់ត្រាស់សួរ**អៀវពីវ**ថា កលឧបាយដែលគិតនោះតើប្រការម្ដេច? **អៀវពីវ**ក្រាបទូលថា ភរិយា**គុយគី**នោះជាស្រីប្រច័ណ្ឌប្ដីណាស់ ទូលព្រះបង្គំជាខ្ញុំនឹងប្រើស្រីម្នាក់ឲ្យទៅញុះញង់ភរិយា**គុយគី** ឲ្យកើតសន្ទិះសង្ស័យនឹងគ្នាឡើង។ ព្រះចៅ**ហៀនតេ**ទ្រង់ព្រះសណ្ដាប់ ក៏ធូរស្រាលក្នុងព្រះទ័យមានសេចក្ដីត្រេក

អរ ទើបទ្រង់ព្រះសុភអក្សរដែលនឹងហៅ**ចូឆ្វ**នោះ ប្រគល់ទៅឲ្យ**អៀវពីវ**រក្សាទុក ហើយត្រាស់ផ្តាំថា បើកើតហេតុឡើងកាលណា អ្នកត្រូវចាត់បម្រើឲ្យនាំសំបុត្រនេះទៅឲ្យ**ចូឆ្វ**វេលានោះ។

**អៀវពីវ**ទទួលសុភអក្សរហើយក្រាបបង្គំលាថយទៅវិញ នាំជូហ៊ីត្រឡប់ទៅផ្ទះ ហើយនិយាយពន្យល់ភរិយារបស់ខ្លួនជាមាំមួន ហើយទើបប្រើឲ្យទៅសួរភរិយា**គុយគី**។ ភរិយា**អៀវពីវ**លុះឡើងទៅលើផ្ទះក៏គំនាប់តាមទំនៀមទម្លាប់ ហើយនិយាយថា នាងខ្ញុំឮកិត្តិស័ព្ទថា ស្វាមីរបស់អ្នកបានទៅលបស្ម័គ្រសាហាយស្មន់នឹងប្រពន្ធ**លីឈុយ** បើរឿងនេះដឹងដល់**លីឈុយ**ហើយ **លីឈុយ**គង់នឹងធ្វើអន្តរាយដល់**គុយគី**ស្វាមីអ្នកមិនខាន អ្នកត្រូវគិតអានហាមប្រាមស្វាមីកុំឲ្យទៅប្រព្រឹត្តដូច្នេះទៀត ដែលខ្ញុំអាចកាត់ចិត្តចូលមកជម្រាបដំណឹងអ្នកដូច្នេះ ព្រោះមានសេចក្តីអាណិតអ្នកណាស់។ ភរិយា**គុយគី**បានឮដូច្នោះ ក៏ភ័យលោះព្រលឹង ហើយនឹកខឹងក្នុងចិត្តខ្លាំងណាស់ឆ្លើយថា ប្តីខ្ញុំតែងទៅរក**លីឈុយ**ជាញឹកញយណាស់ ជួនកាលទៅដេកឯផ្ទះគេក៏មាន ខ្ញុំគិតថាភឿនភក្តិអ្នករាជការជាមួយគ្នា ដែលប្តីខ្ញុំទៅលបបរទារការនឹងភរិយា**លីឈុយ**នោះ ខ្ញុំឥតដឹងសោះ អ្នកមានចិត្តសប្បុរសមកប្រាប់ខ្ញុំ ៗអរគុណច្រើន អំណើះពីថ្ងៃនេះទៅខ្ញុំនឹងត្រូវហាមមិនឲ្យប្តីខ្ញុំទៅផ្ទះ**លីឈុយ**ទៀត។ ភរិយា**អៀវពីវ**ក៏លាទៅផ្ទះខ្លួន។

លុះកន្លងមកថ្ងៃមួយ **លីឈុយ**ឲ្យបម្រើទៅអញ្ជើញ**គុយគី**មកបរិភោគអាហារ។ ភរិយា**គុយគី**ដឹងក៏អង្វរឃាត់ប្តីថា ដែលអ្នកនឹងទៅសេពសុរារបស់**លីឈុយ**នោះ អ្នកនឹង**លីឈុយ**មិនមែនចំណុះគ្នា សុទ្ធតែប្រកាន់ខ្លួនជាធំរៀងខ្លួន ក្រែងអ្នកសេពសុរាស្រវឹងមិនដឹងខ្លួន ហើយ**លីឈុយ**នឹងលបដាក់ថ្នាំបំពុលឲ្យអ្នក

ផឹក អ្នកនឹងដល់សេចក្តីស្លាប់អសារឥតការ ខ្លួនខ្ញុំជាស្រីនឹងបែរមុខទៅរកអ្នកឯណាបាន? **គុយគី**បានស្តាប់ភរិយាឃាត់ ក៏មិនបានទៅ។ **លីឈុយ**អង្គុយចាំបាយទាល់តែថ្ងៃរសៀលមិនឃើញ**គុយគី**មក ទើបប្រើបម្រើឲ្យយកម្ហូបចំណីមួយតុទៅជូន**គុយគី**ដល់ផ្ទះ។ **គុយគី**នៅដេកមិនទាន់ភ្ញាក់ ភរិយាក៏ក្រោកម្នីម្នាទៅទទួលសម្រាប់នេះទុក ហើយលបយកថ្នាំបំពុលដាក់ចូលក្នុងម្ហូបនោះគ្រប់ចាន។ **គុយគី**ភ្ញាក់ឡើង មនុស្សបម្រើលើកម្ហូបនោះទៅឲ្យ**គុយគី**បរិភោគជម្រាបថា តុនេះ**លីឈុយ**ឲ្យបម្រើយកមកជូន។ ភរិយាក៏ម្នីម្នាស្ទុះទៅហាមឃាត់មិនឲ្យប្តីបរិភោគ ហើយថា “ចំណីនេះអ្នកកុំអាលពិសា ចូរពិសោធមើលសិន” ថាហើយក៏ចាក់ឲ្យសុនខស៊ី។ សុនខនោះក៏ស្លាប់មួយរំពេច **គុយគី**ឃើញដូច្នោះក៏រឹតតែសង្ស័យ។

មានកាលមួយថ្ងៃ **លីឈុយ**ចេញអំពីទីគាល់ ហើយអញ្ជើញ**គុយគី**ទៅប្រឹក្សាការរាជការឯផ្ទះ រួច**លីឈុយ**អញ្ជើញ**គុយគី**ឲ្យបរិភោគអាហារ។ **គុយគី**ភ្លេចរឿងដើម ទើបបរិភោគអាហារនោះ រួចក៏លាទៅ លុះទៅដល់ផ្ទះក៏បណ្តាលឲ្យឈឺក្នុងពោះ។ ភរិយាសួរថា អ្នកចេញទៅគាល់បានទៅឯណាខ្លះ? **គុយគី**ថា បានទៅប្រឹក្សាការរាជការនៅផ្ទះ**លីឈុយ** ហើយគេបានរៀបបាយទឹកឲ្យបរិភោគ។ ភរិយាធ្វើជាតក់ស្លុត ហើយថា “ខ្ញុំឃើញច្បាស់ម្តងហើយ ម្តេចខំទៅពិសាបាយទឹករបស់គេទៀត គេមិនដាក់ថ្នាំបំពុលទេឬ?” ថាហើយក៏យកអាចម៍មករំលាយនឹងទឹកឲ្យ**គុយគី**ផឹកចូលទៅ **គុយគី**ក៏ក្អួតចង្អោរចេញមកអស់ ពោះនោះក៏បាត់ឈឺទៅវិញ ។

**គុយគី**ក៏នឹកខឹងនឹង**លីឈុយ**ថា “យើងបង់កម្លាំងដែលបានរួមគំនិតគិតធ្វើការធំជាមួយគ្នាមកនោះសោះ ព្រោះ**លីឈុយ**នោះ មិនមែនត្រង់សុចរិត គិតប្រទូសរ៉ាយ

យើងវិញដូច្នោះ ត្រូវតែយើងគិតសម្លាប់វាចេញឲ្យបាន” គិតហើយក៏រៀបចាត់ចែងសេនាទាហាន នឹងលើកទៅព័ទ្ធចាប់**លីឈុយ**ក្នុងផ្ទះ។

ពេលនោះមានមនុស្សលបទៅប្រាប់**លីឈុយ**ថា **គុយគី**នឹងលើកទាហានមកធ្វើអន្តរាយឥឡូវហើយ។ **លីឈុយ**ភ្ញាក់ខ្លួនហើយថា “យើងមិនមានទោសអ្វីនឹង**គុយគី**សោះ ហេតុម្តេច**គុយគី**អង់អាចគិតមកប្រទូសរ៉ាយនឹងយើងដូច្នេះ រឿងនេះយើងនឹងនៅស្ងៀមក៏ពុំបាន ត្រូវលើកទាហានទៅចាប់សម្លាប់**គុយគី**ជាមុន” គិតហើយក៏ប្រមូលផ្តុំទាហានលើកទៅ ប្រទះនឹង**គុយគី**នៅក្បែរកំពែងស្រុក ក៏តាំងតយុទ្ធគ្នាទៅវិញទៅមកជាចលាចល។ ពលទាហានទាំងសងខាង ក៏ឆក់ដណ្តើមទ្រព្យរបស់អាណាប្រជានុរាស្ត្រគ្រប់ផ្ទះ។ ឯ**លីឈុយ**ក៏ប្រើ**លីសៀម**ជាក្មួយលើកទាហានទៅឡោមព័ទ្ធវាំងទុក។ **លីសៀម**ទើបប្រើ**កាសៀង**ឲ្យមានព្រះរាជរថពីរចេញមក ហើយអញ្ជើញព្រះចៅ**ហៀនតេ**ឲ្យឡើងគង់លើព្រះរាជរថមួយ ឲ្យព្រះនាង**ហូហៅ**ដែលជាព្រះអគ្គមហេសីគង់រាជរថមួយ ហើយភ្ជាប់ពីក្រោយគឺពួកព្រះស្នំ និងក្រុមខន្ទីបរចេញចាកព្រះរាជវាំង តាមទ្វារព្រះស្នំចេញទៅ។ ឯ**លីឈុយ** និង**គុយគី**ក៏តាំងតែច្បាំងគ្នាជាចលាចលរាល់ថ្ងៃ ។ កាលព្រះរាជរថបរចេញចាកព្រះរាជវាំងទៅនោះ **គុយគី**ក៏ក្រឡេកឃើញ**លីសៀម** និង**កាសៀង**លើកទាហាននាំស្តេចព្រះចៅ**ហៀនតេ** និងអគ្គមហេសីនូវស្រីស្នំចេញទៅដូច្នោះ ក៏បង្គាប់សេនាទាហានបាញ់ធ្នូរណ្តំពីក្រោយ ព្រួញរត់បណ្តោយទៅត្រូវពលទាហាន និងស្រីស្នំស្លាប់អស់ជាច្រើន។ **លីឈុយ**ដឹងដូច្នោះ ក៏លើកទាហានស្រូតទៅស្ទាក់កាប់ចាក់ទាហាន**គុយគី**ៗតទល់ពុំឈ្នះ ក៏ប្រាសទ័ពលើកត្រឡប់ក្រោយ។ **លីឈុយ**ក៏នាំព្រះចៅ**ហៀនតេ** និងព្រះមហេសីស្រីស្នំទៅតាំងជំរំនៅក្រៅក្រុងមួយអន្លើ។

ឯ**គុយគី**ក៏លើកទាហានចូលទៅក្នុងព្រះរាជវាំង រើយកទ្រព្យរបស់ក្នុងផ្ទៃព្រះឃ្លាំង ហើយចាប់ពួកព្រះស្នំដែលលាក់ខ្លួនពួនក្នុងព្រះរាជវាំងនោះមកទុក រួចយកភ្លើងដុតព្រះរាជវាំងឆេះវិនាសអស់។ លុះពេលព្រឹក**គុយគី**ដឹងថា **លីឈុយ**នាំព្រះចៅ**ហៀនតេ**ទៅតាំងជំរំនៅក្រៅទីក្រុង ក៏លើកទាហានទៅតាមប្រទះទ័ព**លីឈុយ** ហើយប្រយុទ្ធគ្នាដណ្ដើមយកព្រះចៅ**ហៀនតេ**។ **លីឈុយ**ក៏ដេញទាហានចូលប្រយុទ្ធនឹងកងទ័ព**គុយគី**ៗតទល់ពុំឈ្នះ ក៏ប្រាស់ត្រឡប់ទ័ពទៅ។

**លីឈុយ**ឃើញកងទ័ព**គុយគី**ថយទៅវិញ ក៏អញ្ជើញព្រះចៅ**ហៀនតេ**និងអគ្គមហេសី ព្រមទាំងស្រីស្នំទៅប្រថាប់គង់ឯទីក្រុងដែល**តាំងតុះ**កសាង ហើយបង្គាប់**លីសៀម**ឲ្យនៅមើលត្រួតត្រារក្សាព្រះអង្គ កុំឲ្យអ្នកឯណាយកចំណីត្រីសាច់អ្វីៗទៅឲ្យពួកខន្ទី ឬពួកស្រីស្នំបរិភោគឡើយ។ ព្រះចៅ**ហៀនតេ**ឃើញខ្ញុំរាជការទាំងស្រីប្រុស អត់ឃ្លានគ្មានអាហារចំណីនឹងបរិភោគដូច្នោះ ក៏ទ្រង់មានសេចក្ដីទោមនស្សអាណិតអាសូរណាស់ ត្រាស់ប្រើខន្ទីឲ្យទៅសុំបាយ និងសាច់គោពី**លីឈុយ** ៗខឹងនឹងព្រះចៅ**ហៀនតេ**ថា បានសោយគ្រប់វេលាហើយ ហេតុម្ដេចបានជាទៅសុំអាហារ នឹងឲ្យអ្នកឯណាស៊ីទៀត?

**លីឈុយ**ក៏ឲ្យយកបាយដែលផ្អូម និងសាច់គោស្អុយៗប្រគល់ឲ្យខន្ទីនាំយកទៅថ្វាយ។ ព្រះចៅ**ហៀនតេ** ក៏ទ្រង់ព្រះក្រោធ ហើយថាអាសត្រូវវាមើលងាយប្រមាថដល់អញខ្លាំងណាស់។

ខណៈនោះ **អៀវពីវ**លបចូលទៅគាល់ ហើយក្រាបទូលឃាត់ថា **លីឈុយ**មានចិត្តអាក្រក់ណាស់ គ្រានេះព្រះអង្គនៅក្នុងបង្គាប់វា ត្រូវតែខំអត់សង្កត់ព្រះទ័យ

សិនចុះ។ ព្រះចៅ**ហៀនតេ**មិនឆ្លើយតបសោះ ទ្រង់ព្រះកន្សែងសោកាទាល់តែស្នងព្រះអង្គនោះទទឹកដោយព្រះនេត្រា។

វេលានោះ មានមនុស្សលបចូលទៅយកសេចក្ដីក្រាបទូលព្រះចៅ**ហៀនតេ**ថា មានទ័ពលើកមកទទួលស្ដេច។ ព្រះចៅ**ហៀនតេ**ប្រើខន្ទីឱ្យលបចេញទៅស្ដាប់ការណ៍ ក៏ដឹងថា **គុយគី**លើកទ័ពមក។ ព្រះចៅ**ហៀនតេ**ទ្រង់ព្រះតម្រិះថា “**គុយគី**នឹងធ្វើឃាតដល់យើងហើយ” ក៏រឹតតែទ្រង់ព្រះកន្សែងឡើងទៀត ទទួលបានឮសំឡេងក្រៅកំពែងស្រែកហ៊ោអឺងកង។ **លីឈុយ**ដឹងថា **គុយគី**លើកទ័ពមក ក៏ផ្ដុំកងទ័ពលើកចេញទៅ ទើបយករំពាត់សេះចង្អុលមុខ**គុយគី**ហើយស្រែកថា អញចិញ្ចឹមរក្សាឯងដល់ខ្នាត ហេតុម្ដេចឯងត្រឡប់គិតប្រមាថធ្វើអន្តរាយអញវិញ?

**គុយគី**តបថា ខ្លួនឯងជាសត្រូវរាជសម្បត្តិ បានជាអញគិតសម្លាប់ឯងចេញ។ **លីឈុយ**ថា អញអញ្ជើញស្ដេចព្រះចៅ**ហៀនតេ**ចេញមករក្សាទុក ហេតុម្ដេចបានជាឯងថាអញជាសត្រូវរាជសម្បត្តិទៅវិញ? **គុយគី**តបថា ឯងជាមួយក្មួយហៅហានចូលទៅនាំស្ដេចមក ប្រាថ្នានឹងធ្វើអន្តរាយព្រះអង្គចេញ លុះអញលើកទាហានតាមមក ឯងកែខ្លួនថានាំស្ដេចមករក្សាទុក។ **លីឈុយ**ខឹងណាស់ស្រែកថា “កុំឱ្យក្ដៅក្រហាយដល់សេនាទាហានឯទៀតឡើយ ឯងនឹងអញចេញមកតទល់គ្នាតតួចុះ បើឯងឈ្នះក៏នាំស្ដេចយកទៅចុះ” ថាហើយបរសេះចេញទៅប្រយុទ្ធគ្នានឹង**គុយគី**បានដប់ភ្លែង មិនចាញ់មិនឈ្នះ។

**អៀវពីរ**ដឹងថា អ្នកទាំងពីរកើតទោសទាស់គ្នាជាខ្លាំង ខុសពីគំនិតដែលគិតទុកនោះ ទើបនាំពួកនាហ្មឺនតូចធំប្រហែលហុកសិបនាក់ស្រូតរូតទៅ ឃើញ**លីឈុយ**, **គុយគី**កំពុងច្បាំងគ្នា។ **អៀវពីរ**ស្រែកឃាត់ថា លោកទាំងពីរកុំច្បាំងគ្នាឡើយ ខ្ញុំនឹង

នាហ្មឺនទាំងអស់គ្នា មកអង្វរសុំឃាត់ឲ្យលោកទាំងពីរជានឹងគ្នាដូចប្រក្រតីវិញចុះ។ **លីឈុយ**, **គុយគី**បានស្ដាប់ដូច្នោះ ទាំងសងខាងក៏នាំទាហានត្រឡប់ថយរៀងខ្លួន។ **អៀវពីវ**នាំនាហ្មឺនទាំងនោះទៅតាមឃាត់**គុយគី** ៗឃើញនាហ្មឺនទាំងពួងមក ក៏បង្គាប់ទាហានឲ្យចាប់ខ្លួននាហ្មឺនទាំងអស់ដាក់គុកទុក។ នាហ្មឺនទាំងអស់ប្រកែកថា យើងទាំងអស់គ្នាគ្មានទោសខុសពីអ្វីសោះ មកនេះប្រាថ្នានឹងឃាត់ហាមលោកមិនឲ្យតាំងច្បាំងគ្នា ហេតុម្ដេចបានជាយកយើងទៅដាក់គុកទៅវិញ? **គុយគី**តបថា **លីឈុយ**នាំយកព្រះចៅ**ហៀនតេ**និងព្រះអគ្គមហេសីស្រីស្នំទៅឃុំឃាំងទុកខាងនោះ។ **អៀវពីវ**ឆ្លើយថា បើ**លីឈុយ**នាំយកព្រះចៅ**ហៀនតេ**ទៅឃុំឃាំងទុកខាងនោះ ហើយលោកឃុំឃាំងយើងខាងនេះ តើនឹងគិតធ្វើម្ដេច? **គុយគី**បានស្ដាប់ខឹងណាស់ ហូតដាវប្រុងនឹងកាប់**អៀវពីវ** ទទួលទាហាន**គុយគី**ម្នាក់ស្ទុះទៅឃាត់ **គុយគី**ក៏លើកលែង**អៀវពីវ**និង**ជូហ៊ី**ចេញទៅ ក្រៅពីនោះក៏ឲ្យឃាត់ឃុំទុកក្នុងគុក។ **អៀវពីវ**និង**ជូហ៊ី**ដើរមកដល់កណ្ដាលផ្លូវក៏ប្រឹក្សាគ្នាថា “យើងជានាហ្មឺនព្រះមហាក្សត្រ ទទួលបៀវត្សរ៍ដែលប្រោសព្រះរាជទាន គ្រានេះព្រះចៅ**ហៀនតេ**មានព្រះគ្រោះទៅរងទុក្ខលំបាកជាទម្ងន់ណាស់ យើងនឹងក្រឡាស់ចោលព្រះអង្គក៏ដូចមិនមានសេចក្ដីកតញ្ញូសោះ ដូច្នេះត្រូវតែយើងគិតទំនុកបម្រុងផែនដី ឲ្យព្រះអង្គបានសេចក្ដីសុខតទៅទើបគួរ” និយាយហើយក៏កៀកកគ្នាយំទាល់តែដួលចុះក្នុងទីនោះ លុះដឹងស្មារតីក្រោកឡើងនាំគ្នាទៅទីលំនៅរៀងខ្លួន។ ឯ**ជូហ៊ី**នោះក៏មានជំងឺឈឺស្លាប់ទៅ។

កាល**លីឈុយ** និង**គុយគី**តតាំងច្បាំងគ្នានោះ ក៏ចេះតែច្បាំងគ្រប់ថ្ងៃមិនឈប់ប្រហែលពីរខែ ទាហានទាំងសងខាងសឹងស្លាប់វិនាសច្រើនណាស់។ ឯ**លីឈុយ**កាលនៅក្នុងបន្ទាយនោះជឿកាន់យកពាក្យ (អម៉ុតអថាវ)។ **កាសៀង**ហាមឃាត់ជា

ច្រើនគ្រាថា កុំឲ្យជឿស្តាប់ពាក្យមនុស្សជំពូកនេះ។ **លីឈុយ**មិនស្តាប់ ចង់ធ្វើអ្វីក៏ធ្វើ (អថាវ) គ្រប់គ្រា។

**អៀវគី**នាហ្មឺនក្នុងហ្លួងដឹងដូច្នោះ បានលបចូលទៅក្រាបទូលព្រះចៅ**ហៀនតេ**ថា **កាសៀង**ជាទីប្រឹក្សា**លីឈុយ** តែ**កាសៀង**និយាយការអ្វី**លីឈុយ**មិនដែលស្តាប់តាមសោះ ប្រហែលជា**កាសៀង**មានចិត្តស្វាមីភក្តិនឹងព្រះអង្គនៅឡើយ សូមឲ្យហៅ**កាសៀង**មកគាល់ ហើយត្រាស់ប្រារព្ធពីកិច្ចរាជការទាំងពួង។ កំពុងតែនិយាយទទួល**កាសៀង**ចូលទៅគាល់ព្រះចៅ**ហៀនតេ** ទ្រង់ឲ្យបណ្តេញពួកខន្ទីទៅខាងក្រៅ ហើយទ្រង់ព្រះកន្សែងសោកាពិលាបមានព្រះបន្ទូលនឹង**កាសៀង**ថា គ្រានេះយើងមានសេចក្តីទុក្ខលំបាកខ្លាំងណាស់ អ្នកចូរមានចិត្តស្វាមីភក្តិជួយធុរការផែនដីដោយសុចរិត ជួយយកអាសារជីវិតយើងឲ្យរួចផង។

**កាសៀង**ក្រាបទូលព្រះឱង្ការថា សព្វថ្ងៃនេះ ទូលព្រះអង្គំជាខ្ញុំតាំងចិត្តនឹងធ្វើរាជការថ្វាយស្នងព្រះតេជព្រះគុណមិនមានភ្លេចសោះ សូមព្រះអង្គកុំអាលត្រាស់ឲ្យសេចក្តីទាំងអស់បែកធ្លាយឡើយ ការទាំងនេះហើយជាភ្នាក់ងារទូលព្រះបង្គំជាខ្ញុំនឹងគិតឲ្យសម្រេច។ ព្រះចៅ**ហៀនតេ**ទ្រង់ស្ញើយព្រះទ័យ ទទួល**លីឈុយ**កាន់ដាវចូលទៅ ព្រះចៅ**ហៀនតេ**ក៏ស្លុតព្រះសតិ។

**លីឈុយ**ក្រាបទូលព្រះចៅ**ហៀនតេ**ថា គ្រានេះ **គុយគី**គិតក្បត់នឹងព្រះអង្គ បានជាវាចាប់យកនាហ្មឺនច្រើននាក់ទៅដាក់គុកទុក ហើយវានឹងមកចាប់ព្រះអង្គយកទៅទៀត ដោយសារទូលព្រះបង្គំជាខ្ញុំនាំបង្វែរព្រះអង្គមក បានជាព្រះអង្គរួចអំពីភ័យនេះ។ ព្រះចៅ**ហៀនតេ**យល់ថាពិតមែន ក៏គំនាប់**លីឈុយ**ហើយត្រាស់ថា ដែល

អ្នកបានជួយឧបត្ថម្ភយើងដូច្នេះ យើងមានអំណរគុណរកទីបំផុតគ្មាន។ **លីឈុយ**ក៏ថ្វាយបង្គំលាទៅវិញ។

ខណៈនោះ**ហង់ហ៊ូហៀប**ចូលទៅគាល់ព្រះចៅ**ហៀនតេ** ៗទ្រង់ព្រះតម្រិះដឹងថា "**ហង់ហ៊ូហៀប**មានសតិបញ្ញា ហើយធ្លាប់នៅស្រុកជាមួយគ្នានឹង**លីឈុយ**" ទើបទ្រង់មានឡាយព្រះហស្តលេខាឲ្យទៅហាមឃាត់**លីឈុយ**, **គុយគី**កុំឲ្យទាស់ទែងគ្នាតទៅ។ **ហង់ហ៊ូហៀប**ទទួលយកឡាយព្រះហស្ត ហើយចូលទៅរក**គុយគី**ក្នុងបន្ទាយ។ **គុយគី**ឃើញឡាយព្រះហស្តហើយនិយាយថា បើ**លីឈុយ**បើកលែងព្រះអង្គ**ហៀនតេ**ចេញ យើងនឹងលែងពួកនាហ្មឺនដែលឃុំទុកនោះចេញដែរ យើងនឹង**លីឈុយ**ក៏ប្រក្រតីនឹងគ្នាតទៅ។ **ហង់ហ៊ូហៀប**បានស្តាប់ហើយ លាត្រឡប់ទៅរក**លីឈុយ**ក្នុងបន្ទាយនិយាយថា ខ្ញុំនិងលោកជាពួកនៅស្រុកជាមួយគ្នា បានជាព្រះករុណាប្រើខ្ញុំឲ្យកាន់ឡាយព្រះហស្តនេះមកហាមឃាត់លោក និង**គុយគី**កុំឲ្យតតាំងច្បាំងគ្នា ឯ**គុយគី**ព្រមស្តាប់តម្រាស់អស់ហើយ នៅឡើយតែខាងលោកឯនេះ តើថាដូចម្តេច? **លីឈុយ**តបថា យើងបានទំនុកបម្រុងមកបួនឆ្នាំហើយ សេចក្តីគាប់ប្រសើរក៏មានជាច្រើន **គុយគី**គ្រាន់តែជាមនុស្សកំណាចដើរលួចសេះ មកបានឡើងដល់ប៉ុណ្ណេះមិនគួរនឹងប្រកាន់ខ្លួនជាធំ ហើយយកនាហ្មឺនទាំងពួងទៅឃុំទុកក្នុងគុក ហើយប្រទូសរ៉ាយដល់យើង ៗនឹងសម្លាប់ចេញឲ្យបាន។

**ហង់ហ៊ូហៀប**តបថា កាលគ្រា**តាំងតុះ**លើកខ្លួនជាធំនោះ មិនបានធ្វើឲ្យទាហានម្នាក់ខូចសោះ តែបាបគ្រោះព្រោះ**លីប៉ោ**គ្មានកតញ្ញូ លបសម្លាប់**តាំងតុះ**បាន។ សព្វថ្ងៃនេះ អាណាខេត្តក្នុងក្រៅនៅមិនទាន់រាបទាបទេ លោកកុំអាលគ្នេរថាខ្លួនលោកជាធំជាងគេនោះឡើយ ប្រការមួយបងប្អូនញាតិសន្តានរបស់លោក បាន

ធ្វើរាជការជានាហ្មឺនមុខមន្ត្រីទាំងអស់ ព្រោះព្រះចៅ**ហៀនតេ**ទ្រង់ប្រោសប្រទានឲ្យលោកមានបណ្តាស័ក្តិជាធំដល់ខ្នាត ហេតុម្តេចលោកយកព្រះអង្គទៅបង្ខាំងទុកដោយអំណាច? **គុយគី**ឃើញលោកធ្វើដូច្នេះ បានជាយកនាហ្មឺនទាំងនោះទៅឃុំក្នុងគុកដូចគ្នា។ លោកទាំងពីរសុទ្ធតែជាអ្នកទំនុកបម្រុងផែនដីរៀងមក ដែលមកធ្វើដូច្នេះមិនត្រូវសោះ នឹងថាខាងណាខុសខាងណាត្រូវក៏នៅថាមិនបាន សូមឲ្យលោករិះធ្យានគិតមើលចុះ។

**លីឈុយ**បានឮដូច្នោះក៏ខឹងលើសលុប ចាប់យកគ្រប៊ីកាន់ហើយស្រែកគំហកថា ព្រះចៅ**ហៀនតេ**ប្រើខ្លួនឲ្យមកទ្រគោះបោះបោកឲ្យយើងឬ បានជាខ្លួនហ៊ាននិយាយដូច្នេះ? យើងនឹងកាត់ក្បាលខ្លួនឥឡូវនេះ។ **អៀវហង**ឃើញដូច្នោះក៏ឃាត់ហាមថា ការដែល**គុយគី**និងលោកទាស់ទែងគ្នាជាធំមិនទាន់ដឹងដូចម្តេច គេចមកចង់សម្លាប់**ហង់ហ៊ូហៀប**ជាព្រះរាជបម្រើទៀតមិនគួរសោះ បើសេចក្តីនោះដឹងទៅដល់អាណាខេត្តខាងក្រៅហើយ មិនលែងឡើយ នឹងលើកទ័ពមកជួយខាង**គុយគី** ធ្វើឲ្យលោកខ្ទេចខ្ទីមិនខាន។ **កាសៀង**ក៏ចូលទៅឃាត់ហាមតាមសម្តី**អៀវហង**ទៀត **លីឈុយ**ក៏មិនបានសម្លាប់**ហង់ហ៊ូហៀប**។ **កាសៀង**នាំ**ហង់ហ៊ូហៀប**ចេញទៅ។ **ហង់ហ៊ូហៀប**ស្រែកប្រកាសថា **លីឈុយ**ធ្វើការអាក្រក់ណាស់ មានព្រះតម្រាស់បង្គាប់ក៏មិនស្តាប់សោះ ដែលធ្វើដូច្នេះប្រុងនឹងដណ្តើមយករាជសម្បត្តិហើយ។

**ឱម៉ៅ**ឮហើយក៏ឃាត់ហាមកុំឲ្យនិយាយដូច្នោះ ក្រែងនឹងមានអន្តរាយមកដល់ខ្លួន។ **ហង់ហ៊ូហៀប**មិនស្តាប់ស្រែកគំហកថា “ខ្លួនជាមន្ត្រី ស៊ីប្រាក់បៀវត្សរ៍ដែលប្រោសព្រះរាជទាន ឥឡូវនេះព្រះចៅ**ហៀនតេ**មានទុក្ខលំបាកផ្ទាល់ព្រះអង្គដូច្នេះ យើងជាខ្ញុំរាជការមិនត្រូវស្តាយជីវិត ត្រូវតែគិតតបស្នងព្រះតេជគុណ ខ្លួន

មកនិយាយដូច្នេះជាមនុស្សអកតញ្ញូណាស់ ឬខ្លួនជាមនុស្សក្បត់ដែរ?” ថាហើយក៏ស្រែកជេរ**លីឈុយ**ជាពាក្យអាស្រូវភាសហើយដើរទៅ។

ព្រះចៅ**ហៀនតេ**ទ្រង់ជ្រាប ក៏ឲ្យ**ហង់ហ៊្វូហៀប**ចូលទៅគាល់ ហើយត្រាស់ថាអ្នកនឹងនៅក្នុងស្រុកក្រុងនេះមិនបានទេ អន្តរាយនឹងមានដល់ខ្លួនអ្នក បើដូច្នេះត្រូវតែដោះចេញឲ្យផុត ចូរទៅនៅស្រុកស៊ីឡុងចុះ។ **ហង់ហ៊្វូហៀប**បានស្តាប់ព្រះតម្រាស់ក៏ក្រាបថ្វាយបង្គំលា ហើយនិយាយបបួលពួកទាហាន**លីឈុយ** ដែលមកពីស្រុកស៊ីឡុងថា **លីឈុយ**គ្រានេះធ្វើការទុច្ចរិតគិតក្បត់នឹងផែនដីហើយ អ្នកទាំងឡាយនៅជ្រកកោននឹងវាមិនបានទេ បើនៅហើយអន្តរាយទាំងពួងក៏គង់នឹងមានដល់ខ្លួន។ ទាហានទាំងពួងបានឮ**ហង់ហ៊្វូហៀប**ប្រាប់ដូច្នោះ ក៏ភិតភ័យណាស់ នាំគ្នារត់ចេញពីផ្ទះ**លីឈុយ**ទៅជាច្រើន។

**លីឈុយ**បានដឹងដំណើរ ក៏ប្រើ**អងផៀង**លើកទាហានតាមចាប់**ហង់ហ៊្វូហៀប**មកវិញ។ **អងផៀង**លើកតាមទៅដល់កណ្តាលផ្លូវក៏គិតថា “**ហង់ហ៊្វូហៀប**ជាមនុស្សសុចរិតពិតត្រង់នឹងផែនដី បើតាមចាប់ខ្លួនបានមក **លីឈុយ**ក៏ឲ្យសម្លាប់អសារឥតការ សេចក្តីគរហានិន្ទាក៏នឹងមានដល់ខ្លួនយើង” គិតហើយក៏លើកទ័ពត្រឡប់មកវិញ ហើយចូលទៅប្រាប់**លីឈុយ**ថា ខ្ញុំបាទតាម**ហង់ហ៊្វូហៀប**ទៅរកមិនឃើញទេ។ **លីឈុយ**មិនបានថាប្រការម្តេច។ ខណៈនោះ**កាសៀង**ចូលទៅក្រាបបង្គំគាល់ព្រះចៅ**ហៀនតេ** ហើយទូលថា **លីឈុយ**ធ្វើការរាជការគ្រានេះ ជាផ្លូវប្រទូសរ៉ាយអាក្រក់នឹងផែនដីខ្លាំងណាស់ អស់សេនាទាហានសឹងតែប្រែចិត្តរត់ចោល**លីឈុយ**ជាច្រើន សុំឲ្យមានព្រះតម្រាស់ជាឧបាយយកចិត្ត តាំងឲ្យ**លីឈុយ**ឡើងជាមហាឧបរាជចុះ ទូលព្រះបង្គំជាខ្ញុំនឹងសុំតាំងចិត្តគិតការតទៅ។ ព្រះចៅ

**ហៀនតេ**ទ្រង់យល់ឃើញត្រូវផង ក៏តាំង**លីឈុយ**ជាមហាឧបរាជ។ **លីឈុយ**មានសេចក្ដីសោមនស្សណាស់ ហើយថា “យើងបានឡើងទីគ្រានេះក៏ព្រោះ (អម៉ុតអថាវ)ជួយ” ថាហើយយកមាសប្រាក់ និងគ្រឿងសម្លៀកបំពាក់ឲ្យដល់ (អម៉ុតអថាវ) ជាច្រើន ឯទាហានឯទៀត **លីឈុយ**នឹងបានឲ្យរបស់អ្វីក៏ទេសោះ។

**អៀវហង**ឃើញដូច្នោះខឹងណាស់ និយាយនឹង**សងកោ**ថា យើងជាទាហាន**លីឈុយ** បានធ្វើការសឹកសង្គ្រាមមកក៏ច្រើនដងច្រើនគ្រា **លីឈុយ**នឹងបានឲ្យរង្វាន់ជាគុណបំណាច់អ្វីគ្មានសោះ ហើយយករបស់ទៅបំពេញ (អម៉ុតអថាវ) វិញ។

**សងកោ**តបថា យើងក៏មានសេចក្ដីតូចចិត្តណាស់ដែរ យើងនឹងគិតសម្លាប់**លីឈុយ**ចេញ ហើយចូលទៅគាល់បម្រើព្រះចៅ**ហៀនតេ**វិញប្រសើរជាង។ **អៀវហង**យល់ឃើញត្រូវថា យើងនឹងទៅបញ្ចុះបញ្ចូលទាហានឲ្យបានច្រើន វេលាបីថ្ងៃនេះ អ្នកនៅខាងក្នុងត្រូវប្រុងយកភ្លើងដុតបន្ទាយឲ្យឆេះឡើង យើងលើកទាហានមកចាប់**លីឈុយ**សម្លាប់ចេញ។ **សងកោ**យល់ព្រម **អៀវហង**ក៏ចេញទៅពន្យល់ទាហានក្រៅបន្ទាយ។ មានទាហានម្នាក់ដឹងសេចក្ដីក៏ចូលទៅប្រាប់**លីឈុយ** តាមដំណើរ**អៀវហង** និង**សងកោ**គិតគ្នានោះ។ **លីឈុយ**ឲ្យចាប់យកខ្លួន**សងកោ**បានហើយនាំទៅសម្លាប់។ ឯ**អៀវហង**ហ្វឹកហាត់ទាហានបាន ចាំមើលដល់យាមពីរប្លាយ មិនបានឃើញពន្លឺភ្លើងឆេះឡើងសោះ ក៏ឲ្យទាហានទាំងអស់សំងំនៅ។ ខណៈនោះ**លីឈុយ**លើកទាហានចេញពីបន្ទាយជួបប្រទះនឹងកងទ័ព**អៀវហង**ក៏តាំងច្បាំងគ្នា។ ទាំងសងខាងមានរបួសពិការស្លាប់ជាច្រើន ។ **អៀវហង**ឃើញថាកម្លាំងនឹងតទល់ពុំឈ្នះ ក៏នាំទាហានដែលសេសសល់រត់ចេញទៅទិសឯលិច។

ខណៈនោះមានបម្រើសេះមកប្រាប់**លីឈុយ**ថា **តៀវចេ**លើកទាហានមកមួយកងពីទិសឯលិច ហើយស្រែកប្រកាសថា នឹងមកឃាត់ហាមលោកមិនឲ្យច្បាំងនឹង**គុយគី** បើខាងណាមិនស្តាប់ **តៀវចេ**នឹងធ្វើសង្គ្រាមតនឹងអ្នកនោះ។ **លីឈុយ**គិតថា ទាហានយើងក៏នៅស្រាលស្តើងណាស់ហើយ ដែលនឹងធ្វើសឹកតទៅនឹង**គុយគី**នោះឃើញទុញទាល់ណាស់ **តៀវចេ**មកឃាត់ហាមនេះក៏សមប្រកបនឹងគំនិតយើងដែរ គួរតែយើងធ្វើមេត្រីទុកឲ្យ**តៀវចេ**ឃើញថា យើងស្តាប់ពាក្យសម្តី។ គិតហើយក៏ចាត់ទាហានឲ្យទៅទទួល ហើយផ្តាំឲ្យប្រាប់**តៀវចេ**ថា យើងបានឮដំណឹងថា **តៀវចេ**នឹងមកឃាត់ហាមមិនឲ្យច្បាំងគ្នានឹង**គុយគី**នោះ យើងយល់មុខ**តៀវចេ**ណាស់ បានជាព្រមស្តាប់តាមពាក្យ។

**គុយគី**បានដឹងដំណឹង ក៏ប្រើទាហានចេញទៅនិយាយនឹង**តៀវចេ**ថា ដែលលោកលើកទាហានមកឃាត់ហាម មិនឲ្យច្បាំងគ្នានឹង**លីឈុយ**នោះ **គុយគី**ព្រមស្តាប់តាមពាក្យឃាត់ហើយ។ **តៀវចេ**មានចិត្តត្រេកអរណាស់ តាំងឲ្យបោះទ័ពនៅទីនោះ ហើយធ្វើសំបុត្រចូលទៅក្រាបបង្គំទូលព្រះចៅ**ហៀនតេ**ថា ទូលព្រះបង្គំជាខ្ញុំ **តៀវចេ**បានមកឃាត់ហាម**លីឈុយ, គុយគី**ទាំងសងខាង បានព្រមសះសាជានឹងគ្នាលែងច្បាំងគ្នាហើយ ទូលព្រះបង្គំជាខ្ញុំសូមអញ្ជើញព្រះអង្គយាងទៅគង់នៅស្រុកហងឡុង ដែលជាមុខគយស្រុកតៀវហាន់។

ព្រះចៅ**ហៀនតេ**មានសេចក្តីសោមនស្សត្រាស់ថា សម័យ**តាំងតុះ**យើងក៏ចេញចាកស្រុកឡុងអៀង មកនៅស្រុកតៀវហាន់ គ្រានេះយើងមកនៅស្រុកដែល**តាំងតុះ**សាងថ្មីទៀត ក៏មានតែទុក្ខចង្អៀតរកសេចក្តីសុខគ្មាន។ ឥឡូវនេះ**តៀវចេ**ចង់ឲ្យទៅនៅស្រុកហងឡុងវិញ ប្រហែលនឹងបាត់ទុក្ខ មានសេចក្តីសុខ ព្រោះបុណ្យ

របស់យើងទេដឹង។ ទ្រង់ព្រះចិន្តាហើយ ក៏តាំងឲ្យ**តៀវចេ**ធ្វើជា “**តៀវគីចុងគុន**” ប្រែថា “នាយទាហានធំ”។ **តៀវចេ**បានឡើងទី ក៏មានសេចក្ដីត្រេកអរណាស់ ទើបចាត់ចែងចំណីត្រីសាច់ និងរបស់ត្រកាលនាំចូលទៅថ្វាយ។ ព្រះចៅ**ហៀនតេ**ក៏ទ្រង់ព្រះរាជទានដល់បាវព្រាវទាំងពួងដែលអត់ឃ្លាន។

**គុយគី**ដឹងដូច្នោះ ក៏បើកលែងនាហ្មឺនដែលត្រូវឃុំក្នុងគុកនោះនាំយកទៅថ្វាយព្រះចៅ**ហៀនតេ**។ បណ្ដានាហ្មឺនមុខមន្ត្រីខ្ញុំរាជការតូចធំក៏ប្រជុំគ្នា ចាត់ចែងទាហាន និងគ្រឿងហែហមព្រមបរិបូរហើយ ក៏អញ្ជើញព្រះចៅ**ហៀនតេ** និងព្រះអគ្គមហេសីស្រីស្នំ ឡើងគង់ព្រះរាជរថ លើកព្យុហៈយាត្រាកាត់ស្រុកស៊ិនឡុង ឆ្លងទៅដល់ស្ពានទន្លេប៉ាឡេង ទទួលឮសំឡេងស្រែកហ៊ោកញ្ជ្រៀវ ហើយលើកទាហានមកស្កាត់នៅលើស្ពាន នាយទាហានក៏ស្រែកសួរថា ព្រះចៅ**ហៀនតេ**ស្ដេចយាងមកដែលអ្នកលើកទាហានមកស្កាត់លើស្ពាននេះឈ្មោះអ្វី? ម្ដេចមិនក្រាបថ្វាយបង្គំ? ទាហានឯកពីនាក់ឆ្លើយតបថា **គុយគី**ឲ្យយើងមករក្សាផ្លូវនេះ មិនឲ្យនរណាទៅជួយ**លីឈុយ** ដែលអ្នកថាព្រះចៅ**ហៀនតេ**ស្ដេចមកនោះ ចូរឲ្យយើងឃើញច្បាស់សិន យើងនឹងថ្វាយបង្គំហើយបើកផ្លូវឲ្យស្ដេចយាងទៅ។ **អៀវគី**ក៏ឲ្យទាហានស្រូតបង្ខំបរព្រះរាជរថនោះឡើងនឹងអាលផុតស្ពាន។ ទាហានទាំងពួងឃើញជាក់ច្បាស់ក៏លុតជង្គង់ថ្វាយបង្គមទាំងអស់គ្នា រាថយពីលើស្ពានចេញទៅ ព្រះរាជរថក៏លឿនផុតស្ពាន។

ខណៈនោះនាយទាហានទាំងពីរនាក់ ត្រឡប់ទៅប្រាប់**គុយគី**ថា ព្រះចៅ**ហៀនតេ**យាងទៅដល់ស្ពានទន្លេប៉ាឡេងហើយឆ្លងហួសទៅហើយ។ **គុយគី**ឮដូច្នោះខឹងណាស់ថា “យើងស្ដាប់**តៀវចេ**តែមាត់ យើងនឹងឲ្យលើកទាហានទៅស្កាត់ចាប់

ព្រះចៅ**ហៀនតេ**ឯទីក្រុង**តាំងតុះ**សាងថ្មី ហេតុម្ដេចមិនធ្វើតាមបង្គាប់ ក៏ត្រឡប់ឲ្យស្ដេចយាងហួសទៅបាន?” ថាហើយក៏ឲ្យយកនាយទាហានទាំងពីរនោះទៅសម្លាប់ចោល រួចលើកទ័ពតាមទៅ។ ព្រះចៅ**ហៀនតេ**យាងទៅដល់ស្រុកហួហិម ក៏បានឮសំឡេងទាហានហ៊ោកញ្ជៀវពីក្រោយថា នាហ្មឺនទាំងអស់គ្នាកុំអាលនាំស្ដេចទៅណា ឲ្យបង្អង់ឈប់សិន។

ព្រះចៅ**ហៀនតេ**ឮដូច្នោះ ទ្រង់ព្រះកន្សែងសោកា ហើយត្រាស់ថា ផុតពី**លីឈុយ**មកហើយ គិតថានឹងធូរទូលាយសប្បាយចិត្តខ្លះ ថែមមកប្រទះនឹងទាហានវាំងផ្លូវស្ពានទៀត ឥឡូវនេះមានគេតាមមកច្រៀកបៀតដល់ទីនេះ នឹងរាសទៅខាងណា ចេញពីមាត់ខ្លាទៅចូលមាត់ក្រពើ ដូច្នេះគ្រានេះនឹងគិតដូចម្ដេចទើបនឹងបានរួចភ័យ? មន្ត្រីទាំងអស់មិនបានឆ្លើយថាដូចម្ដេច។ ឯទ័ព**គុយគី**ក៏លើកមួយរំពេចចូលមកទៀត ព្រះចៅ**ហៀនតេ**រឹតតែទ្រង់ព្រះកន្សែងសោកានៅលើព្រះរាជរថនោះ។

ឯ**អៀងហាង** ដែលរត់ពី**លីឈុយ**ទៅ ៗនៅសំណាក់ក្នុងភ្នំសាំសាន់ខាងលិចបស្ចិមនោះ លុះដឹងដំណឹងថា ព្រះចៅ**ហៀនតេ**ស្ដេចយាងទៅដល់ស្រុកហាងឡុង ក៏តាំងតែភ្ជុំសេនាទាហានលើកតាមស្ដេចទៅ ដើម្បីនឹងជួយការពារសេចក្ដីអន្តរាយ លុះលើកទៅដល់ទល់នឹងក្បួនហែដែលស្ដេចព្រះរាជដំណើរ ក៏ពើបប្រទះនឹងកងទ័ព**គុយគី**លើកដេញតាមពីក្រោយ **អៀងហាង**ក៏លើកទាហានបណ្ដោយចូលទៅស្កាត់កងទ័ព**គុយគី**ជាប់។ **ស៊ុយយ៉ុង**សេនា**គុយគី**ក្រឡេកឃើញកងទ័ព**អៀវហាង**លើកមកស្កាត់ ក៏ញាក់សេះពារទាហានពានទៅមុខ ហើយស្រែកជេរ**អៀវហាង**ពាក្យអាស្រូវភាសផ្សេងៗ។ **អៀវហាង**ខឹងណាស់ ប្រើ**ស៊ីឡុង**សេនាឯកឲ្យកាន់ពូថៅធំដែកចេញទៅតយុទ្ធនឹង**ស៊ុយយ៉ុង** បានតែមួយស្របក់ **ស៊ីឡុង**ក៏កាប់**ស៊ុយយ៉ុង**ធ្លាក់ពីលើសេះ

ស្លាប់។ **អៀវហាង**ក៏លើកកងទាហានបំពានចូលទៅ ប្រកាប់កងទ័ព**គុយគី**ស្លាប់ ដេរដាសពលទាហានរត់រទាសចូលព្រៃ ហើយដេញតាមទៅចម្ងាយផ្លូវប្រហែលពីររយសិន (៨ គ.ម) រួច**អៀវហាង**លើកត្រឡប់នាំកងទ័ពចូលទៅថ្វាយបង្គំព្រះចៅ**ហៀនតេ** ៗទ្រង់ព្រះតម្រាស់ត្រាស់សួរដោយរួសរាយហើយថា **អៀវហាង**លើកទាហានមកជួយយើងគ្រានេះ ជាគុណូបការៈដ៏ទម្ងន់ណាស់ យើងមិនភ្លេចគុណអ្នកតទៅទៀត ឯសេនារបស់អ្នកដែលបានសម្លាប់**ស៊ុយយ៉ុង**នោះ ឥឡូវនៅឯណា? សុំឲ្យនាំខ្លួនមកបង្ហាញយើងស្គាល់មុខ។ **អៀវហាង**ក៏ហៅ**ស៊ីឡុង**ចូលមកគាល់ ហើយ**អៀវហាង**ក្រាបបង្គំទូលថា **ស៊ីឡុង**នេះជាពួកអ្នកស្រុកហោតាំង។

ព្រះចៅ**ហៀនតេ**ទ្រង់មានព្រះតម្រាស់ថា អ្នកទាំងពីរនេះបានធ្វើសេចក្តីគាប់ប្រសើរលើខ្លួនយើងៗសុំឲ្យអ្នកទាំងអស់គ្នានៅជាមួយនឹងយើងតទៅចុះ។ លុះវេលាយប់ **អៀវហាង**ឲ្យរៀបតាំងបន្ទាយរាយជុំវិញ ដើម្បីការពាររក្សាព្រះចៅ**ហៀនតេ**។

ឯ**គុយគី**ដែលបែកទ័ពត្រឡប់ទៅនោះ បានបញ្ចុះបញ្ចូលប្រមូលសេនាទាហានច្រើនឡើងវិញ លុះព្រឹកឡើងក៏លើកជាក្បួនទ័ពត្រឡប់តាមទៅច្បាំងនឹង**អៀវហាង**ទៀត។ **ស៊ីឡុង**ក៏ប្រុងប្រៀបរៀបទាហានជាក្បួនទ័ពស្រេច ដល់ឃើញទាហាន**គុយគី**លើកទៅឡោមព័ទ្ធជុំវិញ ក៏បរសេះចេញទៅតទល់គ្នា ស្រាប់តែឃើញ**តាំងស៊ិន**លើកយោធាពារទម្លាយកងទ័ព**គុយគី** ពីទិសខាងកើតចូលមក កងទ័ព**គុយគី**ក៏បែកបាក់ខ្ចាត់ខ្ចាយរត់ជ្រៀតជ្រកជាចលាចល។ **ស៊ីឡុង**ក៏បរពលចូលខ្ទប់ពីខាងលិច គេចចាក់កាប់សម្លាប់ទាហាន**គុយគី**វិនាសស្លាប់ជាច្រើន។ **គុយគី**បែកទ័ពលើកត្រឡប់ទៅវិញ មិនមានសេសសល់ឡើយ។

**តាំងស៊ិន**នោះមិញចូលទៅក្រាបបង្គំគាល់ព្រះចៅ**ហៀនតេ** ៗទតយល់ **តាំងស៊ិន** ទ្រង់ព្រះកន្សែងសោកា ត្រាស់បរិហាររឿងរ៉ាវដែលព្រួយលំបាកឲ្យ**តាំងស៊ិន**ស្ដាប់គ្រប់ប្រការ។ **តាំងស៊ិន**ក្រាបទូលថា កុំឲ្យព្រះអង្គទ្រង់វិតក្កតទៅទៀត ការក្រងាយទូលាយចង្អៀត សឹមទូលព្រះបង្គំជាខ្ញុំ និង**អៀវហាង**រងទទួលរក្សាការពារព្រះអង្គតទៅ ឯខ្លួនអាសត្រូវទាំងពីរនាក់ ទូលព្រះបង្គំជាខ្ញុំនឹងសុំជាធុរៈកាប់សម្លាប់ចេញឲ្យបាន ដើម្បីនឹងឲ្យផែនដីសុខក្សេមក្សាន្តតទៅ។ ព្រះចៅ**ហៀនតេ**ទ្រង់ត្រេកអរសាទរក្នុងព្រះទ័យណាស់ ត្រាស់ឲ្យលើកព្យុហៈទ័ពទៅទាំងយប់ថ្ងៃ ក៏បានទៅដល់ស្រុកហាងឡុង។

ឯ**គុយគី**មានតែទីទោមនស្ស ព្រោះចាញ់ទ័ពពីរគ្រា ខំប្រមូលពលយោធាដែលបាក់បែកនោះបានមកវិញខ្លះ។ ខាង**លីឈុយ**នោះ លើកកងទ័ពតាមទៅទៀតប្រាថ្នានឹងធ្វើអន្តរាយព្រះចៅ**ហៀនតេ**ឲ្យបាន លុះទៅជួបនឹង**គុយគី** អ្នកទាំងពីរក៏សះជានឹងគ្នាហើយប្រឹក្សាគ្នាថា **តាំងស៊ិន** និង**អៀវហាង** នាំយកព្រះចៅ**ហៀនតេ**ស្ដេចទៅឯស្រុកហាងឡុង ដែលមានផ្លូវទៅលើក្រុងតៀវហាន់ បើយាងស្ដេចរហូតទៅនៅតាំងទ័ពខ្ជាប់ខ្ជួនក្នុងខេត្តតៀវហាន់ហើយ គង់នឹងមានសំបុត្រព្រះតម្រាស់ទៅដល់អាណាខេត្តក្រៅទាំងប៉ុន្មាន ឲ្យលើកពលទាហានមកធ្វើទុក្ខបុកម្នេញយើងទាំងពីរជាប្រាកដ។ **លីឈុយ**តបថា ឥឡូវនេះ **តៀវចេ** តាំងទីរក្សាស្រុកតៀវហាន់ មានសេនាទាហានខ្លាំងពូកែច្រើនណាស់ យើងនឹងលើកទៅប៉ះក៏មិនបាន ត្រូវតែយើងទាំងពីរលើកតាមទៅឯស្រុកហាងឡុងវិញ ដើម្បីនឹងចាប់យកព្រះចៅ**ហៀនតេ**សម្លាប់ចេញ បើសម្លាប់បានហើយ ទ្រព្យសម្បត្តិទាំងប៉ុន្មានយើងត្រូវបែងចែកគ្នាពាក់កណ្ដាលម្នាក់។ **គុយគី**បានស្ដាប់ក៏ចាប់ចិត្តអរណាស់ ព្រោះជាមនុស្សមាន

សេចក្តីលោភលន់ នាំ**លីឈុយ**លើកទ័ពទៅដល់ទីតំបន់ណា ឱ្យសេនាទាហានទន្ទ្រាន រឹបរាតត្បាតយកទ្រព្យរបស់ អស់អាណាប្រជានុរាស្ត្រក្នុងទីនោះ។

ចំណែក**តាំងស៊ុន**, **អៀវហាង**នាំស្តេចទៅដល់តំបន់តាន់កាន់ ដឹងថា**លីឈុយ** និង**គុយគី** រួមគំនិតលើកទ័ពតាមចាប់ព្រះចៅ**ហៀនតេ** ក៏បញ្ឈប់ពួកកងទ័ពនៅទីនោះ ហើយប្រុងប្រៀបរៀបសេនាទាហានការពាររក្សាព្រះអង្គ។

**លីឈុយ** និង**គុយគី**ប្រឹក្សាគ្នាថា ទាហានយើងលើកមកច្រើនជាងទាហាន **តាំងស៊ិន** និង**អៀវហាង** យើងនឹងលើកឆ្លងចូលទៅតតាំងច្បាំងដណ្តើមយកព្រះចៅ**ហៀនតេ**ប្រហែលបាន។ លុះគិតគ្នាហើយ ក៏បែងកងទ័ពម្នាក់ពាក់កណ្តាលលើកចូលទៅជាប៉ែកឆ្វេង-ស្តាំ។ **តាំងស៊ិន** និង**អៀវហាង**ក៏រងទទួលតាំងច្បាំងគ្នា លុះឃើញថាកម្លាំងនឹងតតាំងពុំឈ្នះ **តាំងស៊ិន** និង**អៀវហាង**ក៏លើកប្រាសរត់យកតែខ្លួនចោលអស់របស់ទ្រព្យនិងគ្រឿងប្រដាប់ផ្សេងៗ ហើយនាំយកព្រះចៅ**ហៀនតេ**និងអគ្គមហេសីស្រីស្នំនូវអស់នាហ្មឺនមុខមន្ត្រី ពារទម្លាយកងទ័ព**លីឈុយ**, **គុយគី**ចេញទៅទិសខាងជើង។ **លីឈុយ**, **គុយគី**ក៏លើកទាហានដេញចេញទៅ ឯទ្រព្យរបស់ដែលសល់នៅ ពួកទាហាន**លីឈុយ**, **គុយគី**រើទៅទាំងអស់។

ខណៈនោះ**តាំងស៊ិន** និង**អៀវហាង**រត់ទៅដល់តំបន់មួយ ក៏ឱ្យតែងព្រះតម្រាស់ព្រះចៅ**ហៀនតេ**ពីរច្បាប់ គឺមួយច្បាប់ជាសេចក្តីល្បួងលួងលោម**លីឈុយ**, **គុយគី** មួយច្បាប់ទៀតឱ្យទៅដល់**ហាន់សៀម**, **លីង៉ាក់** និង**ហោចាយ** បីនាយនេះជាពួកចោរនៅដែនស្រុកហោតាំង។ សេចក្តីសំបុត្រនោះថា ទ្រង់ឱ្យលើកទោសហើយឱ្យអ្នកទាំងបីនាំយកបក្សពួកមកបម្រុងទទួលស្តេចនៅឯស្រុកហោតាំង។ ឯ**ហាន់សៀម**, **លីង៉ាក់** និង**ហោចាយ**បានទទួលព្រះតម្រាស់នោះហើយ ក៏លើកបក្ស

ពួកមកក្រាបបង្គំគាល់។ **តាំងស៊ិន**ឃើញពួកចោរមកដល់ក៏ប្រឹក្សាថា យើងនឹងលើកកងទ័ពត្រឡប់ទៅវាយយកស្រុកហាងឡុងវិញ ឲ្យបានជាទីមាំសិន រួចសឹមគិតការតទៅ។ នាយចោរទាំងបីនាក់ក៏ស្ម័គ្រចូលចិត្តព្រមផង **តាំងស៊ិន**ក៏លើកកងទ័ពត្រឡប់ជាមួយនឹងព្រះចៅ**ហៀនតេ** មកប្រទល់នឹងកងទ័ព**លីឈុយ, គុយគី**។ ឯ**លីឈុយ, គុយគី**កាលលើកទ័ពទៅតាមនោះ លុះទៅដល់ទីតំបន់ណាក៏ឲ្យទាហានរឹបរាគត្បាតពិឃាដមនុស្សចាស់ជរាជាច្រើន ណាដែលមានកម្លាំងខ្លាំងពូកែក៏យកទុកជាទាហាន ហើយឲ្យឈ្មោះថា ពួកមិនខ្លាចស្លាប់។

កាលកងទ័ព**លីឈុយ, គុយគី**និងកងទ័ព**តាំងស៊ិន**បានជួបប្រទះគ្នានោះ នៅតំបន់យូអៀង។ ទាហានទាំងសងខាងបានតយុទ្ធគ្នាជាយូរថ្ងៃ។

**លីឈុយ, គុយគី**ប្រឹក្សាគ្នាថា ឥឡូវនេះ**តាំងស៊ិន**បានពួកចោរមកធ្វើជាកម្លាំងច្រើនណាស់ បើដូច្នេះយើងត្រូវប្រើឧបាយឲ្យទាហានយើងយកអស់របស់ទ្រព្យ និងសំពត់អាវសារស្បែទៅបោះចោលរាយក្បែរផ្លូវ បើពួកចោរបានឃើញ មុខជាមានសេចក្ដីប្រាថ្នាលង់ចិត្តគិតតែរើសយក មិនរវាំងខ្លួន យើងត្រូវលើកទាហានទៅពួនបង្កប់ ហើយចេញមកវាយខ្ទប់ទាំងសងខាង ទ័ព**តាំងស៊ិន**ក៏នឹងអស់ទីអាងបែកបាក់ទៅឯង។

**គុយគី**បានស្ដាប់ក៏ចាប់ចិត្តគិតឃើញត្រូវ ទើបចាត់ឲ្យទៅយករបស់ទ្រព្យ និងសំពត់អាវសារស្បែរាយចោលតាមផ្លូវរៀងទៅ ហើយឲ្យទាហានពួនបង្កប់ទាំងសងខាង។ កងទ័ពពួកចោរឃើញដូច្នោះ ក៏ចេះតែបបួលគ្នាដើររើសយកមិនបានរវាំងខ្លួន។ **លីឈុយ, គុយគី**ឃើញបានការ ទើបលើកសេនាទាហានចូលវាយចាក់កាប់សម្លាប់កងទ័ព**តាំងស៊ិន** និងពួកចោរវិនាសស្លាប់ជាច្រើន។ លុះ**តាំងស៊ិន** និង

**អៀវហាង**តតាំងពុំឈ្នះ ក៏នាំព្រះចៅ**ហៀនតេ**រត់ទៅទិសខាងជើង **លីឈុយ, គុយគី**ក៏លើកតាមទៅ។

**លីង៉ាក់**នាយចោរឃើញដូច្នោះ ទើបក្រាបទូលព្រះចៅ**ហៀនតេ**ថា កងទ័ពតាមមកជិតនឹងទាន់ហើយ អញ្ជើញព្រះអង្គទ្រង់ចុះចាកព្រះរាជរថឡើងគង់ព្រះទី នាំងអស្សពាហ៍រត់ទៅមុនចុះ ទូលព្រះបង្គំជាខ្ញុំទាំងពួងនឹងតទល់ការពារពីខាង ក្រោយ។ ព្រះចៅ**ហៀនតេ**ត្រាស់ថា ដែលយើងរត់ទៅមុននោះមិនគួរទេ បើអ្នកទាំងអស់គ្នានឹងជាប្រការដូចម្ដេច យើងក៏ត្រូវដូច្នោះឯង។ នាហ្មឺននិងចោរទាំងពួងនាំគ្នាទួញយំរងំ ហើយក៏ឲ្យទាហានច្បាំងការពារជាលំដាប់ទៅ។ **ហោចាយ**នាយចោរឃើញកងទ័ពសន្ធាប់តាមមកជិតណាស់ ក៏បរសេះទៅតតាំងរាំងរា។ ទាហាន **លីឈុយ, គុយគី**ក៏បានបាញ់ធ្នូចម្រុះទៅ ត្រូវ**ហោចាយ**ធ្លាក់ពីលើសេះស្លាប់។

**តាំងស៊ិន** និង**អៀវហាង**ឃើញកងទ័ពជាប់មកជិតណាស់ ក៏អញ្ជើញព្រះចៅ**ហៀនតេ** និងព្រះមហេសីស្រីស្នំរត់ទៅដល់ឆ្នេរស្ទឹងហាងហោ។ **លីង៉ាក់**ក៏ចុះទៅមាត់ស្ទឹងប្រឹងរកបានទូកមួយចែវមកចម្លងស្ដេចចុះ តែមាត់ច្រាំងនៅខ្ពស់ទ្រង់យាងចុះពុំបាន។ ទាហាន**លីឈុយ, គុយគី**ក៏កាន់តែដេញជិតប្រកិតមកមាត់ព្រៃ។ **ហុកតិច**ជាបងព្រះមហេសីក៏យកព្រៃសូត្រនិងដើមឫស្សី ចងព្រះអង្គព្រះចៅ**ហៀនតេ**និងព្រះអគ្គមហេសីយាងចុះទៅដាក់លើទូកបាន រៀបនឹងច្រានចេញ ពួកនាហ្មឺននិងទាហាននោះមិញ ក៏ដណ្ដើមគ្នាចុះលើទូករៀបនឹងភ្លូកលិចក្នុងជលធី។ **លីង៉ាក់**ដកគ្រប៊ីកាប់នាហ្មឺននិងទាហានស្លាប់ជាច្រើននាក់ ទើបនាំគ្នាចាក់ទូកនោះអណ្ដែតចេញទៅដល់ត្រើយម្ខាង ស្ដេចក៏យាងទៅលើមាត់ច្រាំង ហើយតែងតែទៅមកចម្លងគ្នាជាច្រើនសា មិនទាន់អស់គ្នា ទ័ព**លីឈុយ, គុយគី**លើកមកដល់ មនុស្សដែលនៅសល់មិន

ទាន់បានឆ្លង ក៏ស្រែកហៅគ្នាអឹងកងទៅវិញទៅមក ខ្លះស្រែកយំសោករត់ឆ្កែឆ្កា មុខគួរឱ្យអនិច្ចកម្មស្ដេច និងរាស្ត្រត្រូវនិរាសចាកគ្នាក្នុងវេលានោះ។ **អៀវហាង**ឱ្យស្វែងរករទេះបានមួយ ហើយអញ្ជើញព្រះចៅ**ហៀនតេ** និងព្រះអគ្គមហេសីស្ដេចយាងទៅ។

នាហ្មឺនដប់មួយដប់ពីរនាក់ និងមេចោរពីរនាក់ បាននាំព្រះចៅ**ហៀនតេ**ស្ដេចទៅដល់ស្រុកថៃហៀង ទទួលពេលយប់ក៏បានចូលទៅឈប់សំណាក់ក្នុងរោងក្បឿង តាចាស់ជាម្ចាស់រោងនោះបានយកបាយសម្លមកថ្វាយ ព្រះចៅ**ហៀនតេ**សោយមិនបាន លុះព្រឹកឡើងស្ដេចក៏យាងចាកទីនោះ ទទួលជួបប្រទះនឹង**អៀវពីវ** ដែលជានាហ្មឺនខ្ញុំរាជការជាន់ចាស់ ចូលមកក្រាបសំពះ ហើយយំសោកា អាណិតអានាថព្រះចៅ**ហៀនតេ**ក្សត្រពន់ប្រមាណណាស់។ **ហាន់យ៉ុង**ក្រាបបង្គំទូលថា **លីឈុយ, គុយគី**នោះរមែងជឿស្ដាប់ពាក្យទូលព្រះបង្គំជាខ្ញុំ សូមព្រះអង្គគង់ប្រថាប់នៅទីនេះសិន ទូលព្រះបង្គំជាខ្ញុំនឹងវិលទៅនិយាយឧបាយហាមឃាត់ ឱ្យលើកទ័ពត្រឡប់ទៅវិញឱ្យបាន។ ព្រះចៅ**ហៀនតេ**ទ្រង់ព្រះសណ្ដាប់ ទើបត្រាស់តបថា ដែលអ្នកមានសន្ដានអាណិតដល់យើង ទទួលវិលទៅហាមឃាត់**លីឈុយ, គុយគី**វេលានេះក៏ទៅចុះ ។ **ហាន់យ៉ុង**ក្រាបថ្វាយបង្គំលាចេញទៅ។ **លីង៉ាក់**មិនព្រមស្ដាប់ពាក្យ**ហាន់យ៉ុង** ទើបប្រៀបប្រុងនាំស្ដេចទៅដល់តំបន់អាន់អឹប ជួនពេលយប់ ក៏អញ្ជើញស្ដេចទៅឈប់ក្នុងរោងមួយ ហើយឱ្យមនុស្សទាំងអស់គ្នានោះផ្លាស់វេនគ្នាយាមរក្សា។

ឯ**លីឈុយ, គុយគី**កាលលើកទ័ពមកដល់ស្ទឹងហាងហោ ឃើញពួកស្រីស្នំក្រមការ និងបណ្ដាខ្ញុំរាជការព្រមទាំងពួកខន្ទី ក៏ចាប់ខ្លួនឃុំទុកនៅទីនោះ។ លុះ**ហាន់យ៉ុង**ទៅទាន់បាននិយាយហាមឃាត់**លីឈុយ, គុយគី**ថា ដែលលោកលើក

ព្យុហៈទ័ពជាប់តាមព្រះចៅ**ហៀនតេ**មក ប្រាថ្នានឹងធ្វើឲ្យអន្តរាយដល់ព្រះអង្គនោះមិនគួរទេ បណ្ដារាស្ត្រទាំងពួងនឹងមានសេចក្ដីគរហានិន្ទាបាន លោកចូរលើកសេនាទាហានវិលទៅវិញចុះ បើលោកស្ដាប់ពាក្យខ្ញុំ មនុស្សទាំងពួងនឹងនិយមសរសើរដល់លោកតទៅឯមុខ។ **លីឈុយ, គុយគី**បានស្ដាប់ក៏ចុះចិត្តថាត្រូវ ទើបលើកលែងនាហ្មឺនខ្ញុំរាជការ និងក្រមការស្រីស្នំឲ្យចេញទៅទាំងអស់។ គ្រានោះស្រូវថ្លៃណាស់អាណាប្រជានុរាស្ត្រកើតទុរភិក្សអត់ឃ្លានដាច់ពោះស្លាប់គ្រប់តំបន់។

**តៀវហៀវ**ចៅហ្វាយស្រុកហោឡាយ, **ហងអ៊ឹប**ចៅហ្វាយស្រុកហោតង ដឹងដំណឹងដូច្នោះ ក៏ចាត់ចែងសំពត់អាវសាវស្បៃ និងចំណីអាហារ នាំយកទៅថ្វាយព្រះចៅ**ហៀនតេ** ៗមានព្រះហឫទ័យត្រេកអរណាស់។ ឯ**តាំងស៊ុន** និង**អៀវហង**ប្រឹក្សានឹងបណ្ដាជាខ្ញុំទាំងពួងថា យើងនឹងឲ្យទាហានទៅធ្វើដំណាក់ក្នុងស្រុកឡុកអៀងនឹងបានអញ្ជើញស្ដេចយាងទៅប្រថាប់។ **លីង៉ាក់**ឆ្លើយថា ដែលលោកគិតដូច្នេះខ្ញុំមិនយល់ព្រមផងទេ។ **តាំងស៊ុន**តបថា ស្រុកឡុកអៀងនោះជាទីក្រុងមកពីដើមយូរហើយ គួរនឹងអញ្ជើញព្រះបាទ**ហៀនតេ**ទៅគង់ ដែលអ្នកនឹងឲ្យតាំងក្រុងនៅទីនេះឃើញមិនសប្បាយសោះ។ **លីង៉ាក់**និយាយថា បើលោកនឹងអញ្ជើញស្ដេចទៅគង់ឯក្រុងឡុកអៀងក៏តាមចិត្តចុះ តែខ្លួនខ្ញុំ នឹងសុំតាំងទ័ពបញ្ឈប់នៅតំបន់អាន់អ៊ឹបនេះ។ **តាំងស៊ុន, អៀវហង**ក៏លើកកងទាហាននាំព្រះចៅ**ហៀនតេ**និងព្រះអគ្គមហេសីស្រីស្នំឲ្យឡើងគង់រទេះលើកតម្រង់ទៅស្រុកឡុកអៀង។

ឯ**លីង៉ាក់**ប្រែចិត្តគិតក្បត់ ទើបលបប្រើមនុស្សស្និទ្ធស្នាលឲ្យទៅប្រាប់**លីឈុយ, គុយគី**ថា **តាំងស៊ុន** និង**អៀវហង**នាំយកព្រះចៅ**ហៀនតេ**ទៅស្រុក

ឡុកអៀង ហើយនិងសុំខ្លួនលើកកងទ័ពទៅស្កាត់ចាប់ព្រះចៅ**ហៀនតេ**សម្លាប់ចេញ។ **លីឈុយ, គុយគី**ឮដូច្នោះ ក៏ត្រឡប់ចិត្តគិតត្រេកអរនាំគ្នាទៅធ្វើការជាមួយ។

ខណៈនោះ**តាំងស៊ិន** និង**អៀវហង** បានដឹងកិត្តិស័ព្ទថា**លីង៉ាក់**ប្រែចិត្តក៏នាំពង្រត់ព្រះចៅ**ហៀនតេ**ទៅទាំងយប់ទាំងថ្ងៃគ្មានឈប់ឈរ។ **លីង៉ាក់**ជាមនុស្សលោភា មិនរង់ចាំ**លីឈុយ, គុយគី**ឲ្យព្រមគ្នា ម្នីម្នាលើកទាហានរបស់ខ្លួនស្រូតតាមស្តេចទៅដល់ភ្នំគីសាន់ ជួនពេលយប់ប្រមាណយាមបីប្លាយ ក៏ទាន់ស្តេចនៅទីនោះ។ **លីង៉ាក់**ក៏ស្ទុះចេញទៅស្រែកឃាត់ជាឧបាយកលថា នរណាដែលនាំស្តេចនៅទីនោះឲ្យឈប់ពិគ្រោះនិយាយគ្នាសិន ដ្បិត**លីឈុយ, គុយគី**លើកទ័ពសង្កិនមកពីក្រោយហើយ។ ព្រះចៅ**ហៀនតេ**ទ្រង់ព្រះសណ្តាប់ច្បាស់ក៏ទោមនស្សព្រួយព្រះទ័យស្លុតព្រះកាយា។ **អៀវហង**ក្រាបទូលថា “សំឡេងដែលស្រែកមកនេះចំពោះជាសំឡេង**លីង៉ាក់**ជាចោរអប្បលក្ខក្លែងក្លាយឧបាយ។ សុំឲ្យព្រះអង្គទ្រង់ស្រូតទៅចុះ” ទូលហើយក៏ចាត់ឲ្យ**ស៊ីឡុង**រាថយទៅក្រោយចាំតយុទ្ធគ្នានឹង**លីង៉ាក់**បានបីភ្លែង។ **ស៊ីឡុង**យកពូថៅកាប់ត្រូវ**លីង៉ាក់**ធ្លាក់ពីលើសេះស្លាប់ ដេញកាប់ចាក់សម្លាប់ពួកចោរទាំងនោះវិនាសស្លាប់ជាច្រើន ទើបត្រឡប់តាមស្តេចទៅទៀត រហូតផុតភ្នំគីសាន់។

លុះដល់ព្រឹកឡើង ទទួលជួបប្រទះនឹង**តៀវអៀន**នាំយកស្បៀងអាហារចូលមកថ្វាយ ព្រះចៅ**ហៀនតេ**ក៏ទ្រង់រួសរាយទទួល ហើយត្រាស់ឲ្យឡើងទីជា**តៃស៊ូ** គឺមន្ត្រីធំ។ **តៀវអៀន**ក្រាបបង្គំលាទៅវិញ ព្រះចៅ**ហៀនតេ**ក៏លើកចូលទៅក្នុងស្រុកឡុកអៀង។ ទ្រង់យាងទតឃើញព្រះដំណាក់ពន្លាភាក់ក្នុងព្រះរាជវាំង និងតឹកឃ្លាំងរោងទង ផ្ទះសម្បែងអាណាប្រជានុរាស្ត្រផង សឹងតែភ្លើងឆេះវិនាសខ្ចាត់ខ្ចាយអស់ស្មៅនិងដើមឈើទាំងឡាយក៏ដុះលូតលាស់ទៅជាព្រៃរហោស្ថាន។ ព្រះចៅ**ហៀនតេ**

ទប់ពុំបាន ទ្រង់ព្រះកន្សែងសោកាពិលាប ព្រះអស្សុជលនេត្រហូរជ្រួតជ្រាបសព្វព្រះកាយ ទ្រង់មានព្រះរាជឱង្ការថា ទីនេះជារបស់ព្រះមហាក្សត្រអំពីបុរាណលោកបានកសាងទុក ជាទីបរមសុខរៀងមកយូរហើយ ម្ដេចឡើយមកវិនាសសាបសូន្យដូច្នេះ។

គ្រានោះអស់នាហ្មឺនសព្វមុខមន្ត្រីខ្ញុំរាជការ បានចាត់ឲ្យមនុស្សម្នាកាប់ឆ្ការបោសជម្រះក្នុងទីបរិវេណវាំងចាស់នោះ ហើយឲ្យរៀបសង់ជាប្រាសាទដំណាក់ខាងមុខខាងក្រោយ និងទីព្រះរាជរោងរម្យ សម្រាប់ខ្ញុំរាជការតូចធំចូលក្រាបបង្គំគាល់តាមទំនៀម។ ឯអាណាប្រជានុរាស្ត្រទាំងឡាយ នាំគ្នាខ្វល់ខ្វាយរុះរើផ្ទះសម្បែង ចូលទៅសង់ក្នុងកំពែងក្រុងប្រហែលប្រាំរយខ្នង។

ក្នុងសម័យនោះស្រូវថ្លៃណាស់ អស់បណ្ដារាស្ត្រគ្រប់ស្រុកអត់ឃ្លាន គ្មានស្រូវអង្ករបរិភោគ ដាច់អាហារស្លាប់ច្រើនណាស់ ខ្លះនាំគ្នាទៅជីកឫសស្មៅនូវមើមឈើមកបរិភោគតាងអាហារ បណ្ដានាហ្មឺនតូចធំខ្ញុំរាជការ និងអាណាប្រជានុរាស្ត្រក្នុងស្រុកឡុកអៀង ខ្លះស្វែងទៅជ្រៀតជ្រករកកាច់ខសបេះស្លឹកឈើនៅក្បែរព្រះដំណាក់ចាស់ ខ្លះជីកគាស់ដំឡូងក្ដួចក្រោមរោងតឹកឃ្លាំងដែលភ្លើងឆេះ ធ្នឹមផ្ទោងផ្ដានពុករបេះបាក់ធ្លាក់មកត្រូវមនុស្សស្លាប់ជាច្រើន។

ខណៈនោះ**អៀវពីវ**យកសេចក្ដីក្រាបបង្គំទូលព្រះចៅ**ហៀនតេ**ថា ឡាយព្រះហស្ដរបស់ព្រះអង្គ ដែលទ្រង់ប្រគល់ឲ្យទូលព្រះបង្គំជាខ្ញុំទុកនោះ ក៏មិនទាន់បានយកទៅឲ្យ**ចូឆ្នូ**នៅឡើយ។ ព្រះចៅ**ហៀនតេ**ឮហើយត្រាស់បង្គាប់**អៀវពីវ**ថា "អ្នកចូរនាំយកទៅឲ្យ**ចូឆ្នូ**ចុះ ដើម្បីនឹងបានចូលមកជួយធ្វើរាជការក្រុង" **អៀវពីវ**ចាត់បម្រើឲ្យនាំឡាយព្រះហស្ដនោះទៅឲ្យ**ចូឆ្នូ** ៗឃើញព្រះសុភអក្សរ ក៏សោមនស្ស

ត្រេកអរណាស់ ទើបប្រឹក្សានឹងសេនាទាហានទាំងពួងថា ឥឡូវនេះមានព្រះតម្រាស់ត្រាស់ហៅយើងឲ្យចូលទៅជួយធ្វើការក្នុងក្រុងឡុកអៀងហើយ អ្នកទាំងឡាយនឹងយល់ឃើញដូចម្ដេច?

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ១២ និង ១៣

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**ចូឆូ**នាំពលរេហ៍ចូលទៅក្នុងក្រុងឡុកអៀងតាមព្រះរាជតម្រាស់ តរៀងទៅ ដល់**អ៊ួនសុត**ចៅហ្វាយស្រុកឡាំយ៉ុងលើកទ័ពដប់ម៉ឺន ទៅវាយ**ឡៅពី**ចៅហ្វាយស្រុកឈីជីវ)។*

**ស៊ុនហុក**ឆ្លើយថា រជ្ជកាលព្រះចៅ**ជីវសងអង**បានសោយរាជសម្បត្តិនោះ អាណាខេត្តកើតចលាចលខ្លាំងណាស់ ព្រះចៅ**ជីវសងអង**ទ្រង់ត្រាស់ឲ្យ**ជិនប៊ុនកុង**ទៅជួយធ្វើរាជការផ្ទាល់ព្រះអង្គ បណ្ដានាហ្មឺនក្នុងស្រុកក្រុង ក៏នៅក្រោមបង្គាប់**ជិនប៊ុនកុង**ទាំងអស់ អំណឹះតមក**ជិនប៊ុនកុង**បានសោយរាជសម្បត្តិដោយងាយ។ គ្រានេះព្រះចៅ**ហៀនតេ**ឲ្យហៅលោកចូលទៅជួយធ្វើរាជការ ខ្ញុំយល់ថាជាការប្រពៃណាស់ គួរលោករហ័សចូលទៅតាមព្រះបង្គាប់ បើលោកបង្អស់ឲ្យយឺតយូរទៅទៀត អាណាខេត្តទាំងអស់ណាដែលមានថ្វីដៃ គេនឹងកែខៃចូលទៅបានមុនលោក ការរាជការទាំងប៉ុន្មានក៏នឹងបានជាកម្មសិទ្ធិដល់គេនោះ ឯខ្លួនលោកដែលមានឈ្មោះក៏នៅសោះទទេ ហេតុនេះគួរលោកគ្នេរគិតតាមគំនិតរបស់ខ្ញុំបាទ ចូលទៅឲ្យឆាប់។

**ចូឆូ**បានស្ដាប់ក៏យល់ឃើញត្រូវ ទើបចាត់ឲ្យទៅប្រុងប្រៀបរៀបសេនាទាហានប្រមូលបានសាមសិបម៉ឺនស្រេចហើយ លើកជាក្បួនទ័ពទៅដល់ពាក់កណ្ដាលផ្លូវ ទទួលមានបំរើសេះនាំសេចក្ដីចូលទៅក្រុង ក្រាបបង្គំទូលព្រះចៅ**ហៀនតេ**ថា **លីឈុយ, គុយគី**លើកទ័ពទៅជិតដល់ស្រុកឡុកអៀងហើយ ដោយគិត

បំណងប៉ងនឹងវាយទម្លាយចាប់យកព្រះចៅ**ហៀនតេ**ធ្វើអន្តរាយ។ ព្រះចៅ**ហៀនតេ**ទ្រង់ព្រះតម្រិះថា ទីស្ថាននៅមិនទាន់បានរៀបតាក់តែងធ្វើបន្ទាយ វាយចម្រូងជីកគូកំពែងជាមាំមួន នាហ្មឺននិងបណ្តារាស្ត្រក្នុងក្រុងក៏មានតិចណាស់ ឯបម្រើដែលនាំសំបុត្រទៅហៅ**ចូវឆ្វ**ក៏មិនឃើញត្រឡប់មកវិញ បើដូច្នេះអស់អ្នកទាំងឡាយនឹងយល់ឃើញដូចម្តេច ដ្បិត**លីឈុយ, គុយគី**លើកទ័ពមកជិតហើយ។

**អៀវហង** និង**ហាន់សៀម**យកសេចក្តីក្រាបបង្គំទូលថា ដែល**លីឈុយ, គុយគី**លើកទ័ពមកនោះ សូមកុំឲ្យព្រះអង្គទ្រង់វិតក្កឡើយ ទូលព្រះបង្គំជាខ្ញុំនឹងសូមអាសាចេញទៅច្បាំងរាំងរា ជាទីស្នងព្រះតេជគុណត្រាតែអស់ជីវិត។ **តាំងស៊ិន**ឆ្លើយតបថា ក្នុងស្រុកឡុកអៀងនេះនៅមិនទាន់រៀបចំតាំងបន្ទាយជាមាំមួនសោះ ដែលអ្នកទាំងពីរនឹងរាប់រងធានាលើកសេនាទាហានចេញទៅតតាំងច្បាំងនឹង**លីឈុយ, គុយគី**នោះ យើងយល់ថានឹងបរាជ័យចាញ់គេជាប្រាកដ យើងគិតនឹងអញ្ជើញព្រះចៅ**ហៀនតេ**ស្តេចរត់ចេញពីទីនេះទៅនៅខាងអាណាខេត្តទិសបូព៌ាវិញ ទើបនឹងបានរួចអំពីភ័យ។

ព្រះចៅ**ហៀនតេ**ទ្រង់យល់ឃើញផង **តាំងស៊ិន**និងនាហ្មឺនមន្ត្រីទាំងពួងក៏រៀបអញ្ជើញស្តេច ព្រមទាំងព្រះអគ្គមហេសីស្រីស្នំក្រមការឡើងគង់ព្រះរាជរថចេញចាកក្រុងឡុកអៀង យាងតាមផ្លូវទៅចម្ងាយប្រហែលម្ភៃសិន (៨០០ម) ក៏ក្រឡេកទៅឃើញកងទ័ពតាន់តាប់ លើករន្លាន់ចូលមកពីទិសបូព៌។ សូរទាហានហ៊ោកញ្ជ្រៀវគឹកកងរំពឹងទាំងផែនពសុធា។ ឯព្រះរាជអាជ្ញាដែលកាន់ព្រះតម្រាស់ក៏ជិះសេះចូលមកមុន ដល់មុខព្រះទីនាំងរថហើយ យកសេចក្តីក្រាបបង្គំទូលថា ឥឡូវនេះ**ចូវឆ្វ**លើកសេនាទាហានមកពាក់កណ្តាលផ្លូវហើយ ឮកិត្តិស័ព្ទថា**លីឈុយ, គុយគី**លើកកងទ័ពមកធ្វើអន្តរាយដល់ព្រះអង្គក្នុងក្រុងឡុកអៀង **ចូវឆ្វ**ក៏ប្រើ**ហែហួទុន,**

**ខៅធូ, តៀនអ៊ុយ**លើកទាហានប្រាំម៉ឺនជែកចូលមក ដើម្បីនឹងបានជួយការពាររក្សាព្រះអង្គ។ ព្រះចៅ**ហៀនតេ**ទ្រង់ព្រះសណ្ដាប់ក៏មានព្រះទ័យត្រេកអរពន់ប្រមាណ។ ទទួល**ហែហួទុន, ខៅធូ** និង**តៀនអ៊ុយ**ចូលមកក្រាបថ្វាយបង្គំក្នុងទីនោះ។ មានបម្រើសេះចូលមកក្រាបទូលទៀតថា ឃើញកងទ័ពលើកមកពីទិសបូព៌ាជាក្រោយបណ្ដោយមកទៀតហើយ។ ព្រះចៅ**ហៀនតេ**ត្រាស់ប្រើ**ហែហួទុន**ទៅពិនិត្យមើលឲ្យច្បាស់ ។ **ហែហួទុន**ក៏បរសេះចេញទៅជួប**ចោហុង, លីតៀន, ង៉ាក់ជិន** លើកទាហានមក ក៏នាំនាយទាហានទាំងបីនាក់នេះចូលទៅក្រាបបង្គំគាល់ ហើយទូលថា **ចូឆូ**ប្រើ**ហែហួទុន, ខៅធូ** និង**តៀនអ៊ុយ**លើកទ័ពមកមុននោះ ក្រែងមិនធួនការ បានជាប្រើទូលព្រះបង្គំជាខ្ញុំទាំងបីនាក់ឲ្យលើកទាហានមកជួយថែមទៀត ដើម្បីនឹងចាប់អាសត្រូវសម្លាប់ចេញឲ្យបាន។ ព្រះចៅ**ហៀនតេ**ទ្រង់ព្រះសណ្ដាប់ ក៏ចាប់ព្រះរាជហឫទ័យណាស់ត្រាស់ថា **ចូឆូ**នេះពេញជាមនុស្សមានសតិបញ្ញាឆ្លៀវឆ្លាត ហើយត្រង់សុចរិតពិតល្អដល់យើង គួរនឹងតម្កើងលើកឲ្យធ្វើជាសេនាបតីធំសម្រេចរាជការតទៅ។

ខណៈនោះ មានបម្រើសេះពីទិសបស្ចិមនាំដំណឹងចូលមកក្រាបបង្គំទូលព្រះចៅ**ហៀនតេ**ទៀតថា ទ័ព**លីឈុយ, គុយគី**លើកចូលមកដល់ដែនស្រុកឡុកអៀងហើយ ឥឡូវនេះគ្មានអ្នកណានឹងទប់ទល់សោះ។ ព្រះចៅ**ហៀនតេ**ត្រាស់សួរ**ហែហួទុន**ថា ដែល**លីឈុយ, គុយគី**លើកទ័ពមកដូច្នេះ អ្នកនឹងគិតប្រការម្ដេច? **ហែហួទុន**ក្រាបបង្គំទូលថា “សូមព្រះអង្គទ្រង់កុំព្រួយព្រះហឫទ័យនឹងទ័ព**លីឈុយ, គុយគី**ឡើយ ទុកងារទូលព្រះបង្គំជាខ្ញុំ ហើយនិងសេនាទាំងពួង ជាកងទ័ពមុខ**ចូឆូ**ទទួលយកអាសាទៅជាន់សង្កត់ពួកអាចោរកំណាចទាំងនោះឲ្យរាបដូចផ្ទៃផែនដី”

ថាហើយក៏ក្រាបថ្វាយបង្គំលាចេញទៅចាត់ចែងបែងសេនាទាហាន **ហែហ្សូទុន**ជាកងស្តាំ **ចោហាង**ជាកងឆ្វេង ហើយលើកចេញទៅ លុះទៅដល់ប្រទល់កងទ័ព ក៏បរពលចូលប្រកាប់គ្នាពារទម្លាយដោយកម្លាំងអាវុធ និងសេនាទាហាន។ ពល**លីឈុយ, គុយគី**ទាំងប៉ុន្មានក៏សឹងតែរបួសពិការស្លាប់ត្រៀបត្រានឹងគណនារាប់ពុំបាន។ **លីឈុយ, គុយគី**ទប់ពុំបាន ក៏នាំទាហានដែលសល់នោះស្ទុះរត់រួចទៅ។ **ហែហ្សូទុន** និង**ចោហាង**ក៏លើកកងទ័ពដេញសង្កុញទៅទៀត ឃើញថា**លីឈុយ, គុយគី**រត់ព្រាត់ព្រាយឆ្ងាយទៅ ក៏លើកកងទ័ពត្រឡប់មកវិញ ហើយអញ្ជើញព្រះចៅ**ហៀនតេ**ស្តេចយាងចូលទៅក្នុងក្រុងឡកអៀងដូចដើម រួចចាត់ចែងបំបែកកងទ័ពឲ្យឡោមព័ទ្ធប្រយ័ត្នរក្សាទីក្រុងជុំវិញ។

លំដាប់នោះ **ចូឆូ**លើកកងទ័ពធំមកដល់ ហើយចូលទៅលុតជង្គង់ក្រាបបង្គំគាល់ព្រះចៅ**ហៀនតេ**ដោយគោរព។ ព្រះចៅ**ហៀនតេ**ទតឃើញមុខ**ចូឆូ**ក៏ទ្រង់សោមនស្សស្មោះសរ មានព្រះរាជឱង្ការត្រាស់ថា អ្នកកុំគប្បីលុតជង្គង់ក្រាបបង្គំគាល់យើងដូច្នេះឡើយ ចូរអង្គុយឈរដោយប្រក្រតីចុះ។ **ចូឆូ**ក៏ធ្វើតាមព្រះតម្រាស់ ហើយទូលថា ដែលព្រះអង្គជប់លៀងទទួលទូលព្រះបង្គំជាខ្ញុំមកតាំងពីដើមនោះ ព្រះតេជគុណមិនមានទីបំផុត ទូលព្រះបង្គំជាខ្ញុំតាំងចិត្តគិតនឹងធ្វើរាជការថ្វាយឆ្លងព្រះតេជព្រះគុណ នៅជាដរាបមិនមានភ្លេចសោះ គ្រានេះ **លីឈុយ, គុយគី**មានសេចក្តីប្រទូសរ៉ាយដល់ព្រះអង្គនេះ សូមកុំឲ្យទ្រង់បរិវិតក្កឡើយ ទុកងារទូលព្រះបង្គំជាខ្ញុំនឹងត្រិះរិះរកឧបាយសម្លាប់**លីឈុយ, គុយគី**ចេញឲ្យបាន។ ព្រះចៅ**ហៀនតេ**ទ្រង់មានព្រះរាជហឫទ័យបីតិបាមោជ្ជពន់ប្រមាណ ទើបតាំងឲ្យ**ចូឆូ**ឡើងជា**ទី**

សេនាបតីធំសម្រេចរាជការ តាងព្រះកាណ៏ព្រះនេត្រទូទាំងព្រះរាជអាណាខេត្តក្នុងក្រៅគ្រប់ក្រសួង។

ឯ**លីឈុយ, គុយគី**ដែលបែកទ័ពទៅនោះ ក៏តាំងតែហ្វឹកហាត់សេនាទាហានបានជាច្រើន លុះដឹងថា**ចូឆូ**មកដល់ហើយ ទើបប្រឹក្សាគ្នាថា ឥឡូវនេះទាហាន**ចូឆូ**កំពុងខ្សោយកម្លាំងណាស់ ហេតុនេះគួរយើងប្រញាប់លើកទ័ពទៅខ្ទប់វាយកុំឱ្យដឹងខ្លួន ក៏នឹងបែកដោយងាយ។ **កាសៀង**ឆ្លើយថា លោកគិតដូច្នោះមិនស្រួលទេ ព្រោះ**ចូឆូ**នោះមានសេនាឯក និងទាហានច្រើនណាស់លើសនឹងគណនា។ ឯសេនាទាហានខាងយើងស្ដើងស្ដួចពេក បើទុកជានឹងលើកទៅប្រឹងវាយបំបែកដូចម្ដេចក៏ពុំបាន ឧបមាដូចសត្វតិរច្ឆានតូចៗ ទៅទទូចប្រយុទ្ធនឹងខ្លា គំនិតខ្ញុំយល់ថា ត្រូវឱ្យលោកចាត់បម្រើចូលទៅសុំទោស**ចូឆូ**វិញស្រួលជាង ហើយសុំផ្ញើរូបរាងជ្រកកោន ឱ្យបាន**ចូឆូ**មានមេត្តាដល់លោកទាំងពីរ។ **លីឈុយ, គុយគី**បានស្ដាប់ពាក្យ**កាសៀង**ដូច្នោះ ក៏ពុះពោរឃោរខឹងនឹង**កាសៀង**ណាស់ យកដៃទះតប់តុហើយថា “យើងកំពុងគិតធ្វើសង្គ្រាមនឹង**ចូឆូ**ជាមាំមួន ហេតុម្ដេចខ្លួនហ៊ានមកនិយាយបន្ទាបបន្ថោកយើងដូច្នេះ ដែលខ្លួននិយាយយ៉ាងនេះ នឹងចង់ឱ្យសេនាទាហានយើងរួញរាឬ?” ថាហើយក៏កន្ត្រាក់គ្រប៊ីឡើងកាន់ គិតនឹងស្ទុះទៅកាប់សម្លាប់**កាសៀង**ក្នុងខណៈនោះ។ បណ្ដាទាហានក៏ស្ទុះទៅរាំងប្រឹងជួយសុំទោសបាន។ **កាសៀង**ទោមនស្សតូចចិត្តពេកណាស់ លុះវេលាយប់ក៏ឡើងសេះជិះរត់ទៅនៅស្រុកទេសរបស់ខ្លួន។ លុះព្រឹកឡើង**លីឈុយ, គុយគី**ក៏ភ្ជុំពលយោធាជាក្បួនទ័ព បង្គាប់ប្រើ**លីសៀម** និង**លីប៉េក**ជានាយទ័ពស្រួចលើកទៅច្បាំងនឹង**ចូឆូ**។

ខណៈនោះ**ចូឆ្វ**ចាត់ប្រើ**ខៅធូ, តៀនអ៊ុយ, ចោយិន**ឲ្យលើកទាហានសេះបីរយឲ្យចេញទៅតយុទ្ធនឹងកងទ័ព**លីឈុយ, គុយគី** តាំងតែចាក់កាប់សម្លាប់កងទ័ពនោះស្លាប់វិនាសជាច្រើន។ ឯ**លីសៀម** និង**លីប៉េក**ជាសេនាក៏ចេញមកតនឹង**ខៅធូ** មិនទាន់បានមួយភ្លែង **ខៅធូ**ក៏ចាក់នឹងលំពែងត្រូវ**លីសៀម**ធ្លាក់ពីលើសេះស្លាប់។ ឯ**លីប៉េក**នោះ គ្រាន់តែក្រឡេកឃើញ**ខៅធូ**ភ្លាម ក៏តក់ស្លុតភ្ញាក់ធ្លាក់ពីលើសេះខ្លោក**ខៅធូ**ស្ទុះមកចាក់នឹងទួនស្លាប់ទៅទៀត ហើយកាត់យកក្បាល**លីសៀម** និង**លីប៉េក**នាំទៅឲ្យ**ចូឆ្វ** ៗមានសេចក្ដីត្រេកអរណាស់ យកដៃអង្អែលខ្នង**ខៅធូ** ហើយសរសើរថា មានថ្វីដៃខ្លាំងពូកែសមគួរជាសេនាឯក។

**ចូឆ្វ**ក៏ប្រើ**ហែហួទុន**ជាមេកងទ័ពស្រួច **ចោយិន**ជាមេកងទ័ពប៉េកខាងស្ដាំ ខ្លួន**ចូឆ្វ**ឯងជាមេទ័ពហ្លួង លើកជាស្លាបក្អែកដែកចូលទៅច្បាំងនឹងកងទ័ព**លីឈុយ, គុយគី** សម្លាប់រេហ៍ពល**លីឈុយ, គុយគី**ស្លាប់ច្រើនណាស់។ **លីឈុយ, គុយគី**ក៏បែកទ័ពរត់ទៅ។ **ចូឆ្វ**បរពលទាំងក្នុងក្រៅដេញតាមទៅទៀត រើសបានគ្រឿងសាស្ត្រាវុធជាច្រើនណាស់ នៅតែ**លីឈុយ** និង**គុយគី**តែពីរនាក់ នាំគ្នារត់ទៅជ្រកពួននៅក្នុងកៀនភ្នំមួយ។ **ចូឆ្វ**ក៏លើកទ័ពថយត្រឡប់មកវិញ។

ឯ**អៀវហង**ដឹងថា**ចូឆ្វ**វាយទម្លាយទ័ព**លីឈុយ, គុយគី**បែកហើយ ក៏ប្រឹក្សានឹង**ហាន់សៀម**ថា **ចូឆ្វ**ធ្វើសង្គ្រាមគ្រានេះធំពន្លឹកពេកណាស់ យូរទៅរាជការទាំងអស់ក្នុងស្រុកក្រុងនឹងនៅក្នុងកណ្ដាប់ដៃ**ចូឆ្វ**តែម្ដង យើងទាំងពីរក៏នឹងនៅក្រោមអំណាច**ចូឆ្វ** បើដូច្នេះយើងត្រូវតែគិតកលឧបាយលើកស្ម័គ្របក្សពួករបស់យើងទាំងឡាយ ទៅចាប់**លីឈុយ, គុយគី**សម្លាប់ចោល ហើយរត់យកខ្លួនទៅជ្រកពួនឯស្រុកតែលៀងវិញ។ **ហាន់សៀម**ឃើញត្រូវផង ទើបនាំគ្នាចូលទៅក្រាបទូល

ព្រះចៅ**ហៀនតេ**ទូលថា ដែល**ចូឆូ**លើកទ័ពទៅសម្លាប់អេហ៍ពល**លីឈុយ**, **គុយគី**ខ្ចាត់ខ្ចាយទៅហើយនោះ ទូលព្រះបង្គំជាខ្ញុំសូមចេញយកអាសាលើកគ្នាតាមទៅទៀត បើជួបប្រទះនឹង**លីឈុយ**, **គុយគី**នៅទីណា នឹងចាប់ខ្លួនវាសម្លាប់ចេញឲ្យបាន។ ព្រះចៅ**ហៀនតេ**ក៏ទ្រង់យល់ព្រម **អៀវហង** និង**ហាន់សៀម**ក៏ក្រាបបង្គំលាម្ទីម្នារៀបប្រមូលស្ម័គ្របក្សពួក លើកចេញពីទីក្រុងឡុកអៀងទៅ។

ព្រះចៅ**ហៀនតេ**ទ្រង់ត្រាស់ប្រើ**តាំងជៀវ**ឲ្យទៅហៅ**ចូឆូ** ឲ្យចូលមកប្រារព្ធកិច្ចរាជការ **តាំងជៀវ**ក៏ម្ទីម្នាយាត្រាចេញទៅ លុះទៅជួបនឹង**ចូឆូ**ៗ ក៏សម្លឹងមើលលក្ខណៈរូបរាង ឃើញថា**តាំងជៀវ**វែវាងទាំងឫកពារកិរិយាពណ៌សម្បុរក៏ជ្រះថ្លាស្អាងស្អាត ដួងនេត្រាក៏មូលធំ ចិញ្ចើមផុតកន្ទុយភ្នែក **ចូឆូ**ឃើញប្លែកក៏សួរថា ក្នុងទីក្រុងនេះខ្សត់អត់ស្បៀងអាហារ អស់បណ្ដាជនក៏មានតែសេចក្ដីទុរភិក្សអត់ឃ្លានណាស់ ហេតុម្ដេចអ្នកឯងចេះតាក់តែងរក្សារូបកាយឲ្យមានសាច់ឈាមលោមពណ៌ល្អសម្បុរស្អាតបាតបាន? **តាំងជៀវ**ឆ្លើយថា ខ្លួនខ្ញុំបាទនឹងបានបម្រុងថែរក្សាដោយប្រការម្ដេចក៏ឥតអង្គីមាន ខ្ញុំបាទទទួលទានតែអាហារដរាបមកដល់អាយុសាមសិបឆ្នាំហើយ។ **ចូឆូ**ស្ដាប់ហើយក៏អស់សំណើចហើយសួរថា អ្នកឯងជានាហ្មឺនតំណែងអ្វី? **តាំងជៀវ**ឆ្លើយថា ខ្ញុំបាទជាពួកអ្នកស្រុកតេងតោ ជាទីប្រឹក្សា**អួនសៀវ** លុះឮដំណឹងថា ព្រះចៅ**ហៀនតេ**យាងត្រឡប់មកប្រថាប់នៅក្នុងឡុកអៀងវិញ ក៏ចូលមកថ្វាយខ្លួនជាខ្ញុំរាជការ សព្វថ្ងៃទ្រង់ព្រះមេត្តាប្រោសព្រះរាជទានជាទី "**ជៀងឃីឡុង**" ប្រែថា "ទីប្រឹក្សាផ្ទាល់ព្រះអង្គ"។ **ចូឆូ**តបថា "យើងបានឮកេរ្តិ៍ឈ្មោះអ្នកឯងមកយូរហើយ តែមិនដែលឃើញខ្លួនសោះ វេលានេះយើងបានមកជួបប្រទះក៏ជាបុណ្យភព្វល្អណាស់របស់យើង" ថាហើយក៏រៀបលៀងអាហារហើយឲ្យហៅ**ស៊ុនហុក**មក

បរិភោគជាមួយ ដើម្បីនឹងបង្ហាញឲ្យស្គាល់រាប់អានគ្នា។ **ចូឆ្វ** និង**តាំងជៀវ**, **ស៊ុនហុក**បរិភោគតុរួមគ្នា។

មានបម្រើសេះចូលមកជម្រាប**ចូឆ្វ**ថា ឃើញទាហានមួយកងលើកចេញមកអំពីក្រុងឡុកអៀងចេញទៅទិសបូព៌ តែមិនច្បាស់ជានរណានាយទ័ពនោះ។ **ចូឆ្វ**ក៏ចាត់បម្រើសេះឲ្យតាមទៅស៊ើបចង់ដឹង **តាំងជៀវ**ក៏ប្តឹងជម្រាបថា កុំឲ្យលោកប្រើទៅធ្វើអ្វី នាយកងដែលលើកទាហានទៅនោះពីរនាក់ មួយឈ្មោះ**អៀវហាង**ជាបក្សពួក**លីឈុយ** មួយឈ្មោះ**ហាន់សៀម**ជានាយចោរ បានចូលមកថ្វាយខ្លួនជាខ្ញុំរាជការផ្ទាល់គាល់ព្រះចៅ**ហៀនតេ** ស្តេចទើបយាងចេញពីក្រុងតៀវហាន់។ ឥឡូវនេះឃើញលោកចូលមកធ្វើរាជការក្នុងស្រុកក្រុងនេះ ឈ្មោះទាំងពីរភ័យបារម្ភខ្លាចលោក បានជានាំស្ម័គ្របក្សពួកលើកទៅជ្រកពួននៅស្រុកតោលៀង។ **ចូឆ្វ**សួរថា ដែលឈ្មោះទាំងពីរនាក់ខ្លាចយើង ហើយរត់ទៅនោះព្រោះហេតុអ្វី? **តាំងជៀវ**ឆ្លើយថា វាដឹងថាតម្រិះប្រាជ្ញារបស់លោកលើសហួសប្រាជ្ញាគំនិតរបស់វា បានវាខ្លាច។ **ចូឆ្វ**តបថា ដែលឈ្មោះទាំងពីរលបរត់ចេញទៅនេះ មុខជាមានសេចក្តីគិតធ្វើការផ្សេងៗជាប្រទូសរ៉ាយដល់យើងហើយ។ **តាំងជៀវ**ឆ្លើយថា អាទាំងពីរនេះឧបមាដូចខ្លាគ្មានចង្កូម ឬក៏ដូចសត្វឥតស្លាបហើរ បើវានឹងទៅគិតគំនិតយ៉ាងណា សូមកុំឲ្យលោកមានសញ្ញាជាវិតក្កឡើយ ខ្ញុំបាទយល់ថា យូរទៅឯមុខគង់នឹងចាប់ខ្លួនវាបានដោយងាយ។

**ចូឆ្វ**ស្តាប់ហើយក៏គិតថា **តាំងជៀវ**នេះចរចាមុតមាំណាស់ ទើបប្រឹក្សានឹង**តាំងជៀវ**ថា ស្រុកឡុកអៀងនេះកើតអន្តរាយដោយភ្លើងឆេះវិនាសច្រើនណាស់ យើងនឹងត្រូវគិតប្រការម្តេច? **តាំងជៀវ**ឆ្លើយថា លោកលើកទាហានមកកម្ចាត់

**លីឈុយ, គុយគី**គ្រានេះ បីដូចលោកមានតម្រិះនឹងជួយព្រះចៅ**ហៀនតេ** នូវប្រជាជនឱ្យបានសេចក្តីសុខក្សេមក្សាន្ត គំនិតរបស់លោកនឹងជួយឧបត្ថម្ភផែនដី ហើយគុណបំណាច់ក៏គង់នឹងមានដល់លោកជាយ៉ាងថ្លៃថ្លាប្រពៃណាស់ តែថាទីនេះ បើលោកនឹងតុបតែងកកំពែងលើកសើនជីកគូជាស្នាមភ្លោះ ឬនឹងធ្វើបន្ទាយឱ្យទូលាយធំខ្ពស់ក៏ពុំបាន ព្រោះអ្នកស្រុកក្រខ្សត់អត់ស្បៀងអាហារ បណ្តានាហ្មឺនខ្ញុំរាជការក៏នៅតាំងខ្លួនមិនមួនមាំ បើមានសឹកសង្គ្រាមលើកមកញាំញី ក៏គង់នឹងលំបាកដល់អាណាប្រជានុរាស្ត្រ និងខ្លួនលោកជាប្រាកដ។ ខ្ញុំបាទយល់ឃើញថាស្រុកហ្វ៊ូតោជាទីធំទូលាយ សប្បាយដោយមនុស្សម្នាមហាជនច្រើនណាស់ ទាំងស្បៀងអាហារក៏មិនខ្វះខាតបរិបូរជាងខេត្តខណ្ឌដទៃ ប្រសិនបើលោកនឹងយកជាទីសមរភូមិជ័យនៃដែនខេត្តនោះ ចំពោះជាស្រួលណាស់ ហាក់បីដូចជាលោកចេះក្លែងផ្លាស់និមិត្តទីថ្វាយព្រះចៅ**ហៀនតេ** ដោយបុញ្ញឫទ្ធិរបស់លោក សូម្បីព្រះហឫទ័យព្រះចៅ**ហៀនតេ** និងនាហ្មឺនសព្វមុខមន្ត្រីទាំងក្នុងក្រុង និងខេត្តក្រៅ ក៏មាននូវពាក្យសរសើរតម្រិះប្រាជ្ញាលោកទូទៅ ទាំងបណ្តារាស្ត្រក៏មិនមានសេចក្តីក្តៅក្រហាយ។ ខ្ញុំបាទអធិប្បាយតាមសេចក្តីយល់ដូច្នេះ ស្រេចហើយតែលោកត្រិះរិះមើលតាមអធ្យាស្រ័យដោយគួរចុះ។

**ចូឆូ**បានស្តាប់ដូច្នោះក៏មានសេចក្តីត្រេកអរពន់ប្រមាណ ក្រោកឡើងចាប់ដៃ**តាំងជៀវ** ហើយនិយាយថា ដែលអ្នកពណ៌នាមកដូច្នេះត្រូវនឹងគំនិតយើងគិតណាស់ តែថាបើយើងនឹងអញ្ជើញព្រះចៅ**ហៀនតេ**ស្តេចយាងទៅកាលណា ក្រែង**អៀវហង**និង**ហាន់សៀវ** លើកគ្នាមកធ្វើអន្តរាយកណ្តាលផ្លូវទេដឹង? ប្រការមួយបណ្តានាហ្មឺនមុខមន្ត្រីតូចធំក្នុងក្រុងនេះ ក៏មិនទាន់ដឹងនិងយល់ព្រមដូចយើងដែរឬទេ? **តាំងជៀវ**

ឆ្លើយថា សព្វថ្ងៃនេះ បណ្ដានាហ្មឺនមុខមន្ត្រីនិងបណ្ដារាស្ត្រទាំងស្រីប្រុសក្នុងទីក្រុង ក៏ក្រខ្សត់អត់ឃ្លានដាច់ស្បៀងអាហារច្រើនណាស់ សូមឲ្យលោកប្រកាសឲ្យដឹងគ្រប់គ្នាថា ឥឡូវនេះអ្នកស្រុកឡុកអៀងក្រខ្សត់អត់ឃ្លានដាច់ស្បៀងអាហារណាស់ លោកនឹងអញ្ជើញព្រះចៅ**ហៀនតេ**ស្ដេចទៅគង់ស្រុកហ្វ៊ូគោ នៅជិតគ្នានឹងស្រុកឡៅអៀង ស្រុកនោះបរិបូរសប្បាយដោយស្បៀងអាហារចំណីត្រីសាច់មិនមានខ្វះខាតសោះ។ បើអស់នាហ្មឺននិងបណ្ដារាស្ត្របានឮដឹងហើយ ក៏គង់នឹងមានសេចក្ដីត្រេកអរសាទរតាមលោក ម្យ៉ាងទៀត**អៀវហង** និង**ហាន់សៀម** ដែលរត់ទៅនៅស្រុកតៃលៀងនោះ ក៏សុំឲ្យលោកមានសំបុត្រទៅបញ្ចុះបញ្ចូលល្បួងលោមយកចិត្ត គង់នឹងមិនគិតប្រទូសរ៉ាយនឹងលោកតទៅ។

**ចូឆូ**បានស្ដាប់ក៏មានសេចក្ដីត្រេកអរណាស់ ហើយនិយាយថា ចាប់តាំងពីថ្ងៃនេះតទៅ បើយើងមានកិច្ចការអ្វី នឹងសូមអញ្ជើញអ្នកឲ្យមកជួយពិគ្រោះប្រឹក្សាផង។ **តាំងជៀវ**ទទួលពាក្យ**ចូឆូ**ហើយក៏លាចេញទៅ។ ក្រោយពីពេលនោះមក **ចូឆូ** បានប្រឹក្សាការនឹងសេនាទាហានឯទៀត អំពីរឿងដែលត្រូវអញ្ជើញព្រះចៅ**ហៀនតេ** ទៅគង់នៅស្រុកហ្វ៊ូគោ តែការរឿងនោះមិនបានយល់ព្រមគ្នាសោះ។

ឯ**អងលិប** និង**ឡៅង៉ាយ** ជាពូជព្រះរាជវង្សនឹងព្រះចៅ**ហៀនតេ** បានប្រឹក្សាគ្នា **អងលិប**ថាខ្ញុំបានឃើញផ្កាយ**ថៃប៉េក** គឺផ្កាយសនោះភ្លឺថ្លាតែរដូវវស្សា តែថាដល់រដូវប្រាំងកាលណា ក៏ដើរឆ្លងមកត្រឡប់រស្មីអន់អាប់អស់ទៅ។ ខ្ញុំពិចារណាតាមក្បួនខ្នាតទៅឃើញថា ព្រះចៅ**ហៀនតេ**នឹងចុះរាសីសាបសូន្យគ្រានេះ ហើយនឹងមានអ្នកដទៃមកសោយរាជសម្បត្តិជាព្រះមហាក្សត្រវិញ។ **អងលិប**ក៏នាំយកសេចក្ដី

នោះលបចូលទៅក្រាបទូលព្រះចៅ**ហៀនតេ**ៗ ទ្រង់ព្រះសណ្ដាប់ ហើយមិនមានត្រាសថាប្រការម្ដេច។

**ចូឆ្វ**បានឮកិត្តិស័ព្ទដែល**អងលិប**និង**ឡៅង៉ាយ**និយាយគ្នានោះ លុះពេលយប់ក៏ប្រើមនុស្សជំនិតឲ្យទៅនិយាយនឹង**អងលិប**ថា បើខ្លួនអ្នកមានចិត្តសុចរិតនឹងផែនដី ហើយទោះបានដឹងឃើញហេតុភេទស្រុកទេសប្រការម្ដេច ក៏កុំអាលនិយាយឲ្យបែកខ្ចាយផ្សាយសេចក្ដីជាមុន ព្រោះការនេះជ្រៅធំពន្លឹកណាស់។ មនុស្សបម្រើក៏ទៅនិយាយនឹង**អងលិប**តាមពាក្យ**ចូឆ្វ**បង្គាប់នោះគ្រប់ប្រការ។ **អងលិប**ក៏មិនបានថាប្រការម្ដេច **ចូឆ្វ**ក៏ឲ្យហៅ**ស៊ុនហុក**មកនិយាយទៀត តាមដំណើរដែល**អងលិប**និយាយគ្នានោះ។ **ស៊ុនហុក**ឆ្លើយថា ព្រះចៅ**ហៀនតេ**កំណើតជាធាតុភ្លើង ខ្លួនលោកជាធាតុដី បើលោកនឹងគិតធ្វើការអ្វី ក៏ត្រូវប្រឹងគិតឲ្យជ្រៅទូលាយជាឆាប់ ដូចរឿងដែលលោកគិតទៅនៅស្រុកហ៊ូតោនេះ ត្រូវទៅជាប្រញាប់កុំបង្អង់ លោកក៏គង់នឹងសម្រេចដូចពាក្យ**អងលិប**ថាជាប្រាកដណាស់។

**ចូឆ្វ**បានស្ដាប់ដូច្នោះក៏មានសេចក្ដីត្រេកអរពន់ប្រមាណ លុះពេលព្រឹកក៏ចូលទៅក្រាបបង្គំគាល់ព្រះចៅ**ហៀនតេ**ហើយទូលថា ស្រុកឡុកអៀងនេះ មានសេចក្ដីអន្តរាយវិនាសសាបសូន្យតាំងពីគ្រា**តាំងតុះ**ម្ដងហើយ ឥឡូវនេះព្រះអង្គទ្រង់យាងមកប្រថាប់វិញ ថែមទាំងទុរភិក្សអត់ឃ្លានផង មានតែសេចក្ដីលំបាកគ្រប់គ្នា បើនឹងតាក់តែងជាវាំងកំពែងឡើងវិញកាលណា ក៏មានតែសេចក្ដីវេទនាដល់អាណាប្រជានុរាស្ត្រខ្លាំងណាស់ ឯស្រុកហ៊ូតោនេះប្រកបដោយសើនបន្ទាយទូលាយធំមាំមួន អាណាប្រជានុរាស្ត្រសឹងតែមានទ្រព្យសម្បត្តិជាធនធាន មានទាំងស្រូវអង្ករ ចំណីត្រីសាច់បរិបូរព្រម ហើយជិតនឹងស្រុកឡៅអៀងផង ប្រសិនបើមានសឹកសង្គ្រាម

វេលាណាក៏នឹងបានលើកជួយគ្នាដោយស្រួលរហ័ស។ ទូលព្រះបង្គំខ្ញុំស្គាល់ច្បាស់មកយូរហើយ សូមអញ្ជើញព្រះអង្គយាងទៅគង់នៅក្នុងស្រុកនោះចុះ នឹងបានសេចក្ដីសុខសប្បាយក្នុងព្រះកាយពល ព្រមទាំងនាម៉ឺនមន្ត្រី និងអាណាប្រជានុរាស្ត្រទាំងពួងនឹងបានសេចក្ដីសុខក្សេមក្សាន្ត។

ព្រះចៅ**ហៀនតេ**ទ្រង់ព្រះសម្ដាប់ហើយត្រាស់ថា បើអ្នកនឹងគិតការពារខ្លួនយើងដោយប្រការម្ដេច នោះស្រេចនៅលើគំនិតរបស់អ្នកចុះ យើងមិនយល់ទាស់ទេ។ ឯនាហ្មឺនតូចធំដែលជួបជុំបង្គំគាល់នៅទីនោះ លុះបានឮ**ចូឆ្វ**ទូលដូច្នោះ សឹងខ្លាចអំណាច**ចូឆ្វ**គ្រប់គ្នា មិនមាននរណានឹងឆ្លើយទាស់ថាដូចម្ដេចឡើយ។

ក្នុងសម័យនោះ **ចូឆ្វ**ក៏បង្គំឱ្យមនុស្សម្នាមហាជនប្រុសស្រីរៀបជញ្ជូនរបស់ទ្រព្យផ្ទុករទេះគោក្របី ហើយនិងផ្ទុកសេនាទាហានមានសេះដំរីត្រៀបត្រា រៀបទាំងព្រះរាជរថរួចស្រេច ក៏អញ្ជើញស្ដេចព្រះចៅ**ហៀនតេ** និងអគ្គមហេសីស្រីស្នំឡើងគង់ព្រះរាជរថ ខ្ញុំរាជការនិងសេនាទាហានក៏ហែហមអមចេញទៅ។ **ចូឆ្វ**ជាទ័ពលើកនាំស្ដេចចេញចាកព្រះរាជវាំងក្រុងឡុកអៀង ទៅចម្ងាយផ្លូវប្រមាណហាសិបសិន (២ គ.ម) ដល់ជើងភ្នំមួយក៏ជួបប្រទះនឹង**អៀវហង, ហាន់សៀម**លើកទាហានស្រែកហ៊ោស្កាត់ពីមុខ។ **ចូឆ្វ**ឃើញដូច្នោះក៏បរសេះស្ទុះទៅមុខទាហាន**ស៊ីឡុង**ស្រែកឱ្យ**ចូឆ្វ**ថា អ្នកនាំព្រះចៅ**ហៀនតេ**ស្ដេចទៅទីឯណា? **ចូឆ្វ**មិនឆ្លើយតបប្រើ**ខៅធូ**សេនាឯកចេញទៅតយុទ្ធនឹង**ស៊ីឡុង**បានដប់ប្រាំភ្លែងមិនចាញ់ឈ្នះ **ចូឆ្វ**ឱ្យវាយឃ្មោះថយត្រឡប់ក្រោយវិញ **ស៊ីឡុង**ក៏រាថយទៅចូលក្នុងបន្ទាយ។ **ចូឆ្វ**ប្រឹក្សានឹងសេនាទាហានទាំងពួងថា **អៀវហង** និង**ហាន់សៀម**នោះ យើងត្រូវគិតសម្លាប់

ចេញចុះ តែ**ស៊ីឡុង**នោះមានកម្លាំងខ្លាំងពូកែ យើងចង់បានទុកធ្វើជាសេនាឯក បើដូច្នោះត្រូវគិតឧបាយកលល្បួងលោមយកឲ្យបាន។

**ម៉ាន់ថង**ឆ្លើយថា បើលោកចង់បានខ្លួន**ស៊ីឡុង**នោះមិនក្រប៉ុន្មានទេ ខ្ញុំបាទនិង**ស៊ីឡុង**ជាមនុស្សធ្លាប់រាប់អានស្រឡាញ់គ្នាមកពីដើម យប់នេះខ្ញុំបាទនឹងសូមយកអាសាចេញទៅនិយាយល្បួងលោមយកខ្លួន**ស៊ីឡុង**ឲ្យបាន។ **ចូឆូ**បានស្ដាប់ក៏មានចិត្តត្រេកអរណាស់ ហើយថា អ្នកចូរទៅគិតគួរធ្វើការតាមតម្រិះប្រាជ្ញាចុះ។ លុះវេលាយប់ **ម៉ាន់ថង**ក៏តែងខ្លួនជាទាហានឡេវ បន្លំចូលទៅក្នុងបន្ទាយ**អៀវហង** ឃើញ**ស៊ីឡុង**ពាក់ក្រឹសអុជទានអង្គុយមើលសំបុត្រ។ **ម៉ាន់ថង**ក៏ចូលទៅគំនាប់ ហើយជម្រាបថា តាំងពីយើងបែកចាកគ្នាមកយូរហើយ អ្នកបានសេចក្ដីសុខសប្បាយទេឬ? **ស៊ីឡុង**បានឮសម្ដីក៏ងើបមុខឡើងមើលឃើញទាហានប្លែកមុខក៏តក់ស្លុតស្មារតី លុះប្រឹងសម្លឹងមើលច្បាស់ក៏ស្គាល់បាន ទើបសួរថា អ្នកនេះឈ្មោះ**ម៉ាន់ថង**នៅស្រុកសាន់យ៉ុងឬ? មានការអ្វីមករកយើងថ្មើរនេះ? **ម៉ាន់ថង**តបថា ខ្ញុំបាទចូលធ្វើខ្ញុំរាជការនៅនឹង**ចូឆូ** កាលពីថ្ងៃមុនខ្ញុំបាទឃើញអ្នកចេញទៅប្រយុទ្ធគ្នានឹង**ខៅធូ** ខ្ញុំមិនបានសាកសួរអ្នកក្នុងវេលានោះ ព្រោះចាំចិត្តគិតថាយប់នេះនឹងវេះចូលមករក ដែលខ្ញុំចូលមកនេះមិនមែនថាមិនខ្លាចសេចក្ដីស្លាប់ទេ ទើបបន្លំចូលមកចរចានឹងអ្នកឲ្យបាន។ **ស៊ីឡុង**ស្ដាប់ហើយក៏អញ្ជើញឲ្យ**ម៉ាន់ថង**អង្គុយក្នុងទីសមគួរ ហើយថា អ្នកមានការមករកខ្ញុំនោះដោយកិច្ចធុរៈអ្វីនិយាយទៅចុះ។

**ម៉ាន់ថង**ឆ្លើយថា ខ្លួនអ្នកជាមនុស្សមានកម្លាំងខ្លាំងពូកែគ្មាននរណាស្មើសោះ ចុះវាទាស់អ្វី បានជាមកនៅក្នុងកណ្ដាប់ដៃ**អៀវហង, ហាន់សៀម**ដូច្នេះ? មនុស្សធម្មតាក្នុងសម័យនេះ ខ្ញុំយល់ថា **ចូឆូ**ជាអ្នកមានអធ្យាស្រ័យល្អ ប្រកបទាំងស្មារតី

ប្រាជ្ញាក្លាហាន មានចិត្តធូរទូលាយរួសរាយរាប់អានសេនាទាហានមិនឲ្យអនាទរសោះ កិត្តិស័ព្ទនោះអ្នកគង់នឹងឮមកហើយ កាលអ្នកចេញទៅតយុទ្ធនឹង**ខៅធូ**នោះ **ចូឆូ**ឃើញអ្នកក៏មានចិត្តអាណិតពន់ប្រមាណ មិនបានបើកឲ្យទាហានបាញ់ធ្នូថែមទៅក្រែងត្រូវអ្នកមានរបួសពិការ ទើបប្រើខ្ញុំមកចរចាអញ្ជើញអ្នកទៅឲ្យបាន ដើម្បីនឹងរាប់អានសួរសន្ទនាពន្យល់ពីផ្លូវត្រូវនិងខុស ខ្ញុំក៏ពិគ្រោះឃើញថា អ្នកនៅក្នុងទីងងឹត ចូរប្រឹងរិះគិតទៅរកទីភ្លឺស្រឡះទើបដឹងសេចក្ដីសុខជាក់ច្បាស់តទៅ ដែលខ្ញុំនាំសេចក្ដីដ៏ជ្រៅឆ្ងាយទូលាយមកនិយាយនឹងអ្នកដូច្នេះ ក៏ព្រោះចិត្តស្រឡាញ់រាប់អានអ្នកត្រូវតែគិតប្រមាណឲ្យសមនឹងអធ្យាស្រ័យចុះ។

**ស៊ីឡុង**បានស្ដាប់ក៏ស្ងប់ស្ងៀមមួយស្របក់ ហើយដកដង្ហើមធំរួចឆ្លើយថា ខ្ញុំដែលមកផ្ញើខ្លួននៅនឹង**អៀវហង, ហាន់សៀម**ជាមនុស្សមានសតិបញ្ញាតិចនេះ នឹងគិតការអ្វីមិនសម្រេចទៅបាន តែចាំចិត្តព្រោះគិតឃើញថា បានជានៅនឹងគ្នាមកយូរហើយ បើនឹងដើរចោលសោះក៏មិនគួរ។

**ម៉ាន់ថង**តបថា អ្នកមិនឮទេឬ? ពាក្យបុរាណថាទុកមក "បើសត្វនឹងធ្វើសម្បុកជ្រកនៅ ក៏ត្រូវអាស្រ័យរកព្រៃស្ដុក ទើបធ្វើសម្បុកនៅជាសុខបាន ទោះមានខ្យល់ព្យុះបក់បោកមកប៉ុន្មាន សម្បុកនោះក៏មិនជ្រុះធ្លាក់អន្តរាយ" ប្រការមួយទៀតធម្មតាជាតិទាហានហើយ ត្រូវស្វែងរកនាយថៅហ្វាយដែលជាមេទ័ពប្រកបដោយចិត្តធូរទូលាយ រួសរាយរាប់អានពួកក្រុមធំតូចមិនរើសមុខ ហើយចេះឧបត្ថម្ភទំនុកបម្រុងអ្នកនឿយហត់ និងចេះចាំស្ទាត់ក្បួនពិជ័យសង្គ្រាម សូម្បីសត្រូវនឹងលើកមកប៉ងប្រមាថតិចច្រើនយ៉ាងណា ក៏មិនរួញរាញញញើតកោតខ្លាច មានអំណាចនឹងការពាររក្សាទាហានមិនឲ្យអន្តរាយ បើអ្នកឯណាជួបនឹងនាយថៅហ្វាយដ៏វិសេស

ដូច្នេះហើយ មិនចូលទៅធ្វើខ្លួនផងទេ គឺជាមនុស្សគិតខុស អំណើះតទៅមុខនឹងបានជួបតែទុក្ខ ពុំបានសុខក្សេមក្សាន្តឡើយ។

**ស៊ីឡុង**បានស្តាប់សព្វគ្រប់ហើយ ក្រោកលុតជង្គង់គំនាប់**ម៉ាន់ថង** ហើយថា អ្នកមានប្រសាសន៍ទាំងនេះខ្ញុំពេញចិត្តណាស់ បើដូច្នេះខ្ញុំនឹងទទួលធ្វើតាមពាក្យអ្នក។ **ម៉ាន់ថង**តបថា បើអ្នកនឹងដាច់ចិត្តគិតទៅធ្វើរាជការជាមួយនឹង**ចូឆូ**ហើយ ចូរកាត់យកក្បាល**អៀវហង** និង**ហាន់សៀម**យកទៅធ្វើជាជំនូន**ចូឆូ**ចុះ ឈ្មោះអ្នកនឹងបានគាប់ប្រសើរថ្លាថ្លៃណាស់។ **ស៊ីឡុង**ឆ្លើយកាត់ថា ធម្មតាបាវព្រាវដែលបានទទួលដុំបាយរបស់នាយចៅហ្វាយរបស់ខ្លួនហើយ បើមិនពេញចិត្តគិតនឹងនៅតទៅទេ ក៏មិនត្រូវត្រឡប់ជាប្រទូសរ៉ាយដល់នាយចៅហ្វាយដែលឥតខុសវិញសោះ បើដូច្នោះទុកជាមនុស្សទ្រុស្តគុណអកតញ្ញូមិនល្អសោះដែលអ្នកឲ្យខ្ញុំធ្វើនោះ ខ្ញុំមិនយល់ព្រមតាមផងទេ។ **ម៉ាន់ថង**ឮហើយសរសើរថា ខ្លួនអ្នកពេញជាមនុស្សកតញ្ញូល្អណាស់ ខ្ញុំនឹងបបួលយកតែខ្លួនអ្នកទៅនៅនឹង**ចូឆូ**ចុះ។ វេលានោះ**ស៊ីឡុង**ក៏ប្រុងប្រៀបរៀបចំរបស់ទ្រព្យប្រដាប់ខ្លួនគ្រប់ធួនអស់ហើយ ក៏នាំស្ម័គ្របក្សពួកប្រហែលសាមសិបនាក់ លបរត់ចេញពីសំណាក់នោះចូលទៅក្នុងបន្ទាយ**ចូឆូ** ក្នុងវេលាយប់ជាមួយនឹង**ម៉ាន់ថង**។ ឯ**អៀវហង**បានដឹងច្បាស់ថា**ស៊ីឡុង**នាំស្ម័គ្របក្សពួករត់ទៅចូល**ចូឆូ**ហើយ ក៏នឹកខឹងខ្លាំងណាស់ លើកទាហានមួយពាន់តាម**ស៊ីឡុង**នៅក្នុងពេលយប់នោះ លុះទៅដល់កណ្តាលផ្លូវឃើញគំនរភ្លើងឆេះឡើងលើភ្នំភ្លឺស្រឡះ ទទួល**ចូឆូ**មើលច្បាស់ទៅឃើញ**អៀវហង**លើកកងទ័ពចូលមក **ចូឆូ**ក៏លើកសេនាទាហានឡោមព័ទ្ធជុំវិញហើយស្រែកប្រកាសថា យើងមកចាំនៅទីនេះតាំងពីព្រលប់ បើខ្លួនខ្លាំងពូកែកុំរាថយទៅវិញ។ **អៀវហង**ឃើញទាហាន**ចូឆូ**ឡោមព័ទ្ធដូច្នេះមិញ ក៏ភ័យស្លុតរន្ធត់ស្មារតី

នឹងនាំទាហានរត់ទៅខាងណាក៏មិនរួចសោះ វេលានោះទទួល**ហាន់សៀម**លើកកងទ័ពតាមមកទៀត លុះឃើញកងទ័ព**ចូឆ្វ**ឡោមព័ទ្ធ**អៀវហាង**នៅក្នុងចំណោមដូច្នេះហើយ **ហាន់សៀម**ក៏លើកពារទម្លាយចូលទៅយក**អៀវហាង**ចេញមកវិញបាន។ **ចូឆ្វ**ឃើញដូច្នោះខំបរពលចូលចាក់កាប់ សម្លាប់ទាហាន**អៀវហាង**ស្លាប់ជាច្រើន ខ្លះដែលរស់នៅក៏ចូលមកខាង**ចូឆ្វ**ប្រហែលពីររយប្លាយ **អៀវហាង** និង**ហាន់សៀម**ឃើញថានឹងតទល់ពុំបាន ក៏នាំទាហានដែលសល់នោះរត់ទៅនៅនឹង**អ៊្វនសុត**ឯខេត្ត**ឡាំយ៉ុង**។

**ចូឆ្វ**ថយទ័ពត្រឡប់មកទីដើមវិញ គ្រានោះ**ម៉ាន់ថង**នាំខ្លួន**ស៊ីឡុង**ចូលទៅគំនាប់**ចូឆ្វ** ៗក្រឡេកឃើញ**ម៉ាន់ថង**នាំខ្លួន**ស៊ីឡុង**មក ក៏ក្រោកទទួលស្រាកស្រួលរួសរាយឲ្យយកមាសប្រាក់និងសម្លៀកបំពាក់មកឲ្យរង្វាន់**ស៊ីឡុង** ហើយតាំងឲ្យធ្វើជានាយទាហាន។

ខណៈនោះ **ចូឆ្វ**អញ្ជើញព្រះចៅ**ហៀនតេ**ស្ដេចទៅដល់ស្រុកហ៊ូតោ ហើយរៀបសង់ជាព្រះរាជវាំង ឃ្លាំងដំណាក់តាមថ្នាក់របៀបត្រៀបត្រា ព្រមទាំងទីក្រឡាព្រះគំនាល់រាជរោងរម្យជុំវិញព្រះរាជវាំង តាំងឲ្យជីកគូបង្ហូរទឹកព័ទ្ធជុំវិញ ឯកំពែងនិងសើននោះមិញក៏លើកឲ្យខ្ពស់ស្រឡះ នឹងគន់មើលឃើញល្អណាស់គ្រប់ប្រាង្គប្រាសាទខាងក្នុង ព្រះចៅ**ហៀនតេ**ទ្រង់ឡើងគង់នៅក្នុងទីព្រះរាជវាំងក្រុងហ៊ូតោនោះហើយតាំងឲ្យ**តាំងស៊ិន** និងនាហ្មឺនសាមសិបនាក់ពេញជាទីសេនាបតី។

ខណៈនោះ **ចូឆ្វ**ក៏មិនចិត្តកំរើបក្លៀវក្លា និយាយរាជការពេញអំណាចគ្រប់មុខក្រសួងត្បូងងារតាំងខ្លួនឡើងជាមហាឧបរាជធំ នាហ្មឺនគ្រប់ក្រុមក៏នៅក្រោមបង្គាប់ស្ដាប់ការ។ **ចូឆ្វ**បានតាំង**ស៊ុនហុក**, **ស៊ិនស៊ីវ**, **គុយកែ**, **ឡៅហូ** ទាំងបួននាក់នេះជា

នាហ្មឺនខាងរដ្ឋបាល តាំង**ម៉កាយ, ឡិកចោ, យិនដុន** បីនាក់នេះជានាហ្មឺនខាងក្រសួងឃ្លាំង និងជង្រុកស្រូវ។ **ផៀយ៉ុក**ជាចៅហ្វាយស្រុកតាំងប៉េង, **អួនសេង** និង **តាំងជៀវ** ជាចៅហ្វាយស្រុកឡុកអៀង, **ម៉ាន់ថង**ជាចៅហ្វាយស្រុកហ៊្វូតោ។ **ហែហួទុន, ហែហួអួន, ង៉ាក់ជិន, អ៊ីគឹម, ស៊ីឡុង** ប្រាំនាក់នេះជាសេនាទោ។ **ខៅធូ, តៀនអ៊ុយ** ពីរនាក់នេះជាសេនាត្រី។ បណ្តាសេនាទាហានដែលមានថ្វីដៃខ្លាំងពូកែទាំងអស់នេះ សុទ្ធតែតាំងជានាហ្មឺនមានបណ្តាស័ក្តិដូចគ្នា។ ឯក្នុងក្រុងហ៊្វូតោនោះ បើអ្នកឯណានឹងនិយាយការរាជការអ្វីៗ ក៏ត្រូវនាំសេចក្តីនោះមកប្តឹង**ចូអូ**ជាមុន ទើបនាំក្រាបបង្គំទូលព្រះចៅ**ហៀនតេ**ជ្រាបជាក្រោយ។

**ស៊ុនហុក**ឆ្លើយជម្រាប**ចូអូ**ថា **ខៅធូ**ជាទាហានមានកម្លាំងខ្លាំងពូកែក៏មែនហើយ តែថាមិនសូវមានគំនិតគិតឲ្យចំណាប់សោះ មួយទៀតក្នុងក្រុងហ៊្វូតោនេះ លោកទើបនឹងលើកមកនៅថ្មី របៀបស្រុកក៏មិនទាន់បានរៀបរយ ដែលលោកនឹងឲ្យលើកទ័ពទៅច្បាំងវេលានេះ ខ្ញុំបាទមិនយល់ព្រមផងទេ ដ្បិត**ឡៅពី** និង**លីប៉ោ**នោះប្រៀបដូចខ្លាមួយគូ គំនិតខ្ញុំបាទគិតឲ្យខ្លាទាំងពីរនេះដណ្តើមអំណាចគ្នាស៊ីល្អជាង ព្រោះថាបើ**ឡៅពី**និង**លីប៉ោ**កើតទាស់គ្នាជាសឹកសត្រូវហើយ គង់ច្បាំងគ្នាទាល់តែវិនាសម្ខាងៗជាប្រាកដ រួចសឹមយើងគិតយកជ័យជម្នះជាក្រោយតទៅ។ ឥឡូវនេះ សូមឲ្យលោកយកសេចក្តីក្រាបបង្គំ ទូលព្រះចៅ**ហៀនតេ**ថា ដ្បិត**ឡៅពី**ចៅហ្វាយស្រុកឈីជីវនោះមិនទាន់បានតាំងជាស៊ប់ទេ សូមឲ្យមានព្រះរាជឱង្ការត្រាតាំង**ឡៅពី**ជាចៅហ្វាយស្រុកឈីជីវចុះ បើបានដូច្នោះហើយគង់នឹងតាំងចិត្តធ្វើរាជការមាំមួន ចំណែកលោកក៏ត្រូវមានសំបុត្រប្រធួនទៀតថា លោកបានក្រាបពិតទូលព្រះចៅ**ហៀនតេ**ប្រោសតាំង**ឡៅពី**ជាចៅហ្វាយស្រុកឈីជីវ បើ**ឡៅពី**បានពេញទីជា

ចៅហ្វាយស្រុកឈើជីវហើយ **លីប៉ោ**នោះក៏រមែងប្រទូសរ៉ាយដល់អ្នកមានគុណដរាបយើងត្រូវបញ្ឈឺឱ្យ**ឡៅពី**ខឹងសម្លាប់**លីប៉ោ**ចេញ។

**ចូឆូ**បានស្ដាប់ពេញចិត្តណាស់ ក៏ចូលទៅទូលស្នើព្រះចៅ**ហៀនតេ** សុំឱ្យមានព្រះរាជតម្រាស់ទៅតាំង**ឡៅពី**ជាចៅហ្វាយស្រុកឈើជីវ ព្រះចៅ**ហៀនតេ**ក៏ប្រោសឱ្យ ហើយទ្រង់ព្រះអក្សរឱ្យ**ឡៅពី**ជាចៅហ្វាយស្រុកឈើជីវ។ **ចូឆូ**ក៏ទទួលនាំចេញមក ហើយតែងសំបុត្រមួយច្បាប់អមត្រាតាំងតាមពាក្យ**ស៊ុនហុក**ថានោះ ទើបចាត់បម្រើស្និទ្ធឱ្យនាំត្រាតាំងចេញទៅ **ចូឆូ**ក៏ផ្ដាំនឹងបម្រើឱ្យប្រាប់**ឡៅពី**ថា **ចូឆូ**បានជួយពិតទូលសុំត្រាតាំងបានជាទ្រង់ប្រោសព្រះរាជទាន ម្យ៉ាងទៀត ឱ្យស្ដាប់កិត្តិស័ព្ទថា**ឡៅពី**នឹងគិតធ្វើ**លីប៉ោ**ដូចម្ដេចខ្លះ? បម្រើក៏បានទៅដល់ស្រុកឈើជីវ **ឡៅពី**ក៏ចេញមកទទួលគំនាប់តាមទំនៀមទម្លាប់ ហើយក៏មើលសំបុត្រនោះដឹងសេចក្ដី មានសេចក្ដីត្រេកអរជាពន្លឹក ទើបរៀបចំឱ្យបម្រើនោះបរិភោគអាហារ។ លុះអ្នកបម្រើនោះបរិភោគរួចហើយ ក៏និយាយជម្រាប**ឡៅពី**ថា ដែលព្រះចៅ**ហៀនតេ**តាំងឱ្យលោកបានពេញជាទីចៅហ្វាយស្រុកឈើជីវនេះ ព្រោះ**ចូឆូ**ទូលស្នើសុំឱ្យ និយាយហើយក៏ហុចសំបុត្រនោះឱ្យ**ឡៅពី** ៗទទួលមើលដឹងសេចក្ដីហើយនិយាយថា ចូរអ្នកនាំព័ត៌មានទៅជម្រាប**ចូឆូ**ចុះ ថាយើងសូមបង្អង់រង់គិតសិន។ លុះវេលាយប់ក៏ប្រជុំទីប្រឹក្សាប្រាប់ថា **ចូឆូ**ឱ្យសំបុត្រមកយើងឱ្យគិតសម្លាប់**លីប៉ោ**ចេញ តើអ្នកទាំងពួងនឹងយល់ឃើញដូចម្ដេច?

**តៀវហ៊ុយ**ឆ្លើយថា **លីប៉ោ**នោះចិត្តវាអាក្រក់ណាស់ មិនជាអ្នកស្គាល់គុណគេសោះ បើនឹងសម្លាប់វាចេញតាមពាក្យ**ចូឆូ**ថា ខ្ញុំក៏យល់ឃើញផង។ **ឡៅពី**តបថា**លីប៉ោ**បានជាបែរមុខមកពឹងយើងហើយ បើយើងនឹងធ្វើអន្តរាយគេចេញវេលានេះ

ក៏មិនល្អមើលសោះ ព្រោះតទៅមុខនរណានឹងមករកយើងទៀត។ **តៀវហ៊ុយ**ឆ្លើយថា លោកនឹងធ្វើចិត្តល្អតនឹងមនុស្សកំណាចនោះមិនបានទេ។ **ឡៅពី**ក៏មិនស្ដាប់**តៀវហ៊ុយ**។

ថ្លែងពី**លីប៉ោ**វិញ កាលបានដំណឹងថា ព្រះចៅហៀនតេមានព្រះតម្រាស់មកតាំង**ឡៅពី**ពេញជាទីចៅហ្វាយស្រុកឈីជីវហើយ ក៏ទៅសួរ**ឡៅពី**ហើយថា ខ្ញុំបាទបានឮដំណឹងថា លោកបានទទួលត្រាតាំងពេញទីជាចៅហ្វាយស្រុកនេះ ខ្ញុំបាទមានសេចក្ដីត្រេកអរដ៏ក្រៃលែង។ ទទួល**តៀវហ៊ុយ**កាន់ដាវដើរចូលទៅប្រុងនឹងសម្លាប់**លីប៉ោ**។ **ឡៅពី**ភ័យស្លុតក៏ស្ទុះទៅចាប់គ្រប៊ីចេញ។ **លីប៉ោ**និយាយនឹង**ឡៅពី**ថា **តៀវហ៊ុយ**នេះមានសេចក្ដីខឹងគំនុំនឹងខ្ញុំដោយហេតុអ្វី បានជាមានសេចក្ដីព្យាបាទប្រុងនឹងសម្លាប់ខ្ញុំជាច្រើនដងហើយ? **តៀវហ៊ុយ**បានឮក៏ឆ្លើយថា បានជាអញខឹង ព្រោះខ្លួនឯងមិនស្គាល់គុណគេសោះ **ចូឆូ**ក៏បានផ្ញើសំបុត្រមកបងអញឲ្យសម្លាប់ឯងចេញ។ **ឡៅពី**ឮដូច្នោះក៏ស្រែកគំហក ហើយបង្គាប់ទាហានឲ្យនាំខ្លួន**តៀវហ៊ុយ**ចេញទៅក្រៅ ទើប**ឡៅពី**នាំ**លីប៉ោ**ចូលទៅខាងល្វែងក្នុងហើយហុចសំបុត្រ**ចូឆូ**ឲ្យមើល ហើយនិយាយរាយរឿងប្រាប់តាមបង្គាប់**ចូឆូ**ផ្ដាំមកគ្រប់ប្រការ។

**លីប៉ោ**មើលសំបុត្រហើយ ក៏យំស្រក់ទឹកភ្នែកហើយនិយាយថា ដែល**ចូឆូ**គិតមកដូច្នេះប្រាថ្នាឲ្យលោកនិងខ្ញុំមានសេចក្ដីរង្កៀសចិត្តគ្នា ទៅជាសត្រូវតទៅមុខ។ **ឡៅពី**តបថា អ្នកកុំវិតក្កឡើយ ទោះបីមាននរណាមកញុះញង់ប្រការម្ដេច យើងក៏មិនត្រូវជឿស្ដាប់ធ្វើប្រការអាក្រក់នឹងគ្នា។ **លីប៉ោ**បានស្ដាប់ត្រឡប់ធូរស្រាលក្នុងចិត្តនិយាយថា ដែលលោកចេញវាចាមកដូច្នេះ ព្រះគុណមិនមានទីបំផុត។ **ឡៅពី**ក៏

បបួល**លីប៉ោ**បរិភោគអាហារទាល់តែថ្ងៃរសៀលល្ងាច ហើយ**លីប៉ោ**ក៏លា**ឡៅពី**ទៅស្រុកសៀវផាយវិញ។

**គួនអ៊ូ, តៀវហ៊ុយ** នាំគ្នាចូលទៅនិយាយនឹង**ឡៅពី**ថា លោកបណ្ដោយឲ្យ**លីប៉ោ**ត្រឡប់វិលទៅវិញ មិនសម្លាប់ចេញតាមសំបុត្រ**ចូឆ្វ**ផ្ញើមកនោះ តើដោយប្រការម្ដេច? **ឡៅពី**តបថា ឯសន្ដានចិត្ត**ចូឆ្វ**នោះគង់នឹងចង់ឲ្យយើងទាស់ទែងគ្នានឹង**លីប៉ោ** បានជាទូលស្នើសុំព្រះចៅ**ហៀនតេ**តាំងយើងពេញជាទីចៅហ្វាយស្រុក ហើយថែមទាំងសំបុត្រ**ចូឆ្វ**មកទៀត ឲ្យយើងសម្លាប់**លីប៉ោ**ចេញ គឺធ្វើឲ្យយើងនិង**លីប៉ោ**នោះមិញទាស់អធ្យាស្រ័យគ្នា បើខាងណាបរាជ័យហើយ **ចូឆ្វ**នឹងធ្វើសឹកនឹងអ្នកនោះយកជ័យតែម្ដងមិនព្រួយរវល់ប៉ុន្មាន បើយើងនឹងធ្វើតាមគំនិត**ចូឆ្វ**ដែលបង្គាប់មកនោះមិនគួរសោះឡើយ។ **គួនអ៊ូ**ស្ដាប់ហើយក៏យល់ថាត្រូវ តែ**តៀវហ៊ុយ**នោះនៅទទូចថា ខ្ញុំនឹងចាំសម្លាប់**លីប៉ោ**ចេញឲ្យបាន តទៅមុខទើបមិនព្រួយ។ **ឡៅពី**តបថា បើប្អូននឹងគិតធ្វើដូច្នេះ ក៏ជាមនុស្សគ្មានសតិបញ្ញាសោះ។

ឯបម្រើដែលនាំព្រះតម្រាស់មក លុះបានដឹងឮកិត្តិស័ព្ទគ្រប់ប្រការដូចពណ៌នាមកដូច្នេះហើយ ទើបលា**ឡៅពី**ត្រឡប់វិលទៅវិញ កាលបើបានទៅដល់ក្រុងហ៊ូតោហើយ ក៏ចូលទៅជម្រាបការនោះឲ្យ**ចូឆ្វ**ស្ដាប់ថា **ឡៅពី**មិនបានធ្វើតាមបង្គាប់គាត់ទេ។

ខណៈនោះ**ចូឆ្វ**បានប្រឹក្សានឹង**ស៊ុនហុក**ថា ការដែលអ្នកគិតឲ្យយើងធ្វើនោះ**ឡៅពី**ក៏មិនព្រមធ្វើតាមទេ តើអ្នកនឹងគិតធ្វើដូចម្ដេចតទៅទៀត? **ស៊ុនហុក**ជម្រាបថា ខ្ញុំនឹងគិតកលឧបាយមួយយ៉ាងទៀតហៅថា ខ្លាធំលេបខ្លាឃ្មុំ។ **ចូឆ្វ**សួរថា ខ្លាធំលេបខ្លាឃ្មុំនោះ គឺធ្វើកលដូចម្ដេច? **ស៊ុនហុក**ជម្រាបថា ឯសន្ដានចិត្ត**លីប៉ោ**មិនជា

ត្រង់ល្អនឹងអ្នកឯណាសោះ សូមឲ្យលោកប្រើបម្រើឲ្យទៅនិយាយប្រាប់**អ៊្លូនសុត**ចៅហ្វាយស្រុកឡាំយ៉ុងថា ឥឡូវនេះ**ឡៅពី**មានសំបុត្រចូលទៅក្រាបទូលព្រះចៅ**ហៀនតេ** សុំសេនាទាហានលើកទៅវាយស្រុកឡាំយ៉ុងហើយ បើ**អ៊្លូនសុត**ឮហើយគង់នឹងខឹងជាប្រាកដ ចិត្ត**អ៊្លូនសុត**មិនអត់មុខជាលើកទ័ពទៅវាយ**ឡៅពី**មុន ហើយឲ្យលោកមានសំបុត្រទៅប្រាប់**ឡៅពី** ឲ្យលើកទាហានទៅវាយយកក្រុង**អ្លូនសុត**វិញ កាល**ឡៅពី**និង**អ៊្លូនសុត**ប្រយុទ្ធជាប់ដៃគ្នា បើខាងណាភ្លាត់ចំណាប់ **លីប៉ោ**គង់នឹងលើកទ័ពទៅព្រួតបន្ថែមជាប្រាកដ រួចសឹមលោកគិតការតស៊ូ។ **ចូឆូ**យល់ឃើញត្រូវក៏រៀបចាត់បម្រើឲ្យទៅប្រាប់**អ៊្លូនសុត**ចៅហ្វាយស្រុកឡាំយ៉ុង ហើយធ្វើសំបុត្រព្រះតម្រាស់ឲ្យបម្រើកាន់ទៅឲ្យ**ឡៅពី**ចៅហ្វាយស្រុកឈីជីវជាសេចក្ដីថា ដ្បិតវេលានេះ**អ៊្លូនសុត**ចៅហ្វាយស្រុកឡាំយ៉ុងរឹងទទឹង មិនបានចំណុះចុះចូលព្រះចៅ**ហៀនតេ**ជាម្ចាស់ផែនដីទេ ឲ្យ**ឡៅពី**លើកទ័ពទៅវាយបង្ក្រាប**អ៊្លូនសុត**ឲ្យបាន។ កាល**ឡៅពី**ទទួលព្រះតម្រាស់ហើយក៏និយាយនឹងបម្រើកាន់ព្រះតម្រាស់នោះថា ចូរអ្នកវិលទៅយកសេចក្ដីបង្គំទូលព្រះចៅ**ហៀនតេ**ចុះថា ដែលមានព្រះតម្រាស់បង្គាប់មកនោះ ខ្ញុំនឹងទទួលធ្វើតាមគ្រប់ប្រការ។

**ប៊ីតុក**ជម្រាប**ឡៅពី**ថា ដែលមានព្រះតម្រាស់បង្គាប់មកនេះ ខ្ញុំបាទយល់ឃើញថា ជាគំនិតឧបាយកលរបស់**ចូឆូទេ។ ឡៅពី**តបថា “ដែលមកស្មានថា**ចូឆូ**ប្រើកលឧបាយនោះ ទោះបីយ៉ាងណា ក៏ជាតួព្រះតម្រាស់ពិតប្រាកដ យើងត្រូវតែគិតធ្វើតាម” ហើយក៏បង្គាប់ឲ្យរៀបចាត់ចែងបែងសេនាទាហានទាំងពួងបានប្រហែលបីម៉ឺនត្រៀមទុកជាស្រេច ដល់ពេញឫក្សល្អកាលណា ក៏នឹងលើកចេញទៅ។

**ស៊ុនខៀវ**ជម្រាប**ឡ្យោពី**ថា ដែលលោកនឹងលើកទ័ពទៅនេះ សុំឲ្យចាត់ចែងបែងសេនាទាហាន ដែលមានថ្វីដៃ និងតម្រិះប្រាជ្ញាទុកឲ្យនៅរក្សាស្រុក ។ **ឡ្យោពី**ក៏យល់ព្រមផង **គួនអ៊ូ**ឆ្លើយជម្រាបថា ខ្ញុំបាទសុំនៅរក្សាស្រុកចុះ។ **ឡ្យោពី**តបថា ប្អូនជាទីប្រឹក្សារបស់យើងនឹងនៅម្ដេចបាន។ **តៀវហ៊ុយ**ឆ្លើយឡើងទៀតថា បើលោកយក**គួនអ៊ូ**ទៅជាទីប្រឹក្សាហើយ ឲ្យខ្ញុំបាទនៅរក្សាស្រុកចុះ។ **ឡ្យោពី**តបថា ប្អូនឯងនេះចេះតែផឹកស្រាស្រវឹង និងជេរវាយទាហានគ្មានប្រណីសោះ ថែមទាំងចិត្តនោះក៏ស្រាលរហ័ស ទោះគេនឹងស្ដីរំឭកក៏ពុំស្ដាប់ បើនឹងទុកឲ្យនៅកាន់កាប់រក្សាស្រុកក្រែងពុំបាន។ **តៀវហ៊ុយ**ឆ្លើយថា ពីត្រឹមថ្ងៃនេះទៅមុខ ខ្ញុំបាទលែងទទួលទានស្រាសោះ ទោះបីនឹងធ្វើអ្វីៗក៏ចាំប្រឹក្សាពិគ្រោះនឹងអ្នកមានសតិបញ្ញាសិន បើមានគេស្ដីរំឭក ក៏ត្រូវតែស្ដាប់គ្រប់ប្រការ។

**ប៊ីតុក**ឆ្លើយថា ក្រែងមិនពិតដូចពាក្យប្ដេជ្ញាទេដឹង? **តៀវហ៊ុយ**ខឹងណាស់ឆ្លើយថា ពីខ្ញុំបានតាំងចិត្តធ្វើការជាមួយនឹង**ឡ្យោពី**ជាបង រំលងមកច្រើនឆ្នាំហើយគ្មាននរណាឡើយនឹងចាប់ពិរុទ្ធខ្ញុំជាវៀចបាន ហេតុម្ដេចអ្នកមកហ៊ានទាយចិត្តខ្ញុំនោះមិនតគួរទេ។ **ឡ្យោពី**ឃាត់ហាម**តៀវហ៊ុយ**ថា កុំឲ្យខឹងសម្បារនឹង**ប៊ីតុក**ឡើយ ដែលប្អូននឹងទទួលនៅរក្សាស្រុកនោះបងក៏មិនទាន់ទុកចិត្តដែរ តែថាបានឲ្យសញ្ញាហើយនឹងនៅក៏នៅចុះ តែត្រូវទុក**តាន់តេង**ឲ្យនៅជាទីប្រឹក្សាផង នឹងបានដាស់តឿនរំឭកព្រឹកល្ងាច កុំឲ្យផឹកស្រាស្រវឹងពេក ទើបធ្វើការរក្សាស្រុកទេសនឹងមិនកើតថ្លោះការ។ **តៀវហ៊ុយ**និង**តាន់តេង**ក៏ទទួលប្រសាសន៍**ឡ្យោពី**គ្រប់ប្រការ។

លុះបានពេលមង្គលឫក្ស **ឡ្យោពី**ក៏លើកទ័ពចេញទៅស្រុកឡាំយ៉ុង ឯ**អ៊ួនសុត**ជាចៅហ្វាយស្រុកឡាំយ៉ុងនោះ លុះដឹងថា **ឡ្យោពី**មានសំបុត្រទៅក្រាបទូលព្រះចៅ

**ហៀនតេ**សុំសេនាទាហាននឹងលើកមកវាយស្រុករបស់ខ្លួន ក៏ខឹងណាស់ ស្ដីដៀលត្អះឲ្យ**ឡៅពី**ថា ជាតិត្រកូលវាជាអ្នកត្បាញសំពត់លក់ទេតើ ឥឡូវនេះបានធ្វើចៅហ្វាយស្រុកប៉ុណ្ណោះ ក៏មកចេះកំរើបចិត្តគិតលើកទ័ពមកវាយយកស្រុកយើង ៗនឹងឲ្យវាជាន់ដីយើងធ្វើអ្វី។ ថាហើយក៏ប្រើ**គីឡេង**សេនាឯកជាមេទ័ពលើកទាហានដប់ម៉ឺនចេញទៅវាយស្រុកឈីជីវ។

**គីឡេង**លើកកងទ័ពទៅដល់ស្រុកអ៊ីថៃ ឃើញកងទ័ព**ឡៅពី**លើកមកប្រទះគ្នា **គីឡេង**ក៏បោះទ័ពឈប់តាំងបន្ទាយ ប្រទល់គ្នាចម្ងាយល្មមមើលគ្នាឃើញទៅវិញទៅមក ។ ឯ**ឡៅពី**ឃើញ**គីឡេង**ជាពួកស្រុកស៊ូតាំងលើកទ័ពមក ក៏គិតថា សេនាទាហានយើងតិច គួរតាំងបន្ទាយជាប៉ែកឆ្វេងស្ដាំភ្ជាប់ទល់នឹងជើងភ្នំ រហូតទៅដល់នឹងមាត់ទឹកទន្លេ។ **គីឡេង**ឃើញដូច្នោះក៏ឡើងកាន់ដាវវែងទម្ងន់ហាសិបនាឡិ បរពលចូលទៅប្រទល់មុខបន្ទាយ**ឡៅពី** ហើយស្រែកជេរ**ឡៅពី**ថា អាពួកមនុស្សព្រៃ! ឯងមាន**ថ្វី**ដៃយ៉ាងណា ទើបអង់អាចលើកទ័ពមកធ្វើសង្គ្រាមនឹងអញ ហួសចូលមកដល់ស្រុកអ៊ីថៃ ជាដែនឡើងខេត្តឡាំយ៉ុង? **ឡៅពី**តបថា ចៅហ្វាយឯងឈ្មោះ**អ៊្វិនសុត**ពេញជាក្បត់ខ្នាំងនឹងផែនដី មិនចំណុះព្រះចៅ**ហៀនតេ** ៗទ្រង់ត្រាស់ប្រើអញឲ្យលើកកងទ័ពមកប្រាបប្រាម**អ៊្វិនសុត**ឲ្យចំណុះស្ដេចជាម្ចាស់ផែនដី ហេតុអ្វីបានជាឯងមិនគំនាប់អញជាព្រះរាជអាជ្ញា ថែមមកចរចាទ្រគោះមើលងាយអញវិញ ទោសឯងមិញក៏ត្រូវប្រហារបង់នូវជីវិត។

**គីឡេង**បានស្ដាប់ក៏ត្រឡប់ក្រេវក្រោធ ច្រឡោតបរសេះគ្រវីដាវចូលទៅប្រយុទ្ធនឹង**ឡៅពី**។ **គួនអ៊ូ**ក៏បរសេះគ្រវីដាវចូលតនឹង**គីឡេង**បានសាមសិបភ្លេង មិនទាន់ចាញ់ឈ្នះ **គីឡេង**អស់កម្លាំងស្រែកប្រាប់**គួនអ៊ូ**ថា យើងឈប់ថ្វបកម្លាំងបន្តិច

សិន រួចសឹមលេងគ្នាតទៅទៀត។ **គួនអ៊ូ**ក៏ថយសេះវិលមកវិញ **គីឡេង**ក៏បរសេះចូលបន្ទាយ ហើយប្រើ**ស៊ុនចេង**ជាសេនារង ចេញមកតយុទ្ធនឹង**គួនអ៊ូ** ។ក្រឡេកឃើញក៏ញាក់សេះវិលត្រឡប់ទៅស្រែកថា ខ្លួនឯងនេះមិនសមគួរមកតនឹងយើងសោះ ចូរវិលត្រឡប់ទៅប្រាប់**គីឡេង**នាយឯយ ឲ្យចេញមកតនឹងយើងទៀតទើបនឹងសមថ្វីដៃគ្នា។

**ស៊ុនចេង**ឆ្លើយថា ខ្លួនអង់អាចមើលងាយយើងណាស់ ខ្លួនក៏គ្រាន់តែជាសេនាទាហានមិនទាន់មានល្បីប៉ុន្មាន ហេតុម្តេចហ៊ានលើកខ្លួនចង់ប្រឡងនឹងនាយអញ? **គួនអ៊ូ**ឮដូច្នោះ ក៏បរសេះចូលទៅប្រយុទ្ធនឹង**ស៊ុនចេង**បានមួយភ្លែង ក៏លើកដាវកាប់**ស៊ុនចេង**ធ្លាក់ពីលើសេះស្លាប់។ **ឡៅពី**បរពលចូលកាប់ទម្លាយបន្ទាយ**គីឡេង**បាន។ **គីឡេង**នាំទាហានថយទៅតាំងបន្ទាយនៅក្បែរស្ទឹងស្រុកឈ្លួយមិន ហើយលើកទាហានទៅប្លន់យកបន្ទាយ**ឡៅពី**ជាច្រើនដងក៏មិនបាន ទាហាន**ឡៅពី**កាប់សម្លាប់ទាហាន**គីឡេង**ស្លាប់គ្រប់គ្រា។ **គីឡេង**និង**ឡៅពី**ក៏តតាំងច្បាំងគ្នាជាយូរថ្ងៃ។

ឯ**តៀវហ៊ុយ**ដែលនៅរក្សាស្រុកឈីជីវ ចែកមុខងារឲ្យ**តាន់តេង**ត្រួតនិយាយការខាងរដ្ឋបាល **តៀវហ៊ុយ**ឯងត្រួតត្រានិយាយការខាងសេនាទាហាន។ លុះកន្លងមកមួយថ្ងៃ **តៀវហ៊ុយ**ឲ្យរៀបតុលៀងអាហារ ហើយអញ្ជើញភ្នាក់ងារខាងទាហាននិងរដ្ឋបាលមកបរិភោគព្រមគ្នា។ **តៀវហ៊ុយ**និយាយថា កាល**ឡៅពី**នឹងលើកកងទ័ពចេញទៅនោះ បានកំជាប់ពាក្យនឹងយើងថា កុំឲ្យផឹកស្រាពេក តែថ្ងៃនេះយើងសប្បាយចិត្ត បានជាគិតជប់លៀងអស់លោក បរិភោគផឹកស៊ីសប្បាយតែមួយថ្ងៃនេះ តទៅអស់លោកនឹងយើងកុំគប្បីផឹកស៊ីទៀតឡើយ យើងត្រូវតែតាំងមុខធ្វើការ

រាជការ និងរក្សាស្រុកឲ្យសុខសាន្ត ត្រាតែបាន**ឡៅពី**លើកទ័ពត្រឡប់មកវិញ ថាហើយក៏ចាក់ស្រាហុចគំនាប់សព្វមុខមន្ត្រីព្រមគ្នា។

នៅសល់តែ**ចោប៉ា**ម្នាក់មិនព្រមទទួលពែងស្រា ហើយនិយាយនឹង**តៀវហ៊ុយ**ថា បានស្បថស្បាន់ចំពោះមុខទេវតាថា លែងផឹកស្រាហើយ សុំឲ្យអត់ទោសចុះ។ **តៀវហ៊ុយ**តបថា ខ្លួនជាសេនាទាហានហេតុម្តេចបានជាលែងផឹកស្រា យើងត្រូវឲ្យផឹកមួយពែងចុះ បើមិនទទួលយើងក៏មិនព្រមស្តាប់។ **ចោប៉ា**នឹកខ្លាច**តៀវហ៊ុយ**ក៏ទទួលគំនាប់ផឹកស្រាមួយពែងទៅ។ **តៀវហ៊ុយ**ក៏ចាក់ស្រាផឹកខ្លួនឯងអស់ប្រហែលម្ភៃពែងធំ ហើយចាក់ឲ្យអ្នកឯទៀតផឹកជាលំដាប់គ្នាតទៅ។ តែ**ចោប៉ា**អង្វរថា ខ្ញុំទទួលទានមិនបាន។ **តៀវហ៊ុយ**សើចហើយថា អម្បាញ់មិញខ្លួននិយាយថាផឹកមិនបាន តែបានផឹកអស់មួយពែងទៅហើយ ឥឡូវនេះឲ្យផឹកទៀតថាផឹកមិនបាន យ៉ាងនេះគឺខ្លួនក្លែងមិនរាប់អានយើងៗក៏មិនត្រូវស្តាប់ ត្រូវតែបង្ខំឲ្យផឹកទាល់តែបាន។ **ចោប៉ា**អង្វរមិនទទួល តែ**តៀវហ៊ុយ**ខឹងច្រឡោតថា ខ្លួនឯងជាអ្នកតូចជាងយើង ហើយអាចរឹងទទឹងមិនព្រមផឹកស្រាដែលយើងឲ្យ ក៏ឃើញថាខ្លួនមិនកោតខ្លាចយើង។ ថាហើយក៏បង្គាប់ឲ្យមនុស្សបម្រើចាប់ខ្លួន**ចោប៉ា**ទៅវាយមួយរយខ្វាប់។

**តាន់តេង**ឃើញ**តៀវហ៊ុយ**ធ្វើឡូឡា ក៏និយាយថា កាល**ឡៅពី**រៀបដំណើរចេញទ័ពទៅបានផ្តាំផ្តាច់ទុកនឹងអ្នកដូចម្តេចខ្លះ? **តៀវហ៊ុយ**ឆ្លើយថា ខ្ញុំបានបែងមុខងារឲ្យអ្នកត្រួតត្រាមុខងារខាងរដ្ឋបាល ខ្លួនខ្ញុំត្រួតការខាងសេនាទាហាន ឥឡូវនេះ**ចោប៉ា**ជាទាហានប៉ែកខាងខ្ញុំទេ អ្នកមិនត្រូវមកនិយាយឆ្លងរំលងក្រសួង។ ឯមនុស្សបម្រើទាំងពួងក៏ទាញដៃ**ចោប៉ា**ទៅវាយ។ **ចោប៉ា**អង្វរករ**តៀវហ៊ុយ**ថា ខ្ញុំបាទសូមទោសលោកម្តងចុះ ទោះបីលោកមិនយល់ដល់មុខខ្ញុំ ក៏សុំឲ្យឈ្វេងយល់ដល់កូន

ប្រសារខ្ញុំផង។ **តៀវហ៊ុយ**បានឮឈ្មោះ**លីប៉ោ** ក៏ក្រដូខឹងថែមទៀតថា ខ្លួននិយាយមកនេះប្រាថ្នានឹងបញ្ឈឺចិត្តយើង បានជាយកឈ្មោះ**អាលីប៉ោ**មកសម្តែងឲ្យយើងខ្លាច យើងមិនមែនខ្លាចវាទេ ត្រូវតែឲ្យវាយខ្លួនឥឡូវនេះឲ្យបាន ឲ្យសង្កៀរកាល**អាលីប៉ោ**ជាកូនប្រសាខ្លួន ដែលខ្លួនរាប់ថាល្អនោះ។ ថាហើយក៏បង្ខំមនុស្សបម្រើឲ្យចាប់ខ្លួន**ចោប៉ា**ទៅវាយប្រហែលហាសិបខ្នាប់។ នាហ្មឺនខ្ញុំរាជការក៏នាំគ្នាជួយអង្វរករ**តៀវហ៊ុយ**ឲ្យឈប់វាយ។ **ចោប៉ា**ក៏ត្រឡប់ទៅដល់ទីលំនៅ នឹកក្តៅគំនុំចិត្តនឹង**តៀវហ៊ុយ**ពន់ប្រមាណណាស់ គិតហើយក៏សរសេរសំបុត្រឲ្យបម្រើកាន់ទៅឲ្យ**លីប៉ោ**ឯស្រុកសៀវផាយ។

**លីប៉ោ**បានទទួលសំបុត្រហើយមើលក៏នឹកឃើញថា “វេលានេះ**ឡៅ**ពីលើកកងទ័ពទៅវាយស្រុកឡាំយ៉ុង ទុក**តៀវហ៊ុយ**ឲ្យរក្សាស្រុកឈីជីវ ឥឡូវ**តៀវហ៊ុយ**ផឹកស្រាស្រវឹងឲ្យវាយយើងឥតកំហុស ថែមទាំងស្តីទ្រគោះបញ្ចោះមកដល់អ្នកជាកូនទៀត ហេតុនេះសុំឲ្យអ្នកលើកទាហានទៅវាយយកស្រុកឈីជីវនោះ នៅវេលាយប់នេះមុខជានឹងបានដោយងាយ ព្រោះ**តៀវហ៊ុយ**កំពុងដេកស្រវឹងពុំដឹងខ្លួន”។

**លីប៉ោ**ដឹងដូច្នោះក៏ហៅ**តាន់កុង**មកប្រឹក្សា **តាន់កុង**ឆ្លើយថា ដែល**តៀវហ៊ុយ**មើលងាយនិយាយទ្រគោះមកដល់លោកដូច្នោះ ជាការអាក្រក់ខ្លាំងណាស់ លោកនឹងទ្រាំនៅក្នុងស្រុកសៀវផាយឃើញមិនសប្បាយជាទីមាំមួនសោះ គ្រានេះបានចន្លោះស្រួលហើយ ត្រូវតែលើកទាហានទៅវាយយកស្រុកឈីជីវកុំបង្អង់ បើបានហើយនឹងតាំងគិតការតទៅទៀត។ **លីប៉ោ**យល់ឃើញត្រូវ ក៏តម្រូវឲ្យ**តាន់កុង** និង**កោស៊ុន**កេណ្ឌប្រមូលទាហានបានព្រម ហើយនិយាយថាយើងលើកស្រួតទៅមុន ឲ្យអ្នកទាំងពីរលើកតទៅជាខាងក្រោយ។ **លីប៉ោ**ក៏ពាក់ក្រឹសឡើងជិះសេះ**សឹក**ថៅនាំ

ទាហានប្រមាណប្រាំរយ លើកទៅដល់ជើងកំពែងស្រុកឈីជីវវេលាយាមបី ហើយស្រែកប្រាប់ទាហានចាំទ្វារថាឲ្យបើកទ្វារជាប្រញាប់ ដ្បិត**ឡៅពី**ប្រើយើងឲ្យមកពន្យល់ការរាជការនឹង**តៀវហ៊ុយ**។ ទទួលលើទាហានរបស់**ចោប៉ា** ដែលចាំរក្សាទ្វារនោះ បានឮ**លីប៉ោ**ក៏រត់ទៅប្រាប់**ចោប៉ា** ៗក៏រត់ស្រូតមកមើល លុះឃើញ**លីប៉ោ**ក៏ឲ្យបើកទ្វារទទួល **លីប៉ោ**លើកទាហានចូលទៅ។

ឯបក្សពួក**តៀវហ៊ុយ** ឃើញ**លីប៉ោ**និងសេនាទាហានចូលទៅក្នុងស្រុកបាន ក៏ភ័យតក់ស្លុតរត់ទៅប្រាប់**តៀវហ៊ុយ** ៗភ្ញាក់ឡើងកំពុងស្រវឹងស្រាវ ឮទាហានថា**លីប៉ោ**លើកទាហានចូលមកស្រុកបានហើយ **តៀវហ៊ុយ**ភ័យណាស់ ឡើងសេះកាន់ទួនចេញមកដល់មាត់ទ្វារផ្ទះ ឃើញទាហាន**លីប៉ោ**ព័ទ្ធជុំវិញក៏គិតថា ខ្លួនអញនៅស្រវឹង កម្លាំងក៏តិចនឹងតស៊ូ**លីប៉ោ**មិនបាន គិតដូច្នេះហើយក៏នាំទាហានដែលស្និទ្ធប្រហែលដប់ប្រាំបីនាក់រត់ចេញចាកស្រុកឈីជីវទៅ ឯគ្រប់គ្រួ**ឡៅពី**ក៏ចោលនៅក្នុងស្រុកនោះទាំងអស់។

**លីប៉ោ**ដឹងថា**តៀវហ៊ុយ**រត់ទៅហើយ ក៏មិនបានដេញដិតដោយព្រោះកោតញញើតថា **តៀវហ៊ុយ**មានថ្វីដៃខ្លាំងពូកែ។ ឯ**ចោប៉ា**នៅក្ដៅផ្សានឹង**តៀវហ៊ុយ**ណាស់ ក៏លើកទាហានប្រមាណមួយរយនាក់តាម**តៀវហ៊ុយ**ទៅ។ **តៀវហ៊ុយ**ក្រឡេកក្រោយ ឃើញ**ចោប៉ា**ដេញតាម ក៏ញាក់សេះត្រឡប់មកតយុទ្ធនឹង**ចោប៉ា**បានបីភ្លែង **ចោប៉ា**កម្លាំងតិចគេចបរសេះរត់មកក្រោយ **តៀវហ៊ុយ**ក៏ដេញបណ្ដោយមកដល់ទល់នឹងមាត់ស្ទឹង ប្រឹងស្រូតទៅទាន់លើកទួនចាក់**ចោប៉ា**ធ្លាក់ពីលើសេះស្លាប់។ បណ្ដាសេនាទាហាន**តៀវហ៊ុយ**ដែលនៅក្នុងស្រុកឈីជីវប៉ុន្មាន ក៏នាំគ្នាបររត់ចេញទៅខ្លះ។ លុះវេលាព្រឹកឡើង ទើបទៅប្រទះនឹង**តៀវហ៊ុយ** ៗក៏លើកតាម**ឡៅពី**ស្រុកឡាំយ៉ុង។

ឯ**លីប៉ោ**កាលបានស្រុកឈីជីវហើយ ក៏ឲ្យទាហានមួយរយនាក់ទៅនៅយាមរក្សាភរិយាបុត្រ**ឡៅពី** មិនឲ្យនរណាប្រមាថមើលងាយ។ កាល**តៀវហ៊ុយ**ទៅដល់ស្រុកអ៊ីថៃ ក៏ចូលទៅប្រាប់សេចក្តីសុខទុក្ខដល់**ឡៅពី**គ្រប់ប្រការ បណ្តាសេនាទាហានក្នុងកងទ័ពដែលបានដឹងកិត្តិស័ព្ទថា**លីប៉ោ**ដណ្តើមយកស្រុកឈីជីវបាន ក៏មានចិត្តព្រួយរំខាននឹកដល់ភរិយាបុត្រញាតិសន្តានគ្រប់ៗគ្នា នឹងធ្វើការក៏រសាយដៃពុំដូចថ្ងៃមុនសោះ។ **ឡៅពី**ដឹងចិត្តសេនាទាហានទាំងអស់ពុំមានក្តៀវក្លា ក៏ប្រើប្រាជ្ញានិយាយយកចិត្តថា “ធម្មតាមនុស្សយើងកើតមករាល់គ្នាជាជាតិទាហានហើយ បើនឹងបង់ទីលំនៅក៏មិនត្រូវជាទុក្ខ បើនឹងវាយបានស្រុកក៏មិនត្រូវត្រេកអរ”។

**គួនអ៊ូ**ក៏សួរ**តៀវហ៊ុយ**ថា ខ្លួនលោកមកនេះបាននាំយកគ្រប់គ្រួរបស់យើងមកដែរឬទេ? **តៀវហ៊ុយ**ឆ្លើយថា បងថ្លៃយើងទាំងពីរនាក់ធ្លាក់ក្នុងកណ្តាប់ដៃសត្រូវនៅក្នុងក្រុងឈីជីវទាំងអស់ទៅហើយ។ **គួនអ៊ូ**ឮដូច្នោះក៏ញ័រអស់ទាំងខ្លួន កន្ត្រាក់យកទូនកាន់ ហើយទន្ទ្រាំបាទាថា កាល**ឡៅពី**ជាបងរៀបនឹងចេញដំណើរមក លោកក៏បានសុំខ្លួននៅគ្រប់គ្រងរក្សាស្រុក បានតាំងចុះសញ្ញាថាម្តេចខ្លះ លោកគិតឃើញឬទេ? បើគ្រាន់តែខូចស្រុកឈីជីវទៅហើយ ម្តេចឡើយឲ្យបង់ទាំងគ្រប់គ្រួរបស់បងទៅទៀត បើដូច្នោះលោកនឹងគិតឆ្លៀតធ្វើដូចម្តេច? **តៀវហ៊ុយ**ឃើញ**គួនអ៊ូ**ខឹងសម្បារថារំឭកសព្វគ្រប់ ក៏ដាក់មុខសញ្ចប់សញ្ជឹង តាំងតែទោមនស្សខ្មាសអស់សេនាទាហានពន់ប្រមាណណាស់ ទើបហូតគ្រប៊ីលើកឡើងប្រុងនឹងអារកខ្លួនឯងសម្លាប់។ **ឡៅពី**ឃើញក៏ស្ទុះប្រញាប់ចាប់ដណ្តើមយកគ្រប៊ីបានហើយនិយាយថា “ពាក្យបុរាណមានពោលទុកថា ធម្មតាភរិយាបុត្រនោះឧបមាដូចជាសំពត់អាវដែលស្លៀកពាក់ បើរហែកជ្រុះធ្លាក់ ក៏ត្រូវរកទៀតបាន ឯបងប្អូនញាតិសន្តានដូចជាដៃ

ជើងទាំងឆ្វេងស្ដាំ បើបាក់បែករហែកស្រាំកម្រនឹងតភ្ជាប់បាន យើងបីនាក់ក៏ស្បថស្បាន់ទុកគ្នាជាចិត្តជីវិតមួយមកយូរហើយ ថ្វីបើខូចស្រុកឈើជីវ និងភរិយាបុត្រប៉ុណ្ណោះជាការក្រៅទេ បើសម្លាប់ខ្លួនចេញហើយ នឹងបានរបស់ដែលខូចនោះមកវិញកាលណា បើជីវិតសង្ខារយើងនៅតទៅមុខ យើងក៏គង់រកសេចក្ដីសុខឡើងទៀតឲ្យបាន" និយាយហើយក៏យំសោកា។ **គួនអ៊ូ, តៀវហ៊ុយ**ឃើញ**ឡៅពី**យំកាលណា ក៏នាំគ្នាយំសោកជាមួយទាំងអស់គ្នា។

ឯ**អ៊្វួនសុត**លុះដឹងថា **លីប៉ោ**វាយបានស្រុកឈើជីវហើយ ក៏ប្រើទាហានកាន់សំបុត្រទៅឲ្យ**លីប៉ោ** សេចក្ដីថា "ឲ្យ**លីប៉ោ**ជួយច្បាំងវាយទ័ពឡៅពីឲ្យបែកចុះ យើងនឹងឲ្យសេះប្រាំរយ ស្រូវប្រាំរយម៉ឺនថាំង មាសមួយម៉ឺនតម្លឹង ព្រែមួយពាន់ផាប់។ **លីប៉ោ**ឃើញដូច្នោះក៏ពេញចិត្តណាស់ ចាត់ប្រើ**កោស៊ុន**លើកទាហានប្រាំម៉ឺនទៅវាយខ្នប់ពីក្រោយ**ឡៅពី**ៗ ក៏ប្រឹក្សានឹង**គួនអ៊ូ, តៀវហ៊ុយ**ថា យើងមានសេនាទាហានតិចណាស់ ឃើញជាតស៊ូនឹងគេមិនបាន។ លុះដល់ពេលយប់ធ្លាក់ភ្លៀងធំ **ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ក៏លើកទាហានចេញពីបន្ទាយទៅស្រុកកងឡេង។

**កោស៊ុន**ដឹងថា **ឡៅពី**លើកទ័ពរត់ចោលបន្ទាយទៅហើយ ក៏ហួសទៅជួបនឹង**គីឡេង**ក្នុងបន្ទាយ។ **កោស៊ុន**និយាយថា ឥឡូវ**ឡៅពី**រត់ចេញពីយប់មិញបាត់ទៅហើយ របស់ដែលចៅហ្វាយអ្នកនឹងឲ្យចៅហ្វាយខ្ញុំនោះជាម្ដេចទៅវិញ? **គីឡេង**តបថា សេចក្ដីទាំងនេះខ្ញុំមិនទាន់ដឹងច្បាស់ដែរ បើខ្ញុំត្រឡប់ទៅដល់ស្រុកវិញកាលណានឹងសួរ**អ៊្វួនសុត**ឲ្យដឹង។

កងទ័ពទាំងពីរក៏លើកត្រឡប់វិលទៅស្រុកតែសព្វខ្លួន។ ឯ**កោស៊ុន**បានជម្រាប**លីប៉ោ**ថា **ឡៅពី**លើកទ័ពរត់បាត់ទៅហើយ ខ្ញុំបាទបានទៅជួបសួរ**គីឡេង**

នាយទ័ពស្រុកឡាំយ៉ុងពីរឿងរបស់ទ្រព្យដែល**អ៊ួនសុត**ជាចៅហ្វាយ បើបានសេចក្ដីដូចម្ដេចនឹងឱ្យដំណឹងជាក្រោយ។

**លីប៉ោ**បានស្ដាប់ក៏ឱ្យពិភាល់ក្នុងចិត្តគិតសង្ស័យ ទទួលឃើញបម្រើ**អ៊ួនសុត**នាំសំបុត្រទៅដល់ សេចក្ដីថា “អ្នកចាត់ប្រើ**កោស៊ុន**ជានាយកងទ័ពលើកទៅខ្ទប់**ឡៅពី**ក៏មែន តែមិនទាន់បានច្បាំងតាំងតគ្នា ហើយក៏ចាប់**ឡៅពី**មិនបាន បើបានខ្លួន**ឡៅពី**វេលាណា យើងនឹងឱ្យរបស់តាមសញ្ញា”។ **លីប៉ោ**បានស្ដាប់សំបុត្រនោះខឹងណាស់ថា **អ៊ួនសុត**នោះចរចាមិនទៀងទាត់ទេ បើនឹងអត់តទៅទៀតក៏ពុំបាន ទើបប្រឹក្សានឹងសេនាទាហានថា យើងត្រូវលើកទ័ពទៅច្បាំងនឹង**អ៊ួនសុត**ក្នុងគ្រានេះ។

**តាន់កុង**ឆ្លើយថា ឥឡូវ**អ៊ួនសុត**លើកព្យុហៈមកតាំងបន្ទាយនៅស្រុកឈើវឈុនជាទីសំខាន់ សេនាទាហានដែលមានថ្វីដៃក៏ខ្លាំងពូកែច្រើនណាស់ ទាំងចំណីត្រីសាច់ក៏បរិបូរព្រម បើលោកនឹងទៅឥឡូវនេះ ក៏នឹងបរាជ័យមិនខាន សុំឱ្យលោករិះគិតអានបញ្ចុះបញ្ចូល**ឡៅពី**មកទុកក្នុងស្រុកសៀវផាយវិញ បើយើងលើកទ័ពទៅក៏ត្រូវបានទីស្នាក់នឹង**ឡៅពី**, **គួនអ៊ូ**, **តៀវហ៊ុយ**ជាកម្លាំង យើងនឹងតាំងគិតការតទៅក៏នឹងបានសម្រេចដោយងាយ។ **លីប៉ោ**យល់ឃើញត្រូវ ក៏ចាត់បម្រើឱ្យកាន់សំបុត្រទៅឱ្យ**ឡៅពី**។

ឯ**ឡៅពី**កាលលើកទ័ពរត់ទៅដល់ស្រុកកងឡេង ទទួល**អ៊ួនសុត**លើកទៅវាយស្រុកកងឡេងបែក **ឡៅពី**ក៏រត់ចេញពីស្រុកនោះទៅទៀត ប្រទះនឹងបម្រើកាន់សំបុត្រ**លីប៉ោ**ទៅដល់ ទទួលយកសំបុត្រមកមើលដឹងសេចក្ដីហើយ ក៏ពិគ្រោះនឹង**គួនអ៊ូ**ថា **លីប៉ោ**ឱ្យសំបុត្រមកអន្ទងយើងទៅវិញ ចៅនឹងយល់ឃើញដូចម្ដេច? **គួនអ៊ូ**ជម្រាបថា **លីប៉ោ**ជាមនុស្សចេះនិយាយពីរោះ តែជាពាក្យមុសាវាទមិនពិតត្រង់ណា

បើយើងនឹងគប់ប្រសព្វយកជាគ្នាតទៅក៏មិនបានល្អ។ **ឡៅពី**តបថា ឥឡូវ**លីប៉ោ**ឲ្យមកអន្ទងយើងដោយសុភាពហើយ ត្រូវតែយើងទៅទើបគួរ។

ក្នុងពេលដែល**លីប៉ោ**ឲ្យទាហានកាន់សំបុត្រទៅឲ្យ**ឡៅពី** ហើយខ្លាចក្រែង**ឡៅពី**មិនព្រមមកវិញ **លីប៉ោ**ក៏ចាត់ទាហានឲ្យនាំខ្លួននាង**កាំហ៊ូយិន** និងនាង**ប៊ីហ៊ូយិន** ដែលជាភរិយា**ឡៅពី**ទៅជូន**ឡៅពី** ដើម្បីនឹងឲ្យឡៅពីអស់សេចក្តីសង្ស័យ ទទួល**ឡៅពី**លើកទ័ពមកជួបនឹងភរិយាកណ្តាលផ្លូវ **ឡៅពី**ឃើញភរិយាក៏សោមនស្សត្រេកអរណាស់ សាកសួរថា កាល**លីប៉ោ**យកស្រុកឈីជីវបាន ៗពិភ័ក្តិរក្សាថៅទាំងពីរដូចម្តេចខ្លះ? នាង**កាំហ៊ូយិន** នាង**ប៊ីហ៊ូយិន** ជម្រាបថា **លីប៉ោ**ចាត់ទាហានមួយរយនាក់ឲ្យទៅយាមល្បាតរក្សាយើងខ្ញុំមាំមួនណាស់ មិនឲ្យនរណាចូលចេញតាមអំពើចិត្តឥតគួរសមសោះឡើយ ហើយចាត់ឲ្យមានស្រីបម្រើបម្រាស់ជូនចំណីអាហាររាល់វេលា។ **ឡៅពី**និយាយនឹង**គួនអ៊ូ, តៀវហ៊ុយ**ថា យើងបាននិយាយពីមុនមកហើយថា**លីប៉ោ**ប្រាកដជាមានកតញ្ញូនឹងយើង ទោះបីយ៉ាងណាក៏មិនប្រទូសរ៉ាយដល់ភរិយាយើងដែរ បើដូច្នេះត្រូវតែយើងចូលទៅជួបនឹង**លីប៉ោ**ទើបគួរ។ ចំណែកខាង**គួនអ៊ូ**យល់ព្រមហើយ តែ**តៀវហ៊ុយ**នៅជាប់អាឃាដព្យាបាទ ក៏និយាយថា ខ្ញុំមិនសុំឃើញមុខ**អាលីប៉ោ**តទៅទៀត ហើយបងទាំងពីរនឹងចង់ទៅក៏ទៅចុះ ខ្លួនខ្ញុំនឹងនាំបងថ្លៃទៅនៅស្រុកសៀវផាយ។ ហើយ**តៀវហ៊ុយ**ក៏នាំភរិយា**ឡៅពី**ទៅស្រុកសៀវផាយ ឯ**ឡៅពី, គួនអ៊ូ**ក៏ចូលទៅរក**លីប៉ោ**។

**លីប៉ោ**ចេញមកទទួលហើយ ក៏អញ្ជើញឡើងលើគេហដ្ឋានចាប់ផ្តើមនិយាយថា ខ្ញុំធ្វើការទាំងនេះ មិនមែននឹងឃើញនូវទ្រព្យសម្បត្តិសព្វសារពើរបស់អ្នកទេ ដោយហេតុ**តៀវហ៊ុយ**ប្អូនអ្នកផឹកស្រាស្រវឹងខឹងរំលោភធ្វើការហួសខ្នាត ខ្ញុំក៏គិត

ខ្លាចគេព្យាបាទដល់ខ្ញុំនឹងកើតវឹកវរឡើង បានជាខ្ញុំលើកទាហានមកយកស្រុកនេះ ប្រាថ្នានឹងរក្សាទុកជូនអ្នកកុំឲ្យបែកបាក់អន្តរាយ ឥឡូវអ្នកមកដល់ត្រូវខ្ញុំប្រគល់ជូន។

**ឡៅពី**តបថា ស្រុកនេះកាលពីមុនខ្ញុំបានលើកជូនអ្នកម្តងហើយ អ្នកមិនព្រមយក ឥឡូវអ្នកមកនៅស្រាប់ក៏ជាការគាប់ប្រសើរ គួរជាស្រុករបស់អ្នកហើយ ចូរនៅឲ្យបានសេចក្តីសុខចុះ ឯខ្លួនខ្ញុំសូមនាំបក្សពួកទៅនៅស្រុកសៀវផាយវិញ។ **លីប៉ោ**និយាយលួងលោមឲ្យ**ឡៅពី**ទទួលយកស្រុកដូចដើម។ **ឡៅពី**មិនព្រម ក៏លា**លីប៉ោ**ចេញទៅនៅស្រុកសៀវផាយ។

ឯ**គួនអ៊ូ, តៀវហ៊ុយ** ក៏នៅចាំចិត្តគិតព្យាបាទ**លីប៉ោ**ជាដរាប។ **ឡៅពី**ដឹងក្នុងកិរិយា**គួនអ៊ូ, តៀវហ៊ុយ** ក៏និយាយលួងលោមថា ចៅទាំងពីរកុំអាលធ្វើការអ្វីឲ្យវឹកវរចលាចលឡើយ ចូរទ្រាំទម្រាំតែបានឱកាសល្អរបស់យើងសឹមគិតការតទៅ។ ចំណែក**លីប៉ោ**ក៏បញ្ជូនរបស់គួរសមទៅឲ្យ**ឡៅពី**ជារឿយៗ ឡៅពីនិង**លីប៉ោ**ក៏រាប់អានគ្នាជាប្រក្រតី ដោយមេត្រីដ៏ស្មោះសរដរាបមក។

ចំណែក**អ៊្វិនសុត**ចៅហ្វាយស្រុកឡាំយ៉ុងនោះ មានថ្ងៃមួយក៏ឲ្យរៀបតុតាំងលៀងអាហារភោជន អស់បណ្តានាហ្មឺនសព្វមុខមន្ត្រីទាំងពួង កាលកំពុងបរិភោគអាហារ ទទួល**ស៊ុនសេក**នៅស្រុកកាំងតាំង ដែលវិលពីច្បាំងយកស្រុកលោកាំងបានចូលទៅរក**អ៊្វិនសុត** ៗក្រឡេកឃើញ**ស៊ុនសេក** ក៏ចាប់ដឹកដៃឲ្យចូលទៅបរិភោគជាមួយ។

ឯ**ស៊ុនសេក**នោះ នឹងបានជាបាវព្រាវ**អ៊្វិនសុត**ពីដើមក៏ទេ គឺជាបុត្ររបស់**ស៊ុនកៀន** លុះដល់**ស៊ុនកៀន**ជាបិតាស្លាប់ទៅ ក៏លើកទៅនៅស្រុកកាំងណាំ កាលដែល**តូកៀម**ចៅហ្វាយស្រុកឈីជីវនៅមិនទាន់ស្លាប់ ទាស់គ្នានឹង**ង៉ំកេង**ចៅហ្វាយ

ស្រុកតាន់អៀងជាមា**ស៊ុនសេក** ៗនឹងនៅក្នុងស្រុកកាំងណាំឃើញមិនសុខ ព្រោះស្រុកនោះចំណុះស្រុកឈីជីវ **ស៊ុនសេក**ក៏នាំមាតានិងគ្រប់គ្រួទៅទុកឯតំបន់ខយ៉ុកឱជិតស្រុកតាន់អៀង ឯខ្លួន**ស៊ុនសេក**ទៅនៅធ្វើរាជការជាមួយនឹង**អ៊្វូនសុត** ៗស្រឡាញ់រាប់អានតាំងឲ្យធ្វើកៅអ៊ុយនាយទាហាន បានប្រើឲ្យទៅវាយយកស្រុកកេងគួនបានមួយគ្រា ហើយថែមទៅវាយយកបានស្រុកលោកាំង មានសេចក្ដីគាប់ប្រសើរណាស់ តែ**អ៊្វូនសុត**មិនឲ្យបំណាច់រង្វាន់ គ្រាន់តែឲ្យលៀង។ លុះបរិភោគរួចហើយ នាហ្មឺនទាំងពួងក៏លាទៅអស់ **ស៊ុនសេក**ក៏លា**អ៊្វូនសុត**ទៅផ្ទះ ហើយដើរលេងក្នុងសួនផ្កាក្រោយផ្ទះខ្លួន នឹកក្រំក្រួនតូចចិត្តណាស់ថា ព្រោះ**អ៊្វូនសុត**មិនសូវរាប់អាន **ស៊ុនសេក**អង្គុយយំក្នុងសួននោះ។ ទទួល**ជូទី**ជាសេនា**ស៊ុនកៀន**ជាបិតា**ស៊ុនសេក** ដើរទៅប្រទះឃើញ**ស៊ុនសេក**កំពុងអង្គុយយំ **ជូទី**ក៏សើចហើយថា កាលបិតាអ្នករស់នៅ នឹងគិតធ្វើមធ្វើការអ្វី តែងពិគ្រោះនឹងយើងគ្រប់គ្រា ឥឡូវអ្នកទោមនស្សទាស់ចិត្តដូចម្ដេចទើបបានជាមិនដែលពិគ្រោះនឹងយើងដល់ម្ដងសោះ ហើយបែរជាមកអង្គុយយំដូច្នេះ? **ស៊ុនសេក**ក្រឡេកទៅឃើញ**ជូទី**ក៏ធូរស្រាលក្នុងចិត្ត ហើយអញ្ជើញ**ជូទី**ឲ្យអង្គុយជិតប្រារព្ធនិយាយថា ខ្ញុំបានធ្វើសេចក្ដីគាប់ប្រសើរដល់**អ៊្វូនសុត**ជាច្រើនលើកមកហើយ ម្ដេចឡើយគេមិនសូវរាប់អានខ្ញុំសោះ? ហេតុនេះបានជាខ្ញុំឈឺចិត្តមកអង្គុយយំដូច្នេះ បើខ្ញុំនឹងគិតធ្វើការតទៅឲ្យដូចបិតា ឃើញថាកម្លាំងនិងសតិបញ្ញាក៏គិតមិនធ្លុះធ្លាយ។

**ជូទី**តបថា ខ្លួនអ្នកមានត្រកូលខ្ពង់ខ្ពស់ឧត្ដុង្គឧត្ដម នឹងមកអង្គុយយំដូច្នេះ ដូចមិនមែនជាជាតិទាហាន ឲ្យអ្នកគិតអានចូលទៅនិយាយនឹង**អ៊្វូនសុត** សុំទាហានលើកទៅជួយ**ង៉ំកេង**ដែលជាមាអ្នកនៅស្រុកតាន់អៀង គង់នឹងមានកម្លាំងខ្លាំង

ឡើង។ ទទួល**លីហម**ទីប្រឹក្សា**អ៊្លូនសុត**ចូលទៅរក**ស៊ុនសេក** ឮ**ជូទី**និយាយនឹង**ស៊ុនសេក**ក៏ឈរអែបស្តាប់សព្វសេចក្តី ហើយក៏ដើរចូលទៅនិយាយនឹង**ស៊ុនសេក**ថា ដែលអ្នកគិតគ្នាអម្បាញ់មិញនេះល្អណាស់ ទាហានរបស់ខ្ញុំដែលមានថ្វីដៃខ្លាំងពូកែមានមួយរយនាក់ ចិត្តវាចង់ធ្វើការនឹងអ្នកណាស់ តែខ្ញុំក្រែង**អ៊្លូនសុត**មិនព្រមឲ្យទាហាន។ **ស៊ុនសេក**ថា “អ្នកកុំមានសេចក្តីព្រួយ ត្រាឆ្លាក់សម្រាប់ព្រះមហាក្សត្ររបស់បិតាខ្ញុំក៏មាននៅនឹងខ្ញុំ ៗនឹងនាំត្រានោះទៅជូន**អ៊្លូនសុត** ៗអស់សង្ស័យគង់នឹងឲ្យទាហានមកខ្ញុំដោយងាយ” និយាយហើយក៏ចូលទៅរក**អ៊្លូនសុត**ជម្រាបថា តាំងពីបិតាខ្ញុំបាទអនិច្ចកម្មទៅ នៅមិនទាន់បានសងសឹក**ឡៅអ៊ីវ**សោះ ឥឡូវនេះខ្ញុំបាទនាំមាតានិងភរិយាទៅផ្ញើនឹង**ង៉កេង**ជាមានៅតាន់អៀង។ ឯ**ឡៅអ៊ីវ**ជាពូជព្រះរាជវង្សព្រះចៅ**ហៀនតេ**ធ្វើការសព្វថ្ងៃ រមែងបៀតបៀនបណ្តារាស្ត្រតាមអំពើចិត្ត ខ្ញុំបាទទើបគិតនាំយកត្រាឆ្លាក់នេះមកប្រចាំទុកនឹងលោក សុំលោកឲ្យទាហានលើកទៅជួយ**ង៉កេង**ជាមា ខ្ញុំបាទនឹងបានសងសឹក**ឡៅអ៊ីវ**។

ចំណែក**អ៊្លូនសុត**បានឃើញត្រាឆ្លាក់ដូច្នោះ ក៏មានចិត្តត្រេកអរជាពន្លឹក ទទួលយកមកមើលហើយធ្វើជាថា “យើងនឹងប្រាថ្នាអ្វីដល់ត្រាឆ្លាក់នោះ តែបើអ្នកបានជាយកមកហើយក៏ត្រូវរក្សាទុកឲ្យ” និយាយហើយក៏ចាត់ទាហានបីពាន់ និងសេះប្រាំរយឲ្យ**ស៊ុនសេក** ហើយផ្តាំថា បើអ្នកទៅធ្វើការបានសម្រេចសេចក្តីប្រាថ្នាហើយចូរត្រឡប់មកវិញ កុំអាលធ្វើការអ្វីតទៅទៀត ព្រោះខ្លួនអ្នកនៅក្មេងសេចក្តី ខ្ចីគំនិតទាំងបណ្តាស័ក្តិក៏តូចណាស់ បើកាលណាអ្នកត្រឡប់មករកយើង នឹងតាំងឲ្យធ្វើជានាហ្មឺនធំឡើងទៀត។

**ស៊ុនសេក**ក៏សុំ**ជូទី** និង**លីហម**ជាទីប្រឹក្សា សុំ**ធៀភៅ, ហាន់តុង, អ៊ុយកាយ**ជានាយទាហាន ដែលធ្លាប់ធ្វើការនឹងបិតានោះយកទៅផង។ **អ៊ួនសុត**ក៏ព្រមព្រៀងប្រគល់ឲ្យពេលនោះ។ **ស៊ុនសេក**ក៏លើកព្យុហៈទ័ពចេញចាកស្រុកឡាំយ៉ុង តម្រង់ទៅកាន់ស្រុកតាន់អៀង ក៏បានជួបប្រទះនឹង**ជីវយី**លើកទាហាននឹងទៅសួរមាតាឯស្រុកស៊ីសេង។ **ស៊ុនសេក**ក៏បញ្ឈប់ទ័ព **ជីវយី**ក្រឡេកឃើញ**ស៊ុនសេក**ក៏លោតចុះពីលើសេះ ទៅគំនាប់**ស៊ុនសេក** ៗក៏គំនាប់តបវិញ។

**ជីវយី**នោះកាលបិតា**ស៊ុនសេក**រស់នៅទៅច្បាំងនឹង**តាំងតុះ**នោះ បិតា**ស៊ុនសេក**បាននាំយកគ្រប់គ្រួសារទៅទុកឯស្រុកស៊ីសេង ជិតផ្ទះ**ជីវយី** ៗនិង**ស៊ុនសេក**ក៏បានស្គាល់រាប់អានគ្នាមក តែ**ស៊ុនសេក**ចាស់ជាង**ជីវយី**ពីរខែ **ជីវយី**ហៅថាបង។

បណ្ដាអ្នកទាំងពីរនាក់ដែលបានជួបគ្នានោះ **ស៊ុនសេក**ក៏ប្រាប់រឿងទាំងពួងឲ្យ**ជីវយី**ស្ដាប់គ្រប់ប្រការ។ **ជីវយី**ស្ដាប់ហើយឆ្លើយថា ខ្ញុំនឹងសុំយកអាសាចូលធ្វើការជាមួយនឹងអ្នក នឹងបានជួយគ្នាគិតការធំត**ទៅ**។ **ស៊ុនសេក**តបថា ប្រសិនបើអ្នកស្ម័គ្រចិត្តគិតមកនៅនឹងយើងហើយ ការដែលយើងគិតទុកទាំងប៉ុន្មាន ក៏គង់នឹងបានសម្រេចដោយងាយ។ ហើយក៏នាំ**ជីវយី**ទៅនិយាយគ្នានឹង**ជូទី, លីហម**។ **ជីវយី**ជម្រាបថា ក្នុងស្រុកកាំងតាំងនោះ មានមនុស្សល្អពីរនាក់ អ្នកដែលឮដែរឬ? **ស៊ុនសេក**សួរថា អ្នកទាំងពីរនាក់នោះឈ្មោះអ្វី? **ជីវយី**ថា ម្នាក់ឈ្មោះ**តៀវជៀវ** ពួកអ្នកស្រុកផេងសៀ ម្នាក់ទៀតឈ្មោះ**តៀវហៀន** ជាពួកអ្នកស្រុកកងឡេង។ អ្នកទាំងពីរនេះមានប្រាជ្ញាឆ្លៀវឆ្លាតណាស់ ឥឡូវរត់ពីរចោរមកនៅស្រុកកាំងតាំង។ អ្នកចូរខំរិះគិតយកចិត្តមនុស្សទាំងពីរ ឲ្យបានចូលមកជួយធ្វើការតទៅ **ស៊ុនសេក**ត្រេកអរណាស់ ក៏ចាត់ប្រើទាហានឲ្យនាំយកគ្រឿងឧបភោគនិងបរិភោគជាច្រើនមុខ យក

ទៅជូន**តៀវជៀវ** និង**តៀវហៀន** ហើយឲ្យអញ្ជើញចូលមក នោះឈ្មោះទាំងពីរក៏បានចូលមករក**ស៊ុនសេក** ៗក៏ពណ៌នារឿងរ៉ាវទាំងពួងឲ្យស្តាប់។ **តៀវជៀវ,** **តៀវហៀន**ព្រមចូលធ្វើរាជការជាមួយនឹង**ស៊ុនសេក** ៗក៏តាំង**តៀវជៀវ**ជាធំ ត្រួតទាហានឆ្វេងស្តាំ តាំង**តៀវហៀន** ជាទីប្រឹក្សា លុះប្រជុំគ្នារួចស្រេចហើយ ក៏ប្រុងប្រៀបរៀបនឹងលើកទ័ពទៅវាយ**ឡៅអ៊ីវ**នៅតំបន់ខយ៉ុកឱ។

ឯ**ឡៅអ៊ីវ**នោះ កាលពីដើមនៅស្រុកអេងជីវ ក្រោយមកនៅស្រុកឈីវឈុន កាលគ្រា**អ៊ួនសុត**លើកទ័ពមកច្បាំង ក៏រត់មកតាំងនៅតំបន់ខយ៉ុកឱ លុះដឹងថា**ស៊ុនសេក**លើកទ័ពមក ទើបហៅទីប្រឹក្សាមកប្រជុំគិតគ្នាថា ឥឡូវ**ស៊ុនសេក**លើកទ័ពមកហើយ តើយើងនឹងគិតធ្វើដូចម្តេច? **តៀវអេង**នាយទាហានក៏ឆ្លើយទទួលយកអាសាថា ខ្ញុំនឹងសុំកងទ័ពទៅតាំងនៅតំបន់ងីវជូ ទីនោះមានទំនងស្រួល ព្រោះជាទីទំនាប សូម្បី**ស៊ុនសេក**នឹងលើកទ័ពមកប៉ុន្មានរយម៉ឺនក៏ល្មមនឹងតស៊ូបាន។

**ថៃស៊ូជូ**បានឮ**តៀវអេង**និយាយឲ្យយល់ឃើញត្រូវ ចេញទទួលយកអាសាសុំទាហានលើកទៅជាទ័ពស្រួច។ **ឡៅអ៊ីវ**មិនព្រម ដោយនិយាយថា ខ្លួនឯងនៅក្មេងសេចក្តីណាស់ បើនឹងតាំងជានាយទ័ពក៏នៅមិនទាន់ទុកចិត្ត។ **ថៃស៊ូជូ**ខឹងណាស់ក៏នៅស្ងៀម **ឡៅអ៊ីវ**ក៏ចាត់ចែងសេនាទាហានឲ្យ**តៀវអេង**ទៅច្បាំងនៅតំបន់ងីវជូ។ **តៀវអេង**ក៏តាំងទ័ពខ្ជាប់ខ្ជួន ហើយក៏ហ្វឹកហាត់ទាហាន ហើយប្រមូលយកស្រូវមកដាក់ជង្រុកទុកនៅតំបន់តេកោះ ប្រហែលមួយម៉ឺនថាំង។

ឯ**ស៊ុនសេក**លុះលើកកងទ័ពទៅឈប់នៅតំបន់ងីវជូ ក៏ជួបប្រទះនឹងទ័ព**តៀវអេង** ៗស្រែកជេរជាពាក្យអាស្រូវភាសផ្សេងៗឲ្យ**ស៊ុនសេក** ៗខឹងណាស់ក៏ប្រើ**អ៊ុយកាយ**ចេញទៅតយុទ្ធនឹង**តៀវអេង**បានប្រាំភ្លែង។

ក្នុងខណៈនោះ ឈ្មោះ**ធីវឃឹម**ជាពួកស្រុកឈើវឈុន និង**ធីវថាយ**ជាពួកស្រុកហែឈ ដែលធ្វើជាចោរក្នុងព្រៃ លុះឮដំណឹងថា**ស៊ុនសេក**ជាមនុស្សមានប្រាជ្ញាត្រិះរិះគិត ចិត្តក៏ល្អនឹងអាណាប្រជានុរាស្ត្រ មេចោរទាំងពីរនេះក៏នាំបក្សពួកប្រហែលបីរយនាក់ លើកមកប្រាថ្នានឹងចូលទៅជាពួក**ស៊ុនសេក** លុះមកដល់តំបន់ធីវជូ ឃើញ**ស៊ុនសេក** និង**តៀវអេង**កំពុងច្បាំងគ្នាជាប់ដៃ **ធីវឃឹម, ធីវថាយ**ក៏លបចូលទៅដុតភ្លើងក្នុងបន្ទាយ**តៀវអេង** ទាហានក្នុងបន្ទាយឃើញភ្លើងឆេះរាលឡើង ក៏រត់ទៅប្រាប់**តៀវអេង** ៗភ័យស្លុតក៏រត់ពីក្នុងស្នាមចម្បាំងចូលមកក្នុងបន្ទាយ។ **ស៊ុនសេក**ឃើញបានការ ក៏បរពលចូលទៅដេញកាប់ទ័ព**តៀវអេង** ៗចូលបន្ទាយមិនទាន់ ក៏រត់ចោលទាហាន ពានកាត់ព្រៃត្រឡប់ទៅដល់តំបន់ខយ៉ុកឱវិញ។ ពេលនោះ**ស៊ុនសេក**ឲ្យទាហានរើសយកបានគ្រឿងសាស្ត្រាវុធ និងរបស់ទ្រព្យសព្វវត្ថុទាំងពួងជាច្រើនក្រៃលែង ហើយតាំងបញ្ចុះបញ្ចូលទាហានបានប្រហែលបួនពាន់ប្លាយ រួចលើកទៅបោះទ័ពផ្ទាប់ភ្នំខយ៉ុកឱ។

ឯ**ឡៅអ៊ីវ** កាលឃើញ**តៀវអេង**បែកទ័ពត្រឡប់មក ក៏ខឹងណាស់ថា "ខ្លួនសុំទទួលយកអាសាចេញទៅធ្វើការនឹង**ស៊ុនសេក** ហេតុម្តេចក៏បែកទ័ពត្រឡប់មកតែខ្លួន" ថាហើយបង្គាប់ទាហានឲ្យចាប់**តៀវអេង**យកទៅសម្លាប់។ ខណៈនោះ**ឆុកយ៉ុង, ស៊ីឡេ**ជាទីប្រឹក្សាក៏នាំគ្នាទៅអង្វរ**ឡៅអ៊ីវ**ថា **តៀវអេង**ជាសេនាមានថ្វីដៃខ្លាំងពូកែ បើលោកឲ្យយកទៅសម្លាប់គ្រានេះ ដឹងទៅដល់**ស៊ុនសេក**ហើយក៏នឹងបានចិត្តឥតកោតខ្លាច។ ឥឡូវខ្ញុំសុំឲ្យ**តៀវអេង**លើកទ័ពទៅតាំងនៅស្រុកកងឡេងម្តងទៀត ដើម្បីនឹងចាំទទួលទ័ព**ស៊ុនសេក**យកជ័យជម្នះឲ្យបាន។ **ឡៅអ៊ីវ**បានស្តាប់ក៏ត្រឡប់លើកទោសព្រមឲ្យ**តៀវអេង**លើកកងទ័ពទៅតាំងតាមពាក្យ**ឆុកយ៉ុង, ស៊ីឡេ**ថានោះ។ តែ**ឡៅអ៊ីវ**

នៅមិនទុកចិត្ត ខ្លាច**ស៊ុនសេក**នឹងលើកទាហានពីខាងជើងមក ក៏លើកទ័ពទៅតាំងនៅជើងភ្នំស៊ិនតេងខាងទិសឯជើង។

**ស៊ុនសេក**លើកទ័ពទៅតំបន់ភ្នំស៊ិនតេង ក៏បោះទ័ពផ្ទាប់ជើងភ្នំខាងត្បូង ហើយឲ្យរកហៅអ្នកស្រុកសួរថា ទីភ្នំស៊ិនតេងនេះមានរោង (សាល) ទេពារក្សឬទេ? អ្នកស្រុកប្រាប់ថា មាននៅលើកំពូលភ្នំ។ **ស៊ុនសេក**និយាយថា កាលពីយប់មិញយើងយល់សប្តិឃើញថា មានទេពារក្សឲ្យមករកយើងឡើងទៅ ឥឡូវនេះយើងនឹងឡើងទៅគោរពទេពារក្សនោះសិនទើបគួរ។ **តៀវជៀវ**ហាមឃាត់ថា ដែលលោកនឹងទៅនោះ ខ្ញុំឃើញមិនស្រួលទេ ខ្លាច**ឡៅអ៊ីវ**ដឹងនឹងលើកទាហានឡើងទៅចាំស្កាត់ ធ្វើអន្តរាយដល់លោកពុំខាន។ **ស៊ុនសេក**មិនស្តាប់ក៏ចាប់ទូនឡើងជិះសេះ ទៅជាមួយនឹងទាហានដប់ពីរនាក់ឡើងទៅដល់រោង (សាល) ទេពារក្ស ហើយក៏ធ្វើអភិវាទមនស្សការបន់ស្រន់ថា "បើខ្ញុំបានស្រុកកាំងតាំងសម្រេចដូចចិត្តគិតវេលាណា ខ្ញុំនឹងឡើងមកធ្វើពលីកម្មបូជាវេលានោះ"។ លុះបន់ស្រន់ហើយ ក៏ចុះចាកទីនោះមកដល់កណ្តាលផ្លូវ បែរទៅពិគ្រោះនឹងទាហានទាំងពួងថា យើងចង់ទៅលបមើលទ័ព**ឡៅអ៊ីវ**និងក្បួនដូចម្តេចខ្លះ។ ទាហានទាំងអស់ក៏ហាមឃាត់ **ស៊ុនសេក**មិនស្តាប់ ក៏បរសេះនាំទាហានដប់ពីរនាក់ជ្រៀតចេញទៅតាមជើងភ្នំ។

ឯទាហាន**ឡៅអ៊ីវ**ឃើញ**ស៊ុនសេក**ច្បាស់ ក៏រូតរះទៅប្រាប់**ឡៅអ៊ីវ**ថា ឥឡូវ**ស៊ុនសេក** និងទាហានប្រមាណដប់មួយឬដប់ពីរនាក់កន្លងឡើងមកលើកំពូលភ្នំ។ **ឡៅអ៊ីវ**ដឹងសេចក្តីហើយក៏គិតសង្ស័យថា ដែល**ស៊ុនសេក**ឡើងទៅលើភ្នំនោះប្រហែលប្រើឧបាយបញ្ឆោតយើងជាកលសឹកទេដឹង យើងកុំទៅឡើយ។ **ថៃស៊ូជូ**ឆ្លើយឡើងថា "គ្រានេះបានការល្អហើយ ហេតុម្តេចមិនគិតចាប់ខ្លួន**ស៊ុនសេក** លោក

នឹងបង្អង់ដល់ណាទៅទៀត?" ថាហើយ**ថៃស៊ូជូ**ក៏កាន់ទួនឡើងជិះសេះចេញទៅបញ្ឈរនៅមុខបន្ទាយ ហើយស្រែកប្រកាសដល់ទាហានទាំងពួងថា ឥឡូវនឹងចេញទៅចាប់ខ្លួន**ស៊ុនសេក** អ្នកឯណាដែលមានថ្វីដៃខ្លាំងពូកែ ស្ម័គ្រចិត្តចូលធ្វើការជាមួយនឹងយើងក៏ឲ្យប្រញាប់ចេញមុខមក។ ទាហានទាំងពួងក៏នៅស្ងៀម មានទាហានម្នាក់សរសើរថា **ថៃស៊ូជូ**មានថ្វីដៃខ្លាំងពូកែមែន យើងសុំទៅជាមួយផង ហើយក៏ឡើងជិះសេះតាម**ថៃស៊ូជូ**ទៅ។ **ថៃស៊ូជូ**ពីរនាក់នឹងទាហាននោះក៏បរសេះឡើងទៅលើភ្នំ ទាហានក្នុងបន្ទាយទាំងប៉ុន្មានក៏បបួលគ្នាតាមមើល ហើយនាំគ្នាសើច។ ឯ**ស៊ុនសេក**នោះ លុះក្រឡេកឃើញក្បួនទ័ព**ឡៅអ៊ីវ**សព្វគ្រប់ហើយ ក៏ញាក់សេះចុះពីលើភ្នំមកប្រទះនឹង**ថៃស៊ូជូ** ៗស្រែកថា **ស៊ុកសេក**ឯងរត់ទៅណា? **ស៊ុនសេក**ក្រឡេកមើលក្រោយឃើញទាហានពីរនាក់បំផាយសេះតាម **ស៊ុនសេក**ក៏ឲ្យទាហានបង្អង់នៅក្បែរភ្នំ ខ្លួនឯងក៏បញ្ឈរសេះពីមុខទាហាន **ថៃស៊ូជូ**មកជិតហើយស្រែកសួរថា នរណាឈ្មោះ**ស៊ុនសេក**នោះ? **ស៊ុនសេក**ឆ្លើយថា អញឈ្មោះ**ស៊ុនសេក** ចុះខ្លួនឯងឈ្មោះអ្វី? **ថៃស៊ូជូ**ឆ្លើយថា អញឈ្មោះ**ថៃស៊ូជូ**នឹងមកចាប់ខ្លួនឯង។ **ស៊ុនសេក**សើចហើយថា ឯងមកចាប់អញតែពីរនាក់នេះអញមិនខ្លាចទេ បើត្រឡប់ខ្លាច វិញមិនពេញជាជាតិទាហាន។ **ថៃស៊ូជូ**ឆ្លើយថា អញតែម្នាក់គត់ ឲ្យឯងដប់ពីរនាក់ចេញមកតចុះអញមិនខ្លាចទេ។ **ស៊ុនសេក**ខឹងណាស់បរសេះចូលប្រយុទ្ធនឹង**ថៃស៊ូជូ**បានប្រាំភ្លួង **ថៃស៊ូជូ**ឃើញកម្លាំងនិងថ្វីដៃ**ស៊ុនសេក**ខ្លាំងពូកែពេក ក៏ក្រឡះពាក់សេះថយរត់ទៅ។

**ស៊ុនសេក**ស្រែកថា តស៊ូគ្នាមិនបានចាញ់ឈ្នះម្ដេចក៏ត្រឡប់រត់ទៅដូច្នេះ នេះហៅថាមិនមែនជាតិទាហានទេ។ **ថៃស៊ូជូ**ធ្វើជាមិនឮក៏ប្រឹងបំផាយសេះបញ្ឆោតឲ្យ

ដេញ។ **ស៊ុនសេក**ក៏បរសេះដេញពីក្រោយទៅទាន់នៅតំបន់ផេងឈ្នួន **ថៃស៊ូជូ**ក៏រាមកវិញតយុទ្ធគ្នាបានហាសិបភ្លែង **ស៊ុនសេក**យកទួនចាក់**ថៃស៊ូជូ** ៗយកដៃចាប់ទួនជាប់ហើយយកទួនចាក់**ស៊ុនសេក**វិញ **ស៊ុនសេក**យកដៃចាប់ទួនជាប់ទាំងសងខាង ទាំងពីរនាក់ក៏តន្ត្រាក់ដណ្តើមទួនគ្នាទាល់តែរបូតធ្លាក់ពីលើសេះ ឯទួននោះក៏ភ្លាត់របូតផុតពីដៃទាំងសងខាងនៅតែខ្លួនទទេ ទាំងពីរនាក់ក៏ឡើងដាល់គ្នានឹងដៃទាល់តែក្រើសនិងអាវនោះរហែកដាច់អស់ **ស៊ុនសេក**កន្ត្រាក់យកទួនខ្លីដែលសៀតបង្កប់ពីក្រោយខ្នង**ថៃស៊ូជូ**បាន **ថៃស៊ូជូ**ក៏ដណ្តើមបានមួកពី**ស៊ុនសេក** ៗចាក់**ថៃស៊ូជូ**នឹងទួនខ្លី **ថៃស៊ូជូ**យកមួក**ស៊ុនសេក**រងជាប់ ទទួលទាហានទាំងសងខាងតាមមកទាន់ ទាហាន**ថៃស៊ូជូ**ប្រហែលមួយពាន់ប្លាយ ស្រែកហ៊ោជុំវិញទាហាន**ស៊ុនសេក**តែដប់ពីរនាក់។ **ស៊ុនសេក** និង**ថៃស៊ូជូ**ឃើញទាហានមកទាំងសងខាង ក៏ដោះថយផុតពីគ្នាទាំងសងខាង **ថៃស៊ូជូ**ក៏រត់ចូលទៅក្នុងហ្វូងទាហានកន្ត្រាក់បានទួនមួយ ក៏ឡើងសេះបរចេញមកតនឹង**ស៊ុនសេក** ៗក៏ឡើងសេះកាន់ទួនតស៊ូគ្នាទៀត។ **ស៊ុនសេក**ទាហានតិចណាស់ ក៏តភ្លាងរត់ថយភ្លាង **ថៃស៊ូជូ**ក៏ដេញតាមដល់មាត់បន្ទាយ ទទួល**ជីវយី**ឃើញក៏ឲ្យទាហានចេញទៅជួយ។ **ស៊ុនសេក**ប្រយុទ្ធគ្នានឹង**ថៃស៊ូជូ**ទាល់តែព្រលប់ងងឹតធ្លាក់ព្យុះខ្យល់ភ្លៀងធំក៏នាំគ្នាលើកទាហានចូលបន្ទាយទាំងសងខាង។

ឯ**ស៊ុនសេក**នឹកខ្នាញ់ក្តៅចិត្តដេកមិនលក់ លុះព្រឹកឡើង **ស៊ុនសេក**ក៏លើកទាហានទៅដល់បន្ទាយ**ឡៅអ៊ីវ** ៗក៏លើកទាហានចេញពីបន្ទាយច្បាំងគ្នានឹង**ស៊ុនសេក** ៗបរពលចេញឈរពីមុខទាហាន ហើយយកទួនរបស់**ថៃស៊ូជូ**ដែលដណ្តើមបាននោះលើកឡើងហើយស្រែកចំអកថា កាលពីម្សិលមិញ បើកុំតែ**ថៃស៊ូជូ**រត់រួចទាន់កុំអីនឹងស្លាប់ដោយទួននេះ។ **ថៃស៊ូជូ**ឮហើយក៏លើកមួក**ស៊ុនសេក**ឡើង ហើយស្រែកចំអក

តបថា “នេះក្បាលរបស់អ្នកណា យើងយកបានមក?” ទាំងពីរនាក់ក៏ចំអកឡកឲ្យគ្នាទៅវិញទៅមក។

ទើប**ឡៅអ៊ីវ** បណ្ដេញឲ្យ**ថៃស៊ូជូ**ចេញទៅតយុទ្ធគ្នានឹង**ស៊ុនសេក**ម្ដងទៀត **ផៀផៅ**ឃើញ**ថៃស៊ូជូ**ជិះសេះចេញមក ក៏បរសេះចេញទៅតយុទ្ធនឹង**ថៃស៊ូជូ** ៗក៏ស្រែកឲ្យ**ផៀផៅ**ថា ឯងជាមនុស្សថោកទាបណាស់ មិនសមមកតនឹងអញសោះ ឯងនឹងស្លាប់អសារឥតការ ឲ្យ**ស៊ុនសេក**ចៅហ្វាយឯងចេញមកទើបសមគ្នានឹងដៃអញ **ផៀផៅ**ខឹងណាស់ក៏បរសេះចូលប្រយុទ្ធនឹង**ថៃស៊ូជូ**បានសាមសិបភ្លែង។

កាល**ស៊ុនសេក**លើកទ័ពទៅច្បាំងនឹង**ឡៅអ៊ីវ** **ជីវយី**ក៏លើកទាហានគេចទៅពីក្រោយ ចុះទៅដល់តំបន់ខយ៉ុកឱ វេលានោះ**តាន់ប៊ូ**ពួកស្រុកលោតាំងនាំបក្សពួកចូលមករក**ស៊ុនសេក**នៅតំបន់ខយ៉ុកឱនោះ។ **តាន់ប៊ូ**នេះជាមនុស្សមានកម្លាំងច្រើន រូបធំខ្ពស់ប្រហែលប្រាំហត្ថប្លាយ មុខលឿង វង់ភ្នែកក្រហម លុះដឹងថា**ជីវយី**លើកពលទៅដល់តំបន់ខយ៉ុកឱ **តាន់ប៊ូ**ក៏បើកទ្វារទទួល**ជីវយី** ៗក៏ចូលទៅក្នុងបន្ទាយខយ៉ុកឱ ទាហាន**ឡៅអ៊ីវ**ដែលនៅរក្សាបន្ទាយនោះ ក៏រត់មករក**ឡៅអ៊ីវ** ៗដឹងហើយក៏ភ័យតក់ស្លុតចិត្ត ទើបឲ្យវាយឃ្មោះហៅ**ថៃស៊ូជូ**ៗត្រឡប់ថយទៅដល់**ឡៅអ៊ីវ**។ **ថៃស៊ូជូ**សួរ**ឡៅអ៊ីវ**ថា ខ្ញុំបានច្បាំងនឹង**ផៀផៅ**ជិតនឹងមានជ័យហើយ ហេតុអ្វីលោកវាយឃ្មោះហៅខ្ញុំបាទមកវិញ?

**ឡៅអ៊ីវ**និយាយរ៉ាយរឿងឲ្យ**ថៃស៊ូជូ**ស្ដាប់ ហើយក៏លើកទ័ពទៅរក**ស៊ីឡៅ** និង**ផុកយ៉ុង**នៅតំបន់វូឡេង។ ឯ**តាន់ប៊ូ**ក៏លើកបក្សពួកមករក**ស៊ុនសេក** ប្រាប់ព័ត៌មានដែលបានធ្វើការទាំងឡាយឲ្យ**ស៊ុនសេក**ស្ដាប់គ្រប់ប្រការ។ **តៀវជីវ**ទីប្រឹក្សាក៏ជម្រាប**ស៊ុនសេក**ថា ឥឡូវនេះតំបន់ខយ៉ុកឱក៏មកជារបស់យើង **ឡៅអ៊ីវ**លើកទ័ពរត់

ទៅហើយ សង្គ្រាមយើងក៏មានជ័យជម្នះ ដូច្នេះត្រូវតែយើងលើកតាមទៅទៀត។ **ស៊ុនសេក**ក៏ឃើញត្រូវ ទើបនាំខ្លួន**តាន់ប៊ូ**លើកទាហានទៅតាមទាំងយប់ថ្ងៃ ក៏បានទាន់**ឡៅអ៊ីវ**កណ្ដាលផ្លូវ **ឡៅអ៊ីវ**ក៏ឲ្យ**ថៃស៊ូជូ**ចេញច្បាំង។ **ថៃស៊ូជូ**តទល់កម្លាំងនិងថ្វីដៃ**ស៊ុនសេក**មិនបាន ក៏នាំទាហានដប់ប្រាំនាក់រត់ទៅស្រុកកេងកួន ទ័ព**ឡៅអ៊ីវ**ក៏បែកខ្ញែកទៅតាំងនៅតំបន់ងីវជូ។

ឯ**ផុកយ៉ុង** និង**ស៊ីឡេ** ក៏លើកទ័ពចេញពីបន្ទាយនឹងមកទទួល**ឡៅអ៊ីវ**តែមិនទាន់ ក៏ជួបប្រទះនឹង**ស៊ុនសេក** ៗក៏ប្រើ**តាន់ប៊ូ**ចេញវាយទ័ព**ផុកយ៉ុង**និង**ស៊ីឡេ** អ្នកទាំងពីរក៏បែកខ្ញែកគ្នាទៅដោយខ្លួន ឯ**ផុកយ៉ុង**រត់ទៅតំបន់ងីវជូជួបប្រទះនឹង**ឡៅអ៊ីវ**។ ចំណែក**ស៊ីឡេ**ត្រឡប់ចូលបន្ទាយបានសម្លាប់ទាហានពលទាហាន**ស៊ុនសេក**ប្រហែលហុកសិបនាក់។ **ស៊ុនសេក**ក៏ឲ្យលើកទ័ពត្រឡប់ទៅតាម**ឡៅអ៊ីវ** ៗក៏លើកចេញចាកបន្ទាយ **ស៊ុនសេក**ឃើញពីចម្ងាយក៏ស្រែកថា ឯងរត់ពីអញមក ឥឡូវអញតាមមកទាន់ហើយ ម្ដេចឯងមិនទទួលចាញ់?

**អ៊ីប៊ី**បានឮ**ស៊ុនសេក**ថាដូច្នោះ ក៏ស្ទុះជិះសេះចេញមកតទល់នឹង**ស៊ុនសេក**បានបីភ្លែង **ស៊ុនសេក**ចាប់ខ្លួន**អ៊ីប៊ី**បានចងសេកទុក ហើយបរសេះនឹងចូលទៅក្នុងបន្ទាយ។

**វូឡេង**ក្រឡេកឃើញ ក៏បំផាយសេះកាន់ទួនចូលទៅដណ្ដើមយកខ្លួន**អ៊ីប៊ី** ទាហាន**ស៊ុនសេក**ឃើញ**វូឡេង**ស្ទុះទៅជិតខ្លួន**ស៊ុនសេក** ក៏ស្រែកប្រាប់**ស៊ុនសេក** ៗក្រឡេកឃើញក៏ស្រែកគំហកដូចរន្ទះ **វូឡេង**ភ្ញាក់ធ្លាក់ពីលើសេះបែកក្បាលស្លាប់។ **ស៊ុនសេក**បំផាយសេះទៅដល់មុខបន្ទាយហើយស្រាយចំណង**អ៊ីប៊ី**ចេញ **អ៊ីប៊ី**ក៏អស់ជីវិតស្លាប់នៅទីនោះ ទាហានទាំងពួងក៏សរសើរថ្វីដៃ**ស៊ុនសេក**ថា មានកម្លាំងខ្លាំង

ពូកែនឹងរកអ្នកឯណាស្មើគ្នា។ បណ្ដាសេនាទាហានក៏ហៅ**ស៊ុនសេក**ថា **សៀវអង** គឺមហាឧបរាជ។

ឯ**ឡៅអ៊ីវ**ដែលខូចខាតរេហ៍ពលជាច្រើនក្រៃលែង ក៏នាំ**ឆុកយ៉ុង**រត់ទៅនៅស្រុកអ៊ីចៀង។ **ស៊ុនសេក**ក៏លើកទ័ពត្រឡប់មកព័ទ្ធបន្ទាយ**ស៊ីឡៀ**ទុកយូរថ្ងៃ ឲ្យទាហានស្រែកហៅ**ស៊ីឡៀ**ចេញមកតស៊ូ។ **ស៊ីឡៀ**ក៏ឡើងទៅ**មើល**លើជើងបន្ទាយយកធ្នូបាញ់ត្រូវជើង**ស៊ុនសេក**ធ្លាក់ពីលើសេះ។ ទាហានឃើញដូច្នោះ ក៏នាំគ្នាស្ទុះទៅគ្រាហ៍នាំចូលបន្ទាយ ឲ្យពេទ្យរក្សារបួស**ស៊ុនសេក**ជាយូរថ្ងៃទើបសះ។ **ស៊ុនសេក**ក៏នឹកគិតរកឧបាយឲ្យទាហានថយបន្ទាយអំពីទីនោះ ហើយឲ្យនាំគ្នាយំសោកថា **ស៊ុនសេក**ត្រូវព្រួញស្លាប់។ លុះវេលាយប់ **ស៊ុនសេក**ក៏ញែកទាហានចេញទៅបង្កប់ទុកជាបួនកង។ **ស៊ីឡៀ**មិនបានដឹងជាកលឧបាយសម្គាល់ថា **ស៊ុនសេក**ស្លាប់ប្រាកដ លុះពេលយប់ស្ងាត់ក៏នាំ**តៀវអេង,** **តាន់ហេង**លើកទាហានចេញទៅចាប់ទាហាន**ស៊ុនសេក**។ ឯពួកទាហានដែលបង្កប់គ្រប់កន្លែងឃើញ**ស៊ីឡៀ**ចេញចោលបន្ទាយ ក៏បបួលគ្នាស្រែកហ៊ោព័ទ្ធ**ស៊ីឡៀ**ជាប់ជុំវិញ **ស៊ុនសេក**ក៏បរសេះកាន់ទួនទៅឈរមុខទាហាន ឲ្យ**ស៊ីឡៀ**ឃើញហើយស្រែកថា អញឈ្មោះ**ស៊ុនសេក**។ ទាហាន**ស៊ីឡៀ**ក៏ភ័យស្លុតនាំគ្នារត់ចោលសាស្ត្រាវុធទាំងអស់មិនបានតស៊ូ នៅតែ**ស៊ីឡៀ,** **តៀវអេង** និង**តាន់ហេង**ឈរកាន់ទួន ទាហាន**ស៊ុនសេក**ក៏ស្ទុះស្រចូលទៅសម្លាប់**ស៊ីឡៀ**ស្លាប់។ **តាន់ប៉ូ**ក៏រត់ចូលទៅចាក់**តៀវអេង**ធ្លាក់ពីលើសេះស្លាប់ **ជីវឃីម**ក៏យឹតធ្នូបាញ់ទៅត្រូវ**តាន់ហេង**ស្លាប់ទៅទៀត។

**ស៊ុនសេក**ក៏លើកទ័ពចូលបន្ទាយ**ស៊ីឡៀ**បាន តាំងបញ្ចុះបញ្ចូលទាហាន**ស៊ីឡៀ**បានជាច្រើន ហើយក៏លើកទៅតាម**ថៃស៊ូជួង**ស្រុកកេងកួន។ កាលទៅដល់ស្រុក

នោះក៏បោះទ័ពផ្ទាប់កំពែងស្រុក ហើយប្រឹក្សានឹង**ជីវយី**ថា ធ្វើម្តេចនឹងចាប់ខ្លួន**ថៃស៊ូជួ**បាន? **ជីវយី**ជម្រាបថា សុំឲ្យលោកលើកទាហានចូលវាយស្រុកជាបីប៉ែក បើកទុកមួយប៉ែក ហើយឲ្យទាហានទៅបង្កប់នៅពីមុខស្រុក ចម្ងាយមួយទំហឹងសេះ យកព្នួរចងសន្ទឹងរាំងផ្លូវចាំចាប់**ថៃស៊ូជួ** ធ្វើដូច្នេះឃើញនឹងបានដោយងាយ។ **ស៊ុនសេក**យល់ឃើញត្រូវ លុះដល់ពេលយប់ក៏លើកទ័ពចូលវាយស្រុកនោះជាបីប៉ែក បើកទុកមួយប៉ែក។

ឯ**ថៃស៊ូជួ**ក៏នឹកតូចចិត្តណាស់ ថាកាលនឹងលើកទាហានចេញតយុទ្ធនឹង**ស៊ុនសេក**ទាហានក៏មានតិច មានប្រហែលតែមួយពាន់ប្លាយ ហើយសុទ្ធតែមិនប្រសប់ក្នុងការសង្គ្រាម ព្រោះជាពួកព្រៃលើ។ **ថៃស៊ូជួ**គិតហើយ ក៏បើកទ្វារបន្ទាយរត់ចេញទៅទិសឯកើត ទាហានក៏លើកដេញតាម ហើយក្លែងញែកគ្នាឲ្យ**ថៃស៊ូជួ**រត់រហូតទៅតាមផ្លូវដែលគិតទុកនោះ **ថៃស៊ូជួ**ក៏ប្រាសចោលទាហានរត់ចេញទៅ សេះនោះក៏ប៉ះជាប់នឹងព្នួរដែលចងសន្ទឹងទទឹងផ្លូវដួលចុះ ទាហានដែលបង្កប់ប្របនោះ ក៏ចេញស្រមកចោមរោមចាប់**ថៃស៊ូជួ**ចងបានហើយនាំទៅឲ្យ**ស៊ុនសេក** ៗឃើញក៏រត់ទៅស្រាយចំណងចេញ ហើយទាញដៃឲ្យអង្គុយនិយាយគ្នាថា **ឡៅអ៊ីវ**ចិញ្ចឹមរក្សាអ្នកមិនសួននឹងគុណបំណាច់ទេ បើអ្នកចូលចិត្តមកនៅធ្វើការនឹងយើង ៗនឹងចិញ្ចឹមរក្សាអ្នកឲ្យប្រពៃជាង**ឡៅអ៊ីវ**។

**ថៃស៊ូជួ**បានឮ**ស៊ុនសេក**និយាយដូច្នោះ ក៏មានសេចក្តីត្រេកអរជាពន្លឹក ហើយគិតក្នុងចិត្តថា **ស៊ុនសេក**មិនមានសេចក្តីអាឃាតព្យាបាទដល់ខ្លួនអញទេ ទើបថាខ្ញុំសុំស្ម័គ្រចូលធ្វើរាជការនឹងលោកតទៅ។ **ស៊ុនសេក**ចាប់ដៃ**ថៃស៊ូជួ**ហើយសើចថា កាលគ្រាយើងច្បាំងគ្នានៅតំបន់ស៊ិនតេងនោះ បើប្រសិនជាអ្នកចាប់យើងបានប្រហែល

នឹងសម្លាប់យើងឬអ្វី? **ថៃស៊ូជូ**ឆ្លើយតបថា ការនោះនឹងនិយាយមិនត្រូវទេ។ **ស៊ុនសេក**និង**ថៃស៊ូជូ**បបួលគ្នាអស់សំណើចទាំងពីរនាក់ រួចឱ្យរៀបតុលៀងអាហារព្រមទាំងសេនាទាហានទាំងពួង ក៏បរិភោគជាមួយគ្នា។ **ថៃស៊ូជូ**និយាយថា ស្ម័គ្របក្សពួក**ឡៅអ៊ីវ**ក៏នៅព្រាត់ប្រាសនិរាសគ្នាទៅផ្សេងៗ ខ្ញុំសុំលាលោកទៅបញ្ចុះបញ្ចូលប្រមូលយកមកជាពួករបស់យើង នឹងបានជាកម្លាំងធ្វើការតទៅ ឬលោកមិនជឿខ្ញុំទេ?

**ស៊ុនសេក**តបថា ខ្ញុំជឿណាស់ទៅហើយ តែបើអ្នកចេញទៅព្រឹកស្អែក ដល់ពេលថ្ងៃត្រង់ឱ្យស្រួតត្រឡប់មកវិញ ខ្ញុំនៅចាំនៅទីនេះ។ **ថៃស៊ូជូ**ទទួលពាក្យហើយក៏គំនាប់លាចេញទៅ ឯទីប្រឹក្សាទាំងអស់និយាយជម្រាប**ស៊ុនសេក**ថា លោកបើកលែងឱ្យ**ថៃស៊ូជូ**ចេញទៅដូច្នេះ ប្រហែលមិនវិលត្រឡប់មកវិញទេ។ **ស៊ុនសេក**តបថា **ថៃស៊ូជូ**ជាមនុស្សសុចរិតល្អណាស់ បានទទួលពាក្យប្ដេជ្ញានឹងយើងដូច្នេះហើយដែលនឹងមិនត្រឡប់មកវិញនោះ យើងមិនឃើញផងទេ។ ទីប្រឹក្សាទាំងអស់គ្នានៅតែមិនអស់សង្ស័យ ដោយកោតញញើត**ស៊ុនសេក**ហើយក៏ស្ងៀមនៅ។ លុះព្រឹកឡើងក៏នាំគ្នា យកឈើទៅបោះបញ្ឈរនៅមុខបន្ទាយ ដើម្បីនឹងចាំចាប់ពិរុទ្ធវៀចរបស់**ថៃស៊ូជូ**។ លុះដល់ពេលសន្ធតស្រមោលត្រង់ ក៏នាំស្ម័គ្របក្សពួកមកដល់បន្ទាយមួយពាន់ប្លាយ។ ទាហានទាំងពួងឃើញ**ថៃស៊ូជូ**មកដល់បន្ទាយដូចពាក្យ**ស៊ុនសេក**និយាយ ក៏បបួលគ្នាសរសើរ**ស៊ុនសេក**ថា ស្គាល់មនុស្សវៀចត្រង់ក្នុងដួងចិត្តជាប្រាកដ។

**ស៊ុនសេក**បានសេនាទាហានប្រហែលបីម៉ឺន ក៏លើកព្យុហៈទ័ពទៅនៅស្រុកកាំងតាំង បណ្ដាមនុស្សម្នាមហាជនក្នុងស្រុកនោះ លុះឃើញ**ស៊ុនសេក**ចូលទៅដល់ក៏បបួលគ្នាស្ម័គ្រចិត្តចូលមកនៅជាបក្សពួក**ស៊ុនសេក**ទាំងអស់។ **ស៊ុនសេក**ដាក់អាជ្ញាហាមប្រាមសេនាទាហាន មិនឱ្យទៅបៀតបៀនអាណាប្រជានុរាស្ត្រឱ្យមាន

សេចក្ដីក្ដៅក្រហាយ។ មនុស្សទាំងឡាយក៏នៅជាសុខក្សេមក្សាន្ត មានពាក្យហៅ**ស៊ុនសេក**ថា **ស៊ុនល្លួង ខ្លះ**ក៏នាំយកសុរាមានទាំងចំណីអាហារគ្រឿងបរិភោគ នាំមកជូនជាជំនូន**ស៊ុនសេក** ៗក៏ឲ្យគំនាប់ទៅវិញជាមាសប្រាក់សំពត់អាវសារស្បៃតាមតម្លៃដ៏សមគួរដល់បណ្ដាជនទាំងពួង។ តែបណ្ដាទាហានរបស់**ឡៅអ៊ីវ**ដែលនៅក្នុងស្រុកកាំងតាំងនោះ នរណានឹងស្ម័គ្រចិត្តចូលមកធ្វើការជាមួយ**ស៊ុនសេក**ៗចិញ្ចឹមរក្សាតាមគួរសម នរណាមិនព្រមនៅដោយបង្ខំ **ស៊ុនសេក**ក៏ឲ្យមាសប្រាក់គ្រឿងសម្លៀកបំពាក់គ្រប់គ្នា ហើយបើកឲ្យលាទៅនៅរកស៊ីធ្វើការតាមភូមិលំនៅ។ កិត្តិស័ព្ទក៏រន្ទឺឮទូទៅថា **ស៊ុនសេក**ជាមនុស្សល្អគួរជាទីពឹងដល់ជនទាំងពួង។

**ស៊ុនសេក**ក៏ចាត់ប្រើទាហានទៅទទួលមាតានិងមា ហើយនិងប្អូនប្រុសស្រីមកទុកនៅតំបន់ខយ៉ុកឱ ហើយតាំង**ស៊ុនគួន**ជាប្អូនប្រុសនិង**ជីវថាយ**ឲ្យទៅឈររក្សាស្រុកហ្លួនសៀ ខ្លួន**ស៊ុនសេក**ក៏លើកសេនាទាហានទាំងពួងទៅវាយស្រុកតងង៉។

គ្រានោះ **ង៉ៀមប៉ែះហ**ដែលតាំងខ្លួនឡើងជាស្ដេចហៅថាតិកអងនៅស្រុកតងង៉ ភ្នំទាហានឲ្យលើកទៅរក្សាស្រុកនៅតំបន់អសេង, **កែហ៊ុន**ដែលជាដែនស្រុកតងង៉ ចាត់ចែងរៀបចំស្រុកជាស្រេច ក៏មានទាហានទៅប្រាប់ថា **ស៊ុនសេក**លើកទ័ពមក **ង៉ៀមប៉ែះហ**ក៏ប្រើប្អូនប្រុសឈ្មោះ**ង៉ៀមអ៊ី** លើកទ័ពទៅតាំងនៅស្ពានហងកៀវជាផ្លូវសំខាន់ **ង៉ៀមអ៊ី**ជិះសេះកាន់គ្រប៊ីឈរចាំ**ស៊ុនសេក**នៅលើស្ពាន។ ទាហានយកសេចក្ដីទៅប្រាប់**ស៊ុនសេក**ថា **ង៉ៀមអ៊ី**លើកទ័ពមកចាំច្បាំងនឹងលោកនៅលើស្ពាន។

**ស៊ុនសេក**បង្គាប់ទាហានថា យើងត្រូវលើកទ័ពទៅច្បាំងនឹង**ង៉ៀមអ៊ី**វេលានេះ។ **តៀវហៀន**ទីប្រឹក្សាជម្រាបថា ទាហានដែលមានថ្មីដែក៏ច្រើនខ្លួនមិនគួរលោកចេញទៅច្បាំងខ្លួនឯងទេ បើលោកទៅបីដូចយកមាសទៅដុសនឹងថ្ម។

**ស៊ុនសេក**យល់ឃើញត្រូវ ក៏ប្រើ**ហាន់តុង**លើកទាហានទៅតនឹង**ងៀមអ៊ី**លើស្ពាន ហើយឱ្យ**តាន់ប៊ូ, ជីវឃើម**ចុះទូកតូចមួយ យកធ្នូបាញ់ចម្រុះផ្ទប់ទាំងសងខាងស្ពាន។ **ងៀមអ៊ី**ខូចខាតទាហានជាច្រើនក៏ថយទ័ពត្រឡប់ចូលទៅក្នុងស្រុកវិញ **ហាន់តុង**ក៏ដេញសង្កៀញទៅទល់នឹងជើងកំពែង។ **ស៊ុនសេក**លើកកងទ័ពចូលឡោមព័ទ្ធជុំវិញស្រុកតងង៉ទាំងផ្លូវគោក ទាំងផ្លូវទឹកដល់បីថ្ងៃ មិនបានឃើញអ្នកឯណាចេញមកតស៊ូ។ **ស៊ុនសេក**ក៏លើកទាហានដើរមើលជុំវិញកំពែងស្រុក ហើយស្រែកថា នរណាចូលមកជាពួកយើងក៏ឱ្យបើកទ្វារចេញមក យើងមិនធ្វើឱ្យអន្តរាយទេ។

ខណៈនោះទាហាន**ងៀមប៉េះហ**ម្នាក់ឈរលើសើនបន្ទាយ បានឮសំឡេង**ស៊ុនសេក**ស្រែកដូច្នោះក៏ខឹងណាស់ យកដៃឆ្វេងច្រត់លើសំយាបសើន យកដៃស្តាំចង្អុលមុខ**ស៊ុនសេក**ហើយស្រែកជេរពីលើសើន។ **ថៃស៊ូជូ**ក្រឡេកឃើញ ក៏តម្លើងធ្នូផ្គងបាញ់ ហើយងាកមកប្រាប់សេនាទាហានថា យើងនឹងដោតដៃអាមនុស្សកំណាចជាប់នឹងសើន។ មនុស្សទាំងពួងងាកមើលទៅក៏ឃើញព្រួញធ្នូដោតដៃទាហាននោះ ក៏នាំគ្នាសរសើរ**ថៃស៊ូជូ**ថាស្ទាត់ធ្នូរកអ្នកណាស្មើគ្មាន។

ឯទាហាន**ចោនាទី**ក្រឡេកឃើញថ្វីដៃ**ថៃស៊ូជូ** ក៏នាំសេចក្តីនោះទៅជម្រាប**ងៀមប៉េះហ** ៗគ្រវីក្បាលហើយថា “បើយើងបានទាហានយ៉ាងនេះតែម្នាក់មកធ្វើការជាមួយផង យើងក៏មិនត្រូវខ្លាចអ្នកឯណាឡើយ” ហើយក៏ប្រឹក្សានឹងទាហានទាំងពួងថា សឹកគ្រានេះធំពន្លឹកក្រៃលែង យើងនឹងគិតប្រការម្តេច? **ងៀមអ៊ី**ឆ្លើយថា ខ្ញុំបាទនឹងសុំយកអាសាចេញទៅនិយាយនឹង**ស៊ុនសេក**ដោយល្អ។ **ងៀមប៉េះហ**ក៏យល់ព្រមផង។ **ងៀមអ៊ី**ក៏ចេញទៅរក**ស៊ុនសេក**ក្នុងបន្ទាយ **ស៊ុនសេក**ឃើញ**ងៀមអ៊ី**ដើរចូលទៅ ក៏ធ្វើជារួសរាយក្រោកឡើងគំនាប់ ហើយអញ្ជើញអង្គុយតាមទីសមគួរ ចាក់

ស្រាឲ្យផឹក លុះ**ងៀមអ៊ី**ស្រវឹងស្រាហើយ **ស៊ុនសេក**ក៏សួរថា **ងៀមប៉េះហ**ជាបងអ្នកឥឡូវនេះនឹងគិតការដូចម្ដេចទៅវិញ? **ងៀមអ៊ី**ឆ្លើយថា បងខ្ញុំនិងទីប្រឹក្សាទាំងពួងពិគ្រោះយល់គ្នាថា នឹងសុំចូលមកអង្វរបែងស្រុកឲ្យលោកពាក់កណ្ដាល។

**ស៊ុនសេក**ឮដូច្នោះខឹងណាស់និយាយថា “ស្រុកតងង៉នេះនៅក្នុងកណ្ដាប់ដៃអញអស់ហើយ ឯងម្ដេចក៏ហ៊ានមកចរចាដូច្នោះ?” ថាហើយក៏ស្រែកហៅទាហានឲ្យចាប់**ងៀមអ៊ី**នឹងយកទៅសម្លាប់ **ងៀមអ៊ី**ឮដូច្នោះក៏ហូតគ្រប៊ីក្រោកឡើងនឹងកាប់**ស៊ុនសេក** ៗហូតគ្រប៊ីដែលសៀតបង្កប់ពីក្រោយនោះគ្រវាសទៅត្រូវ**ងៀមអ៊ី**ដាច់កស្លាប់ ហើយឲ្យទាហានលើកយកក្បាល**ងៀមអ៊ី**ចោលទៅក្នុងកំពែង។ **ងៀមប៉េះហ**ឃើញ ក៏ភ័យស្លុតរន្ធត់ស្មារតីនឹងរិះគិតលើកកងទ័ពចេញទៅច្បាំងនឹង**ស៊ុនសេក**ក៏នឹកកោតញញើត លុះដល់ពេលយប់ស្ងាត់ **ងៀមប៉េះហ**ក៏នាំទាហានបើកទ្វាររត់ចេញទៅ ។

**ស៊ុនសេក**ដឹងថា **ងៀមប៉េះហ**រត់ចោលស្រុកទៅហើយ ក៏ចាត់ប្រើ**អ៊ុយកាយ**ទៅវាយតំបន់កែហ៊ិន ឲ្យ**ថៃស៊ូជូ**ទៅវាយតំបន់អសេង លុះវាយបានស្រុកទាំងពីរតំបន់នេះហើយ **ស៊ុនសេក**ក៏ចាត់ចែងឲ្យបណ្ដារាស្ត្រអ្នកស្រុកតងង៉នៅជាសុខក្សេមក្សាន្ត ហើយក៏លើកទាហានទៅតាម**ងៀមប៉េះហ**ដែលរត់ទៅនោះ។

**ងៀមប៉េះហ**ក្លែងខ្លួនជាចោរព្រៃ នាំស្ម័គ្របក្សពួកលើកទៅដល់តំបន់អ៊ុខង ប្រព្រឹត្តធ្វើចោរកម្មផ្សេងៗ។ **ឡេងឆោ**ពួកស្រុកអ៊ុខង ក៏បបួលកេណ្ឌរាស្ត្រអ្នកស្រុកលើកចេញទៅវាយ **ងៀមប៉េះហ** ៗរត់ឆ្លងទៅត្រើយម្ខាងមាត់ស្ទឹង តាំងបន្ទាយនៅតំបន់សៃសិន ដើម្បីនឹងរំហូតទៅស្រុកហាយខេ។

ឯ**ស៊ុនសេក**ដែលលើកទ័ពតាមទៅនោះ បានទៅដល់តំបន់អ៊ីខង។ **ឡេងឆោ**ដឹងដំណឹង ក៏នាំយកកូនប្រុសពីរនាក់មករក**ស៊ុនសេក**ហើយជម្រាបថា **ង៉ៀមប៉េះហ**រត់សំដៅតាមផ្លូវទៅស្រុកហាយខេ ។ **ស៊ុនសេក**ក៏តាំង**ឡេងឆោ**ជានាយទាហានរងហើយក៏ស្រូតលើកទ័ពទៅតាម**ង៉ៀមប៉េះហ**ទៀត បានលើកទៅទាន់គ្នានៅតំបន់សៃស៊ិន **ង៉ៀកៅ**ក៏បរពលចូលវាយទ័ព**ង៉ៀមប៉េះហ** ៗក៏បែកទ័ពរត់ទៅស្រុកហាយខេ។

ឯ**អងឡួង**ចៅហ្វាយស្រុកហាយខេដឹងថា **ង៉ៀមប៉េះហ**បែកទ័ពរត់មក ក៏ឲ្យប្រមូលទាហាននឹងលើកចេញទៅជួយ**ង៉ៀមប៉េះហ** នោះ**ងីហ្លួន**ពួកស្រុកអ៊ីហៀវដែលជាទីប្រឹក្សានិយាយថា **ស៊ុនសេក**នោះជាមនុស្សមានថ្វីដៃខ្លាំងពូកែ ហើយតាំងនៅក្នុងសេចក្ដីសត្យសុចរិតល្អណាស់ ឯ**ង៉ៀមប៉េះហ**ជាមនុស្សប្រព្រឹត្តទុច្ចរិតអាក្រក់ ហេតុម្ដេចលោកគិតទៅជួយខាងមនុស្សអាក្រក់វិញមិនគួរសោះ សូមឲ្យលោករិះគិតប្រើគំនិតជាកលឧបាយ ចាប់ខ្លួន**ង៉ៀមប៉េះហ**បញ្ជូនទៅឲ្យ**ស៊ុនសេក**វិញប្រសើរជាង។ **អងឡួង**ស្ដាប់មិនត្រូវចិត្តក៏ខឹងណាស់ ស្រែកគំហកឲ្យ**ងីហ្លួន** ៗទាល់គំនិតក៏នៅស្ងៀម។ **អងឡួង**ក៏លើកទាហានចេញទៅជួបនឹង**ង៉ៀមប៉េះហ**ហើយនាំគ្នាទៅតាំងបន្ទាយបោះទ័ពនៅកណ្ដាលវាលស្រែ ក្បែរជើងភ្នំចាំទទួល**ស៊ុនសេក**។

កាល**ស៊ុនសេក**លើកទ័ពទៅដល់បន្ទាយ**ង៉ៀមប៉េះហ** ក៏ក្រឡេកឃើញ**អងឡួង**ជិះសេះឈរនៅមុខទាហានកាន់គ្រប៊ី **ស៊ុនសេក**ស្រែកថា យើងធ្វើការទាំងនេះប្រាថ្នានឹងឲ្យបណ្ដារាស្ត្របានសេចក្ដីសុខ ឯ**ង៉ៀមប៉េះហ**ជាមនុស្សអន្ធពាល ហេតុម្ដេចខ្លួនធ្វើជាចៅហ្វាយស្រុកខ្ញុំរាជការផែនដី ទៅចងមេត្រីនឹងមនុស្សអាក្រក់ទៅវិញ?

**អងឡង**បានឮដូច្នោះ ក៏ស្រែកជេរទៅ**ស៊ុនសេក**ថា ឯងជាមនុស្សលោភក្រៅធម៌ណាស់ ស្វះស្វែងដើរច្បាំងដណ្ដើមយកស្រុកទេសរបស់គេជាច្រើនតំបន់ នៅមិនទាន់អស់ចិត្ត ឥឡូវលើកមកលម្អិតញាំញីក្នុងទីដែនរបស់អញ បានជាអញត្រូវលើកទ័ពមកជួយ**ង៉ៀមប៉េះហ**វិញ ប្រាថ្នានឹងសងសឹកឯងឲ្យបាន។

**ស៊ុនសេក**ខឹងណាស់ ក៏បរសេះចូលប្រយុទ្ធនឹង**អងឡង**បានប្រាំមួយភ្លែង **ថៃស៊ូជូ**ឃើញដូចនោះក៏បរសេះស្ទុះទៅកាត់មុខ**ស៊ុនសេក**។ **ជីវជៀវ**ទាហាន**អងឡង**ក៏ចេញមកតស៊ូនឹង**ថៃស៊ូជូ**បានប្រាំភ្លែង ទទួល**ជីវឃី, ផៀកៅ** លើកទាហានមកទាន់ ក៏ត្រឡប់ទ័ពពីក្រោយឡោមជុំវិញ**អងឡង** ៗក៏នាំ**ង៉ៀមប៉េះហ**រត់ត្រឡប់ចូលស្រុកវិញ ហើយទាញស្ពានទម្លាក់បិទទ្វារជិតយ៉ាងមាំមួន។ **ស៊ុនសេក**ក៏លើកទាហានឡោមព័ទ្ធជុំវិញស្រុកនោះ។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ១៤

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(ចាប់តាំងពី**អ៊ួនសុត**មិនព្រមឲ្យត្រាទៅ**ស៊ុនសេក** ហើយប្រឹក្សារកហេតុរកទំនងនឹងទៅវាយ**ស៊ុនសេក** រហូតដល់**ចូឆូ**លើកទ័ពទៅច្បាំងនឹង**តៀវស៊ីវ** ៗទទួលចំណុះចុះចូលចាញ់**ចូឆូ**)។*

**ឯអ៊ួនសុត**នោះ ចាប់ដើមពីបានត្រាផ្លាក់មកទុក ក៏គិតនឹងតាំងខ្លួនជាស្ដេចជានិច្ច លុះឃើញបម្រើ**ស៊ុនសេក**ទៅទារត្រា ក៏ប្រកែកមិនព្រមឲ្យ។ ទាហានបម្រើក៏លាត្រឡប់មកវិញ យកសេចក្ដីនោះជម្រាប**ស៊ុនសេក**គ្រប់ប្រការ។

ខណៈនោះ **អ៊ួនសុត**ឲ្យហៅ **អៀវតៃជៀង, តៀវហ៊ុន, គីឡេង, តៀវសេង, លុយប៉ុក, តាន់ឡាន់** និងទាហានទាំងពួងមកប្រឹក្សាគ្នាថា **ស៊ុនសេក**នោះកាលពីដើមបាននៅធ្វើការនឹងយើង ៗក៏បានទំនុកបម្រុងឲ្យធ្វើជានាហ្មឺន ហើយសុំទាហានយើងថានឹងជួយមាខ្លួន ដើម្បីនឹងសងបិតា យើងក៏ព្រមឲ្យ **ស៊ុនសេក**បានប្រស្រ័យពីកម្លាំងយើងជាមុន ទើបតាំងខ្លួនឡើងដល់ប៉ុណ្ណេះ។ ឥឡូវ**ស៊ុនសេក**បានធ្វើធំក្នុងត្រើយមាត់ទន្លេកាំងតាំង ត្រឡប់រមិលគុណយើង ប្រើបម្រើទាហានឲ្យមកទារយកត្រាផ្លាក់។ អ្នកទាំងអស់នឹងយល់ដូចម្ដេច ឲ្យយើងបានខ្លួន**ស៊ុនសេក**មកវិញ?

**អៀវតៃជៀង**ឆ្លើយថា **ស៊ុនសេក**បានគ្រប់គ្រងត្រើយទន្លេស្រុកកាំងតាំង ហើយបានទាហានដែលមានថ្វីដៃខ្លាំងពូកែច្រើន ឯដែនស្រុកកាំងតាំងនោះសោត ក៏ធំទូលាយជាងស្រុកយើងទៅទៀត បើយើងនឹងលើកទ័ពទៅតតាំងក៏មិនបាន សុំឲ្យ

លោកលើកទ័ពទៅវាយ**ឡៅពី**ឲ្យបែកសិន បើបានឈ្នះ**ឡៅពី**ហើយ **ស៊ុនសេក**ក៏ត្រូវនៅក្នុងកណ្ដាប់ដៃយើង។

**អ៊ួនសុត**តបថា **ឡៅពី**តាំងទ័ពនៅតំបន់ស្រុកសៀវផាយ ជិតស្រុកឈីជីវ ដែល**លីប៉ោ**នៅនោះ អ្នកទាំងពីរក៏ត្រូវអធ្យាស្រ័យគ្នា ទោះបីយ៉ាងណា **លីប៉ោ**ក៏គង់លើកទ័ពមកជួយ**ឡៅពី** ឃើញថាកម្លាំង**ឡៅពី**នឹងមាំឡើង យើងនឹងធ្វើការគង់មិនសម្រេច បើដូច្នេះត្រូវយើងរិះគិតឧបាយបញ្ចុះបញ្ចូល**លីប៉ោ**ឲ្យត្រូវជើងនឹងយើងសិន។ និយាយហើយ**អ៊ួនសុត**ក៏ចាត់សំបុត្រឲ្យ**ហាន់អ៊ិន**ជាបម្រើ នាំយកស្រូវម្ភៃម៉ឺនថាំងទៅឲ្យ**លីប៉ោ**។ សេចក្ដីសំបុត្រនោះថា **ឡៅពី**ជាមនុស្សអាក្រក់គ្មានសេចក្ដីសត្យ យើងត្រូវកម្ចាត់**ឡៅពី**ចេញ បើប្រសិន**ឡៅពី**មកពឹងកម្លាំងអ្នក ៗកុំជួយធុរៈឡើយ។

ឯ**លីប៉ោ**កាលបានទទួលសំបុត្រ និងរបស់គំនាប់ពី**អ៊ួនសុត**បញ្ជូនទៅពេញចិត្តណាស់ ទទួលតាមពាក្យ**អ៊ួនសុត**គ្រប់ប្រការ។ **ហាន់អ៊ិន**ក៏លា**លីប៉ោ**ត្រឡប់ទៅស្រុកឡាំយ៉ុងវិញ នាំយកសេចក្ដីនោះទៅជម្រាប**អ៊ួនសុត**គ្រប់ប្រការ។ **អ៊ួនសុត**ក៏ចាត់ប្រើ**គីឡេង**ជាមេទ័ពលើកទាហានប្រាំម៉ឺនទៅជាមួយនឹង**លុយប៉ុក**, **តាន់ឡាន់** ទៅស្រុកសៀវផាយ។

**ឡៅពី**ដឹងហើយក៏ប្រឹក្សានឹង**គួនអ៊ូ**, **តៀវហ៊ុយ**, **ស៊ុនខៀន**ថា ឥឡូវ**អ៊ួនសុត**ឲ្យ**គីឡេង**លើកទ័ពមកច្បាំងនឹងយើង តើយើងនឹងគិតដូចម្ដេច? **ស៊ុនខៀន**ឆ្លើយថា ស្រុកសៀវផាយជាស្រុកតូចណាស់ ឃើញថានឹងតទល់នឹងគេមិនបានទេ ទោះបីយ៉ាងណាក៏**លីប៉ោ**មិនបានជួយយើងដែរ។ **ឡៅពី**តបថា “ដែលអ្នកថានេះគួរហើយ តែយើងត្រូវធ្វើតាមពាក្យ**ស៊ុនខៀន**ល្បងចិត្ត**លីប៉ោ**មើលសិន” ហើយក៏ប្រើទាហានកាន់សំបុត្រទៅដល់**លីប៉ោ**ថា “ខ្ញុំ**ឡៅពី**និងស្ម័គ្របក្សពួកទាំងអស់ បានមកតាំងនៅ

ក្នុងស្រុកសៀវផាយនេះបានសេចក្ដីសុខសប្បាយ ក៏ព្រោះបុណ្យគុណរបស់អ្នកជួយឃុំគ្រងជាទីពឹង ឥឡូវ**អ៊្សួនសុត**បានឲ្យទាហានលើកទ័ពមកច្បាំងនឹងខ្ញុំ ៗសម្លឹងមិនឃើញអ្នកឯណានឹងជួយធុរៈខ្ញុំក្នុងរឿងនេះបាន ឃើញតែអ្នកនឹងជួយទុក្ខខ្ញុំបាន ហេតុនេះសុំឲ្យអ្នកលើកកងទ័ពទៅជួយខ្ញុំ”។

**លីប៉ោ**បានទទួលសំបុត្រហើយក៏ពិគ្រោះនឹង**តាន់កុង**ថា ពីដើម**អ៊្សួនសុត**ឲ្យសំបុត្រនឹងស្បៀងមកដល់យើង ដើម្បីកុំឲ្យយើងលើកទ័ពទៅជួយ**ឡៅពី** យើងក៏បានទទួលពាក្យប្ដេជ្ញាជាប្រាកដ ឥឡូវ**ឡៅពី**ក៏មានសំបុត្រមកយើងដែរ ថាឲ្យលើកទ័ពទៅជួយ។ យើងគិតថា **ឡៅពី**នៅក្នុងស្រុកសៀវផាយជិតយើង បើទោះបីយ៉ាងណាក៏មិនធ្វើអន្តរាយដល់យើងទៅមុខទៀត ឯ**អ៊្សួនសុត**វិញ ប្រសិនបើយើងជួយវាយបានស្រុកសៀវផាយហើយ យើងប្រះក្បាលដល់ខ្នើយដេកមិនបានជាប្រក្រតី គង់តែ**អ៊្សួនសុត**នឹងកំរើបចិត្តលើកទ័ពឆ្លងមកវាយស្រុកយើងទៀតមិនខាន។ បើដូច្នេះគួរតែយើងចូលជួយខាង**ឡៅពី**វិញស្រួលជាង។ **តាន់កុង**ស្ដាប់យល់ត្រូវនឹងគំនិត ក៏រួមគ្នាកេណ្ឌកងទ័ពលើកទៅជួយ**ឡៅពី**ក្នុងខណៈនោះ។

លុះ**គីឡេង**លើកទ័ពមកដល់ស្រុកសៀវផាយ ក៏តាំងបន្ទាយបោះទ័ពនៅខាងទិសឯត្បូង។ **ឡៅពី**មានទាហានក្នុងស្រុកប្រហែលប្រាំពាន់ ដឹងថា**គីឡេង**លើកទ័ពមកដល់នឹងកំពែងហើយ ក៏ប្រុងប្រៀបរៀបសេះទាហានមានគ្រឿងសាស្ត្រាវុធព្រមប្រចាំការ។ **គីឡេង**ស៊ើបដំណឹងច្បាស់ថា **លីប៉ោ**លើកទ័ពទៅជួយច្បាំង**ឡៅពី**វិញ ក៏ប្រើទាហានទៅសួរ**លីប៉ោ**ថា ពីដើមអ្នកបានទទួលពាក្យប្ដេជ្ញានឹងចៅហ្វាយយើងថាមិនជួយ**ឡៅពី**ទេ ឥឡូវហេតុម្ដេចអ្នកលើកទ័ពចូលទៅខាងនោះវិញ? **លីប៉ោ**ស្ដាប់ដូច្នោះក៏ឯអង់ ហើយតបថា យើងនឹងគិតត្រិះរិះឲ្យ**អ៊្សួនសុត**និង**ឡៅពី**ធ្វើមេត្រីនឹងគ្នា

លើកលែងអាឃាដព្យាបាទគ្នាតទៅ ត្រូវខ្លួនវិញទៅប្រាប់**គីឡេង**ឲ្យចូលមកជួបនឹងយើងឥឡូវនេះ។ ទាហានក៏លា**លីប៉ោ**ទៅប្រាប់**គីឡេង**តាមការ។ **លីប៉ោ**ក៏ប្រើទាហានទៅអញ្ជើញ**ឡៅពី**ឲ្យចូលមកទៀត។ **គួនអ៊ូ, តៀវហ៊ុយ** និយាយនឹង**ឡៅពី**ថា **លីប៉ោ**និង**អ៊ួនសុត**គប់គិតត្រូវគំនិតគ្នាមកពីដើម ក្រែងឲ្យហៅទៅធ្វើអន្តរាយយើងទេដឹង? **ឡៅពី**តបថា "យើងមានគុណនឹង**លីប៉ោ**ច្រើនណាស់ បើយ៉ាងណា**លីប៉ោ**ក៏មិនមែនធ្វើបទអាក្រក់នឹងយើងទេ" ថាហើយក៏ឡើងសេះទៅរក**លីប៉ោ**ក្នុងខណៈនោះ។ **គួនអ៊ូ, តៀវហ៊ុយ**ក៏តាមជាប់ទៅជាមួយ។ លុះ**ឡៅពី**ទៅដល់បន្ទាយ **លីប៉ោ**ក៏ចេញមកទទួលហើយនិយាយថា គ្រានេះខ្ញុំនឹងជួយអ្នកឲ្យផុតអំពីភ័យអន្តរាយ អំណឹះតទៅអ្នកកុំត្រូវភ្លេចគុណយើងឡើយ។ **ឡៅពី**ក៏ចាប់ដៃ**លីប៉ោ**ចូលទៅក្នុងអង្គុយជាមួយគ្នា។ **គួនអ៊ូ, តៀវហ៊ុយ**ក៏កាន់គ្របីចូលទៅឈរពីក្រោយខ្នង**ឡៅពី**ទទួល**គីឡេង**ទៅដល់ទៀត មានបម្រើចូលទៅប្រាប់**លីប៉ោ**។ **ឡៅពី**ឮដូច្នោះក៏ភ័យស្លុតគិតថា **លីប៉ោ**នឹងធ្វើអន្តរាយ។ **លីប៉ោ**ដឹងអធ្យាស្រ័យក៏ស្រដីថា អ្នកកុំភ័យបារម្ភ ដែលខ្ញុំអញ្ជើញមកនេះ ប្រាថ្នាឲ្យល្អនឹងគ្នាទាំងសងខាង។ **ឡៅពី**ក៏នៅតែមិនអស់សង្ស័យ។

**គីឡេង**ក៏ដើរចូលទៅ ឃើញ**លីប៉ោ**និង**ឡៅពី**អង្គុយជិតគ្នា ក៏ភ័យស្លុតស្មារតីរំពៃថយក្រោយទៅរកទាហាន ។ **លីប៉ោ**ក៏ក្រោកទៅឃាត់ហើយចាប់ដឹកដៃឲ្យចូលទៅអង្គុយលើកៅអីជាមួយគ្នា ។ **គីឡេង**និយាយថា អ្នកគិតការដូច្នេះ នឹងចង់សម្លាប់ខ្ញុំទេឬៗសម្លាប់អា**ឡៅពី**ត្រចៀកយារ? **លីប៉ោ**ឆ្លើយថា ខ្ញុំមិនមែនគិតធ្វើអន្តរាយដល់អ្នកទាំងពីរទេ ព្រោះ**ឡៅពី**និងខ្ញុំដូចជាបងប្អូនបង្កើត ឥឡូវអ្នកលើកទ័ពមកធ្វើអន្តរាយដល់**ឡៅពី**បានជាខ្ញុំលើកទ័ពមកជួយ។ **គីឡេង**តបថា បើដូច្នេះអ្នកមិនចាំសម្លាប់ខ្ញុំទេឬ? បើចង់ឲ្យ**ឡៅពី**បានសេចក្តីសុខ។ **លីប៉ោ**ថា "ខ្ញុំគិតនឹងឲ្យអ្នកទាំង

ពីរបានជាមិត្តមេត្រីនឹងគ្នា ដើម្បីប្រយោជន៍នឹងមិនឲ្យរាស្ត្រប្រជាបានសេចក្តីលំបាក" ថាហើយក៏ទាញដៃ**គីឡេង**ឲ្យអង្គុយជិត**ឡៅពី**។ **លីប៉ោ**ក៏អង្គុយដែកកណ្តាលបបួលគ្នាផឹកស្រា ហើយនិយាយលួងលោមថា អ្នកទាំងពីរបានមកឃើញមុខខ្ញុំវេលានេះ ខ្ញុំសុំកុំឲ្យមានចិត្តអាឃាដព្យាបាទគ្នាតទៅទៀត។ **ឡៅពី**ក៏ស្ងៀម **គីឡេង**ឆ្លើយថា ខ្ញុំជាបម្រើ**អ៊ួនសុត** ៗប្រើខ្ញុំឲ្យមកចាប់ខ្លួន**ឡៅពី**យកទៅ បើខ្ញុំត្រឡប់ទៅវិញទទេ ខ្ញុំក៏មិនរួចពីកំហុស។

**តៀវហ៊ុយ**ខឹងណាស់ ហូតគ្របីឡើងកាន់ហើយស្រែកគំហកថា អ្នកឯងមិនត្រូវមើលងាយយើងៗមិនមែនកូនក្មេងទេ សូម្បីពួកចោរជូតក្បាលលឿងពីគ្រាជាន់មុន ម្តេចក៏មិនអាចមើលងាយបងអញដែរ។ **គួនអ៊ូ**ឃើញ**តៀវហ៊ុយ**ឡូឡា ខ្លាចក្រែងវឹកវរក៏និយាយឃាត់ថា ចាំស្តាប់ទំនង**លីប៉ោ**នឹងនិយាយបានការដូចម្តេច បើកាលណាមិនស្រុះស្រួលគ្នាសឹមយើងធ្វើជាក្រោយ។ **លីប៉ោ**ឃើញអាការៈដូច្នោះក៏និយាយថា "ខ្ញុំឲ្យអញ្ជើញអ្នកទាំងពីរមកជួបនិយាយសម្រួលសម្រុបឲ្យល្អនឹងគ្នាទាំងសងខាង គ្រានេះ**គីឡេង**គេនៅស្ងៀមហើយ ហេតុម្តេច**តៀវហ៊ុយ**មកនិយាយទ្រគោះដូច្នេះ មិនទុកមុខឲ្យខ្ញុំដែលជាធំផង" ថាហើយក៏ធ្វើជាខឹងចាប់ទ្លួនឡើងកាន់ឈរកណ្តាលទីជំនុំនោះ។ **គីឡេង** និង**ឡៅពី**ឃើញដូច្នោះក៏គិតថា **លីប៉ោ**នឹងធ្វើអន្តរាយ។ **លីប៉ោ**ក៏ហៅទាហានឲ្យយកទ្លួនទៅដោតបញ្ឈរទុកពីចម្ងាយ ប្រហែលពីរសិន "២០ ម៉ែត្រ) ហើយថា ខ្ញុំនឹងប្តឹងឲ្យជាក់ច្បាស់ដល់ទេពតាទាំងឡាយលោកជួយគិតចុះ បើប្រសិនខ្ញុំបាញ់ធ្នូទៅមិនត្រូវចុងទ្លួនទេ សុំឲ្យអ្នកទាំងពីរធ្វើសង្គ្រាមនឹងគ្នាតាមការចុះ បើខ្ញុំបាញ់ត្រូវវិញ ឲ្យអ្នកទាំងពីរលើកទ័ពត្រឡប់ទៅតាមពាក្យខ្ញុំឥឡូវនេះ បើខាងណាមិនស្តាប់ខ្ញុំ ៗនឹងធ្វើសង្គ្រាមនឹងអ្នកនោះ។

**គីឡេង**បានឮ**លីប៉ោ**ប្រកាសដូច្នោះមានសេចក្ដីត្រេកអរណាស់ គិតក្នុងចិត្តថា កាលណាឡើយ**លីប៉ោ**នឹងបាញ់ទៅត្រូវចុងទូននោះ ឥឡូវអញទទួលពាក្យទុកតែតាមគួរទៅចុះ បើ**លីប៉ោ**បាញ់មិនត្រូវហើយ អញនឹងបានធ្វើសង្គ្រាមនឹង**ឡៅពី**ដោយងាយ **លីប៉ោ**ក៏ជួយ**ឡៅពី**មិនកើត។ គិតហើយក៏ព្រមទទួលពាក្យនឹង**លីប៉ោ**គ្រប់ប្រការ។ **លីប៉ោ**បបួល**ឡៅពី, គីឡេង**ផឹកស្រាគំនាប់គ្នាទៅវិញទៅមក រួចក៏ចាប់ធ្នូផ្គងយឹតឡើង ហើយក៏ស្រែកឲ្យទាហានទាំងពួងចាំមើល ក៏លែងព្រួញទៅត្រូវចុងទូនដែលដោតបញ្ឈរនោះ ចំគ្មានល្អៀងបន្តិចសោះ ទាហានទាំងឡាយស្រែកហ៊ោសរសើរថ្វីដៃ**លីប៉ោ**ថាចំណាន ស្ទាត់ក្នុងវិជ្ជាបាញ់ធ្នូឥតអ្នកណាស្មើបាន។ **លីប៉ោ**សើចហើយចាប់ដៃ**ឡៅពី** និង**គីឡេង**ថា ខ្ញុំប្ដឹងដល់ទេវតាឃើញប្រាកដស្ដែងយ៉ាងនេះ រួចក៏រៀបតុលៀងអាហារទាំងអស់គ្នា។ **គីឡេង**និយាយថា ឥឡូវខ្ញុំឃើញជាក់ច្បាស់ដល់ការដែលអ្នកប្ដឹងហើយ បើខ្ញុំនឹងលើកទ័ពត្រឡប់ទៅវិញវេលានេះ **អ៊ួនសុត**មុខជាមិនជឿខ្ញុំទេ។ **លីប៉ោ**ថា “អ្នកកុំវិតក្កឡើយ” ហើយ**លីប៉ោ**តែងសំបុត្រមួយច្បាប់ទៅ**អ៊ួនសុត**។ **គីឡេង**ទទួលសំបុត្រហើយក៏លាលើកទ័ពត្រឡប់ទៅស្រុកឡាំយ៉ុង។

**លីប៉ោ**និយាយនឹង**ឡៅពី**ថា គ្រានេះបើខ្ញុំមិនបានមកជួយរិះគិតដោយគំនិតដូច្នេះទេ ខ្លួនអ្នកគង់មានសេចក្ដីព្រួយលំបាកដោយ**គីឡេង**ជាប្រាកដ។ **ឡៅពី**ទទួលគំនាប់**លីប៉ោ** ហើយក៏លាត្រឡប់ទៅស្រុកសៀវផាយ។ **លីប៉ោ**ក៏លើកទ័ពត្រឡប់ទៅស្រុកឈីជីវ។

កាល**គីឡេង**ទៅដល់ស្រុកឡាំយ៉ុងវេលាណា ក៏យកសំបុត្រទៅជូន**អ៊ួនសុត** ហើយពណ៌នាជម្រាបរឿង**អ៊ួនសុត**គ្រប់ប្រការ។ **អ៊ួនសុត**មើលសំបុត្រហើយក៏ខឹងខ្លាំងណាស់ ថា**លីប៉ោ**ចរចាមិនជាសត្យពិតត្រង់ ទើបប្រជុំសេនាទាហានថា យើង

ត្រូវលើកទ័ពទៅចាប់ខ្លួន**ឡៅពី**ឲ្យបាន ហើយនឹងទៅវាយយកស្រុកឈីជីវទៀត។ **គីឡេង**និយាយឃាត់ថា **លីប៉ោ**ជាមនុស្សខ្លាំងពូកែណាស់ សេនាទាហានដែលមានថ្វីដៃក៏ច្រើន លោកនឹងលើកទ័ពទៅគ្រានេះ **លីប៉ោ**និង**ឡៅពី**កំពុងត្រូវគ្នា គង់នឹងលើកទ័ពប្រសព្វគ្នាធ្វើយើងវិញឲ្យលំបាក។ ខ្ញុំឃើញថា យើងគង់នឹងបរាជ័យពុំខាន ការដែលយើងគិតបម្រុងទុកនោះក៏នឹងមិនសម្រេច បើដូច្នេះខ្ញុំសុំឲ្យលោកចាត់បម្រើទៅសុំដណ្ដឹងកូនក្រមុំ**លីប៉ោ** ដែលកើតនឹងនាង**ងៀមស៊ី**នោះមកឲ្យកូនប្រុសលោក **លីប៉ោ**និងលោកក៏នឹងបានស្និទ្ធជិតរាប់អានគ្នា ទោះនឹងប្រាថ្នាចាប់ខ្លួន**ឡៅពី**ក៏នឹងបានដោយងាយ។ **អ៊្វនសុត**គិតយល់ត្រូវ ក៏ចាត់ប្រើ**ហាន់អ៊ិន**ជាបម្រើនាំគ្រឿងបណ្ណាការដ៏មានតម្លៃទៅជូន**លីប៉ោ** សុំដណ្ដឹងបុត្រីតាមសម្ដីដែល**គីឡេង**ថានោះ។

**ហាន់អ៊ិន**ទៅដល់ស្រុកឈីជីវក៏ចូលទៅគំនាប់**លីប៉ោ** លើកបណ្ណាការជូន ហើយជម្រាបថា **អ៊្វនសុត**ជាចៅហ្វាយខ្ញុំបានគិតមេត្រីដល់លោកជានិច្ច ទើបប្រើខ្ញុំបាទនាំយកវត្ថុទាំងអស់នេះមកជូនសុំផ្លូវលោកដើរ គឺសូមចងស្ពានមេត្រីដណ្ដឹងបុត្រីលោកឲ្យជាភរិយាបុត្រ**អ៊្វនសុត** ជាគូស្រករតាមប្រវេណីតទៅ។

**លីប៉ោ**បានស្ដាប់ ក៏ចាប់ចិត្តត្រេកអរទទួលយកជំនូនបណ្ណាការ ហើយក៏ចូលទៅសារស័ព្ទប្រាប់នាង**ងៀមស៊ី**ជាភរិយាពិគ្រោះគ្នា។ នាង**ងៀមស៊ី**ក៏តបថា **អ៊្វនសុត**ជាមនុស្សមានសតិបញ្ញា ទាំងសេនាយោធាក៏មានច្រើន ឯស្រុកឡាំយ៉ុងក៏ជាស្រុកធំ អំណឹះតទៅមុខ **អ៊្វនសុត**ក៏គង់បានជាម្ចាស់ កូនយើងក៏គង់បានធំដោយសារ។ លុះគិតឃើញព្រមគ្នាហើយ **លីប៉ោ**ក៏ចេញមកនិយាយប្រាប់**ហាន់អ៊ិន** “យើងព្រមឲ្យកូនក្រមុំយើងតាម**អ៊្វនសុត**ប្រាថ្នា” ហើយក៏អញ្ជើញ**ហាន់អ៊ិន**បរិភោគអាហារ រួច**ហាន់អ៊ិន**ក៏លា**លីប៉ោ**ត្រឡប់ទៅស្រុកឡាំយ៉ុងវិញ លុះទៅដល់ក៏ចូលទៅជម្រាប

**អ៊្លួនសុត**ថា **លីប៉ោ**ព្រមឲ្យកូនក្រមុំមកលោកហើយ ៗមានចិត្តមេត្រីនឹងលោកណាស់។

**អ៊្លួនសុត**បានឮដូច្នោះ ក៏នឹកថាដែលខ្លួនគិតនោះមុខជានឹងសម្រេចតាមប្រាថ្នា ហើយក៏គាត់តែងរៀបភស្តុភារបណ្ណាការតាមទំនៀម ដែលលើកស្លាជូនពេលា ឲ្យ**ហាន់អ៊ិន**នាំទៅជូន**លីប៉ោ**ម្តងទៀត ដើម្បីនឹងនាំយកខ្លួនកូនក្រមុំ**លីប៉ោ**មកឯស្រុកឡាំយ៉ុង។ **ហាន់អ៊ិន**នាំភស្តុភារចេញទៅ កាលទៅដល់ស្រុកឈើជីរហើយ ក៏នាំភស្តុភារចូលទៅជូន**លីប៉ោ**ហើយជម្រាបថា **អ៊្លួនសុត**មានសេចក្តីត្រេកអរណាស់ ឲ្យខ្ញុំបាទមកសុំយកខ្លួនកូនក្រមុំលោកនាំទៅ។ **លីប៉ោ**ក៏ស្រាកស្រួលទទួលជំនួនភស្តុភារ រៀបភោជនាហារលៀង**ហាន់អ៊ិន** ហើយរៀបទីកន្លែងទទួលភ្ញៀវឲ្យ**ហាន់អ៊ិន**ទទួលដំណេក។ លុះពេលព្រឹក**តាន់កុង**ទីប្រឹក្សា**លីប៉ោ** ក៏ចូលទៅជួបនឹង**ហាន់អ៊ិន** ៗឃើញក៏ក្រោកចេញមកទទួលហើយអញ្ជើញឲ្យអង្គុយ។ **តាន់កុង**និយាយថា **ឡៅពី**នៅក្នុងអំណាច**លីប៉ោ** នោះនឹងប្រាថ្នាក្បាល**ឡៅពី**ក៏គង់បានដោយងាយ។

**តាន់កុង**តបថា អ្នកកុំគប្បីរង្កៀសចិត្តនឹងខ្ញុំ ៗឃើញថាការរបស់អ្នកដែលគិតនោះប្រសិនបើនឹងលះបង់ចោលទុកយូរហួត ក៏នឹងមិនសម្រេចតាមប្រាថ្នា បានជាខ្ញុំមកជម្រាបនេះដើម្បីនឹងរំឭកស្មារតីអ្នក។ **ហាន់អ៊ិន**យល់គំនិត**តាន់កុង**ដែលនិយាយដោយពិតត្រង់ក៏បណ្តោយថា សុំឲ្យអ្នកជួយជាធុរៈផងចុះ។ **តាន់កុង**ថាអ្នកកុំព្រួយ បើប្រសិន**លីប៉ោ**បានប្រឹក្សានឹងខ្ញុំ សុំខ្ញុំនិយាយឲ្យ**លីប៉ោ**បញ្ជូនកូនក្រមុំទៅឲ្យ**អ៊្លួនសុត**ឲ្យបាន។ **ហាន់អ៊ិន**មានអំណរក្នុងចិត្តណាស់ថា ការនេះប្រសិនបើអ្នកជួយគិតសម្រេចបាន **អ៊្លួនសុត**ក៏គង់ដឹងគុណរបស់អ្នកមិនភ្លេចទេ។ **តាន់កុង**ក៏លា**ហាន់អ៊ិន**ទៅជួបនឹង**លីប៉ោ** ហើយធ្វើជាសួរថា ខ្ញុំបាទបានឮថា លោកព្រមឲ្យកូនក្រមុំទៅ

**អ្នួនស៊ុត**មែនឬទេ? **លីប៉ោ**ឆ្លើយទទួលថាមែន។ **តាន់កុង**ថា លោកបានធ្វើជន្លងនឹង**អ្នួនសុត**គ្រានេះ ខ្ញុំមានសេចក្តីត្រេកអរណាស់ ចុះកាលណានឹងគិតរៀបមង្គលការ?

**លីប៉ោ**ថា ការនេះជាការធំ ចាំខ្ញុំប្រឹក្សាគ្នាឲ្យដឹងទាំងអស់សិន។ **តាន់កុង**ថា ទំនៀមពីដើមបើជាក្សត្រកំណត់មួយឆ្នាំ ទើបបញ្ជូនកូនស្រីទៅឲ្យ បើនាហ្មឺនកំណត់ប្រាំមួយខែ នាហ្មឺនតូចកំណត់បួនខែ បើជារាស្ត្រធម្មតាកំណត់សាមសិបថ្ងៃ។ **លីប៉ោ**ថា ឥឡូវ**អ៊្នួនសុត**បានត្រាចម្លាក់សម្រាប់ព្រះមហាក្សត្រទុកហើយ ខ្លួនគេក៏ចូលរវាងទីម្ចាស់ផែនដីបាន បើដូច្នោះយើងត្រូវបង្អង់ទុកតាមទំនៀមក្សត្រចុះ។ **តាន់កុង**ថា ដូចជាយូរណាស់ ព្រោះសព្វថ្ងៃនេះស្រុកទេសក៏នៅបះបោរមិនបានជាប្រក្រតី មនុស្សទាំងឡាយសឹងដណ្តើមគ្នាធ្វើធំរាល់កន្លែង លោកនឹងបង្អង់ការនេះទុកយូរខ្លាចមនុស្សណាដែលជាសត្រូវនឹងលោក ដឹងជ្រួតជ្រាបទៅនឹងលើកទ័ពមកចាំឆក់ដណ្តើម ឲ្យបានសេចក្តីព្រួយរំខាន។ គំនិតខ្ញុំបាទយល់ថា បើលោកបញ្ជូនកូនក្រមុំលោកទៅឲ្យ**អ៊្នួនសុត**ក្នុងគ្រានេះស្រួលជាងទុកនៅ ព្រោះឥឡូវនេះមិនទាន់មាននរណាដែលជាសត្រូវនោះដឹងការ។ **លីប៉ោ**បានស្តាប់យល់ឃើញថាត្រូវ ក៏ចូលទៅបង្គាប់នាង**ងៀមស៊ី**ជាភរិយា ឲ្យរិះគិតរៀបមង្គលការនៃកូនស្រីរបស់ខ្លួនឲ្យបានសម្រេចក្នុងវេលាយប់នេះតាមទំនៀមទម្លាប់។ ភរិយា**លីប៉ោ**និងវង្សាគណៈញាតិក៏ចាត់ចែងរៀបមង្គលការស្រេច លុះព្រឹកឡើង**លីប៉ោ**ក៏រៀបឲ្យកូនក្រមុំនោះឡើងជិះរទេះឈើក្រអូប ហើយប្រគល់ឲ្យ**ហាន់អ៊ិន**ព្រមទាំងរបស់ទ្រព្យតាមទម្លាប់ ហើយចាត់ប្រើឲ្យ**ស៊ុងហៀង**និង**ងុយសុក**នូវសេនាទាហានជាច្រើនហែហមអមចេញទៅ។

ខណៈនោះ**តាន់គុយ**ជាបិតា**តាន់តេង** ជានាហ្មឺនចាស់ទុំនៅដេកឈឺក្នុងផ្ទះ លុះបានឮសំឡេងគងស្គរត្រួតត្រែទ្រហឹងអឺងកង ក៏សួរមនុស្សម្នាក្នុងផ្ទះៗក៏ប្រាប់ថា

**លីប៉ោ**លើកកូនក្រមុំឲ្យទៅកូន**អ៊្លួនសុត** ឥឡូវឲ្យបម្រើនាំយកទៅជូនខាងប្រុសហើយ។ **តាន់គុយ**ពិគ្រោះមើលក្នុងតម្រា ក៏យល់ថាជាកលឧបាយ**អ៊្លួនសុត**ពិតៗ។ **តាន់គុយ**អង្គុយគិតពិចារណាឃើញថា បើអញនឹងនៅស្ងៀមមើលបំណាំវេលានេះ **ឡៅពី**ក៏ដល់សេចក្តីអន្តរាយជាប្រាកដ។ **តាន់គុយ**ក៏តែងខ្លួនជួតក្បាលសំពត់ស ធ្វើអាការៈហាក់ដូចជាបែបមនុស្សទាំងឡាយទៅសួរសពគេ ហើយខំធ្វើដំណើរទាំងឈឺទៅរក**លីប៉ោ** ។ក្រឡេកឃើញ**តាន់គុយ**តែងខ្លួនឡើងមកប្លែកទាំងសម្លៀកបំពាក់មានទឹកមុខសៅហ្មងក៏សួរថា អ្នកមកធ្វើអ្វី? **តាន់គុយ**ជម្រាបថា ខ្ញុំបាទបានឮសំឡេងភ្លេងស្ពានថាគេប្រគំសពលោក ទើបខំក្រោកដើរមកទាំងឈឺប្រាថ្នានឹងសួរសពតាមទំនៀម។ **លីប៉ោ**ស្ដុតចិត្តភិតភ័យណាស់ក៏សួរថា អ្នកចរចានេះប្លែកណាស់ នរណាប្រាប់អ្នកថាខ្ញុំស្លាប់។

**តាន់គុយ**ថា ពីដើមលោកទទួលសំណូករបស់**អ៊្លួនសុត**គិតនឹងរំលាង**ឡៅពី** ឯក្រោយលោកត្រឡប់លើកទ័ពទៅជួយ**ឡៅពី**វិញ ឥឡូវឮថាលោកលើកកូនក្រមុំទៅឲ្យ**អ៊្លួនសុត**ទៀត ហេតុអ្វីបានជាលោកធ្វើដូច្នេះ ចុះបើលោកនិង**អ៊្លួនសុត**ជាដន្លងនឹងគ្នា កាលណា**អ៊្លួនសុត**នឹងមិនលើកទ័ពមកវាយ**ឡៅពី** លោកនឹងទៅជួយ**ឡៅពី**ឯណាបាន។ កាលបើស្រុកសៀវផាយអន្តរាយដល់**អ៊្លួនសុត**ហើយ ម្ដេចឡើយលោកមិនឃើញថាស្រុកឈីជីវនឹងមិនសុខផង? ថ្វីបើលោកជាដន្លង**អ៊្លួនសុត**ក៏គង់បំណងខ្ចីទាហាន និងស្បៀងអាហារលោកយកទៅបំពេញធ្វើការ លោកនឹងខាំងខារថាមិនឲ្យនោះមិនបានទេ បណ្ដារាស្ត្រទាំងពួងខ្ញុំនិងគេរាល់គ្នាក៏មានតែទុក្ខលំបាកក្ដៅក្រហាយ លោកនិង**អ៊្លួនសុត** ក៏គង់ឃ្លាតឆ្ងាយចិត្តពីគ្នា។ ប្រការមួយទៀត **អ៊្លួនសុត**នោះប្រទូសរ៉ាយនឹងព្រះចៅ**ហៀនតេ** អាណាខេត្តទាំងអស់ក៏រមែងដឹងឮទូទៅ ឥឡូវ

លោកទៅសេពគប់នឹងមនុស្សសត្រូវផែនដីដូច្នេះ អ្នកទាំងអស់ក៏ក្លាយជាសត្រូវនឹងលោកទៅឯងៗ។

**លីប៉ោ**បានឮ**តាន់កុយ**ចរចាដូច្នោះ ក៏យល់ត្រូវផង ឆ្លើយឆ្លងតបនឹង**តាន់គុយ**ថា ខ្ញុំធ្វើការជ្រុលហួសដូច្នេះ ព្រោះជឿពាក្យ**តាន់កុង**ជាទីប្រឹក្សា។ **លីប៉ោ**ក៏ចាត់ប្រើ**តៀវលៀង**ឲ្យលើកទាហានស្រូតរូតតាមទៅ កាលទៅទាន់ហើយ ក៏កំហែងនាំយកកូនក្រមុំនិងខ្លួន**ហាន់អ៊ិន**មកវិញ ហើយឲ្យយកខ្លួន**ហាន់អ៊ិន**ទៅដាក់គុកទុក រួច**លីប៉ោ**ប្រើបម្រើឲ្យនាំសំបុត្រទៅប្រាប់**អ៊្វីនសុត**ថា ខ្ញុំកំពុងតែចាត់ចែងរករបស់ទាំងពួង ដើម្បីជាមេត្រីគួរសមនឹងអ្នក បើបានសម្រេចកាលណាទើបបញ្ជូនកូនស្រីនៃខ្ញុំមកជូនអ្នកកាលនោះ។

**តាន់គុយ**ជម្រាប**លីប៉ោ**ថា ចូរលោកបញ្ជូនខ្លួន**ហាន់អ៊ិន**ទៅជូន**ចូឆូ**ឯក្រុងហ៊ូតោចុះ លោកគង់នឹងបានសេចក្ដីគាប់ប្រសើរមិនខាន។ **លីប៉ោ**មិនទាន់ឆ្លើយថាដូចម្ដេចទទួលមានបម្រើមកប្រាប់**លីប៉ោ**ថា ឥឡូវ**ឡៅពី**កំពុងឲ្យបង្ហាត់សេនាទាហានបានជាច្រើនណាស់ ដែលនឹងគិតគំនិតយ៉ាងម៉េចស៊ើបមិនទាន់ច្បាស់។ **លីប៉ោ**ថា ដែលនឹងឆ្ងល់សង្ស័យនឹង**ឡៅពី**នោះមិនត្រូវទេ ដោយធម្មតាការដែលបង្ហាត់ប្រិតប្រៀបរៀបចំសេនាទាហាននោះ ទុកដើម្បីនឹងរក្សាខ្លួនប៉ុណ្ណោះ ទោះបីនរណាៗក៏រមែងគិតដូចគ្នា។

លុះកន្លងយូរមក **លីប៉ោ**ប្រើ**ស៊ិងហៀង**និង**ងុយសុក**ឲ្យទៅទិញសេះពីស្រុកសួរតាំង។ អ្នកទាំងពីរក៏វិលមកប្រាប់**លីប៉ោ**ថា ខ្ញុំបាទទៅទិញសេះបានបីរយ លុះមកដល់ដែនស្រុកសៀវផាយពាក់កណ្ដាលអាធ្រាត្រ មានមនុស្សកំណាចលើកគ្នាមកវាយដណ្ដើមយកសេះអស់មួយរយហាសិបទៅ ខ្ញុំបាទបានស៊ើបសួរដំណឹងដឹង

ថា **តៀវហ៊ុយប្អូនឡៅពី** លើកបក្សពួកបន្លំធ្វើចោរព្រៃវាយដណ្ដើមយកសេះនោះ។ **លីប៉ោ**បានឮក៏ខឹងណាស់ ទើបឲ្យចាត់ចែងប្រមូលសេនាទាហានបានជាច្រើន ក៏លើកជាក្បួនទ័ពទៅស្រុកសៀវផាយ ដើម្បីនឹងចាប់**តៀវហ៊ុយ**និងស្ម័គ្របក្សពួកដែលជាចោរ។

**ឡៅពី**ដឹងដូច្នោះភ័យណាស់ លើកទាហានចេញមកទទួល ហើយស្រែកសួរ**លីប៉ោ**ថា បងលើកទ័ពមកនេះដោយហេតុអ្វី? **លីប៉ោ**ក៏យករំពាត់សេះចង្អុលមុខ**ឡៅពី**ហើយស្រែកថា កាលគ្រា**គីឡេង**លើកទ័ពមកច្បាំងនឹងស្រុកសៀវផាយ ខ្ញុំឯងមានសេចក្ដីអាណិតក៏បានជួយគិតរកឧបាយកែខៃជួយទាល់តែរួចអាយុជីវិត ឥឡូវខ្លួនទុរយសរមិលគុណ គួរឬមកវាយដណ្ដើមយកសេះរបស់យើងទុកជាប្រយោជន៍ខ្លួនវិញ? **ឡៅពី**តបថា ខ្ញុំបានចាត់ប្រើមនុស្សទៅរកទិញសេះមកខ្លះដែរ នឹងបានវាយដណ្ដើមយកសេះរបស់អ្នកជាប្រយោជន៍ក៏ទេ។ **លីប៉ោ**តបថា ខ្លួនប្រើ**តៀវហ៊ុយ**ជាប្អូនទៅវាយដណ្ដើមយកសេះរបស់យើងមួយរយហាសិប ហេតុម្ដេចក៏ឆ្លើយថាមិនដឹង?

**តៀវហ៊ុយ**ឮ**លីប៉ោ**ស្រដីទ្រគោះឲ្យ**ឡៅពី**សព្វគ្រប់ ក៏នឹកខឹងណាស់ បរសេះទៅខាងមុខ ហើយស្រែកឲ្យ**លីប៉ោ**ថា អញបានវាយដណ្ដើមយកសេះរបស់ខ្លួនឯងមែនហើយ ឯងចង់ធ្វើអញយ៉ាងម្ដេច?

**លីប៉ោ**ឮ**តៀវហ៊ុយ**ថាដូច្នោះខឹងណាស់តបថា អាចោរកំណាចភ្នែកធំនេះព្រហើនខ្លាំងណាស់ បានប្រមាទមើលងាយអញជាច្រើនដងហើយ ឥឡូវត្រឡប់មកប្រទូសរ៉ាយអញ ហើយថែមស្ដីទ្រគោះឲ្យអញទៀត។ **តៀវហ៊ុយ**ថា អញវាយដណ្ដើមយកសេះឯងៗខឹងនឹងអញ ចុះដែលឯងវាយដណ្ដើមយកស្រុកឈីជីវពីមុន

មិញជារបស់បងអញ ឯងចូលចិត្តថា អញមិនចេះខឹងនឹងឯងទេឬ? **លីប៉ោ**បានឮដូច្នោះក៏រឹតតែខឹងពេកណាស់ បរសេះស្ទុះចូលទៅតយុទ្ធនឹង**តៀវហ៊ុយ**បានមួយរយភ្លែង **ឡៅពី**គិតថាក្រែង**តៀវហ៊ុយ**និងសៀបប្រៀបថ្វីដៃ**លីប៉ោ** ក៏វាយឃ្មោះឡើង **តៀវហ៊ុយ**ក៏ត្រឡប់សេះថយក្រោយមករក**ឡៅពី**។ លុះវេលាយប់ **ឡៅពី**ក៏លើកទាហានចូលស្រុកវិញ **លីប៉ោ**ក៏វាយទាហានឡោមព័ទ្ធទុកទាំងបួនទិស។

**ឡៅពី**និយាយនឹង**តៀវហ៊ុយ**ថា កើតហេតុទាំងអម្បាលនេះពីព្រោះតែអ្នកទៅធ្វើវីវរវាយដណ្ដើមយកសេះគេ ឥឡូវខ្លួនយកសេះទៅទុកឯណា? **តៀវហ៊ុយ**ឆ្លើយថា ខ្ញុំយកទៅលាក់ទុកក្នុងវត្តគុកឯលើភ្នំ។

**ឡៅពី**ក៏ប្រើទាហានចេញទៅសុំទោស**លីប៉ោ**ថា ពីដើមមិនបានដឹងរឿងបានជាមិនទទួល ឥឡូវឃើញខុសមែនហើយ នឹងទទួលនាំសេះមកបង្វិលជូនអ្នកវិញ កុំឲ្យអ្នកខឹងគុំគួនព្យាបាទតទៅទៀតឡើយ ដើម្បីនឹងបានឃើញមុខគ្នាជាអង្វែងតទៅ។ **លីប៉ោ**បានស្ដាប់ក៏អស់ខឹងហើយនិយាយនឹងបម្រើថា ដែល**ឡៅពី**ឲ្យបម្រើមកសុំទោសយើងនេះ យើងក៏ព្រមតាមពាក្យហើយ។ **តាន់កុង**ឆ្លើយថា បានការហើយ លោកនឹងរារែកទុកធ្វើអ្វីទៀត? ត្រូវតែកម្ចាត់**ឡៅពី**ចេញទើបស្រួល បើទុកទៅ**ឡៅពី**គង់នឹងចងអាឃាដជាសត្រូវធ្វើអន្តរាយដល់លោកវិញ។ **លីប៉ោ**ក៏យល់ព្រមផង ទើបលើកទាហានចោមរោមព័ទ្ធស្រុកសៀវផាយ។ **ឡៅពី**ឃើញកម្លាំងនឹងតទល់ពុំបាន ក៏ពិគ្រោះគ្នានឹង**ប៊ិតុក, ស៊ុនខៀន**ថា គ្រានេះ**លីប៉ោ**មានកម្លាំងលើសលុបណាស់ អ្នកទាំងឡាយនឹងគិតដូចម្ដេច? **ស៊ុនខៀន**ថា **ចូឆូ**មានចិត្តខឹងព្យាបាទ**លីប៉ោ**ជាដរាប យើងត្រូវច្បាំងពុះទម្លាយរត់ចេញទៅស្រុកហ៊ូតោ ដើម្បីនឹងសុំទាហាន**ចូឆូ**លើកត្រឡប់មកច្បាំងនឹង**លីប៉ោ**វិញទើបបាន។ **ឡៅពី**ឃើញត្រូវផង ទើបនិយាយថា

នរណានឹងហ៊ានយកអាសានាំមុខចេញទៅបាន? **តៀវហ៊ុយ**ឆ្លើយទទួលខ្លួនជាមេនាំមុខ។ វេលានោះ**ឡៅពី**ក៏រៀបចំប្រមូលយកទ្រព្យរបស់និងអស់សេនាទាហាន ឲ្យ**តៀវហ៊ុយ**ជាទ័ពមុខ ខ្លួន**ឡៅពី**នាំគ្រប់គ្រួនិងទ្រព្យរបស់ជាទ័ពកណ្ដាល **គួនអ៊ូ**នាំទាហានមួយកងជាទ័ពក្រោយ ដល់ពេលយាមបីខែភ្លឺច្បាស់ **ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** ក៏លើកព្យុហៈទ័ពកាប់ឆ្ការទម្លាយទ័ព**លីប៉ោ**ចេញទៅទិសឧត្តរ។

ឯ**ស៊ិងហៀង**និង**ង៉ុយសុក**ជានាយកងខាងទិសឧត្តរ ឃើញទ័ព**ឡៅពី**ទម្លាយចេញទៅ ក៏តាំងចូលច្បាំងតទល់នឹង**តៀវហ៊ុយ**ជាពន្លឹក។ **តៀវហ៊ុយ** និង**ឡៅពី**ក៏ពារវាយបំបែកញែកចេញទៅបាន។ **តៀវលៀង**ឃើញ**គួនអ៊ូ** ចេញជាកងក្រោយក៏ដេញទាហានវាយបណ្ដោយទៅទៀត។ **គួនអ៊ូ**ក៏បរសេះវេះតដៃពីក្រោយរួចរហូតទៅទាន់**ឡៅពី, តៀវហ៊ុយ** ក៏លើកទ័ពប្រមូលគ្នាតម្រង់ទៅស្រុកហ៊ូតោ។ **លីប៉ោ**ដឹងថា **ឡៅពី**រត់ទៅហើយក៏មិនបានដេញតាម ទើបនាំទាហានទាំងពួងទៅក្នុងស្រុកសៀវផាយហើយក៏វិលទៅស្រុកឈីជីវវិញ។

កាល**ឡៅពី**លើកគ្រប់គ្រួទៅដល់ដែនក្រុងហ៊ូតោហើយ ក៏បោះទ័ពនៅខាងក្រៅក្រុង ហើយប្រើ**ស៊ុនខៀន**ជាបម្រើចូលទៅអភិប្រាយនិយាយនឹង**ចូឆូ**ថា ដ្បិត**លីប៉ោ**លើកទ័ពទៅវាយស្រុកសៀវផាយ **ឡៅពី**បែករត់មកសុំនៅជ្រកកោនបុណ្យលោក។ **ចូឆូ**ឮដូច្នោះក៏រួសរាយរាក់ទាក់ណាស់ និយាយថា “**ឡៅពី**នេះបីដូចសែជាមួយនឹងយើង” ហើយក៏ប្រើសេនាទាហានឲ្យចេញទៅទទួល**ឡៅពី**ចូលមកក្នុងក្រុង។ **ឡៅពី**ក៏ឲ្យ**គួនអ៊ូ, តៀវហ៊ុយ**នៅរក្សាការពារសត្រូវគ្រប់គ្រួនិងសេនាទាហានទាំងពួង ហើយនាំយក**ប៊ីតុក** និង**ស៊ុនខៀន**ទៅជាមួយ។

**ចូឆ្វូ**ចេញមកទទួលខ្លួនឯង ទាំងពីរនាក់គំនាប់សាកសួរគ្នាតាមសេចក្ដីមេត្រីរាប់អានហើយ **ចូឆ្វូ**អញ្ជើញ**ឡៅពី**ឲ្យអង្គុយតាមទីគួរសម។ **ឡៅពី**អធិប្បាយរួសរាយរឿងពីបឋមដរាប**លីប៉ោ**លើកទ័ពមកវាយស្រុកសៀវផាយ ឲ្យ**ចូឆ្វូ**ស្ដាប់គ្រប់ប្រការ។ **ចូឆ្វូ**តបថា **លីប៉ោ**នោះជាមនុស្សទុរយសអាក្រក់ឥតដឹងគុណអ្នកឯណាសោះ គ្រានេះអ្នកបានមកដល់យើងហើយចូរកុំបីជាទុក្ខឡើយ សុំយើងជួយអ្នកៗនិងយើងត្រូវលើកទ័ពទៅវាយយកស្រុកឈីជីវ ដើម្បីកម្ចាត់**លីប៉ោ**ចេញឲ្យបាន។ **ឡៅពី**តបថា លោកមានប្រសាសន៍តែប៉ុណ្ណេះក៏ឃើញថា ព្រះតេជព្រះគុណមិនមានទីបំផុត។ **ចូឆ្វូ**ក៏ឲ្យរៀបតុលៀងអាហារហើយអញ្ជើញ**ឡៅពី**បរិភោគ រួច**ឡៅពី**ក៏លា**ចូឆ្វូ**ទៅកាន់កងទ័ពវិញ។

**ស៊ុនហុក**និយាយនឹង**ឆ្វូចូ**ថា **ឡៅពី**នេះជាមនុស្សមានសតិបញ្ញាណាស់ បើនឹងគប់ប្រសព្វយកជាគ្នាតទៅ គង់នឹងកើតអន្តរាយដល់ខ្លួនលោក។ ឥឡូវ**ឡៅពី**ចូលមកនៅក្នុងកណ្ដាប់ដៃលោកហើយ ត្រូវតែគិតសម្លាប់ចេញទើបស្រួល។ **ចូឆ្វូ**មិនយល់ព្រមតាមសម្ដី**ស៊ុនហុក**និយាយក៏នៅស្ងៀម **ស៊ុនហុក**លាត្រឡប់ទៅវិញ។ ទទួល**គុយកែ**ចូលទៅរក**ចូឆ្វូ** ៗក៏ពណ៌នារឿងឲ្យ**គុយកែ**ស្ដាប់តាមសម្ដី**ស៊ុនហុក**និយាយនោះ។ **គុយកែ**ឆ្លើយថា ដែល**ស៊ុនហុក**និយាយនោះមិនត្រូវសោះ ព្រោះសព្វថ្ងៃនេះលោកកំពុងគិតការធំ ត្រូវរកអ្នកមានសតិបញ្ញាមកធ្វើជាគ្នាជួយគិតការផង ឯ**ឡៅពី**ជាមនុស្សមានសតិបញ្ញារត់ពីក្ដៅមករកត្រជាក់ បើលោកស្ដាប់ពាក្យ**ស៊ុនហុក**សម្លាប់**ឡៅពី**ហើយ កាលណាឡើយមនុស្សឯទៀតនឹងអាចចូលមកនៅពឹងបុណ្យលោកបាន? បើទោះជាមានសេចក្ដីបំណងប្រុងនឹងចូលមកក៏គង់រាត្រឡប់ថយទៅវិញទាំងអស់ ទោះទាំងអាណាប្រជានុរាស្ត្រក៏នឹងគរហានិន្ទាជាទីតិះដៀលប្រមាថ

មើលងាយ ហេតុនេះខ្ញុំបាទសុំឲ្យលោកត្រិះរិះមើលតាមគួរសិនចុះ។ **ចូឆ្វូ**បានស្តាប់ក៏យល់ត្រូវថា អ្នកនិយាយនេះត្រូវដូចគំនិតរបស់ខ្ញុំគ្រប់ប្រការ។ លុះវេលាព្រឹកព្រាងព្រះសុរិយា **ចូឆ្វូ**ក៏ចូលទៅក្រាបបង្គំគាល់ព្រះចៅ**ហៀនតេ** ហើយយកសេចក្តីក្រាបបង្គំទូល សុំព្រះរាជទានតាំង**ឡៅពី**ជាចៅហ្វាយស្រុកអ៊ីជីវ។ ព្រះចៅ**ហៀនតេ**ក៏ទ្រង់ប្រោសព្រះរាជទាន **ចូឆ្វូ**ក៏ក្រាបបង្គំលាត្រឡប់ទៅកាន់ទីលំនៅ។

**ផៀយ៉ុក**ជម្រាបចូឆ្វូថា **ឡៅពី**នេះមានសតិបញ្ញាណាស់ ដែលនឹងធ្វើឲ្យតូចនៅក្រោមបង្គាប់អ្នកឯណាមិនបានទេ បើនៅក្រោមបង្គាប់យូរទៅនឹងប្រែប្រាសក្រឡះចិត្តចេញអំពីលោក ៗត្រូវចាប់យកខ្លួន**ឡៅពី**សម្លាប់ចេញទើបស្រួល។ **ចូឆ្វូ**ឆ្លើយថា ឥឡូវនេះយើងកំពុងយកចិត្តមនុស្សទាំងពួង **ឡៅពី**ជាមនុស្សមានសតិបញ្ញាល្អ បើយើងត្រឡប់ទៅសម្លាប់ចេញកាលណា បណ្តាមនុស្សទាំងឡាយក៏នឹងរអាចិត្តគិតខ្លាចយើង ថាជាមនុស្សអាក្រក់ សេចក្តីគរហានិន្ទាក៏នឹងមានដល់យើងច្រើនឡើង ការនេះយើងក៏បានប្រឹក្សានឹង**គុយកែ**ហើយ ដែលអ្នកមកនិយាយឲ្យយើងតាមគំនិតដូច្នេះមិនត្រូវទេ។ ទទួល**ឡៅពី**ចូលមករក**ចូឆ្វូ** ៗក៏ចាត់ចែងបែងសេនាទាហានឲ្យ**ឡៅពី**ចំនួនបីពាន់ ហើយ**ចូឆ្វូ**និយាយប្រាប់ថា ខ្ញុំបានយកសេចក្តីក្រាបពិតទូលព្រះចៅ**ហៀនតេ** ទ្រង់តាំងអ្នកធ្វើចៅហ្វាយស្រុកអ៊ីជីវហើយ បើអ្នកទៅដល់ស្រុកអ៊ីជីវកាលណា ត្រូវលើកសេនាទាហានទៅវាយស្រុកសៀវផាយចុះ រួចតាំងបញ្ចុះបញ្ចូលឲ្យបានទាហានជាច្រើនលើកទៅរំលាង**លីប៉ោ**ឯស្រុកឈីជីវទៀត។ **ឡៅពី**ទទួលពាក្យ**ចូឆ្វូ**ក៏ធ្វើគំនាប់ដោយការគោរពយ៉ាងប្រពៃ ហើយលា**ចូឆ្វូ**លើកទ័ពទៅស្រុកអ៊ីជីវ។

ឯ**ចូឆ្វូ**ក៏ត្រៀមសេនាទាហានបានព្រម ប្រុងនឹងលើកទៅវាយស្រុកឈីជីវ ដែល**លីប៉ោ**នៅនោះ លុះរៀបដំណើរនឹងចេញទៅ ទទួលមានបម្រើចូលមកប្ដឹងថា **តៀវស៊ីវ**ចៅហ្វាយស្រុកអ្នូនសៀ ដែលជាក្មួយ**តៀវថេ**នោះបាន**កាសៀង**មកធ្វើជាទីប្រឹក្សា ហ្វឹកហាត់សេនាទាហានបានជាច្រើនណាស់ ឥឡូវគប់គិតគ្នានឹង**ឡៅពៀវ**ចៅហ្វាយស្រុកកេងជីវ នឹងលើកទ័ពមកវាយស្រុកហ៊ូតោនេះ។

# រឿង សាមកុក

## អ្នកឧកញ៉ាខបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ១៥

**ចារឹកឡើងខញដោយ ៖ ឈុល ដារ៉ា**

*(ចាប់តាំងពី**ចូឆូ**លើកកងទ័ពទៅវាយ**តៀវស៊ីវ** រហូតដល់**ឡៅពី**កាត់យកក្បាល**ហាន់សៀម** និង**អៀវហង់**ទៅជូន**ចូឆូ**)។*

**ចូឆូ**ក៏រំពឹងគិតថា “បើនឹងលើកទ័ពទៅវាយស្រុកអួនសៀ ខ្លាចក្រែង**លីប៉ោ**ដឹងការណ៍នឹងលើកកងទ័ពត្រឡប់ពីក្រោយ មកវាយយកស្រុកហ៊ូតោអសារឥតការ” ទើបប្រឹក្សានិង**ស៊ុនហុក**ថា ឮថា**តៀវស៊ីវ**នឹងលើកទ័ពទៅវាយស្រុកយើង បើយើងលើកទ័ពទៅវាយ**តៀវស៊ីវ**ជាមុនខ្លាច**លីប៉ោ**ដឹង នឹងលើកទ័ពទៅវាយស្រុកហ៊ូតោខាងនេះ អ្នកនឹងយល់ឃើញដូចម្តេច បើជាការកង្វល់យ៉ាងនេះ? **ស៊ុនហុក**ឆ្លើយថាឯ**លីប៉ោ**នោះមិនមែនជាមនុស្សឈ្លាសចេះដឹងដល់ប៉ុណ្ណោះទេ ប្រកបតែដោយសេចក្តីលោភកំរើប គិតតែចង់បានយសបណ្តាសក្តិ បើលោកបារម្ភសុំឲ្យមានព្រះតម្រាស់ទៅតាំង**លីប៉ោ**ឲ្យពេញទីជាចៅហ្វាយស្រុកឈីជីវ ហើយតាំងជាទីបេងតាំងចុងគុនគឺជាស្តេចត្រាញ់បង្ក្រាបចោរខាងបូព៌ទិសា ហើយលោកថែមឲ្យមានសំបុត្រផ្ទាល់ខ្លួនលោក ទៅដល់**លីប៉ោ**ទៀតថា ឲ្យ**លីប៉ោ**និង**ឡៅពី**ស្ម័គ្រស្មាគមនឹងគ្នា កុំឲ្យមានអាឃាដព្យាបាទគ្នាតទៅទៀតឡើយ។ បើធ្វើដូច្នោះទោះបីលោកលើកទ័ពទៅវាយស្រុកអួនសៀ **លីប៉ោ**ក៏គង់មានចិត្តភក្តីមេត្រីនឹងលោក មិនលើកទ័ពមកវាយស្រុកហ៊ូតោនេះឡើយ។

**ចូឆ្វ**បានស្តាប់យល់ឃើញត្រូវ ក៏តែងសំបុត្រតាមពាក្យ**ស៊ុនហុក**ថា ហើយឲ្យ**អងចិក**ជាបម្រើនាំទៅឲ្យ**លីប៉ោ** ឯ**ចូឆ្វ**ក៏រៀបចាត់ចែងសេនាទាហានបានដប់ប្រាំម៉ឺន ឲ្យ**ហែហួទុក**និង**អ៊ីគឹម**ជាទ័ពមុខ ហើយបែងទាហានចេញជាបីកង លើកទៅដល់ទន្លេយ៉ុកស៊ុយ ឲ្យបោះទ័ពតាំងបន្ទាយនៅទីនោះយូរថ្ងៃ។

**កាសៀង**បានឮកិត្តិយ័ព្ទថា **ចូឆ្វ**ឲ្យលើកទ័ពមកដូច្នោះក៏ពិគ្រោះនឹង**តៀវស៊ីវ**ថា **ចូឆ្វ**លើកទ័ពមកគ្រានេះប្រហែលម្ភៃម៉ឺន មានទាំងសេនាឯកថ្មីដៃខ្លាំងពូកែក៏ច្រើន បើយើងនឹងចេញច្បាំងវេលានេះ គង់នឹងបរាជ័យនឹង**ចូឆ្វ**ជាប្រាកដ ហេតុនេះត្រូវតែយើងចេញទៅអង្វរចុះចូល**ចូឆ្វ**ស្រួលជាង ទើបនឹងមិនមានអន្តរាយដល់ស្រុកផង។ **តៀវស៊ីវ**ស្តាប់ឃើញត្រូវ ក៏ប្រើ**កាសៀង**ចេញទៅគំនាប់**ចូឆ្វ**ក្នុងបន្ទាយថា ឥឡូវនេះ**តៀវស៊ីវ**ដឹងថាមហាឧបរាជលើកកងទ័ពមក ទើបប្រើខ្ញុំឲ្យចេញមកជម្រាបសុំអង្វរលន់តួសុំចុះចូលលោកតទៅ។

**ចូឆ្វ**បានស្តាប់ដូច្នោះក៏នឹករំពឹងថា **កាសៀង**នេះចរចាមុតមាំសមជាមនុស្សមានសតិបញ្ញា ទើបឆ្លើយថា ឥឡូវ**តៀវស៊ីវ** និងអ្នកព្រមចំណុះចុះចូលមកធ្វើការនឹងយើងៗក៏ត្រូវតាំងឲ្យអ្នកជាទីប្រឹក្សា។ **កាសៀង**ជម្រាបថា កាលខ្ញុំបាទនៅធ្វើការជាមួយនឹង**លីឈុយ** ៗក្បត់ផែនដី សេចក្តីអាក្រក់នឹងជិតជាប់ដល់ខ្លួនខ្ញុំបាទផង ព្រោះខ្ញុំបាទមិនចូលចិត្តនឹងឲ្យមានទោសជាមុនទេ ឥឡូវមហាឧបរាជនឹងតាំងខ្ញុំបាទជាទីប្រឹក្សានោះ ព្រះគុណមិនមានទីបំផុត តែថា**តៀវស៊ីវ**នៅមានឧបការគុណដល់ខ្ញុំបាទ ហើយ**តៀវស៊ីវ**មិនមាននរណាជាទីប្រឹក្សាសោះ ខ្ញុំបាទនឹងសុំអនុញ្ញាតឲ្យនៅធ្វើការជាមួយនឹង**តៀវស៊ីវ** ក៏ដូចជានៅជាមួយនឹងមហាឧបរាជដែរ។ **ចូឆ្វ**មិនបានតបថាដូចម្តេច **កាសៀង**ក៏លា**ចូឆ្វ**ចេញទៅ បានយកសេចក្តីនោះអធិប្បាយឲ្យ**តៀវស៊ីវ**

ស្លាប់គ្រប់ប្រការ។ លុះវេលាព្រឹក**កាសៀង**ក៏នាំ**តៀវស៊ីវ**ចេញទៅគំនាប់**ចូវឆ្វ**ក្នុងបន្ទាយ។ **ចូវឆ្វ**ឃើញ**កាសៀង**និង**តៀវស៊ីវ**ចូលមក ក៏មានសេចក្ដីត្រេកអរ សួរប្រាស្រ័យពីសេចក្ដីសុខទុក្ខក្នុងរាជការស្រុកទេសផ្សេងៗ។ **តៀវស៊ីវ**ក៏ជម្រាបថា បណ្ដារាស្ត្រទាំងពួងសឹងសុខសប្បាយគ្រប់គ្នា ហើយ**តៀវស៊ីវ**អញ្ជើញ**ចូវឆ្វ**ទៅកាន់ទីគេហដ្ឋានព្រមទាំងកងទ័ព។ **ចូវឆ្វ**បានឮដូច្នោះក៏មានសេកក្ដីសង្ស័យ ទើបឱ្យសេនាទាហានតាំងបន្ទាយរាយទ័ពមកជិតកំពែងស្រុក ហើយ**ចូវឆ្វ**ក៏នាំទាហានដែលទំនុកទុកចិត្តចូលទៅក្នុងស្រុកអ្វូនសៀ។ **តៀវស៊ីវ**ក៏ឱ្យតែងតុលៀងភោជនាហារអញ្ជើញ**ចូវឆ្វ**ឱ្យបរិភោគ ហើយរៀបចំទីសំណាក់ឱ្យ**ចូវឆ្វ**ស្នាក់អាស្រ័យនៅក្នុងទីនោះយូរថ្ងៃ។

ក្នុងសម័យថ្ងៃមួយនោះ **ចូវឆ្វ**ផឹកស្រាស្រវឹងហើយចូលទៅក្នុងដំណេកសួរមនុស្សស្និទ្ធស្នាលថា ក្នុងស្រុកនេះមានស្រីរូបល្អខ្លះដែរឬទេ? **ចោអាន់ប៊ិន**ជាក្មួយ**ចូវឆ្វ**ជម្រាបថា កាលក្នុងថ្ងៃរសៀលនោះ ខ្ញុំបាទបានដើរទៅលេងឃើញស្រីម្នាក់រូបល្អស្អាត ខ្ញុំបាទសួរគេ ៗថា នាងនោះជាភរិយា**តៀវចេ**ជាមា**តៀវស៊ីវ** ឥឡូវ**តៀវចេ**ស្លាប់ទៅក៏នៅជាមេម៉ាយ។

**ចូវឆ្វ**បានឮដូច្នោះ ដោយកម្លាំងស្រវឹងស្រាប្រាថ្នាចង់បាន ក៏ប្រើ**ចោអាន់ប៊ិន**និងទាហានទៅនិយាយនឹងស្រីនោះ នាងក៏ព្រមចិត្តស្រឡាញ់**ចូវឆ្វ** បម្រើនាំយកខ្លួនមកជូនក្នុងពេលព្រលប់ **ចូវឆ្វ**គន់ឃើញរូបភាពនាងល្អសក្តិសមក៏មានចិត្តប្រតិព័ទ្ធត្រេកអរ ទើបសួរថា នាងឈ្មោះអ្វី? នាងជម្រាបថា ខ្ញុំឈ្មោះ**ចៅស៊ី** ជាភរិយា**តៀវចេ**ស្លាប់ទៅហើយ។ **ចូវឆ្វ**សួរថា នាងស្គាល់យើងឬទេ? នាង**ចៅស៊ី**ឆ្លើយថា ខ្ញុំមិនស្គាល់លោកទេ គ្រាន់តែឮគេប្រាប់ថា លោកនេះហើយជាមហាឧបរាជ ដែលខ្ញុំបានមកជួបនឹងលោកគ្រានេះ គឺជាបុណ្យវាសនារបស់ខ្ញុំ។ **ចូវឆ្វ**តបថា ព្រោះយើង

យល់មុខនាងទើបព្រមឲ្យ**តៀវស៊ីវ**មកចំណុះតាមសភាព បើកុំតែប៉ុណ្ណោះ យើងត្រូវតែច្បាំងកាប់សម្លាប់**តៀវស៊ីវ**និងវង្សាគណៈញាតិឲ្យអស់។ នាង**ចៅស៊ី**ជម្រាបថា ដែលមហាឧបរាជលើកទោសចោលនោះ ព្រះតេជព្រះគុណមិនមានទីបំផុត។ **ចូឆ្វូ**ថា យើងនឹងចិញ្ចឹមរក្សានាងទុកជាភរិយា ហើយនឹងនាំទៅក្រុងហ៊ូតោ។ នាង**ចៅស៊ី**ជម្រាបថា ត្រង់នេះស្រេចនៅលោកនឹងអាសូរករុណា។ **ចូឆ្វូ**នាំនាង**ចៅស៊ី**ចូលទៅរួមដំណេកនឹងគ្នាទាល់ព្រឹក។ នាង**ចៅស៊ី**ជម្រាប**ចូឆ្វូ**ថា ដែលលោកនឹងនៅក្នុងស្រុកនេះ សេចក្តីគរហានិទ្ទានឹងកើតមានជាច្រើន ប្រការមួយបើ**តៀវស៊ីវ**ដឹងការណ៍ នឹងមានចិត្តទាស់អធ្យាស្រ័យនឹងលោក។ **ចូឆ្វូ**ក៏និយាយថា នាងថាដូច្នោះត្រូវពិតហើយ ព្រឹកនេះយើងត្រូវនាំគ្នាចេញទៅនៅឯបន្ទាយខាងក្រៅស្រុក។ លុះព្រឹកភ្លឺស្វាងវេលាណា **ចូឆ្វូ**ក៏នាំនាង**ចៅស៊ី**ចេញទៅពីបន្ទាយ ហើយបង្គាប់**តៀនអ៊ុយ**ឲ្យនៅយាមល្បាតទ្វារបន្ទាយ កុំឲ្យនរណាចេញចូលបាន បើមានបង្គាប់ពីយើងសឹមឲ្យចេញចូលចុះ។ **ចូឆ្វូ**ក៏វង្វេងជ្រប់ជ្រាប់ប្រតិព័ទ្ធនឹងនាង**ចៅស៊ី** មិនបានចេញនិយាយរាជការ ហើយមិនបានគិតដែលនឹងលើកទ័ពត្រឡប់ទៅស្រុកហ៊ូតោវិញ។

ឯ**តៀវស៊ីវ**ដឹងថា**ចូឆ្វូ**ឲ្យទៅទទួលយកនាង**ចៅស៊ី** ដែលជាម្តាយមីងថ្លៃទៅទុកធ្វើជាភរិយា ក៏នឹកតូចចិត្តពន់ពេកណាស់ ឲ្យហៅ**កាសៀង**មកប្រឹក្សាថា អ្នកនឹងគិតយ៉ាងដូចម្តេច ដើម្បីនឹងឲ្យខ្ញុំបានសងសឹក**ចូឆ្វូ**វិញ? **កាសៀង**ឆ្លើយថា លោកកុំអាលធ្វើរឹកវរសិន ឈប់ចាំមើល**ចូឆ្វូ**ចេញនិយាយរាជការ លោកត្រូវចូលទៅជួបនឹង**ចូឆ្វូ** ហើយនិយាយថា ទាហានដែលបញ្ចុះបញ្ចូលថ្មីនោះលបរត់ចេញទៅជាច្រើន នឹងសុំអនុញ្ញាតចេញទៅស្រាវជ្រាវរកក្នុងបន្ទាយ**ចូឆ្វូ** បើបានពិនិត្យហើយទាហានទាំងពួង

នឹងខ្លាចបុណ្យ**ចូវឆ្វ**មិនប៉ានរត់តទៅទៀត បើ**ចូវឆ្វ**ព្រមឲ្យចូលទៅស្រាវជ្រាវមើលវេលាណា យើងនឹងគិតចាប់**ចូវឆ្វ**បានដោយងាយ។ **តៀវស៊ីវ**យល់ឃើញត្រូវ។

លុះនៅមកថ្ងៃមួយ **តៀវស៊ីវ**ក៏ចូលទៅក្នុងបន្ទាយ**ចូវឆ្វ** ទទួល**ចូវឆ្វ**ចេញនិយាយរាជការ **តៀវស៊ីវ**និយាយនឹង**តៀនអ៊ុយ**ចាំទ្វារថា សុំចូលទៅជួបនឹង**ចូវឆ្វ**។ **តៀនអ៊ុយ**ក៏ចូលទៅជម្រាប**ចូវឆ្វ**ៗថាឲ្យចូលមកចុះ។ **តៀនអ៊ុយ**ក៏នាំ**តៀវស៊ីវ**ចូលទៅ។ **តៀវស៊ីវ**គំនាប់ហើយនិយាយតាមពាក្យ**កាសៀង**បង្គាប់នោះ ឲ្យ**ចូវឆ្វ**ស្តាប់គ្រប់ប្រការ។ **ចូវឆ្វ**ថា អ្នកនឹងលើកទាហានចេញមកតាំងនៅជាមួយនឹងយើងក៏តាមចិត្តចុះ។ **តៀវស៊ីវ**ក៏ត្រឡប់ចេញទៅ កេណ្ឌកងទាហានចេញទៅនៅតាមជ្រុងបន្ទាយ**ចូវឆ្វ**ទាំងបួនទិស ទើបប្រឹក្សានឹង**ហៅឈៀ**ថា ដែលយើងគិតធ្វើការចាប់**ចូវឆ្វ**នោះ នៅបារម្ភខ្លាច**តៀនអ៊ុយ**ដែលរក្សាទ្វារបន្ទាយ ព្រោះជាមនុស្សមានកម្លាំងថ្វីដៃច្រើនណាស់ ក្រែងយើងធ្វើការមិនបានសម្រេច។

**ហៅឈៀ**ឆ្លើយថា ខ្ញុំបាទក៏មានកម្លាំងរែកដែកបានប្រាំរយនាឡិ ដើរផ្លូវមួយថ្ងៃបានចម្ងាយប្រាំពីរពាន់សិន (២៨០ គ.ម) ដែរ សុំឲ្យលោកវិះគិតយកទូនផ្លែពីរដែល**តៀនអ៊ុយ**កាន់នោះចេញឲ្យបាន ទោះបី**តៀនអ៊ុយ**នឹងមានកម្លាំងយ៉ាងណា ខ្ញុំបាទក៏តស៊ូបាន សុំឲ្យលោកអញ្ជើញ**តៀនអ៊ុយ**មកស៊ីលៀង បំផឹកស្រាឲ្យស្រវឹងខ្លាំង គង់ត្រឡប់ទៅនឹងដេកលក់ ខ្ញុំបាទនឹងបន្លំចូលទៅលួចយកទួនផ្លែពីរមកឲ្យបាន លោកនឹងគិតការតទៅក៏មិនត្រូវខ្លាចបារម្ភនឹង**តៀនអ៊ុយ**ឡើយ។

**តៀវស៊ីវ**បង្គាប់ទាហានទាំងបួនបន្ទាយ ឲ្យត្រៀមប្រុងប្រៀបរៀបសាស្ត្រាវុធជាស្រេច ក្នុងពេលអាធ្រាត្រយប់នេះឲ្យស្តាប់សញ្ញា បើបានឮសំឡេងផាវវេលាណា ចូរលើកប្លន់បន្ទាយចាប់ខ្លួន**ចូវឆ្វ**ឲ្យបាន លុះគិតស្រេចចាត់ឲ្យ**កាសៀង**ទៅអញ្ជើញ

**តៀនអ៊ុយ**មកស៊ីលៀងក្នុងបន្ទាយ។ **តៀនអ៊ុយ**ក៏មកបរិភោគអាហារហើយផឹកស្រាស្រវឹងខ្លាំង លុះដល់ពេលប់**តៀនអ៊ុយ**ក៏លា**តៀវស៊ីវ**ត្រឡប់ទៅ ដោយកម្លាំងស្រវឹងស្រា**តៀនអ៊ុយ**ក៏ដេកលក់នៅក្នុងកន្លែងក្បែរទ្វារបន្ទាយ ។

គ្រានោះ**ហៅឈៀ** ក៏បន្លំចូលទៅលួចយកទួនផ្លែពីររបស់**តៀនអ៊ុយ**នោះមកបាន ឯ**ចូឆ្ញ**និងនាង**ចៅស៊ី**ក៏អង្គុយផឹកស្រានៅជាមួយគ្នា ទទួលឮសំឡេងទាហានគឹកកង **ចូឆ្ញ**ក៏ប្រើទាហានទៅស៊ើបស្តាប់ការណ៍ ទាហាននោះត្រឡប់មកប្រាប់ថា**តៀវស៊ីវ**កេណ្ឌទាហានឲ្យត្រួតត្រាយាមល្បាតបន្ទាយ។ **ចូឆ្ញ**ក៏មិនមានសេចក្តីរង្កៀសសង្ស័យ លុះដល់យាមពីរមានទាហានចូលទៅជម្រាប**ចូឆ្ញ**ថា ឃើញរទេះបន្ទុកស្មៅនៅខាងក្រោយបន្ទាយនោះភ្លើងឆេះរាលឡើង។ **ចូឆ្ញ**ក៏មិនមានគិតសង្ស័យហើយនិយាយថា កុំគិតភ្ញាក់ផ្អើលគ្មានហេតុអ្វីទេ ទាហានទាំងពួងយកស្មៅមកដុតដាំបាយទេតើ ហើយមិនមានរវាំងមើលបានជាភ្លើងឆេះរាលឡើង ត្រូវនាំគ្នាទៅជួយលត់ភ្លើងចេញទៅ។ កាល**ចូឆ្ញ**កំពុងនិយាយនោះភ្លើងក៏រឹតតែឆេះឆ្លោឡើងជុំវិញបន្ទាយទាំងសំឡេងផាវក៏ឮទ្រហឹងអឹងអាប់គ្រប់ទាំងបួនទិស សំឡេងទាហានក៏ស្រែកហ៊ោកញ្ជៀវគឹកកងរំពង។ **ចូឆ្ញ**ភ័យស្លុតស្មារតី ក៏ស្រែកហៅរក**តៀនអ៊ុយ** ៗភ័យភ្ញាក់ឡើងមិនទាន់ពាក់គ្រឹស ស្រវារាវរកទួនសម្រាប់កាន់ក៏មិនឃើញ។ ខាងទាហាន**តៀវស៊ីវ**ហែកទម្លាយបន្ទាយចូលបានដល់មាត់ទ្វារ។ **តៀនអ៊ុយ**ក៏ស្ទុះរត់ទៅកន្ត្រាក់បានដាវពីកូនទាហាន កាប់ទាហាន**តៀវស៊ីវ**ស្លាប់ប្រហែលម្ភៃបួន-ម្ភៃប្រាំនាក់។ ទាហានទាំងពួងក៏ថយចេញមករារាំងនៅក្រៅទ្វារ។ ឯទាហាន**តៀវស៊ីវ**ទាំងពីរកងខាងក្រោយបន្ទាយ ក៏ហែកទម្លាយចូលទៅបានជាច្រើន ចូលចោមព័ទ្ធជុំវិញ**តៀនអ៊ុយ** ហើយចាក់**តៀនអ៊ុយ**ត្រូវនឹងអាវុធ របួសពិការអស់ពេញទាំងខ្លួន។

**តៀនអ៊ុយ**ក៏មិនបានរួញរាញញើត កាន់ដាវកាប់ទាហាន**តៀវស៊ីវ**ទាល់តែដាវនោះដាច់ជាពីរ។ **តៀនអ៊ុយ**ក៏អួសកន្ត្រាក់យកខ្មោចស្លាប់ដៃម្ខាងមួយ ការពារតស៊ូក្នុងទីនោះ ហើយយកខ្មោចគ្រវាត់បោកទៅត្រូវទាហាន**តៀវស៊ីវ** ស្លាប់ប្រហែលប្រាំបួន-ដប់នាក់ទៀត។ ទាហាន**តៀវស៊ីវ**តស៊ូនឹង**តៀនអ៊ុយ**មិនបាន ក៏ថយចេញទៅប្រហែលប្រាំបួនដប់ព្យាម ហើយយកធ្នូបាញ់**តៀនអ៊ុយ**បង្រុះទៅត្រូវមុខសុះអស់ទាំងខ្លួន។ **តៀនអ៊ុយ**ក៏នៅគង់ជំហរ មានទាហានមួយកងទៀតរត់ចូលមកពីខាងក្រោយ យកទួនចាក់**តៀនអ៊ុយ**ត្រូវជាច្រើនអន្លើ ទាល់តែ**តៀនអ៊ុយ**ធ្លាយឈាមហូរពេញអស់ទាំងខ្លួន ហើយខំត្រដរទៅឈរផ្អែកនឹងមាត់ទ្វារគ្រាតែដាច់ខ្យល់ស្លាប់ទៅ។ ឯទាហាន**តៀវស៊ីវ**ដែលនៅខាងក្រោយបន្ទាយមិនដឹងថា**តៀនអ៊ុយ**ស្លាប់ ក៏នាំគ្នាញញើតខ្លាចថ្វីដៃ**តៀនអ៊ុយ**មិនហ៊ានចូលទៅ។

ក្នុងពេលដែល**តៀនអ៊ុយ**នៅតស៊ូច្បាំងគ្នានោះ **ចូឆូ**ក៏ឡើងសេះនាំ**ចោអាន់ប៊ុន**និងទាហានប្រហែលប្រាំបួន-ដប់នាក់ រត់ទម្លាយចេញទៅខាងក្រៅបន្ទាយបាន។ ទាហាន**ចូឆូ**ដែលនៅបន្ទាយឯទៀតក៏បែកខ្ចាត់ខ្ចាយទៅអស់ នាំគ្នារត់ឆ្លងទន្លេយ៉ុកស៊ុយទៅបានខ្លះៗ ឯពួកទាហាន**តៀវស៊ីវ**នោះក៏កាប់ទាហាន**ចូឆូ**ស្លាប់ជាច្រើន លុះដឹងថា**ចូឆូ**រត់ចេញទៅខាងក្រោយបន្ទាយ ក៏បបួលគ្នាលើកដេញតាមទៅយកធ្នូបាញ់ត្រូវ**ចោអាន់ប៊ុន**ធ្លាក់ពីលើសេះស្លាប់។ **ចូឆូ**ក៏ត្រូវព្រួញមួយអន្លើ សេះដែល**ចូឆូ**ជិះនោះមានកម្លាំងខ្លាំងក្លាណាស់ ត្រូវព្រួញបីអន្លើក៏មិនដួល។ **ចូឆូ**បរសេះរត់ទៅដល់ត្រើយមាត់ទន្លេយ៉ុកស៊ុយតែម្នាក់ឯង។ ទាហាន**តៀវស៊ីវ**ក៏បាញ់នឹងធ្នូទៅត្រូវភ្នែកសេះនោះដួលស្លាប់ ទទួល**ចោងាំង**ជាកូន**ចូឆូ**រត់ទៅជួបនឹងបិតា ក៏ឲ្យសេះទៅបិតាជិះបរទៅ។ ទាហាន**តៀវស៊ីវ**ក៏បាញ់ធ្នូទៅត្រូវ**ចោងាំង**ស្លាប់នៅក្បែរមាត់ទន្លេ។ **ចូឆូ**រត់ទៅជួប

នឹងទាហានរបស់ខ្លួនដែលបែកមកជាច្រើនក៏នាំគ្នារត់ទៅ ឯ**ហែហ្លួទុន**ដែលបែកមកនោះ ក៏លើកទាហានទៅឆក់យកទ្រព្យរបស់អាណាប្រជានុរាស្ត្រដែលនៅស្រុកក្រៅបានមកជាច្រើន។

ឯ**អ៊ីគឹម**ក៏បែកទ័ពត្រឡប់មកព្រមគ្នា ដឹងថា**ហែហ្លួទុន**និងសេនាទាហានទៅវាយឆក់ដណ្ដើមរបស់ទ្រព្យសព្វបណ្ដារាស្ត្រដូច្នោះ **អ៊ីគឹម**ក៏មានចិត្តអាណិតអាណាប្រជារាស្ត្រទាំងនោះណាស់ លើកទាហានរូតរះទៅដេញកាប់សម្លាប់ទាហាន**ហែហ្លួទុន** ដែលជាពួកជាមួយគ្នា រប្លួសពិការស្លាប់ព្រាត់ព្រាយខ្ចាត់ខ្ចាយអស់ទៅ ទាហាន**ហែហ្លួទុន**ខ្លះរត់ទៅជួបនឹង**ចូឆ្វ** ៗនិងទាហានក៏នាំគ្នាសោកាអាណិតអានាថ ហើយជម្រាបថា **អ៊ីគឹម**ធ្វើប្រទូសរ៉ាយដេញកាប់សម្លាប់ ទើបយើងទាំងឡាយរត់ព្រាត់ព្រាយចូលមកខ្លះ ៗក៏ស្លាប់ ខ្លះក៏បែកទៅទីផ្សេងៗ យើងខ្ញុំយល់ឃើញថា**អ៊ីគឹម**ប្រាកដជាក្បត់នឹងលោកហើយ បានជាធ្វើការយ៉ាងនេះ។

**ចូឆ្វ**ភ័យស្លុត តែមិនទាន់ថាប្រការម្ដេច ក៏ឃើញ**ហែហ្លួទុន, ខៅធូ, លីតៀន, ង៉ាក់ជិន** ចូលមកប្រាប់ថា **អ៊ីគឹម**លើកទាហានដេញកាប់សម្លាប់ពួកទាហានយើងខ្ញុំសមនឹងប្រែចិត្តក្បត់នឹងលោកមែនហើយបានជាធ្វើដូច្នេះ សុំឲ្យលោកត្រៀមបម្រុងសេនាទាហានទុកនៅទីនេះឲ្យស្រេច ដើម្បីនឹងបានលើកទៅចាប់ខ្លួន**អ៊ីគឹម**ឲ្យបាន។

**ចូឆ្វ**ក៏យល់តាម ទើបប្រុងប្រៀបរៀបកងទ័ពបម្រុងទុកជាស្រេច។ ឯ**អ៊ីគឹម**ក៏ឲ្យរៀបតាំងបន្ទាយប្រាថ្នានឹងបម្រុងទទួល**ចូឆ្វ** ដើម្បីនឹងការពារកងទ័ព**តៀវស៊ីវ**។ លុះ**អ៊ីគឹម**ដឹងថា ទាហាន**ចូឆ្វ**បែកទ័ពលើកមកជិតហើយ ក៏ឲ្យទាហានទាំងពួងកាន់សាស្ត្រាវុធគ្រប់ដៃ ដើម្បីនឹងរក្សាបន្ទាយឲ្យមាំមួន។ ទាហាន**អ៊ីគឹម**ឮកិត្តិស័ព្ទថា “**ហែហ្លួទុន** និងទាហានបែកខាងនោះនាំសេចក្ដីទៅញុះញង់**ចូឆ្វ**ថា **អ៊ីគឹម**ប្រែចិត្ត

ក្បត់” ក៏នាំយករឿងនោះមកប្រាប់**អ៊ីគឹម**ហើយសួរថា បើគេពោលទោសលោកយ៉ាងនេះ ហេតុម្តេចលោកតាំងបន្ទាយត្រៀមបម្រុងសេនាទាហានទុកដូច្នេះទៀត? វេលានេះបើលោកមិនចេញទៅជួបនឹង**ចូឆូ** ក៏គង់នឹងជឿតាមពាក្យគេថាពុំខាន។

**អ៊ីគឹម**តបថា ដែលគេពោលទោសដល់យើងនោះជាសេចក្តីឫស្យាគ្នា ហេតុដែលយើងប្រុងប្រៀបរៀបធ្វើបន្ទាយទុកយ៉ាងនេះ ព្រោះដឹងថា **ចូឆូ**ចាញ់ទ័ពរត់មកត្រូវយកបន្ទាយនេះពឹងពាក់អាស្រ័យឲ្យរួចភ័យអន្តរាយ ដើម្បីតស៊ូនឹងសត្រូវទៅវិញ ឯការដែលត្រូវនិងខុសនោះ ត្រូវតែចាំរិះគិតទៅជាក្រោយ។

ខណៈនោះកងទ័ព**តៀវស៊ីវ**ក៏លើកមកស្កាត់ពីមុខជាពីរប៉ែក លុះឃើញបន្ទាយ**អ៊ីគឹម**មាំមួននៅទីនោះ **តៀវស៊ីវ**ក៏រាទ័ពឈប់។ **អ៊ីគឹម**ក៏លើកទាហានបរសេះគ្រវីទួនចេញទៅតយុទ្ធនឹង**តៀវស៊ីវ**ជាមាំមួន។ **តៀវស៊ីវ**យល់ថានឹងតទល់មិនបាន ក៏នាំទាហានថយត្រឡប់ទៅវិញតាមទន្លេយ៉ុកស៊ុយ។ **អ៊ីគឹម**ក៏បរពលដេញតាមចាក់កាប់សម្លាប់ទាហាន**តៀវស៊ីវ**ទៅត្រាតែដល់ប្រទះនឹង**ចូឆូ**។ ទាហាន**ចូឆូ**ក៏លើកគ្នាដេញកាប់សម្លាប់ទាហាន**តៀវស៊ីវ** បែកខ្ចាត់ខ្ចាយអន្តរាយស្លាប់បាត់ជាច្រើន។

ឯ**តៀវស៊ីវ**និងទាហានដែលសល់នៅប៉ុន្មាន ក៏រត់កាត់ផ្លូវសំដៅទៅរក**ឡៀវពៀវ**ចៅហ្វាយស្រុកកេងជីវ **ចូឆូ**ក៏មិនបានដេញតាម បានត្រួតត្រាប្រមូលសេនាទាហានឲ្យមកប្រជុំគ្នា។ **អ៊ីគឹម**ក៏ចូលទៅជួបនឹង**ចូឆូ** ហើយយកសេចក្តីជម្រាប**ចូឆូ**ថា ទាហាន**ហែហួទុន**គប់គិតគ្នា ទៅវាយឆក់ដណ្តើមយកទ្រព្យរបស់អស់បណ្តារាស្ត្រអ្នកស្រុក ខ្ញុំបាទឃើញមិនត្រូវ ក៏ឲ្យដេញកាប់សម្លាប់ពួកនោះចេញជាច្រើននាក់។ **ចូឆូ**តបថា យើងនិងអ្នកទាំងអស់គ្នាបែកទ័ពរត់ត្រឡប់ទៅតែសព្វខ្លួន ហេតុម្តេចខ្លួន

មិនមករកយើងឲ្យជួបជាមុន បានជាទៅតាំងបន្ទាយនៅកណ្ដាលផ្លូវនោះ តើនឹងប្រាថ្នាអ្វី?

**អ៊ីគឹម**បានជម្រាប**ចូឆ្ងូ**តាមគំនិតដែលគិតទុកគ្រប់ប្រការថា ខ្ញុំបាទប្រាថ្នានឹងការពារសឹកសត្រូវដែលវាលើកតាមលោកមក ប្រយោជន៍ដើម្បីឲ្យលោកបានជារបាំងរាំងការ ខ្លួនខ្ញុំបាទក៏បានច្បាំងនឹង**តៀវស៊ីវ**ទាល់តែបែកទ័ព ហើយខ្ញុំស្វែងរកលោកក៏មិនជួបប្រទះ ទោសខ្ញុំបាទក៏ខុសណាស់ទៅហើយ ស្រេចតែលោកនឹងមេត្តា។

**ចូឆ្ងូ**បានស្ដាប់សព្វគ្រប់ ក៏មានសេចក្ដីត្រេកអរសរសើរ**អ៊ីគឹម**ថា "ដែលអ្នកគិតធ្វើបានយ៉ាងនេះទើបបានជ័យជម្នះមែន រីគំនិតដែលអ្នកចេះគិតដូច្នេះ ទោះបីទាហានដែលមានកេរ្ដិ៍ឈ្មោះមកពីដើម ក៏មិនស្មើនឹងអ្នក" លុះសរសើរសព្វគ្រប់ទើបយកទ្រព្យមាសប្រាក់ឲ្យ**អ៊ីគឹម**មួយប្រដាប់សម្រាប់បំណាច់ ហើយតាំង**អ៊ីគឹម**ជា "ឥតស៊ីវតេងហៅ" គឺនាហ្មឺនចម្រើនអាយុ។ ឯ**ហែហួទុន**ដែលមិនបានកំជាប់ទាហាន បណ្ដោយឲ្យធ្វើទុក្ខបុកម្នេញអស់បណ្ដារាស្ត្រ ក៏ឲ្យកាត់សេចក្ដីធ្វើទោសដាក់គុក។

**ចូឆ្ងូ**ឲ្យរៀបតុសើនចាក់ស្រាឲ្យ**តៀនអ៊ុយ** ហើយនិយាយប្រាប់សេនាទាហានទាំងពួងថា "បោះបីកូនចៅរបស់យើងស្លាប់អន្តរាយ យើងក៏មិនសូវសោកស្ដាយស្មើនឹង**តៀនអ៊ុយ**នោះឡើយ" និយាយហើយក៏យំសោកាអាល័យស្ដាយ**តៀនអ៊ុយ**បរិវេទនាការ។ បណ្ដាសេនាទាហានឃើញដូច្នោះ ក៏មានចិត្តអាណិតអានាថ**ចូឆ្ងូ**ពន់ប្រមាណ ក៏ប្រះប្រាណទួញយំទាំងអស់គ្នា។ លុះ**ចូឆ្ងូ**ស្វាងទុក្ខសោកវេលាណា ក៏រៀបចំភ្ជុំពលយោធាលើកត្រឡប់ទៅក្រុងហ៊្សូតោវិញ។

ឯ**អងចិក**ដែល**ចូឆ្វ**ប្រើឲ្យនាំសំបុត្រទៅឲ្យ**លីប៉ោ** លុះទៅដល់ស្រុកឈីជីវ ហើយ **លីប៉ោ**ដឹងក៏ចេញទៅទទួលហើយអញ្ជើញចូលទៅក្នុងស្រុក។ **អងចិក**ក៏ជូនសំបុត្រព្រះតម្រាស់ឲ្យ**លីប៉ោ** ៗទទួលមើលឃើញសេចក្ដីថា ទ្រង់ប្រោសព្រះរាជទានឲ្យ**លីប៉ោ**ជាទីប៉ែងតងចុងគុន គឺជានាហ្មឺនធំសម្រាប់បង្ក្រាបពួកចោរខាងបូព៌ាទិស។ មានសំបុត្រ**ចូឆ្វ**មួយច្បាប់ទៀតថា ឲ្យ**លីប៉ោ**ស្ម័គ្រសមាគមនឹង**ឡៅពី**កុំឲ្យមានសេចក្ដីអាឃាដព្យាបាទគ្នាតទៅ ហើយ**អងចិក**ជម្រាប**លីប៉ោ**ថា សព្វថ្ងៃនេះមហាឧបរាជមានសេចក្ដីមេត្តាលោកច្រើន បានជាយកសេចក្ដីក្រាបទូលព្រះចៅ**ហៀនតេ**សរសើរគុណបំណាច់លោកសុំឲ្យបានជានាហ្មឺនធំ។ **លីប៉ោ**បានស្ដាប់ដូច្នោះ ក៏មានសេចក្ដីសោមនស្សត្រេកអរណាស់។

ខណៈនោះមានបម្រើចូលទៅជម្រាប**លីប៉ោ**ថា ឥឡូវ**អ៊្ហួនសុត**ប្រើទាហានមករកលោក **លីប៉ោ**ក៏ឲ្យហៅចូលទៅហើយសួរថា **អ៊្ហួនសុត**ប្រើឲ្យលោកមកហេតុអ្វី? ទាហាននោះជម្រាបថា **អ៊្ហួនសុត**ប្រើខ្ញុំបាទមកជម្រាបលោកថា វេលានេះ**អ៊្ហួនសុត**កំពុងរៀបចំនឹងតាំងខ្លួនជាស្ដេចម្ចាស់ផែនដី ហើយនឹងតាំងកូនប្រុសជាតុងកុង គឺជាទីតំណាងខាងមុខ ឲ្យលោកស្រូតរូតអញ្ជើញបុត្រីរបស់លោកទៅជាប្រញាប់ នឹងបានរៀបការឲ្យនៅជាមួយគ្នាតែម្ដង។

**លីប៉ោ**បានស្ដាប់ក៏នឹកខឹងណាស់ជេរ**អ៊្ហួនសុត**ថា “អានេះវាគិតប្រទូសរ៉ាយក្បត់ផែនដី” ហើយក៏ឲ្យចាប់ទាហានបម្រើ**អ៊្ហួនសុត**នោះទៅសម្លាប់ចេញ។ ឯ**ហាន់អ៊ិន**ដែលនៅក្នុងគុកនោះ ក៏ឲ្យដាក់ច្រវ៉ាលច្រវាក់ដែកទុកឲ្យខ្ជាប់ខ្លួន ហើយធ្វើសំបុត្របកមក**តាន់តេង**លើកទាហានឃុំនាំខ្លួន**ហាន់អ៊ិន**ចូលទៅជូន**ចូឆ្វ**ឯស្រុកក្រុង។

**ចូឆ្វ**ទទួលសំបុត្រក៏យកមកមើលឃើញសេចក្តីថា “ខ្ញុំបាទ**លីប៉ោ**គំនាប់មកព្រោះមហាឧបរាជមានសេចក្តីមេត្តាខ្ញុំបាទ បានជួយយកសេចក្តីក្រាបបង្គំទូលព្រះចៅ**ហៀនតេ** ឲ្យខ្ញុំបាទបានពេញទីជាចៅហ្វាយស្រុកឈើជីវ ខ្ញុំបាទក៏នឹងបានធ្វើរាជការតបស្នងឆ្លងព្រះតេជព្រះគុណទៅ។ **ចូឆ្វ**យល់តាមសេចក្តីសំបុត្រនោះក៏គិតថា “គ្រានេះ**លីប៉ោ**និង**អ៊្លួនសុត**មានសេចក្តីទាស់ទែងគ្នា មុខជានឹងដាច់ពីជន្លងនឹងគ្នាហើយ បានជាធ្វើដូច្នេះ”។ ហើយក៏ឲ្យយកខ្លួន**ហាន់អ៊ុន**ទៅសម្លាប់។

**តាន់តេង**ចូលទៅខ្សឹបជម្រាប**ចូឆ្វ**ថា **លីប៉ោ**នោះជាមនុស្សទុច្ចរិតអាក្រក់ហាក់ដូចជាសត្វតិរច្ឆាន មានតែកម្លាំងគ្មានសតិបញ្ញាអ្វីសោះ ដែលមហាឧបរាជនឹងចិញ្ចឹមមនុស្សនោះឲ្យជាធំ យូរទៅក៏គង់ប្រែសត្រូវនឹងលោកវិញ។

**ចូឆ្វ**ឆ្លើយថា យើងដឹងណាស់ហើយ យើងប្រុងតែនឹងកម្ចាត់វាចេញ អ្នកឯងពីរនាក់អាពុកនិងកូននៅក្នុងស្រុកឈើជីវស្រាប់ រមែងដឹងគំនិតមារយាទវាច្បាស់ណាស់ហើយ បើកាលណាយើងលើកទ័ពទៅស្រុកឈើជីវហើយ ទោះបីខ្វះខាតរបស់អ្វីអ្នកត្រូវតែជួយគិតគូរ ឲ្យកើតការផងចុះ។

**តាន់តេង**ជម្រាបថា ប្រសិនមហាឧបរាជនឹងត្រូវលើកទ័ពទៅគ្រាណា ខ្លួនខ្ញុំបាទនិងបិតាបម្រុងនឹងចាំធ្វើកលសឹកខាងក្នុងឲ្យបានសម្រេច។ **ចូឆ្វ**ក៏តាំង**តាន់តេង**ជាចៅហ្វាយស្រុកកងឡេង ត្រូវឡើងស្តាប់បង្គាប់ស្រុកឈើជីវ ហើយឲ្យមានត្រាព្រះតម្រាស់ព្រះចៅ**ហៀនតេ** ទៅដល់**លីប៉ោ**ចៅហ្វាយស្រុកឈើជីវ ឲ្យបំពេញស្នួយអាករដល់**តាន់គុយ**ជាបិតា**តាន់តេង**ជាច្រើន។ **តាន់តេង**ក៏គំនាប់លា**ចូឆ្វ** ៗក៏ចាប់ដៃបញ្ឈប់ហើយនិយាយថា ការដែលយើងបានគិតទុកគ្រានេះ យើងសុំទុកចិត្តចំពោះ

រូបអ្នក ចូរអ្នកខំរិះគិតធ្វើការឲ្យសម្រេចប្រយោជន៍កុំឲ្យខាន។ **តាន់តេង**ទទួលពាក្យ**ចូឆ្វ** ហើយក៏លាចេញទៅដល់**លីប៉ោ**ឯស្រុកឈីជីវ។

**លីប៉ោ**សួរ**តាន់តេង**ថា អ្នកបានជួបនឹង**ចូឆ្វ** ៗនិយាយការដូចម្ដេចខ្លះ? **តាន់តេង**ក៏ស្រាយយកត្រាតាំងសម្រាប់ខ្លួន និងត្រាប្រោសព្រះរាជទានស្នួយបិតារបស់ខ្លួនបង្ហាញឲ្យ**លីប៉ោ**មើល។ **លីប៉ោ**ឃើញដូច្នោះក៏ខឹងណាស់ថា “យើងចាត់ប្រើខ្លួនទៅចំពោះការងាររបស់យើង ហេតុម្ដេចខ្លួនទៅរិះគិតយកប្រយោជន៍ខ្លួននិងអាពុកខ្លួនវិញ? ម្យ៉ាងទៀតកាលយើងលើកកូនក្រមុំយើងឲ្យ**អ៊្វិនសុត**, **តាន់គុយ**អាពុកខ្លួននិយាយឃាំងឃាត់យើង ហើយក្លែងឲ្យយើងទៅចូលខាង**ចូឆ្វ** ឥឡូវយើងប្រើខ្លួនទៅក៏មិនឃើញបានការអ្វីដល់តិចសោះ” និយាយហើយក៏ហូតគ្រប៊ីកាន់បម្រុងនឹងសម្លាប់**តាន់តេង**។

**តាន់តេង**ឃើញដូច្នោះក៏ធ្វើជាអស់សំណើចហើយថា លោកស្ដាប់សេចក្ដីមិនទាន់អស់ ប្រញាប់តែខឹងនឹងខ្ញុំបាទ។ **លីប៉ោ**តបថា នៅមានសេចក្ដីអ្វីតទៅទៀតដែលខ្លួនថាយើងស្ដាប់មិនបាននោះ? **តាន់តេង**ជម្រាបថា កាលខ្ញុំទៅរក**ចូឆ្វ**នោះ សុំឲ្យ**ចូឆ្វ**ចិញ្ចឹមលោកឲ្យធំដល់ខ្លាតឧបមាដូចយើងចិញ្ចឹមខ្លា បើបានអាហារបរិភោគឆ្អែតក៏ជាប្រក្រតី បើមិនឆ្អែតហើយរមែងបៀតបៀនសត្វទាំងពួងជាអាហារ។ **ចូឆ្វ**ឮខ្ញុំបាទថាដូច្នោះ អស់សំណើចហើយថា ដែលនឹងចិញ្ចឹមលោកឲ្យពេញយសដូចខ្ញុំបាទនេះមិនបាន ព្រោះសព្វថ្ងៃនេះលោកនៅមានសេចក្ដីលំអុតលំឱនទៅរក**ចូឆ្វ**ដោយសារតែលោកនៅទុញទាល់ទេ បើប្រសិនជាលោកមានពលាការមាំមួនឡើងវេលាណា លោកគង់ប្រែចិត្តចេញអំពី**ចូឆ្វ** មានឧបមាដូចខ្លែងចង់បរិភោគអាហារត្រូវចាំឃ្លាំមើលកូនមាន់ដែលឃ្លាតចេញពីមេវេលាណា ក៏នឹងឆៀរឆាបចាប់យកកូន

មាន់នោះឲ្យបាន បើមានមេវានៅការពារក៏ចាំតែធ្វើសេចក្តីព្យាយាម ត្រាតែចាប់យកកូនមាន់នោះឲ្យបានសម្រេចដូចចិត្តប្រាថ្នា។ ខ្ញុំបាទក៏បានសួរថា ដែលលោកឧបមាថាខ្លែងនោះគឺខ្លួន**លីប៉ោ**ហើយ ចុះកូនមាន់នោះនឹងប្រៀបដូចនរណាវិញ? **ចូវឆ្វូ**តបថា កូនមាន់នោះគឺ**អ៊្លួនសុត**ថៅហ្វាយស្រុកឡាំយ៉ុង, **ស៊ុនសេក**ថៅហ្វាយស្រុកកាំងតាំង, **អ្វូនសៀវ**ថៅហ្វាយស្រុកគីជីវ, **ឡៅពៀវ**ថៅហ្វាយស្រុកកេងជីវ, **ឡៅជៀង**ថៅហ្វាយស្រុកសៃឈួន, **តៀវឡូ**ថៅហ្វាយស្រុកហាន់តុង។ **លីប៉ោ**បានឮដូច្នោះ ក៏ពេញចិត្តណាស់ សម្គាល់ថាពាក្យពិត ទើបទម្លាក់គ្របីចេញពីដៃហើយថា **ចូវឆ្វូ**នោះមានសតិបញ្ញាអាចប្រមាណចិត្តយើងត្រូវមិនខុសសោះ។

ឯ**អ៊្លួនសុត**នោះ តាំងពីបានត្រាចម្លាក់របស់**ស៊ុនសេក**ទុក ក៏គិតតែនឹងតាំងខ្លួនជាស្តេច ហើយប្រឹក្សានឹងសេនាទាហានទាំងពួងថា យើងបានឮពាក្យបុរាណថា កាលគ្រាព្រះចៅ**ហាន់កោចោ**នៅមិនទាន់ទទួលរាជសម្បត្តិ ក៏ជាមនុស្សអនាថឧបមាដូចនៅក្នុងផ្ទៃសមុទ្រ ឧស្សាហ៍ធ្វើសេចក្តីព្យាយាមមកជាច្រើន ទើបបានតាំងខ្លួនឡើងសោយរាជសម្បត្តិ ទ្រង់ព្រះនាមព្រះចៅ**ហាន់កោចោ** លុះជាលំដាប់មកក៏មានព្រះរាជវង្សបានសោយរាជ្យតៗមកទៀតដល់បួនរយឆ្នាំ ដរាបដល់ព្រះចៅ**ហៀនតេ**សព្វថ្ងៃនេះ វេលានេះព្រះចៅ**ហៀនតេ**ទទួលរាជសម្បត្តិ ហើយស្រុកទេសក៏កើតចលាចលអន្តរាយផ្សេងៗ បើតាមសង្កេតទៅក៏ឃើញថាវាសនាបារមីព្រះចៅ**ហៀនតេ** នឹងរៀវរោយសាបសូន្យអស់ហើយ ខ្លួនយើងក៏ជាពូជនាហ្មឺនមកពីដើម បណ្តារាស្ត្រទាំងឡាយក៏មានសេចក្តីស្រឡាញ់យើងច្រើន ហេតុនេះត្រូវតែយើងនឹងតាំងខ្លួនធ្វើជាម្ចាស់ផែនដី តើអ្នកទាំងឡាយនឹងយល់ឃើញដូចម្តេច?

**អៀមសៀង**ទីប្រឹក្សាក៏ហាមឃាត់**អ៊ូនសុត**ថា កាលគ្រាព្រះចៅ**ទីវអង**បានសោយរាជសម្បត្តិនៅក្នុងស្រុកក្រុង រមែងបៀតបៀនឲ្យបណ្ដារាស្ត្របានសេចក្ដីក្ដៅក្រហាយ ខណៈនោះ**ជីវប៊ុនអង**ដែលជានាហ្មឺនធំនៅស្រុកកីសាន់ លោកផ្ចៀវផ្លាតក្នុងការពិជ័យសង្គ្រាម អាណាខេត្តក្នុងប្រទេសចិនក៏នៅក្នុងចំណោម**ជីវប៊ុនអង**ដល់ពីរភាគ នៅក្នុងអំណាចព្រះចៅ**ទីវអង**តែមួយភាគ **ជីវប៊ុនអង**ជាមនុស្សសុចរិតពិតត្រង់នឹងផែនដី មិនបានតាំងខ្លួនធ្វើស្ដេចទេ ចុះឥឡូវនេះព្រះចៅ**ហៀនតេ**នៅមានព្រះជន្មាយុគង់ជាម្ចាស់ផែនដី ហើយមិនបានបៀតបៀនធ្វើអន្តរាយដល់បណ្ដារាស្ត្រឯណាសោះ ដែលលោកមកពិគ្រោះនឹងលើកខ្លួនធ្វើស្ដេចនោះ ខ្ញុំបាទមិនយល់ព្រមផងទេ។

**អ៊ូនសុត**បានឮដូច្នោះក៏ឆ្លើយថា ត្រាចម្លាក់សម្រាប់មហាក្សត្រផែនដីនៅក្នុងកណ្ដាប់ដៃអញ បីដូចជាទេពតាមកប្រសិទ្ធីឲ្យអញបានធ្វើស្ដេចហើយ បើនរណាមិនយល់ព្រមតាមចិត្តអញទេ នឹងឲ្យកាត់ក្បាលចេញ។ ខ្ញុំរាជការទាំងអស់គ្នាក៏នៅស្ងៀម មិនមាននរណាឆ្លើយដូចម្ដេច។ **អ៊ូនសុត**តាំងតែរៀបចាត់ចែងវាំងកំពែងក្នុងស្រុក ហើយក៏សន្មតខ្លួនជាម្ចាស់ផែនដី ឈ្មោះ**តងស៊ី** គឺជាពូជព្រះចៅ**ង៉ឺស៊ុន**មកពីដើម។

លំដាប់តមក**អ៊ូនសុត**ដឹងថា **លីប៉ោ**គិតប្រែប្រួលចាប់ខ្លួន**ហាន់អ៊ិន**ដាក់ក្ដីហើយបញ្ជូនទៅឲ្យ**ចូឆូ** ហើយសម្លាប់ទាំងបម្រើដែលកាន់សំបុត្រគៀនយកកូនក្រមុំនោះចេញផង **អ៊ូនសុត**ខឹងណាស់ ក៏គិតលើកទ័ពទៅច្បាំងនឹង**លីប៉ោ** ទើបចាត់**គៀវហ៊ុន**ជាមេទ័ពធំលើកទាហានម្ភៃម៉ឺន ឲ្យ**គៀវសេង** និង**តាន់គី**ជាមេទ័ពមុខ ឲ្យ**តាន់ឡាន់**ជាមេទ័ពស្ដាំ ឲ្យ**លុយប៉ុក**ជាមេទ័ពឆ្វេង ឲ្យ**អៀវហង** និង**ហាន់សៀម**ជាមេ

ទ័ពក្រោយ ហើយលើកទៅវាយស្រុកឈីជីវ ហើយឲ្យមានសំបុត្រទៅដល់**គិមសៀង** ចៅហ្វាយស្រុកឃួនជីវ ដែលត្រូវឡើងខេត្ត**អ៊្វួនសុត**ថា ឲ្យ**គិមសៀង**ចាត់ស្បៀងអាហារប្រគល់ឲ្យកងទ័ព ដែលលើកទៅវាយស្រុកឈីជីវកុំឲ្យខ្វះខាត បើកងទ័ពខ្វះខាតដោយស្បៀងអាហារវេលាណា យើងត្រូវកាត់ក្បាល**គិមសៀង**វេលានោះ រួចចាត់ប្រើ**គីឡេង**លើកទ័ពណូនតាមទៅទៀត ក៏នៅមិនទាន់ទុកចិត្តក៏ប្រើ**លោហាង, លៀងកង** និង**ងាក់ជីវ** លើកតាមទៅត្រួតត្រាកងទ័ពទាំងពួង ឲ្យស្រូតរូតចូលធ្វើការឲ្យព្រមគ្នា ខ្លួន**អ៊្វួនសុត**ក៏លើកទាហានបីម៉ឺនទៅជាក្រោយ។

កាល**តៀវហ៊ុន**លើកទ័ពទៅជិតនឹងដល់ស្រុកឈីជីវ ក៏ឲ្យបំបែកកងទ័ពញែកជាប្រាំពីរកង ឲ្យ**តៀវសេង**លើកទៅវាយស្រុកសៀវផាយ ឲ្យ**តាន់គី**លើកទៅវាយស្រុកគិនតោ ឲ្យ**លុយប៉ុក**លើកទៅវាយស្រុកឡុកអៀង ឲ្យ**តាន់ឡាន់**លើកទៅវាយស្រុកកៀតសិក ឲ្យ**ហាន់សៀម**លើកទៅវាយស្រុកហែហ្វី ឲ្យ**អៀវហាង**លើកទៅវាយស្រុកជុនស្ស៊ួ ខ្លួន**តៀវហ៊ុន**នោះលើកទ័ពធំទៅវាយស្រុកឈីជីវ ហើយក៏ញែកគ្នាជាប្រាំពីរផ្លូវ ដើរផ្លូវមួយថ្ងៃចម្ងាយប្រាំរយសិន (២០ គ.ម)។

ឯ**លីប៉ោ**កាលដឹងថា ទ័ព**អ៊្វួនសុត**លើកមកច្បាំងដូច្នោះ ក៏ឲ្យហៅ**តាន់កុង, តាន់គុយ, តាន់កេង** និងនាយទាហានទាំងពួងមកប្រឹក្សាថា គ្រានេះ**អ៊្វួនសុត**លើកទ័ពមកធំយ៉ាងពន្លឹក ហើយញែកគ្នាទៅវាយស្រុកចំណុះរបស់យើងទាំងអស់ តើអ្នកទាំងឡាយនឹងគិតប្រការដូចម្តេច? **តាន់កុង**ឆ្លើយថា ដែលកើតហេតុទាំងនេះ ក៏ព្រោះ**តាន់គុយ**និង**តាន់តេង**ពីរនាក់អាពុកនិងកូន ឃាត់មិនឲ្យលោកលើកកូនក្រមុំឲ្យ**អ៊្វួនសុត** ហើយគុបគិតចូលគំនិតគ្នាទៅនិយាយនឹង**ចូឆូ** ៗក៏តាំង**តាន់តេង**ជានាហ្មឺនមានបណ្តាសក្តិ ហេតុនេះសូមលោកចាប់ខ្លួន**តាន់តេង**និង**តាន់គុយ**បញ្ជូនទៅឲ្យ**អ្វួនសុត** ហើយ

សម្ដែងរឿងរ៉ាវទាំងប៉ុន្មានឲ្យ**អ៊ួនសុត**អស់សេចក្ដីសង្ស័យ ប្រហែល**អ្នួនសុត**នឹងលើកទ័ពត្រឡប់ទៅវិញ។ **លីប៉ោ**យល់ឃើញត្រូវ ក៏បង្គាប់ទាហានឲ្យទៅចាប់ខ្លួន**តាន់គុយ**និង**តាន់តេង**ទាំងពីរនាក់ទៅសម្លាប់។

**តាន់តេង**ដឹងថា **លីប៉ោ**បង្គាប់ឲ្យចាប់ខ្លួន ក៏ចូលទៅជួបនឹង**លីប៉ោ** និយាយហើយសើចចំអកឲ្យ**លីប៉ោ**ថា ពីដើមខ្ញុំបាទយល់ថា លោកជាមនុស្សមានសតិបញ្ញាស្គាល់ការខុសត្រូវមាំមួន ឥឡូវសង្កេតទៅឃើញគំនិតនិងតម្រិះប្រាជ្ញារបស់លោកទន់ខ្សោយពេកណាស់ ចុះលោកទៅញញើតខ្លាចអីនឹងចំនួនកងទ័ព**អ៊ួនសុត**ប្រាំពីរកងប៉ុណ្ណោះ ឧបមាដូចជាស្មៅប្រាំពីរក្ដាប់នៅជិតមាត់គោ នឹងទំពារស៊ីក៏អស់ដោយងាយណាស់ ដូចរឿងនេះបើនឹងគិតតស៊ូក៏ឃើញថាកងទ័ព**អ៊ួនសុត**នោះ នៅមិនល្មមនឹងគំនិតរបស់ខ្ញុំបាទទេ។ **លីប៉ោ**សួរថា អ្នកនឹងគិតធ្វើឧបាយដូចម្ដេច ក៏ឲ្យរិះគិតធ្វើឲ្យបានទៅចុះ បើគិតយកអាសាចេញទៅតស៊ូនឹង**អ៊ួនសុត**បាន យើងក៏ព្រមលើកទាំងអាពុកនិងកូន។ **តាន់គុយ**ជម្រាបថា ប្រសិនបើលោកស្ដាប់ពាក្យខ្ញុំបាទ ៗនឹងធានាស្រុកឈីជីវទុកមិនឲ្យកើតមានសេចក្ដីអន្តរាយឡើយ។ **លីប៉ោ**សួរថា គំនិតរបស់អ្នកនឹងគិតធ្វើប្រការដូចម្ដេច? **តាន់គុយ**ជម្រាបថា ទាហាន**អ៊ួនសុត**ច្រើនក៏មែនពិតហើយ តែថាសុទ្ធតែជាមនុស្សផ្ដេសផ្ដាស មិនចំណានក្នុងការសឹកសង្គ្រាម ទាំងខ្លួន**អ៊ួនសុត**សោតក៏មិនសូវទុកចិត្តប៉ុន្មាន ឯទាហានក្នុងស្រុកយើងសុទ្ធតែជាមនុស្សគួរទុកចិត្តបាន បើយើងនឹងលើកចេញទៅច្បាំងនឹង**អ៊ួនសុត**វេលាណាគង់ទាហានខាងយើងនឹងមានជ័យជម្នះ ឯគំនិតខ្ញុំបាទដែលនឹងគិតរក្សាស្រុកឈីជីវនេះត្រូវតស៊ូនឹង**អ៊ួនសុត**មានឧបាយទៅទៀត។ **លីប៉ោ**សួរថា កលឧបាយរបស់អ្នកគិតធ្វើដូចម្ដេចខ្លះ?

**តាន់គុយ**ជម្រាបថា **ហាន់សៀម**និង**អៀវហង**ពីរនាក់នេះ ពីដើមនៅធ្វើខ្ញុំរាជការព្រះចៅ**ហៀនតេ** លុះ**ចូឆូ**ធ្វើទុក្ខបៀតបៀនគ្មានទីពឹងពុំនាក់ក៏នាំគ្នារត់មកពឹងបុណ្យ**អ៊្វីនសុត** ៗក៏មិនជប់លៀងតាមគុណបំណាច់និងតម្រិះប្រាជ្ញាឲ្យដល់ខ្នាត ខ្ញុំបាទឃើញថា **ហាន់សៀម** និង**អៀវហង**មិនមែនតាំងចិត្តទៀងត្រង់នឹង**អ៊្វីនសុត**ប៉ុន្មាន សុំឲ្យលោកមានសំបុត្រជាសម្ងាត់ទៅដល់**ហាន់សៀម** និង**អៀវហង**ថា បើវេលាណាខ្លួននឹង**អ៊្វីនសុត**ចេញច្បាំងនឹងគ្នា ឲ្យ**ហាន់សៀម** និង**អៀវហង**គិតធ្វើកលសឹកខាងក្នុង ហើយឲ្យលោកមានសំបុត្រទៅដល់**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ**លើកទ័ពមកជួយវាយខ្ទប់ពីក្រោយទ័ព**អ៊្វីនសុត** មុខជា**អ៊្វីនសុត**នឹងបរាជ័យមិនខាន។

**លីប៉ោ**យល់ឃើញត្រូវ ក៏ធ្វើសំបុត្រចាត់ប្រើ**តាន់តេង**ឲ្យលបចេញទៅឲ្យ**ហាន់សៀម**និង**អៀវហង** ដែលលើកទ័ពទៅវាយស្រុកហែហ្វី និងស្រុកជុនស្វ ហើយប្រើទាហានឲ្យកាន់សំបុត្រចូលទៅក្រុងហ៊្វូតោជូនដំណឹងដល់**ចូឆូ**មួយច្បាប់ ទៅដល់**ឡៅពី**នៅស្រុកអ៊ីជីវមួយច្បាប់។ លុះ**តាន់តេង**បានសំបុត្រនិងទាហានបីនាក់ ក៏លបចេញទៅស្រុកហែហ្វីមុន ទទួល**ហាន់សៀម**លើកទ័ពទៅដល់ស្រុកហែហ្វីតាំងបន្ទាយនៅក្រៅកំពែងស្រុក។ **តាន់តេង**ក៏ចូលទៅជួបនឹង**ហាន់សៀម**ក្នុងបន្ទាយ **ហាន់សៀម**ក៏សួរ**តាន់តេង**ថា អ្នកឯងនេះក្រែងជាពួកម៉ាក**លីប៉ោ**ទេ ហេតុម្តេចក៏ចូលមកក្នុងបន្ទាយយើង? **តាន់តេង**សើចហើយថា ខ្ញុំជាខ្ញុំព្រះចៅ**ហៀនតេ**ទេ ហេតុម្តេចអ្នកថាជាពួកម៉ាក**លីប៉ោ**វិញ? ខ្លួនខ្ញុំនិងអ្នកក៏ដូចគ្នា ព្រោះអ្នកបាននៅធ្វើជាខ្ញុំរាជការព្រះចៅ**ហៀនតេ** កាលទ្រង់សោយទុក្ខលំបាកនៅទីគយគួនតុង អ្នកក៏បានជួយឲ្យព្រះអង្គរួចចាកទុក្ខ ខ្លួនអ្នកក៏នៅមានគុណបំណាច់នឹងផែនដី ដូចជាបក្សីបានសំបុកនិងទ្រនំហើយ ម្តេចឡើយក៏អ្នកមកលះបង់សំបុកទ្រនំ មកនិយមនៅនឹង

**អ៊ួនសុត**ជាមនុស្សអកញ្ញក្បត់ផែនដី? ខ្ញុំឃើញការមិនគប្បីដូច្នេះ បានជាចូលមកដើម្បីនឹងដាស់តឿនសតិអ្នក ព្រោះខ្ញុំឃើញថា បើអ្នកនឹងជ្រកនៅក្នុងម្លប់**អ៊ួនសុត**តទៅអ្នកក៏គង់មានសេចក្ដីទុក្ខភ័យលំបាកទៅខាងមុខ បើអ្នកចង់ឲ្យរួចចាកទុក្ខជាសុខតទៅត្រូវតែគិតឲ្យហើយជាមុន ទើបផុតរួចចាកកណ្ដាប់ដៃ**អ៊ួនសុត**បាន។

**ហាន់សៀម**បានឮ**តាន់តេង**សម្ដែងពីរឿងដើមទាំងប៉ុន្មាន ក៏មានសេចក្ដីរពួកនឹកឃើញសព្វគ្រប់ ដាក់មុខស្ងួតស្ងប់ហើយដកដង្ហើមធំនិយាយថា ខ្ញុំសព្វថ្ងៃនេះក៏រិះគិតមិនភ្លេចដែរ តែថាបានជាជ្រុលខ្លួនមកនៅនឹង**អ៊ួនសុត**ហើយ មិនដឹងឡើយដែលនឹងគិតដូចម្ដេច ការនេះស្រេចតែអ្នកជួយគិតខ្ញុំផង។ **តាន់តេង**យល់អធ្យាស្រ័យហូតយកសំបុត្រ**លីប៉ោ**ហុចទៅឲ្យ**ហាន់សៀម** ៗមើលដឹងសេចក្ដីច្បាស់ក៏ផ្លាស់ចិត្តទទួលរ៉ាប់រងថា ការនេះកុំព្រួយ ចាំខ្ញុំទៅរិះគិតនឹង**អៀវហាង**ទៀត អ្នកចូរឆ្លៀតទៅជម្រាប**លីប៉ោ**ចុះថា ការនោះខ្ញុំទទួលជាធុរៈហើយ បើកាលណា**លីប៉ោ**ចូលវាយត្រង់គយនោះ ខ្ញុំនឹងជួយធ្វើការនោះឲ្យសម្រេច។ **តាន់តេង**មានសេចក្ដីត្រេកអរជាពន្លឹក ហើយក៏ធ្វើសេចក្ដីគារវៈគំនាប់**ហាន់សៀម** ហើយលាចេញទៅ យកសេចក្ដីនោះមកជម្រាប**លីប៉ោ**គ្រប់ប្រការ។

ខណៈនោះ **លីប៉ោ**ប្រមូលសេនាទាហានបានមួយម៉ឺនប្លាយ បំបែកទ័ពចេញជាបួនកង ឲ្យ**កោស៊ុន**លើកទ័ពទៅជួយស្រុកសៀវផាយ ច្បាំងនឹង**តៀវសេង**មួយកង ឲ្យ**តាន់កុង**លើកទ័ពទៅជួយស្រុកគិនតោ ច្បាំងនឹង**តាន់គី**មួយកង ឲ្យ**តៀវសៀវ**លើកទ័ពទៅជួយស្រុកឡុកអៀងច្បាំងនឹង**លុយប៉ុក**មួយកង ឲ្យ**ស៊ុនហៀន, ង៉ុយសុក**លើកទៅជួយស្រុកកៀតសិក ច្បាំងនឹង**តាន់ឡាន់**មួយកង ខ្លួន**លីប៉ោ**ប្រមូលសេនាទាហានដែលមានថ្វីដៃ លើកចេញទៅតាំងបន្ទាយនៅខាងក្រៅកំពែងស្រុក ចម្ងាយ

ប្រហែលបីរយសិន (១២ គ.ម)។ លុះ**តៀវហ៊ុន**លើកទ័ពមកដល់បន្ទាយ**លីប៉ោ** ក៏ប្រើទាហានឲ្យចូលទៅហៅ**លីប៉ោ**ចេញមកច្បាំងគ្នា។

**លីប៉ោ**គិតបារម្ភថា កងទ័ពដែលលើកទៅជួយរាំងស្រុកទាំងបួនតំបន់នោះ ក្រែងទៅមិនទាន់ដល់ ខ្លាចទាហាន**តៀវហ៊ុន**លើកមកប្រទល់ជួយគ្នាទាន់ ហើយក៏នៅមិនទាន់ឃើញសំខាន់ត្រង់**ហាន់សៀម**និង**អៀវហង**សញ្ញានោះទៀត **លីប៉ោ**ឲ្យរំកិលកងទ័ពទៅតាំងនៅជិតកំពែងស្រុកប្រហែលបីរយសិន (១២ គ.ម)។ **តៀវហ៊ុន**ក៏លើកទ័ពតាមមកតាំងបន្ទាយជាប់ជិតគ្នានឹងបន្ទាយ**លីប៉ោ**។

ឯ**ហាន់សៀម**ទទួលពាក្យ**តាន់តេង**ហើយ ក៏បានទៅប្រឹក្សានឹង**អៀវហង**ហើយបបួលគ្នាទៅរក**តៀវហ៊ុន**ក្នុងបន្ទាយ លុះដល់ពេលយាមបី **ហាន់សៀម** និង**អៀវហង**ក៏ចាត់ទាហានឲ្យយកភ្លើងដុតបន្ទាយឆេះឡើង។ **លីប៉ោ**ឃើញសំខាន់ដូច្នោះ លើកទាហានចូលប្លន់បន្ទាយ**តៀវហ៊ុន**បែកសម្លាប់ទាហានស្លាប់ជាច្រើន។ **តៀវហ៊ុន**ក៏បរពលទម្លុះទម្លាយកងទ័ពរត់ចេញពីបន្ទាយទៅ **លីប៉ោ**ក៏លើកទាហានដេញតាម**តៀវហ៊ុន**ទៅទៀត ទទួលជួបនឹង**គីឡេង** ដែលជាកងទ័ពណ្ហូនខាង**តៀវហ៊ុន**នោះលើកមកទាន់ ក៏បរសេះចូលច្បាំងនឹង**លីប៉ោ**មិនទាន់បានចាញ់ឈ្នះគ្នា ទទួល**ហាន់សៀម** និង**អៀវហង**លើកតាមមកទាន់ ក៏ខ្ទប់វាយទ័ព**គីឡេង**ពីក្រោយ **គីឡេង**ក៏បំផាយសេះរត់ចេញទៅ **លីប៉ោ**ក៏លើកទាហានដេញតាមដល់ជើងភ្នំមួយអន្លើ ដែលកងទ័ព**អ៊ួនសុត**តាំងបន្ទាយនៅនោះ។

**លីប៉ោ**ក្រឡេកមើលទៅក្នុងបន្ទាយ ឃើញដោតទង់ម្កុរនិងទង់ហង្ស ជាគ្រឿងសម្គាល់ទ័ពព្រះមហាក្សត្រ ហើយឃើញ**អ៊ួនសុត**ពាក់អាវផ្ទៃមាស កាន់គ្រប៊ីដៃទាំងពីរ ជិះសេះបញ្ឈរ បាំងសប្ទនមាសនៅក្នុងបន្ទាយ **លីប៉ោ**ក៏បំផាយសេះឡើងទៅ

លើកំពូលភ្នំមុខបន្ទាយ។ **អ៊ួនសុត**កាន់គ្រប៊ីចេញមកហើយស្រែកជេរថា ខ្លួនមឹងជាមនុស្សទាបទេ ហេតុម្ដេចក៏អង់អាចមកក្បត់នឹងម្ចាស់ផែនដី មឹងធ្វើដូច្នេះមិនគួរទេ។ **លីប៉ោ**ទាស់ចិត្តណាស់ ទើបជិះសេះវាំទូនចូលទៅច្បាំងនឹង**អ៊ួនសុត** ៗឲ្យ**ឈោហាង**ចេញតស៊ូនឹង**លីប៉ោ** ៗយកទូនចាក់ត្រូវ**ឈោហាង** ៗក៏បំផាយសេះគេចចូលបន្ទាយ។ **អ៊ួនសុត**មិនបានតស៊ូ នាំពលគេចរត់ចោលបន្ទាយនោះទៅ។

**លីប៉ោ**រើសបានរបស់ទ្រព្យសព្វគ្រឿងសាស្ត្រាវុធក្នុងបន្ទាយជាច្រើន ហើយក៏លើកតាម**អ៊ួនសុត**ទៅ ឯ**អ៊ួនសុត**រត់នឹងសេះទៅឆ្ងាយពីបន្ទាយប្រហែលសាមសិបសិន (១,២ គ.ម) បានជួបនឹងកងទ័ព**គួនអ៊ូ** ដែល**ឡៅពី**ប្រើឲ្យទៅជួយ**លីប៉ោ**។ **គួនអ៊ូ**ស្រែកជេរ**អ៊ួនសុត**ថា អាក្បត់! អាឯងហ៊ានតាំងខ្លួនជាស្ដេចហើយម្ដេចក៏រត់ទៅណា? **អ៊ួនសុត**ខឹងណាស់ក៏ចូលតនឹង**គួនអ៊ូ** ទទួលបានឮសំឡេងទាហាន**លីប៉ោ** ហ៊ោខ្លាន់ៗចូលមកពីក្រោយ **អ៊ួនសុត**ក៏បំផាយសេះរត់រួចទៅសំដៅស្រុកឡាំយ៉ុង។ **លីប៉ោ, គួនអ៊ូ, ហាន់សៀម, អៀវហង** ក៏បបួលគ្នាមកជួយទាហានដែលប្រើឲ្យលើកទៅវាយស្រុកទាំងបួនតំបន់។

ឯ**តៀវសេង, តាន់គី, លុយប៉ុក, តាន់ឡាន់** ដែល**តៀវហ៊ុន**ប្រើឲ្យទៅវាយស្រុកទាំងបួនតំបន់នោះ លុះដឹងថាទ័ពឈ្លួនបែកហើយ ក៏លើកទ័ពត្រឡប់ទៅស្រុកឡាំយ៉ុងវិញ។ **លីប៉ោ, គួនអ៊ូ, ហាន់សៀម, អៀវហង**ក៏នាំគ្នាចូលទៅស្រុកឈីជីវ។ **លីប៉ោ**ឲ្យរៀបតុលៀងភោជនាហារបណ្ដាសេនាទាហានទាំងពួង ហើយចែករង្វាន់មាសប្រាក់គ្រឿងសម្លៀកបំពាក់ដល់ទាហាន**គួនអ៊ូ, ហាន់សៀម, អៀវហង**ជាច្រើន ។ លុះវេលាព្រឹក **គួនអ៊ូ**ក៏លា**លីប៉ោ**ត្រឡប់ទៅស្រុកអ៊ីជីវវិញ។

**លីប៉ោ**ប្រុងនឹងតាំង**ហាន់សៀម**ឲ្យទៅឈរស្រុកគិនតោ ឲ្យ**អៀវហង**ទៅឈរស្រុកឡុងអៀ ក៏ធ្វើជាប្រឹក្សានឹងសេនាទាហានទាំងពួងថា **ហាន់សៀម**និង**អៀវហង**នេះមានសេចក្ដីគាប់ប្រសើរនឹងយើង ត្រូវយើងទំនុកបម្រុងចិញ្ចឹមទុកក្នុងស្រុកឈីជីវនេះឬ ឬក៏ឲ្យទៅឈររក្សាស្រុកឯណាវិញ? **តាន់គុយ**ជម្រាបថា **ហាន់សៀម** និង**អៀវហង**នេះ ពីដើមតាំងបញ្ចុះបញ្ចូលហ្វឹកហាត់ទាហានទៅស្រុកស្វូតាំងខាងទិសឯកើត សុំលោកចាត់ឲ្យ**ហាន់សៀម**ទៅឈរស្រុកគិនតោ ឲ្យ**អៀវហង**ទៅនៅឈរស្រុកឡុកអៀងចុះ បើកាលណាបក្សពួកអ្នកទាំងពីរនឹងមកចុះចូលនៅជាពួកម៉ាកច្រើនឡើង ស្រុកទេសក៏នឹងចម្រើនបរិបូរ។ **លីប៉ោ**បានស្ដាប់ក៏ចាត់**ហាន់សៀម** និង**អៀវហង**ទៅឈររក្សាស្រុកទាំងពីរតំបន់តាមពាក្យ**តាន់គុយ**និយាយនោះ ហើយផ្ដាំនឹង**ហាន់សៀម**, **អៀវហង**ថាឲ្យខំរិះគិតបញ្ចុះបញ្ចូលពួកម៉ាកឲ្យបានច្រើនឡើងទៀតឲ្យមាំមួន ប្រសិនបើយើងនឹងមានកិច្ចធុរៈអ្វីៗ នឹងផ្ញើសំបុត្រទៅដល់អ្នកឲ្យចាត់ការតាមត្រូវការ។ **ហាន់សៀម** និង**អៀវហង**ក៏លា**លីប៉ោ**ចេញទៅឈរស្រុកតាមចំណែករៀងខ្លួន។ ទីប្រឹក្សានិងសេនាទាហានទាំងពួង ក៏លា**លីប៉ោ**ទៅកាន់ទីលំនៅរាល់គ្នា។

**តាន់តេង**នោះ លុះត្រឡប់ទៅដល់ផ្ទះ ក៏ចូលទៅសួរ**តាន់គុយ**ជាបិតាថា ហេតុម្ដេចបិតាបានជាសុំ**លីប៉ោ**ឲ្យ**ហាន់សៀម** និង**អៀវហង**ទាំងពីរនាក់ចេញពីស្រុកឈីជីវទៅនៅស្រុកក្រៅវិញ? **តាន់គុយ**ឆ្លើយថា **ហាន់សៀម** និង**អៀវហង**នេះជាមនុស្សមិននឹងនួនមាំទាំ បើនឹងទុកចិត្តក៏មិនបានជាប្រាកដ បើនឹងឲ្យនៅក្នុងស្រុកឈីជីវយូរទៅ មិនលែង**លីប៉ោ**នឹងទំនុកបម្រុងឲ្យដល់ខ្លាត បើកាលណា**លីប៉ោ**រាប់អានជាទីទុកចិត្តហើយ អ្នកទាំងពីរគង់នឹងប្ដូរចិត្តស្រឡាញ់**លីប៉ោ**ជាប្រាកដ យើងនឹងរិះគិត

ធ្វើការតទៅក៏មិនបានស្រួល។ **តាន់តេង**យល់ត្រូវក៏និយាយថា “គំនិតរបស់បិតាគិតនេះល្អមែន ខ្ញុំបាទគិតមិនដល់ទេ” ហើយក៏លាបិតាទៅកាន់ទីលំនៅ។

ឯ**អ៊្វនសុត**ដែលបរាជ័យ ខូចខាតសេនាទាហាននិងគ្រឿងប្រដាប់របស់ទ្រព្យ ព្រោះ**លីប៉ោ**ជាច្រើននោះ ក៏មានតែសេចក្តីទោមនស្សតូចចិត្តគិតចងគំនុំនឹង**លីប៉ោ**មិនមានភ្លេចមួយវេលា គិតហើយក៏ធ្វើសំបុត្រមួយច្បាប់ទៅដល់**ស៊ុនសេក**នៅស្រុកកាំងតាំង សុំសេនាទាហានឲ្យលើកមកជួយសងសឹកកម្ចាត់**លីប៉ោ**។ **ស៊ុនសេក**បានទទួលសំបុត្រហើយក៏ជេរ**អ៊្វនសុត**ថា “វាឆយកត្រាចម្លក់របស់អញទុកហើយ គិតក្បត់តាំងខ្លួនជាម្ចាស់ផែនដី អញគិតនឹងប្រទូសរ៉ាយវាឲ្យបាន ឥឡូវវាត្រឡប់មកសុំកងទ័ពអញវិញទៀត” ទើបនិយាយនឹងបម្រើថា ដែលចៅហ្វាយឯងឲ្យមកសុំកងទ័ពនោះ អញមិនឲ្យទេ អញនឹងលើកទាហានទៅវាយស្រុកឡាំយ៉ុងសងសឹកឲ្យបាន។ បម្រើកាន់សំបុត្រក៏លា**ស៊ុនសេក**ត្រឡប់ទៅប្រាប់**អ៊្វនសុត**គ្រប់ប្រការ។ **អ្វនសុត**ក៏ជេរ**ស៊ុនសេក**ថា “អាក្មេងទឹកដោះនៅមាត់ វាកោងព្រហើននិយាយមើលងាយគិតចង់ច្បាំងនឹងអញវិញ អញនឹងលើកទ័ពទៅវាយស្រុកកាំងតាំង ចាប់យកខ្លួនអា**ស៊ុនសេក**ឲ្យទាល់តែបាន” ថាហើយក៏បង្គាប់ឲ្យត្រៀមពលយោធា។

**អៀវតៃជៀង**ទីប្រឹក្សាជម្រាប**អ៊្វនសុត**ថា យើងបានលើកទ័ពទៅវាយស្រុកឈីជីវ ហើយទើបតែត្រឡប់មកដល់ ពលទាហានកំពុងតែនឿយហត់ ហេតុម្តេចលោកចង់លើកទៅវាយស្រុកកាំងតាំងទៀត? **ស៊ុនសេក**នោះជាមនុស្សមានថ្វីដៃខ្លាំងពូកែចំណាន សេនាទាហានក៏ច្រើនសុទ្ធតែពូកែទាំងអស់ ក្រែងលោនឹងចាញ់ប្រៀបគេទេដឹង? **អ៊្វនសុត**ស្តាប់យល់ត្រូវ ក៏បង្គាប់ទៅកងទ័ពឲ្យឈប់បង្អង់។

ឯ**ស៊ុនសេក**នោះ លុះបម្រើកាន់សំបុត្រវិលត្រឡប់ទៅហើយ ក៏គិតក្រែង**អ្ហួនសុត**នឹងលើកទ័ពមក ទើបបង្គាប់ឲ្យកេណ្ឌប្រមូលសេនាទាហាន តាំងបន្ទាយរង់ចាំទទួលទ័ព**អ៊្ហួនសុត**នៅមាត់ព្រែកស្រុកកាំងតាំង ទទួល**ចូឆ្វ**ឲ្យសំបុត្រមកដល់**ស៊ុនសេក**ជាសេចក្ដីថា តាំងឲ្យ**ស៊ុនសេក**ជាចៅហ្វាយស្រុកហុយខេ ហើយឲ្យលើកទ័ពទៅវាយ**អ៊្ហួនសុត**នៅក្រុងឡាំយ៉ុងជាប្រញាប់។ **ស៊ុនសេក**បានស្ដាប់ក៏ត្រូវនឹងបំណងរបស់ខ្លួន ទើបប្រឹក្សានឹងសេនាទាហានទាំងពួងថា យើងត្រូវលើកកងទ័ពទៅវាយស្រុកឡាំយ៉ុង។

**តៀវជៀង**ឆ្លើយថា ស្រុកឡាំយ៉ុងនោះស្រូវអង្ករស្បៀងអាហារបរិបូរ មនុស្សម្នាក្នុងទីចំណុះស្រុកសុទ្ធតែអ្នកមានភោគសម្បត្តិច្រើន លោកកុំអាលមើលងាយការ ចូរឲ្យតែងសារទៅដល់**ចូឆ្វ** សុំឲ្យ**ចូឆ្វ**លើកទ័ពមកជួយវាយគយខាងមុខ រួចសឹមយើងលើកទៅខ្ទប់វាយពីក្រោយ ឃើញថា**អ៊្ហួនសុត**និងបរាជ័យផង់យើងជាប្រាកដ។ **ស៊ុនសេក**បានស្ដាប់យល់ឃើញត្រូវ ទើបប្រើទាហានឲ្យកាន់សំបុត្រចូលទៅក្រុងហ៊្សូតោ តាមពាក្យ**តៀវជៀង**និយាយនោះ។

# **រឿង សាមកុក**

## **អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង**

## **កណ្ឌទី ១៦**

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**ចូឆូ** ចាត់ប្រើ**ហែហូទុន**ជាទ័ពស្រួច ចាត់**ឡៅពី**ជាទ័ពស្ដាំ **ចូឆូ**ឯងជាទ័ពហ្លួងលើកទៅវាយស្រុកឡាំយ៉ុង រហូតដល់**លីប៉ោ**លើកទ័ពទៅវាយស្រុកសៀវផាយ **ឡៅពី**ប្រើ**កាន់យ៉ុង**ទៅសុំកងទ័ព**ចូឆូ**មកជួយ”។*

**ឯចូឆូ**តាំងពីខូច**តៀនអ៊ីយ**ទៅពេលណា មិនដែលបានសេចក្ដីសប្បាយរីករាយសោះ ឲ្យតែមានគិតស្ដាយដល់**តៀនអ៊ីយ**ពន់ប្រមាណ ចេះតែសែនគ្រឿងសក្ការៈឲ្យមិនដែលដាច់ ហើយឲ្យយកខ្លួន**តៀនមួន**ជាបុត្រ**តៀនអ៊ីយ**មកតាំងជាតងឡង គឺជំនិតជិតខ្លួន ទទួលមានសំបុត្រ**ស៊ុនសេក**ទៅដល់ **ចូឆូ**ក៏មើលដឹងក្នុងសេចក្ដីសំបុត្រ ហើយមិនទាន់នឹងថាប្រការម្ដេច មានទាហានចូលមកជម្រាបថា ស្រុកឡាំយ៉ុងនោះស្រូវអង្ករស្បៀងអាហារឥឡូវនេះក្រខ្សត់ណាស់ ហើយ**អួនសុត**កំពុងប្រមូលសេនាទាហានទៅវាយដណ្ដើមស្រុកតាន់លីវ។ **ចូឆូ**បានឮដូច្នោះក៏គិតឃើញថា “ស្រុកឡាំយ៉ុងនោះ ទាហានក៏កាន់តែស្ដួចស្ដើង បើយើងនឹងលើកទ័ពទៅវាយក៏នឹងបានដោយងាយ” ទើបធ្វើសំបុត្រទៅដល់**ឡៅពី, ស៊ុនសេក** និង**លីប៉ោ** ឲ្យលើកកងទ័ពទៅផ្ទប់គ្នាវាយយកស្រុកឡាំយ៉ុង ហើយទុក**ចោយិន**ឲ្យនៅរក្សាស្រុកហ៊ូតោ ទើបប្រមូលពលទាហានបានចិតសិបម៉ឺន និងស្រូវអង្ករស្បៀងអាហារមួយពាន់រទេះលើកទៅដល់ដែនស្រុកអ៊ីជៀងជិតស្រុកអ៊ីជីវដែល**ឡៅពី**នៅ។

ឯ**ហាន់សៀម**ដែល**លីប៉ោ**ឲ្យទៅឈរស្រុកគិនតោ និង**អៀវហង**ដែលទៅឈរស្រុកឡុកអៀងប្រព្រឹត្តសេចក្តីអាក្រក់ ធ្វើជាចោរដើរទៅឆក់ដណ្តើមប្លន់យករបស់ទ្រព្យបណ្តារាស្ត្រគ្រប់ភូមិលំនៅ។ មានមនុស្សនាំយកសេចក្តីនោះទៅជម្រាប**ឡៅពី**ៗក៏ពិភាក្សានឹង**គួនអ៊ូ, តៀវហ៊ុយ**ថា “ឲ្យទៅអញ្ជើញ**ហាន់សៀម** និង**អៀវហង**មកស៊ីលៀង បើអ្នកទាំងអស់គ្នាឃើញយើងចោលពែងវេលាណា ត្រូវអ្នកទាំងពីរហូតគ្រប៊ីកាត់ក្បាល**ហាន់សៀម** និង**អៀវហង**ចេញ” ហើយក៏ប្រើបម្រើទៅអញ្ជើញ**ហាន់សៀម, អៀវហង**មកស៊ីលៀង។ លុះស៊ីផឹកឆ្អែត **ឡៅពី**ធ្វើជាស្រវឹងចោលពែងស្រាចេញ។ ឯ**គួនអ៊ូ, តៀវហ៊ុយ**ដែលឈរកាន់គ្រប៊ីក្បែរឆាក ក៏ស្ទុះចូលមកយកគ្រប៊ីកាប់**ហាន់សៀម** និង**អៀវហង**ស្លាប់នៅទីនោះ ទទួលមានទាហានចូលមកជម្រាប**ឡៅពី**ថា **ចូឆ្វូ**នឹងលើកទ័ពទៅវាយស្រុកឡាំយ៉ុង ឥឡូវមកដល់ដែនស្រុកអ៊ីជៀងហើយ។ **ឡៅពី**ដឹងដូច្នោះ ក៏ប្រមូលសេនាទាហានលើកចេញទៅជួបនឹង**ចូឆ្វូ**ឲ្យយួរក្បាល**ហាន់សៀម** និង**អៀវហង**ចូលទៅផង **ចូឆ្វូ**ក្រឡេកឃើញ**ឡៅពី**ក៏ចេញមកទទួលគំនាប់គ្នាតាមយសស័ក្តិតូចធំ។ **ឡៅពី**ឲ្យយកក្បាល**ហាន់សៀម** និង**អៀវហង**បង្ហាញ**ចូឆ្វូ**ហើយនិយាយថា ខ្ញុំធ្វើការគ្រានេះខុសណាស់ សូមមហាឧបរាជអភ័យទោសម្តងចុះ។

**ចូឆ្វូ**ឆ្លើយថា “ដែលអ្នកធ្វើការបានដូច្នេះល្អណាស់ហើយ ព្រោះរាស្ត្រដែលមានសេចក្តីក្តៅក្រហាយទាំងប៉ុន្មាន ក៏បានសេចក្តីសុខសប្បាយ ដោយសារតម្រិះប្រាជ្ញាអ្នក ហេតុម្តេចអ្នកមកថាបានសេចក្តីខុសវិញ?” ដូច្នេះហើយឲ្យរង្វាន់បំណាច់ដល់**ឡៅពី**ជាច្រើន ហើយនាំ**ឡៅពី**លើកទ័ពទៅដល់ជិតស្រុកឈីជីវដែល**លីប៉ោ**នៅនោះ។

**លីប៉ោ**ដឹងថា **ចូឆ្វូ**លើកទ័ពមកក៏ចេញទៅទទួល**ចូឆ្វូ** ៗនិយាយនឹង**លីប៉ោ**ថា “ប្រសិនបើយើងធ្វើការនេះបានសម្រេចហើយ យើងនឹងក្រាបទូលព្រះចៅ**ហៀនតេ**ឱ្យតាំងអ្នកជាធំ” ហើយនិយាយល្បួងលួងលោម**លីប៉ោ**ជាច្រើន។ **លីប៉ោ**មានសេចក្ដីត្រេកអរក្រោកឡើងឱនគំនាប់**ចូឆ្វូ**ដោយគោរព។ **ចូឆ្វូ**ក៏ចាត់**ហែហ្គូទុន** និង**អ៊ីគឹម**ជានាយទ័ពស្រួច ចាត់**ឡៅពី**ជានាយទ័ពស្ដាំ ចាត់**លីប៉ោ**ជានាយទ័ពឆ្វេង ខ្លួន**ចូឆ្វូ**ឯងជាមេទ័ពហ្លួង លើកទៅវាយស្រុកឡាំយ៉ុង។

ពេលនោះ**អ្វូនសុត**ដឹងថា **ចូឆ្វូ**លើកទ័ពមក ក៏ចាត់**គៀវសេង**ឱ្យលើកទាហានប្រាំម៉ឺនចេញទៅរង់ចាំតទល់នៅផ្លូវតំបន់ឈើវឈុន។ **គៀវសេង**ក៏លើកទាហានចេញពីស្រុកទៅ ទទួលកងទ័ព**ហែហ្គូទុន**លើកមកដល់។ **គៀវសេង**ក៏បំផាយសេះចូលច្បាំងនឹង**ហែហ្គូទុន**បានបីភ្លែង។ **ហែហ្គូទុន**យកទួនចាក់**គៀវសេង**ធ្លាក់ពីលើសេះស្លាប់។ ទាហានទាំងពួងក៏នាំគ្នារត់ចូលទៅក្នុងស្រុកវិញ។

ឯ**ស៊ុនសេក**ដែលនៅក្នុងស្រុកកាំងតាំងដឹងថា **ចូឆ្វូ**លើកទ័ពទៅវាយស្រុកឡាំយ៉ុងហើយ ក៏ចាត់ចែងប្រមូលសេនាទាហានជាច្រើន លើកទៅស្រុកឡាំយ៉ុងនៅទិសខាងលិច។ **ចូឆ្វូ**ដឹងថា **ស៊ុនសេក**លើកទ័ពមកហើយ ក៏ចាត់**លីប៉ោ**ទៅតាំងទ័ពនៅទិសខាងកើត ចាត់**ឡៅពី, គួនអ៊ូ, គៀវហ៊ុយ**ទៅបោះទ័ពនៅទិសខាងត្បូង ខ្លួន**ចូឆ្វូ**ឯងនិងសេនាទាហានចិតសិបម៉ឺន ទៅតាំងបន្ទាយនៅទិសខាងជើង ហើយឱ្យសញ្ញាគ្នាថាឱ្យលើកចូលឡោមព័ទ្ធជុំវិញស្រុកឱ្យព្រមគ្នា។

**អ៊្វូនសុត**ឃើញកងទ័ព**ចូឆ្វូ**លើកឡោមព័ទ្ធជុំទាំងបួនទិស ដូច្នោះហើយ ក៏ប្រឹក្សានឹងសេនាទាហានថា វេលានេះសង្គ្រាម**ចូឆ្វូ**ធំពន្លឹក អ្នកទាំងពួងនឹងយល់ឃើញដូចម្ដេច? **អៀវតៃជៀង**ឆ្លើយថា ស្រុកយើងពេលនេះបណ្ដារាស្ត្រកំពុងអត់

ឃ្លានស្បៀងអាហារ បើនឹងគិតគ្នាលើកទ័ពទៅតទល់នឹង**ចូឆ្វូ**មិនបានទេ ព្រោះទាហានខាងយើងមានសេចក្ដីលំបាកច្រើនណាស់ សុំឱ្យលោកប្រុងប្រៀបរៀបចំសេនាទាហានឱ្យនៅត្រួតត្រារក្សាស្រុកឱ្យមាំមួនពីខាងក្នុង ឯខ្លួនលោកត្រូវនាំគ្រប់គ្រួថយទៅតាំងនៅតំបន់ហួយណាំ ដើម្បីនឹងបានអាស្រ័យស្បៀងអាហារ។ **អ្វូនសុត**យល់ឃើញត្រូវ ទើបចាត់ឱ្យ**ឡោហាង១, ងាក់ជីវ១, លៀងកង១, តាន់គី១** និងទាហានដប់ម៉ឺននៅរក្សាស្រុកឡាំយ៉ុង ហើយ**អ្វូនសុត**ក៏នាំទាហាន និងគ្រប់គ្រួទាំងពួងថយទៅនៅឯតំបន់ហួយណាំតាមពាក្យ**អៀវតែជៀង**ជម្រាបនោះ។

**ចូឆ្វូ**មិនបានដឹងថា **អ្វូនសុត**រត់ចេញពីស្រុក ក៏ឱ្យទាហានឡោមព័ទ្ធជុំវិញ។ ឯ**ឡោហាង, ងាក់ជីវ, លៀងកង, តាន់គី** ដែលនៅរក្សាស្រុកនោះ ក៏មិនបានចេញច្បាំងនឹង**ចូឆ្វូ**ៗព័ទ្ធស្រុកទុកយូរប្រហែលមួយខែប្លាយទាល់តែអស់ស្បៀង ទើបប្រើមនុស្សឱ្យទៅខ្ចីស្បៀង**សុនសេក**ខាងទ័ពទូក បានស្រូវដប់ម៉ឺនថាំង **ចូឆ្វូ**ក៏ឱ្យនាំស្រូវទៅប្រគល់ឱ្យ**អងហៅ**ដែលជានាយជង្រុកស្រូវ។

**អងហៅ**ក៏និយាយនឹង**ចូឆ្វូ**ថា ស្រូវនៅក្នុងជង្រុកយើងនោះកាន់តែតិចណាស់ទៅហើយ យូរទៅប្រហែលទាហានទាំងពួងនឹងខ្វះខាត។ **ចូឆ្វូ**ឆ្លើយថា បើដូច្នោះត្រូវតែអ្នកគិតគូរចែកស្រូវឱ្យទាហាននោះ បន្ថយចំនួនឱ្យតិចជាងមុនឱ្យល្មមនឹងបង្ការទុក ត្រាតែការយើងនោះសម្រេច។ **អងហៅ**ជម្រាបថា ដែលលោកធ្វើដូច្នោះ ខ្ញុំបាទឃើញថាទាហានមិនគិតធ្វើការរឿនរង្គសង្គ្រាម។ **ចូឆ្វូ**តបថា យើងនឹងរិះគិតមិនឱ្យទាហានទាំងពួងតូចចិត្តបាន គឺត្រូវធ្វើថាំងឱ្យតូច វាល់ស្រូវចែកទាហាន។ **អងហៅ**ក៏ធ្វើតាមពាក្យ**ចូឆ្វូ**ថា។ ទាហានទាំងពួងទទួលយកស្រូវទៅធ្វើអាហារបរិភោគ មិនបានគ្រប់គ្រាន់ពេញកម្លាំង ក៏តូចចិត្តណាស់ នាំគ្នានិន្ទា**ចូឆ្វូ**ថា ចំណែកខាងទាហាន

ចេះតែប្រើឱ្យធ្វើ ចំណែកខាងអាហារឱ្យស្រូវស៊ីមិនឆ្អែតពេញលេញ បើមិនមានកម្លាំងហើយ កាលណាឡើយនឹងធ្វើសឹកសង្គ្រាមដូចម្តេចបាន។

លុះដល់មជ្ឈិមយាម **ចូឆ្វ**ក៏ប្រើបម្រើដែលទំនុកទុកចិត្ត ឱ្យទៅលបចាំស្តាប់សេចក្តីដែលទាហានទាំងពួងនិយាយតូចចិត្តនោះ ក៏បានឮសំឡេងនិយាយគ្នានិន្ទា**ចូឆ្វ**ផ្សេងៗ **ចូឆ្វ**ក៏តាំងរិះគិតយកចិត្តសេនាទាហាន ឱ្យមានសេចក្តីខំប្រឹងធ្វើការលើកគ្នាចូលប្លន់យកស្រុកនោះ គឺឱ្យហៅខ្លួន**អងហៅ**មកនិយាយថា យើងនឹងសុំរបស់ជាទីស្រឡាញ់នៃអ្នកតែម្យ៉ាងនឹងបានយកចិត្តសេនាទាហាន អ្នកនឹងឱ្យយើងបានទេ? **អងហៅ**ឆ្លើយថា ខ្ញុំបាទគ្មានរបស់អ្វីនឹងឱ្យមហាឧបរាជទេ។ **ចូឆ្វ**ឆ្លើយខ្សឹបថា យើងចង់ខ្ចីក្បាលអ្នក។ **អងហៅ**ក៏តក់ស្លុតរន្ធត់ក្នុងចិត្តឆ្លើយថា ខ្ញុំបាទគ្មានទោសខុសពីអ្វីសោះ ហេតុម្តេចមហាឧបរាជចង់កាត់ក្បាលខ្ញុំបាទដូច្នោះ? **ចូឆ្វ**ឆ្លើយថា "ខ្លួនអ្នកគ្មានទោសខុសពីអ្វីទេ តែថាយើងសុំកាត់ក្បាលជាឧបាយឱ្យសេនាទាហានជឿចូលចិត្តគិតខំធ្វើការ សូម្បីភរិយាបុត្ររបស់អ្នកនឹងស្ម័គ្របក្សពួកដែលនៅខាងក្រោយ យើងនឹងទទួលបីបាច់ថែរក្សាចិញ្ចឹមព្យាបាល មិនឱ្យមានសេចក្តីតោកយ៉ាកទៅមុខឡើយ"។ និយាយហើយ **អងហៅ**មិនទាន់និយាយថាដូចម្តេចផង **ចូឆ្វ**ក៏ប្រើទាហានឱ្យចាប់ខ្លួន**អងហៅ**នាំទៅកាត់ក្បាលក្នុងវេលានោះ ហើយដោតក្បាលផ្កាលស្រែកអាក្រោសថា **អងហៅ**ធ្វើជានាយឃ្លាំងស្រូវ ចំហូវតែបំបាត់មហាឧបរាជលបលួចធ្វើថាំងតូចវាល់ស្រូវចែក ឱ្យទាហានបានស៊ីមិនគ្រប់គ្រាន់។

ខណៈនោះបណ្តាទាហានទាំងពួងក៏បានដឹងឃើញគ្រប់គ្នា ក៏អស់សេចក្តីសង្ស័យ។ **ចូឆ្វ**ក៏ឱ្យប្រកាសឃោសនាឱ្យបណ្តាទាហានទាំងពួងចូលមកបើកស្រូវឱ្យសម្រេចក្នុងរវាងបីថ្ងៃ ហើយ**ចូឆ្វ**ក៏ឱ្យកំជាប់ពាក្យនឹងទាហានទាំងពួងថា "យើងនឹង

លើកទ័ពចូលវាយទម្លាយយកស្រុកក្នុងវេលានេះ បើនរណាមិនមានចិត្តត្រង់នឹងប្រឹងធ្វើការទេ ឲ្យចេញមុខមកយើងនឹងកាត់ក្បាលចេញ” ហើយក៏ដេញទាហានឲ្យជីកដីទម្លុះកំពែងស្រុកនោះ ។ ទាហានក្នុងកំពែងក៏ឡើងលើសើន បាញ់ធ្នូចម្រុះចេញមក ហើយទម្លាក់ដុំថ្មចុះមកទៀត បីដូចគ្រាប់ភ្លៀង ។ ទាហាន**ចូឆ្វូ**ពីរនាក់ដែលចូលទៅជីកគូទម្លុះកំពែងនោះ ក៏ថយមកវិញព្រោះខ្លាចព្រួញនិងដុំថ្ម។ **ចូឆ្វូ**ឃើញក៏យកគ្រប៊ីកាត់ក្បាលទាហានទាំងពីរនាក់នោះស្លាប់ ហើយបោះទម្លាក់ក្នុងគូនោះ។ ទាហានទាំងឡាយឃើញដូច្នោះ ក៏មិនអាចនឹងរាថយមកវិញ។ **ចូឆ្វូ**ក៏បង្ខំទាហានជីកកកាយទម្លាយកំពែង ធ្លាយចូលទៅក្នុងស្រុកបាន។ ទាហាន**ចូឆ្វូ**ក៏ចាក់កាប់សម្លាប់កងទ័ពក្នុងស្រុក វិនាសស្លាប់ជាច្រើន ហើយព្រួតគ្នាចាប់បានខ្លួន**ឡោហាង, តាន់គី, ងាក់ជីវ, លៀងកង**ទាំងបួននាក់។ **ចូឆ្វូ**សួររក**អួនសុត**ថា វារត់ទៅតាំងទ័ពនៅទីណា? ឈ្មោះបួននាក់ឆ្លើយថា **អួនសុត**រត់ទៅនៅស្រុកហួយណាំ។ **ចូឆ្វូ**ក៏ឲ្យយកខ្លួនទាំងបួននោះទៅសម្លាប់ផ្ចាលកណ្តាលផ្សារ ឲ្យបណ្តាអ្នកស្រុកក្រឡេកឃើញទាំងអស់គ្នា។ ឯរបស់ទ្រព្យដែលមាននៅក្នុងស្រុកនោះ **ចូឆ្វូ**ក៏ឲ្យជញ្ជូនយកមកចំណាយចែកចាយឲ្យសេនាទាហានតាមសមគួរ ហើយឲ្យដុតផ្ទះសម្បែងក្នុងស្រុកនោះអស់គ្មានសល់។

**ចូឆ្វូ**ក៏ប្រឹក្សានឹងទាហានទាំងពួងថា យើងនឹងលើកទ័ពទៅតាម**អួនសុត** តើអ្នកទាំងពួងនឹងយល់ឃើញដូចម្តេច? **ស៊ុនហុក**ឆ្លើយថា វេលានេះស្បៀងអាហាររបស់យើងក៏រៀវស្ហួចណាស់ហើយ បើនឹងលើកទ័ពទៅតាម**អួនសុត**នោះ ខ្ញុំបាទយល់ឃើញថា ទាហានទាំងពួងនឹងបានសេចក្តីនឿយព្រួយលំបាក សុំឲ្យលោកលើកត្រឡប់ទៅក្រុងហ៊ូតោវិញស្រួលជាង ព្រោះនឹងបានបម្រុងសេនាទាហានឲ្យមានបរិបូរសិន បើដល់រដូវស្រូវទុំក្នុងស្រែវេលាណា សឹមត្រឡប់មកធ្វើការគង់នឹងបាន

ដោយស្រួល។ **ចូឆ្ងូ**បានឮដូច្នោះ ក៏មិនទាន់គិតជាយ៉ាងណា ទទួល**ចោហាង**ជូនសំបុត្រមកដល់ **ចូឆ្ងូ**ថា **តៀវស៊ីវ**ជាក្មួយ**តៀវ**ចេគប់គិតគ្នានឹង**ឡៀវពៀវ**ដែលនៅស្រុកកេងជីវ លើកទ័ពទៅវាយស្រុកសៀងយ៉ុង និងស្រុកកាំងឡេង បានតតាំងច្បាំងគ្នានឹង**ចោហាង**ជាច្រើនក្តាហើយ **ចោហាង**ធន់ថ្វីដៃ**តៀវស៊ីវ**មិនបាន សុំឲ្យមហាឧបរាជលើកទ័ពទៅជួយ។ **ចូឆ្ងូ**ឃើញសេចក្តីសំបុត្រដូច្នោះ ក៏និយាយនឹង**ស៊ុនសេក**ថា អ្នកចូរលើកទ័ពទូកទៅវាំងស្ទាក់ពីក្រោយផ្លូវស្រុកកេងជីវទុកឲ្យមាំ ដើម្បីនឹងឲ្យ**ឡៀវពៀវ**អន្ទះសារារែកកុំឲ្យធ្វើការតទៅបាន កាលណាយើងប្រុងប្រៀបរៀបចំការខាងឯនេះស្រេច នឹងលើកទ័ពទៅស្រុកសៀងយ៉ុង និងស្រុកកាំងឡេងវាយទម្លាយគយពីមុខ។

**ស៊ុនសេក**ទទួលពាក្យ**ចូឆ្ងូ**ហើយក៏លើកទ័ពចេញទៅ លុះ**ស៊ុនសេក**ទៅដល់ហើយ **ចូឆ្ងូ**ក៏ហៅ**លីប៉ោ** និង**ឡៀពី**មកនិយាយថា អ្នកទាំងពីរកុំបីមានចិត្តគិតអាឃាដព្យាបាទគ្នាតទៅមុខឡើយ ត្រូវតែជួយគ្នាគិតទំនុកបម្រុងផែនដី ដើម្បីឲ្យព្រះចៅ**ហៀនតេ**ទ្រង់បានសេចក្តីសុខ យើងនឹងសុំឲ្យ**ឡៀពី**ត្រឡប់ទៅនៅស្រុកសៀវផាយវិញ។ **លីប៉ោ**ទទួលពាក្យ**ចូឆ្ងូ** ហើយក៏លាលើកទ័ពត្រឡប់ទៅស្រុកឈីជីវ។ **ចូឆ្ងូ**ក៏និយាយនឹង**ឡៀពី**ថា អ្នកដឹងកលយើងឬទេ? យើងឲ្យអ្នកទៅនៅស្រុកសៀវផាយវេលានេះ យើងនឹងបញ្ឆោតឲ្យខ្លាធ្លាក់អណ្តូង បើអ្នកទៅហើយចូរត្រិះរិះគិតគូរគ្នានឹង**តាន់គុយ, តាន់តេង** ខំធ្វើការឲ្យសម្រេចបានជាឆាប់ ។ **ឡៀពី**ក៏លា**ចូឆ្ងូ**ទៅតាំងនៅស្រុកសៀវផាយ។ **ចូឆ្ងូ**ក៏លើកទ័ពត្រឡប់ទៅស្រុកហ៊ូតោ ហើយប្រមូលពលយោធាលើកទៅច្បាំងនឹង**តៀវស៊ីវ**។ ទទួលទាហានចូលទៅជម្រាប**ចូឆ្ងូ**ថា **ទូនអ៊ុយ**និង**ង៉ស៊ិប**សម្លាប់**លីឈុយ, គុយគី**ហើយ ឥឡូវយកក្បាលទាំងពីរនោះ និងស្ម័គ្របក្សពួកមកជូនលោក។ **ចូឆ្ងូ**មានសេចក្តីត្រេកអរណាស់ ចេញមកទទួល**ទូនអ៊ុយ** និង

**ង៉សុិប** ហើយឲ្យទាហាននាំយកស្ម័គ្របក្សពួក**លីឈុយ**, **គុយគី**ទៅកាត់យកក្បាលដោតផ្ទាលក្រៅទ្វារស្រុក ហើយនាំយកសេចក្ដីនោះទៅក្រាបបង្គំទូលព្រះចៅ**ហៀនតេ** ៗទ្រង់ជ្រាបគ្រប់ប្រការ ទ្រង់មានព្រះរាជហឫទ័យសោមនស្សត្រេកអរថា “ផែនដីយើងវេលានេះនឹងបានសេចក្ដីសុខ អស់ចម្រូងចម្រាសហើយ” ទើបមានព្រះរាជតម្រាស់ឲ្យហៅខ្លួន**ទូនអ៊ុយ** និង**ង៉សុិប**ចូលទៅក្រាបបង្គំគាល់ក្នុងទីព្រះរាជរោងរម្យ ហើយទ្រង់ប្រោសព្រះរាជទានលៀងអាហារ ឲ្យ**ទូនអ៊ុយ**និង**ង៉សុិប**បរិភោគជាមួយនឹងនាហ្មឺនខ្ញុំរាជការទាំងពួង រួចទ្រង់ព្រះរាជទានតាំង**ទូនអ៊ុយ**ជា ថងខៅចៀងគុន តាំង**ង៉សុិប**ជា ទៀនលោចៀងគុន គឺនាយទាហានកម្ចាត់ចោរ ហើយមានព្រះរាជតម្រាស់ឲ្យ**ទូនអ៊ុយ** និង**ង៉សុិប**នាំស្ម័គ្របក្សពួកទៅឈរស្រុកតៀវអាន់។ **ទូនអ៊ុយ** និង**ង៉សុិប**ក៏ក្រាបថ្វាយបង្គំលាទៅឈរខេត្តតាមព្រះតម្រាស់។ **ចូឆ្វ**ក៏ក្រាបបង្គំទូលព្រះចៅ**ហៀនតេ**ថា **តៀវស៊ីវ**គប់គិតគ្នានឹង**ឡៅពៀវ**លើកទ័ពទៅវាយស្រុកសៀងយ៉ុង និងស្រុកកាំងឡេង ទូលព្រះបង្គំជាខ្ញុំសូមព្រះរាជទានថ្វាយបង្គំលា លើកទ័ពទៅកម្ចាត់**តៀវស៊ីវ**ក្នុងសម័យនេះ ឯការរាជការគ្រប់ជំពូកក្នុងក្រុង ទូលព្រះបង្គំជាខ្ញុំចាត់ឲ្យ**ស៊ុនហុក**នៅត្រួតត្រារក្សា ហើយក៏ថយទៅរៀបចាត់ចែងសេនាទាហានលើកចេញពីទីក្រុងទៅ។ ព្រះចៅ**ហៀនតេ**ស្ដេចជូនដំណើរ**ចូឆ្វ**ដល់ក្លោងទ្វារ។ ព្រះចៅ**ហៀនតេ**សោយរាជសម្បត្តិគង់ក្រុងហ៊ូតោបានបីព្រះវស្សា។

កាល**ចូឆ្វ**លើកទ័ពទៅនោះ ជារដូវស្រូវភោជសាលីកំពុងទំស្រុះ បណ្ដាមនុស្សម្នាមហាជនដែលនៅក្បែរខាងផ្លូវ ដឹងឃើញថាកងទ័ព**ចូឆ្វ**លើកទៅដល់ទីណា ក៏នាំគ្នាភ័យខ្លាចរត់ចោលស្រែចម្ការអស់។ **ចូឆ្វ**ឃើញដូច្នោះ ក៏ហាមប្រាមនាយទ័ពនាយកងទាំងពួងថា “បើនរណាទៅបៀតបៀនបណ្ដារាស្ត្រអ្នកស្រុក ឬដើរ

ជាន់ស្រូវភោជសាលីសូម្បីតែមួយគុម្ពក្តី  យើងនឹងកាត់ក្បាលនាយទ័ពនាយកងនោះទុកជាបម្រាម”  រួចក៏ឲ្យប្រកាសឃោសនាប្រាបប្រាមបណ្តារាស្ត្រអ្នកស្រុក  ដែលភ័យរត់ទៅនោះ  ឲ្យវិលមកនៅក្នុងភូមិឋានដូចដើមវិញ។  រាស្ត្រអ្នកស្រុក  វិលមកវិញ   ឃើញរបស់ទ្រព្យមិនមានខូចបាត់អន្តរាយ   ហើយថា**ចូឆ្វ**ហាមប្រាមពលទាហានដូច្នោះ  ក៏មានសេចក្តីត្រេកអរសរសើរគ្រប់គ្នាថា  មហាឧបរាជមានសេចក្តីប្រណីអាណិតរាស្ត្រណាស់ នឹងរកអ្នកឯណាស្មើគ្មាន។

ឯនាយកងនាយទ័ពទាំងពួង  កាលលើកទ័ពទៅដល់ពាក់កណ្តាលផ្លូវ  បើត្រូវលើផ្លូវស្រែនៅទីណាក៏លោតចុះពីលើសេះ   ដៃដឹកសេះវែកគុម្ពស្រូវភោជសាលីដើរទៅព្រោះខ្លាចអាជ្ញា**ចូឆ្វ**   សូម្បីតែខ្លួន**ចូឆ្វ**នោះសោត   ក៏ជិះសេះប្រើទាហានវែកគុម្ពស្រូវពីខាងមុខដរាប   លុះសេះនោះដើរទៅ   មានសត្វមួយនៅក្នុងស្រែវាផ្អើលហើរឡើង   សេះនោះក៏ភ្ញាក់ស្ទុះច្រឡោតចូលទៅក្នុងស្រែ   ជាន់ជញ្ជ្រាំងគុម្ពស្រូវភោជសាលីបាក់ល្អិតជាច្រើនគុម្ព   **ចូឆ្វ**ឃើញដូច្នោះក៏ធ្វើឧបាយដើម្បីនឹងឲ្យទាហានទាំងពួងស្រឡាញ់រាប់អាន  និងកោតខ្លាចព្រោះឃើញថាយុត្តិធម៌ត្រឹមត្រូវណាស់  ក៏តាំងឲ្យហៅនាយទ័ពនាយកងទាំងពួងមកប្រាប់ថា   ឥឡូវខ្លួនយើងបានធ្វើខុសនឹងអាជ្ញាហើយ ហើយឲ្យអ្នកទាំងពួងកាត់សេចក្តីធ្វើទោសយើងចុះ។

**ជូផៅ**ទីប្រឹក្សាក៏ជម្រាប**ចូឆ្វ**ថា  មហាឧបរាជធ្វើខុសពីអ្វី?  **ចូឆ្វ**ក៏ពណ៌នារឿងរ៉ាវប្រាប់ពីសេះផ្អើលជាន់គុម្ពស្រូវនោះឲ្យ**ជូផៅ**ស្តាប់   “ពីដើមយើងដាក់អាជ្ញាហាមប្រាមពួកពលទាហានទាំងអស់ថា   បើធ្វើខូចបាក់បែកគុម្ពស្រូវរបស់រាស្ត្រត្រូវមានទោស   ឥឡូវត្រូវលើខ្លួនយើងធ្វើខុសខ្លួនឯង   បើនឹងស្ងៀមបំបាត់សេចក្តីនោះចេញបណ្តាមនុស្សទាំងពួងក៏នឹងតិះដៀលដំនៀលថា    ខ្លួនយើងមិនបានតាំងនៅក្នុងផ្លូវ

សត្យយុត្តិធម៌” ថាហើយហូតគ្របីដែលសៀតពីក្រោយនោះចេញធ្វើទំនងជានឹងអារកខ្លួនឯងសម្លាប់។

**គុយកែ**ភ័យស្លុតស្ទុះរត់ទៅដណ្ដើមគ្របីពីដៃ**ចូឆ្វូ**បាន ហើយឃាត់ថា ដែលមហាឧបរាជធ្វើដូច្នេះក៏គួរណាស់ហើយ តែថាខ្លួនខ្ញុំបាទ និងនាយទ័ពនាយកងនូវទាហានទាំងពួងនៅជាសុខបាន ក៏ព្រោះតែព្រះតេជព្រះគុណមហាឧបរាជឃុំគ្រងរក្សា វេលានេះបើមហាឧបរាជនឹងសម្លាប់ខ្លួនឯងចេញ យើងខ្ញុំទាំងឡាយក៏គ្មានទីពឹងពំនាក់សោះ ព្រះគុណអើយតាំងពីថ្ងៃនេះទៅក៏នៅមានតែទុក្ខព្រួយលំបាកពន់ពេកណាស់។ **ចូឆ្វូ**ស្ដាប់ច្បាស់ក៏ធ្វើជាដកដង្ហើមធំហើយនិយាយថា “អ្នកថាដូច្នេះត្រូវហើយ តែអ្នកនឹងសុំឲ្យដាច់តាមពាក្យនោះមិនបានទេ ត្រូវតែយើងធ្វើឲ្យមានបែបផែនទុក” ថាហើយក៏យកគ្របីកាត់សក់ពីលើក្បាលរបស់ខ្លួនហុចទៅឲ្យទាហានកាន់យកទៅស្រែកអាក្រោសគ្រប់តំបន់តាមផ្លូវថា មហាឧបរាជធ្វើខុសនឹងអាជ្ញាហើយ ក៏មិនបានសោកស្ដាយដល់ជីវិតគិតនឹងសម្លាប់ខ្លួនចេញ តែបណ្ដានាយទ័ពនាយកងនាំគ្នាសុំអង្វរឲ្យលើកទោស បានជាមហាឧបរាជកាត់សក់នេះជំនួសក្បាលឲ្យអ្នកទាំងឡាយមើលឲ្យឃើញជាបែបផែនតទៅចុះ។ បណ្ដាសេនាទាហាន និងអាណាប្រជានុរាស្ត្រទាំងពួង ក៏នាំគ្នាសរសើររាប់អាន និងកោតខ្លាចអំណាច**ចូឆ្វូ**លើសជាងពីដើម។ **ចូឆ្វូ**ក៏បង្ខំពលយោធាលីលាស្រូតរូតទៅច្បាំងនឹង**តៀវស៊ីវ**។

ឯ**តៀវស៊ីវ**នោះ លុះដឹងថា**ចូឆ្វូ**លើកទ័ពមក ក៏ចាត់សំបុត្រទៅដល់**ឡៅពៀវ**ឲ្យលើកទ័ពមកខ្ទប់វាយពីក្រោយ ខ្លួន**តៀវស៊ីវ** និង**លុយឈី**, **តៀវសៀន**ក៏លើកទាហានទៅតាំងនៅក្រៅបន្ទាយចាំទទួលច្បាំងនឹង**ចូឆ្វូ**។ ទទួល**ចូឆ្វូ**លើកទ័ពមកដល់ **តៀវស៊ីវ**ឃើញ**ចូឆ្វូ**ស្រែកជេរថា អាចោរជាងចេះសម្ដីពីរោះឲ្យមនុស្សវង្វេងជឿ

អញមិនដឹងជាអាងងចេះភូតកុហកអាក្រក់លើសសត្វតិរច្ឆាន។ **ចូឆ្វ**បានឮដូច្នោះក៏ខឹងណាស់ ដេញ**ខៅធូ**ឲ្យបំផាយសេះចេញទៅប្រយុទ្ធនឹង**តៀវស៊ីវ** ៗក៏ប្រើ**តៀវសៀន**ឲ្យចេញមកតស៊ូនឹង**ខៅធូ**បានបីភ្លែង។ **ខៅធូ**យកទ្វនចាក់**តៀវសៀន**ធ្លាក់ពីលើសេះស្លាប់។ **តៀវស៊ីវ**ឃើញដូច្នោះ ក៏គិតថានឹងតស៊ូនឹង**ចូឆ្វ**មិនបាន ទើបបរសេះវេះនាំទាហានចូលទៅក្នុងស្រុកសៀងយ៉ុង ហើយឲ្យបិទទ្វារស្រុកទុកជុំវិញមាំមួន ហើយចាត់ទាហានឲ្យឡើងយាមល្បាតលើសើនកំពែង។

**ចូឆ្វ**លើកទាហានឡោមព័ទ្ធជុំវិញពីក្រៅ មើលទៅឃើញជ្រោលជ្រៅពន្លឹក បើនឹងលុយកាត់ទឹកទៅក៏មិនបាន ទើបប្រើទាហានឲ្យជញ្ជូនឈើនិងស្មៅមកចងទុកជាច្រើន ហើយសង់សើនល្បាតតាមជ្រុងទ្វារស្រុកទាំងបួនទិស **ចូឆ្វ**តែងឡើងមើលគ្រប់សើនពេញបីថ្ងៃ ឃើញទាហានដែលល្បាតលើសើនកំពែងទិសខាងកើតស្ងួចស្ងើង ក៏ប្រើទាហានជញ្ជូនឈើនិងស្មៅទៅគរទុកខាងទ្វារបស្ចិម ហើយប្រាប់ទាហានទាំងពួងថា យើងនឹងលើកវាយទម្លាយល្បាតទិសនេះ។

**កាសៀង**ទីប្រឹក្សាឃើញដូច្នោះក៏ជម្រាប**តៀវស៊ីវ**ថា ដែល**ចូឆ្វ**ឲ្យរៀបចាត់ការដូច្នេះ ខ្ញុំបាទយល់ថាធ្វើជាកលឧបាយ ខ្ញុំបាទសូមធ្វើកលទល់ប្រាជ្ញា**ចូឆ្វ**វិញឲ្យចាញ់យើងបាន។ **តៀវស៊ីវ**ក៏សួរទៅ**កាសៀង**ថា អ្នកនឹងគិតធ្វើកលទល់ប្រាជ្ញា**ចូឆ្វ**នោះ តើនឹងគិតធ្វើដូចម្ដេច? **កាសៀង**ជម្រាបថា ខ្ញុំបាទឃើញ**ចូឆ្វ**ឡើងលបមើលលើសើនបីវេលាហើយ **ចូឆ្វ**ឃើញទាហានខាងយើងទិសបូព៌ានោះស្ងើងស្ងួច បានជា**ចូឆ្វ**ឲ្យជញ្ជូនយកឈើនិងស្មៅទៅគរទុកខាងទិសបស្ចិម ដើម្បីនឹងឲ្យយើងប្រុងប្រយ័ត្នខាងទិសបស្ចិម ឯគំនិត**ចូឆ្វ**ប្រែត្រឡប់ទៅទម្លាយខាងទិសបូព៌ាទេ គឺបំណងនឹងធ្វើក្នុងពេលយប់នេះជាប្រាកដ ខ្ញុំបាទនឹងបង្គាប់ឲ្យពួកអ្នកស្រុកស្លៀកពាក់តែង

ខ្លួនបន្លំទៅជាទាហាន ឡើងទៅរក្សាគយខាងទិសបស្ចិមបែបប្រុងប្រយ័ត្នឲ្យមាំមួន តែពួកទាហានទាំងអស់របស់យើង ៗត្រូវប្រមូលមកបង្កប់ចាំខាងទិសបូព៌ាវិញ បើ**ចូឆ្វ**លើកមកធ្វើការវេលាណាយើងឲ្យអុចផាវជាសញ្ញា ឯទាហានដែលបង្កប់ឲ្យចេញមកខ្ទប់ទាំងសងខាង គង់តែ**ចូឆ្វ**នឹងបរាជ័យរបស់យើងជាប្រាកដ។ **តៀវស៊ីវ**យល់ឃើញត្រូវ ក៏បង្គាប់ឲ្យធ្វើតាមពាក្យ**កាសៀង**ថានោះជាស្រេច។

ឯទាហានដែលគយឃ្លាំយាមល្បាត ក៏នាំយកហេតុទៅជម្រាប**ចូឆ្វ**ថា ឥឡូវ**តៀវស៊ីវ**ប្រមូលសេនាទាហានទៅបម្រុងការប្រយ័ត្នទិសខាងបស្ចិមច្រើនណាស់ ឯទិសខាងបូព៌ាក៏មានទាហានបន្តិចបន្តួចស្តួចស្តើងទេ។ **ចូឆ្វ**បានស្តាប់ដូច្នោះ ក៏សោមនស្សត្រេកអរស្មានក្នុងចិត្តថា នឹងសមប្រកបតាមគំនិតគិតទុក ទើបបង្គាប់ទាហានទាំងពួងឲ្យប្រុងប្រៀបរៀបខ្លួនកាន់គ្រឿងសាស្ត្រាវុធទុកឲ្យព្រមគ្នា។ លុះវេលាយាមបីប្លាយ **ចូឆ្វ**ក៏បរពលឲ្យចុះហែលទឹកក្នុងគូឆ្លងទៅខាងទិសបូព៌ាដល់ទ្វារកំពែង ស្តាប់សំឡេងក៏មិនមានមនុស្សនឹងតវ៉ា ទាហានទាំងអស់គ្នាក៏ពារទម្លាយចូលតាមទ្វារទៅក្នុងស្រុកបាន។

ឯទាហាន**តៀវស៊ីវ**ដែលពួនបង្កប់នៅទីនោះ ក៏អុចផាវបោះឡើងជាសញ្ញា ហើយនាំគ្នាចេញមកស្រទាំងសងខាង ព្រួតគ្នាវាយខ្ទប់ចាក់កាប់សម្លាប់កងទ័ព**ចូឆ្វ**ស្លាប់ដាសជាច្រើនណាស់ នៅរស់រួចប៉ុន្មានក៏ទន្ទ្រានស្ទុះរត់រួចថយចេញទៅក្រោយ។ **តៀវស៊ីវ**ក៏បរពលដេញបណ្តោយទៅ។ ឯ**ចូឆ្វ**និងបណ្តាទាហានដែលនៅរក្សាបន្ទាយក៏ភ្លយបែកខ្ញែកទៅជាមួយគ្នា។ **តៀវស៊ីវ**ក៏ដេញបំពារទៅទៀតបានចម្ងាយប្រហែលបីរយសិន (១២ គ.ម) ជួនភ្លឺស្រាង **តៀវស៊ីវ**ក៏នាំទាហានវិលចូលមកស្រុកវិញ។

**ចូឆ្វូ**ឃើញ**អ៊ីគីម** និង**លីយ៉យ**ត្រូវព្រួញជាច្រើនអន្លើ ក៏ឲ្យត្រួតរាប់ទាហានមើលឃើញបាត់ប្រហែលប្រាំម៉ឺននាក់។ **កាសៀង**ដឹងថា **ចូឆ្វូ**ខូចខាតទាហានជាច្រើនក៏និយាយនឹង**តៀវស៊ីវ**ថា សុំឲ្យលោកមានសំបុត្រទៅដល់**ឡៅពៀវ**នៅស្រុកកេងជីវ ឲ្យ**ឡៅពៀវ**ទៅចាំស្ទាក់វាយ**ចូឆ្វូ** ហើយថានឹងចាប់ខ្លួន**ចូឆ្វូ**បាន។ **តៀវស៊ីវ**ឃើញត្រូវ ទើបតែងសំបុត្រផ្ញើទៅឲ្យ**ឡៅពៀវ**។

**ឡៅពៀវ**បានទទួលសំបុត្រដឹងសេចក្តីហើយ ក៏ប្រមូលសេនាទាហាននឹងលើកទៅចាំស្កាត់**ចូឆ្វូ** ទទួលដឹងដំណឹងថា **ស៊ុនសេក**លើកទ័ពទូកមកតាំងនៅបាក់អាវស្រុកកេងជីវ។ **ឡៅពៀវ**ទើបប្រឹក្សានឹង**កេងលៀង**ថា **តៀវស៊ីវ**មានសំបុត្រមកដល់យើង ឲ្យលើកទ័ពទៅស្ទាក់វាយទ័ព**ចូឆ្វូ** ឥឡូវ**ស៊ុនសេក**ក៏លើកទ័ពមកគិតនឹងវាយស្រុកយើង ៗនឹងគិតប្រការដូចម្តេចទៅវិញ។ **កេងលៀង**ឆ្លើយថា ដែល**ស៊ុនសេក**លើកមកគ្រានេះជាគំនិតរបស់**ចូឆ្វូ** ឥឡូវ**ចូឆ្វូ**បរាជ័យនឹងថ្វីដៃ**តៀវស៊ីវ**ហើយ មុខជា**ស៊ុនសេក**ធ្វើការមិនសម្រេច យើងនឹងលើកទ័ពទៅវាយបន្ថែមឲ្យ**ចូឆ្វូ**បែកទ័ពចាញ់យើងឲ្យបាន ទើបមិនកើតមានសេចក្តីអន្តរាយដល់យើងខាងក្រោយ។ **ឡៅពៀវ**យល់ឃើញត្រូវ ក៏ចាត់ប្រើ**ហងច** លើកទាហានទៅស្ទាក់បង្ខំទ័ព**ស៊ុនសេក**កុំឲ្យឆ្លងចូលមកបាន។ **ឡៅពៀវ**ក៏លើកទ័ពទៅស្ទាក់ទ័ព**ចូឆ្វូ**នៅដែនស្រុកអាន់ចុងគួន។

**តៀវស៊ីវ**កាលផ្ញើសំបុត្រទៅ**ឡៅពៀវ**ហើយ ក៏ចាត់ទាហានលើកទ័ពតាម**ចូឆ្វូ**ទៅ។ កាលដែល**ចូឆ្វូ**បែកទ័ពទៅនោះ មិនបានឲ្យទាហានស្រួតរួតប្រញាប់ លើកទ័ពលំហែទៅតាមផ្លូវជាប្រក្រតី លុះទៅដល់ទន្លេយ៉ុកស៊ុយ **ចូឆ្វូ**ក្តែងធ្វើជាយំសោក។ ទាហានទាំងពួងឃើញដូច្នោះក៏ជម្រាបសួរ**ចូឆ្វូ**ថា លោកយំសោកជាទុក្ខព្រោះហេតុ

អ្វី? **ចូឆ្ងូ**ឆ្លើយថា យើងមកដល់ទីនេះ ឲ្យចេះតែមានចិត្តគិតនឹករឭកដល់**តៀនអ៊ុយ**ដែលស្លាប់ ព្រោះធ្លាប់មកជាមួយគ្នាជាមិត្តភក្តិកម្សត់កម្រ ហើយក៏ឲ្យតែងតាំងគ្រឿងសក្ការៈអុចធូបទៀនច្រូចស្រាសែនឲ្យ**តៀនអ៊ុយ**។ ទាហានទាំងពួងក៏យំសោកទាំងអស់គ្នា ហើយ**ចូឆ្ងូ**ក៏សែនឲ្យ**ចូង៉ាង**ជាកូន និង**ចោអាន់ប៊ិន**ជាក្មួយ ហើយនិងបណ្ដាកូនទាហានដែលស្លាប់ទាំងប៉ុន្មាន ហើយលើកទាហានឆ្លងទន្លេយ៉ុកស៊ុយទៅ។ ទទួលមានបម្រើសេះនាំសំបុត្រ**ស៊ុនហុក**មកជូន**ចូឆ្ងូ**ៗមើលសេចក្ដីដឹងថា **តៀវស៊ីវ**ឲ្យ**ឡៅពៀវ**លើកកងទ័ពមកស្ទាក់នៅដែនស្រុកអាន់ចុងគួន ឲ្យលោកគិតការពារប្រយ័ត្នឲ្យមាំមួន។ **ចូឆ្ងូ**ក៏ធ្វើសំបុត្រតបទៅ**ស៊ុនហុក**ថា "ដែល**ឡៅពៀវ**លើកទ័ពមកស្ទាក់ផ្លូវទុកនោះ ហើយ**តៀវស៊ីវ**លើកទ័ពតាមមកពីក្រោយយើងដឹងអស់ហើយ បានជាយើងលើកទ័ពលំហែតែមួយថ្ងៃមួយរយសិន (៤ គ.ម) ដើម្បីនឹងគិតជាកលឧបាយបញ្ឆោត**តៀវស៊ីវ**និង**ឡៅពៀវ** ឲ្យមានចិត្តកំរើបធ្វើសប្រហែស យើងនឹងវាយយកជ័យជម្នះឲ្យបាន ដែល**ស៊ុនហុក**រំឭកស្មារតីយើងនោះ យើងក៏អរគុណណាស់ហើយ កុំឲ្យ**ស៊ុនហុក**វិតក្កឡើយ"។ ដូច្នេះហើយលើកទ័ពទៅជិតនឹងដល់ស្រុកអាន់ចុងគួន ឮកិត្តិស័ព្ទថា កងទ័ព**តៀវស៊ីវ**លើកជិតទាន់ហើយ។ លុះដល់ពេលព្រលប់**ចូឆ្ងូ**ក៏បង្គាប់ទាហានឲ្យញែកគ្នាជាពីរកង ឲ្យជីករំលុងពួនខ្លះ ពួនក្នុងគុម្ពោតព្រៃឈើខ្លះ ពួនក្នុងគុម្ពស្មៅទាំងសងខាងផ្លូវខ្លះ ចម្ងាយប្រហែលប្រាំបួន ទៅដប់សិន (៤០០ ម) ហើយឲ្យតាំងបន្ទាយអែបនៅខាងភ្នំក្បែរផ្លូវខ្លះ ឲ្យទាហាននៅរក្សាបន្ទាយតិចល្មមតាមគួរ បើឃើញទ័ព**តៀវស៊ីវ**តាមមកដល់ ឲ្យទាហានក្នុងបន្ទាយសំងំឲ្យស្ងៀម ទាល់តែ**តៀវស៊ីវ**លើកចូលវាយបន្ទាយគ្រាណា ឲ្យអុជផាវជាសញ្ញាឡើងឲ្យទាហានទាំងពីរកងលើកចេញមកខ្ទប់ទាំងសងខាង។ ឯ**តៀវស៊ីវ**ក៏បង្ខំលើកទ័ព

ទៅទាំងយប់ មិនទាន់ឃើញបន្ទាយដែល**ចូឆ្វ**តាំងទុក ក៏លើកទាហានបង្ហួសចូលទៅជួបកងទ័ព**ឡៅពៀវ** ហើយសួរថា បានជួបនឹងកងទ័ព**ចូឆ្វ**ឬទេ? **ឡៅពៀវ**ឆ្លើយថា មិនបានជួបប្រទះទេ។ លុះព្រឹកឡើងទាហានជម្រាប**តៀវស៊ីវ**ថា **ចូឆ្វ**តាំងបន្ទាយនៅក្បែរនឹងជើងភ្នំខាងក្រោយ ឃើញទាហានក្នុងបន្ទាយមានស្ងួចស្ងើងទេ។ **តៀវស៊ីវ**និង**ឡៅពៀវ**អរណាស់ ទើបលើកទ័ពប្រសព្វគ្នាទាំងសងខាងរួមជាកងមួយ ហើយក៏លើកចោមវាយទម្លាយ បន្ទាយ**ចូឆ្វ**ទាំងថ្ងៃ។

**ចូឆ្វ**ក៏អុជផាវជាសញ្ញាឡើង ទាហានដែលបង្កប់ទាំងសងខាងផ្លូវក៏លើកចេញស្រមកវាយខ្ទប់ប្រសព្វគ្នា កាប់សម្លាប់ទ័ព**តៀវស៊ីវ** និង**ឡៅពៀវ**ស្លាប់ជាច្រើន។ **តៀវស៊ីវ** និង**ឡៅពៀវ** ក៏បែករត់ទៅ **ចូឆ្វ**ក៏លើកទាហានស្រូតទៅទាល់តែផុតដែនស្រុកអាន់ចុងគួន ទើបតាំងបន្ទាយនៅទីនោះ។ **ឡៅពៀវ**និយាយនឹង**តៀវស៊ីវ**ថា ពេលនេះយើងចាញ់កល**ចូឆ្វ**ដោយដឹងកលមិនដល់។ **តៀវស៊ីវ**ឆ្លើយថា ឥឡូវទាហានយើងក៏កំពុងនឿយហត់ណាស់ ត្រូវតែសម្រាកឈប់ឲ្យទាហានមានកម្លាំងកាលណា នឹងគិតការសងសឹក**ចូឆ្វ**ឲ្យបានវិញ។ **ឡៅពៀវ**យល់ឃើញត្រូវ ក៏ឲ្យតាំងបន្ទាយនៅក្នុងទីនោះ។

ឯ**ស៊ុនហុក**ដែលនៅរក្សាស្រុកដល់ដឹងក្នុងសំបុត្រ**ចូឆ្វ**ហើយ ទទួលឮកិត្តិស័ព្ទថា **អ៊ួនសៀវ**លើកទ័ពទៅវាយស្រុកហ៊ូតោ ក៏ធ្វើសំបុត្រប្ដឹងចូល**ចូឆ្វ**តាមដំណើរហេតុនោះ។ **ចូឆ្វ**ឮដូច្នោះក៏ទោមនស្សតូចចិត្តពេក ទើបប្រមូលសេនាទាហានស្រូតលើកទ័ពត្រឡប់ចូលទៅក្រុងហ៊ូតោ។ ឯ**តៀវស៊ីវ**ឮថា **ចូឆ្វ**លើកកងទ័ពត្រឡប់ទៅស្រុកហ៊ូតោហើយ ក៏រៀបប្រមូលសេនាទាហានលើកទៅតាម**ចូឆ្វ**។ **កាសៀង**និយាយហាមឃាត់ថា ដែលលោកនឹងលើកទៅតាមលើកនេះ ខ្ញុំយល់ឃើញថា គង់

ចាញ់គេជាអាសាឥតការ។ **ឡៅពៀវ**ឆ្លើយថា ពេលនេះបានការល្អហើយ នឹងមិនលើកតាមទៅ ចុះនឹងនៅធ្វើអ្វីឲ្យព្រួយការ។

**តៀវស៊ីវ**យល់ឃើញត្រូវ ក៏លើកទាហានប្រមាណមួយម៉ឺនប្លាយ នាំ**ឡៅពៀវ**ទៅតាម**ចូឆូ**ចម្ងាយផ្លូវប្រហែលមួយរយសិន (៤.គ.ម) ទាន់កងទ័ព**ចូឆូ** ៗក៏ឲ្យទាហានកងក្រោយចេញតច្បាំងនឹងកងទ័ព**តៀវស៊ីវ** សម្លាប់ទាហាន**តៀវស៊ីវ**ស្លាប់ជាច្រើន។ **តៀវស៊ីវ**និង**ឡៅពៀវ**ក៏បែកទ័ពទៅ។ **តៀវស៊ីវ**និយាយនឹង**កាសៀង**ថា ដែលយើងតាម**ចូឆូ**ទៅ ត្រឡប់បែកទ័ពមកគ្រានេះ ព្រោះមិនជឿស្តាប់ពាក្យអ្នក។

**កាសៀង**និយាយថា ឥឡូវនេះសូមឲ្យលោកលើកទ័ពតាម**ចូឆូ**ទៅចុះ មុខជានឹងបានជ័យជម្នះជាប្រាកដ បើមិនបានដូចពាក្យខ្ញុំបាទថាទេ សុំឲ្យលោកកាត់ក្បាលខ្ញុំបាទចុះ។ **តៀវស៊ីវ**បានស្តាប់ដូច្នេះក៏នាំ**ឡៅពៀវ**លើកទ័ពទៅ តែ**ឡៅពៀវ**មិនព្រម **តៀវស៊ីវ**ក៏លើកទាហានទៅតាម**ចូឆូ**។ ឯ**ចូឆូ**ដែលបានឈ្នះទ័ព ក៏មានចិត្តធ្វេសប្រហែសមិនបានលើកទាហានជាក្បួនទ័ព។ លុះ**តៀវស៊ីវ**លើកទ័ពទៅទាន់ ក៏ដេញចោមវាយចាក់កាប់សម្លាប់ទាហាន**ចូឆូ**ដល់ជើងភ្នំមួយ ទទួលឮសំឡេងទាហានស្រែកហ៊ោពីលើកំពូលភ្នំហើយលើកចុះមកជាច្រើន។ **តៀវស៊ីវ**យល់ថាមុខជានឹងចាញ់ ក៏នាំទាហានត្រឡប់ចូលបន្ទាយ។ **ឡៅពៀវ**និង**កាសៀង**នាំគ្នាចេញមកទទួល**តៀវស៊ីវ**ចូលទៅក្នុងបន្ទាយ។

**ឡៅពៀវ**សួរទៅ**កាសៀង**ថា កាលយើងលើកទ័ពទៅច្បាំងគ្រាមុននោះ ទាហានទាំងអស់កំពុងស្រុះស្រួលមានកម្លាំង ក៏ត្រឡប់បរាជ័យដូចពាក្យអ្នកថាជាប្រាកដ គ្រានេះទាហានកំពុងនឿយហត់ អ្នកសម្គាល់ថាមុខជានឹងឈ្នះ បានជាឲ្យលើកទ័ពតាមទៅ ឥឡូវមានជ័យជម្នះដូចពាក្យអ្នកថាទៀត ហេតុម្តេចបានជាអ្នក

ដឹងការនេះច្បាស់ម្ល៉េះ? **កាសៀង**ឆ្លើយថា លោកធ្លាប់ធ្វើសឹកសង្គ្រាមមកក៏មែនហើយ តែមិនប្រសប់គិតដល់គំនិត**ចូឆូ**ទេ។ កាលពីដំបូង**ចូឆូ**លើកទ័ពទៅសម្គាល់ថាយើងនឹងលើកទ័ពទៅតាម បានជាហាមប្រាមចាត់ទាហានឲ្យនៅការពារខាងក្រោយសុទ្ធតែមានថ្វីដៃជាងទាហានយើង បានជាយើងបរាជ័យ។ គ្រាក្រោយ**ចូឆូ**ធ្វេសប្រហែសមិនបានប្រយ័ត្នការតាមរបៀបក្បួនទ័ព ប្រញាប់នឹងស្រូតទៅឲ្យដល់ក្រុងជានាប់ បានជាយើងវាយបែកបានដោយងាយ។

**ឡៅពៀវ** និង**តៀវស៊ីវ**ក៏សរសើរគំនិតរបស់**កាសៀង**ថា មានតម្រិះប្រាជ្ញានឹងរកអ្នកណាស្មើគ្មាន។ **ឡៅពៀវ**និង**តៀវស៊ីវ**រឹងរឹតតែស្រឡាញ់**កាសៀង**លើកពីដើមហាក់ដូចជាបងប្អូន អ្នកទាំងសងខាងក៏គំនាប់លាគ្នាទៅខេត្តខណ្ឌរៀងខ្លួន។

កាលទ័ព**តៀវស៊ីវ**លើកតាមទៅវាយទ័ព**ចូឆូ**ជាន់ក្រោយនោះ **ចូឆូ**បានឮសំឡេងឆោឡោឡើង ក៏កេណ្ឌទាហានប្រុងនឹងលើកទៅជួយ ទទួលទាហានដែលបែកទៅនោះរត់ទៅប្រាប់**ចូឆូ**ថា កងទ័ព**តៀវស៊ីវ**លើកមកចោមវាយ ក៏ទទួលមានកងទ័ពមួយលើកចុះមកពីលើភ្នំ **តៀវស៊ីវ**ខ្លាចក្រែងទ័ពបង្កប់ក៏នាំទាហានត្រឡប់ទៅវិញ បើកុំបានដូច្នោះប្រហែលយើងខ្ញុំទាំងឡាយនឹងស្លាប់អន្តរាយទាំងអស់គ្នា។

**ចូឆូ**សួរថា កងទ័ពនរណាដែលលើកចុះពីលើកំពូលភ្នំនោះ? ទទួល**លីថង**លើកទ័ពទៅដល់ប្រទល់នឹងមុខ**ចូឆូ។** **លីថង**ក៏លោតចុះពីលើសេះបោះទួនពីដៃចេញហើយដើរចូលទៅគំនាប់**ចូឆូ** ៗសួរថា អ្នកឯងឈ្មោះអ្វី? **លីថង**ឆ្លើយជម្រាបថា ខ្ញុំបាទឈ្មោះ**លីថង** ជាចៅហ្វាយស្រុកយីឡាំ បានឮកិត្តិស័ព្ទថាមហាឧបរាជលើកទ័ពទៅច្បាំងនឹង**តៀវស៊ីវ** ខ្ញុំបាទក៏លើកទ័ពមកជួយ ទទួលប្រទះនឹងកងទ័ព**តៀវស៊ីវ**លើកតាមលោកមក **តៀវស៊ីវ**ឃើញខ្ញុំបាទបានជាថយត្រឡប់ទៅវិញ។ **ចូឆូ**មាន

សេចក្ដីត្រេកអរណាស់ ក៏តាំង**លីថង**ជាគៀងកុងហៅ គឺនាហ្មឺនមានសេចក្ដីគាប់ប្រសើរនឹងផែនដី នៅគង់ជាចៅហ្វាយស្រុកយីឡាំងដែល ហើយឲ្យលើកទាហានទៅត្រួតត្រាយាមល្បាតខាងអាណាខេត្តទិសបស្ចិម ការពារ**ឡៅពៀវ** និង**តៀវស៊ីវ** កុំឲ្យកន្លងមកធ្វើអន្តរាយដល់អាណាប្រជានុរាស្ត្រទាំងឡាយ **លីថង**ក៏មានសេចក្ដីត្រេកអរ គំនាប់លា**ចូឆូ**ត្រឡប់ទៅស្រុកយីឡាំវិញ។

**ចូឆូ**ក៏លើកទាហានបង្អួសទៅដល់ក្រុងហ៊ូតោ ទើបចូលទៅគាល់ព្រះចៅ**ហៀនតេ**ហើយក្រាបទូលថា ឥឡូវនេះ**ស៊ុនសេក**បានធ្វើសេចក្ដីគាប់ប្រសើរណាស់ សូមឲ្យតាំង**ស៊ុនសេក**ជា**ឆោងសេកចៀងគុន** ប្រែជាខ្មែរថា **ខុនណាងជាធំ** សម្រាប់ប្រាបប្រាមសត្រូវក្នុងស្រុកកាំងតាំង។ ព្រះចៅ**ហៀនតេ**ក៏ទ្រង់ប្រោសព្រះរាជទាន។ **ចូឆូ**ទើបតែងសំបុត្រតាំង**ស៊ុនសេក** និងគ្រឿងយសបញ្ជូនទៅឲ្យ**ស៊ុនសេក**ឯស្រុកកាំងតាំង ហើយថាឲ្យ**ស៊ុនសេក**គិតកម្ចាត់**ឡៅពៀវ**ចេញឲ្យបាន។ លុះ**ចូឆូ**ត្រឡប់ពីទីគំនាល់មកវិញ ក្រុមអ្នករាជការទាំងពួងបានចូលទៅគំនាប់**ចូឆូ**ជាច្រើននាក់។ **ស៊ុនហុក**ជម្រាប**ចូឆូ**ថា មហាឧបរាជបរាជ័យដល់សឹកសត្រូវ មកគ្រានេះមិនបានស្រូតរូតប្រញាប់ បណ្ដោយឲ្យទ័ពដើរលំហែតាមធម្មតា បានជាខ្ញុំបាទធ្វើជាសំបុត្រទៅរំឭកស្មារតីលោក ៗតបមកថា នឹងមានជ័យជម្នះសឹកសត្រូវនោះ តើលោកសម្គាល់ដោយហេតុអ្វី ទើបត្រូវនឹងពាក្យលោកម្ល៉េះ? **ចូឆូ**តបថា យើងបរាជ័យនឹង**តៀវស៊ីវ**នោះ បើនឹងគិតយកជ័យជម្នះវិញក៏មិនបាន ព្រោះសត្រូវនៅមានកម្លាំង បើប្រឹងទៅហើយនឹងខូចខាតទាហានជាច្រើន បានជាយើងបញ្ឆោតដើរឲ្យយូរ មកដល់ដែនស្រុកអាន់ចុងគួនជាចន្លោះចង្អៀត ក៏ឲ្យតាំងបន្ទាយនៅទីនោះអែបនឹងជើងភ្នំ ហើយបង្កប់ទាហានទុកទាំងសងខាងផ្លូវ **តៀវស៊ីវ**មិនដឹងជាកលសឹក ក៏លើកចូល

មកវាយដល់បន្ទាយយើង ៗឲ្យទាហានដែលបង្កប់ចេញមកខ្ទប់វាយទាំងសងខាង បានជាកងទ័ព**តៀវស៊ីវ**បែកទៅ។ **ស៊ុនហុក**បានស្តាប់សព្វសេចក្តី ក៏គ្រវីក្បាលសរសើរថា គំនិតរបស់មហាឧបរាជជំនាញស្ទាញស្ទាត់ក្នុងកលសឹកសង្គ្រាម នឹងរកអ្នកឯណាផ្ទឹមស្មើគ្មាន។ ទទួល**គុយកែ**ចូលទៅគំនាប់**ចូឆ្វ** ៗសួរថា ហេតុម្តេចបានជាអ្នកឯងទើបមកក្រោយគេ? **គុយកែ**ជម្រាបថា បានជាខ្ញុំយឺតយូរព្រោះមានទាហាន**អ៊្វនសៀវ**នាំសំបុត្រមកឯផ្ទះ និយាយហើយក៏ហូតសំបុត្រនោះទៅឲ្យ**ចូឆ្វ**មើល ៗហើយក៏និយាយថា "សំបុត្រ**អ៊្វនសៀវ**ថា នឹងលើកទ័ពទៅវាយ**កងស៊ុនចាន**ចៅហ្វាយស្រុកប៉ាក់ប៉េង សុំទាហាននិងស្បៀងអាហារទៅជួយ បើមិនព្រមដូចសេចក្តីដែលសុំទេ នឹងលើកទ័ពមកវាយយកក្រុងហ៊ូតោ" ដូច្នេះយើងនឹងអាចដឹងគំនិត**អ៊្វនសៀវ**ជាច្បាស់ គឺមុននេះ**អ៊្វនសៀវ**ប្រុងនឹងលើកទ័ពមកវាយស្រុកយើង លុះដឹងថាយើងលើកទ័ពត្រឡប់មកហើយ **អ៊្វនសៀវ**ក៏ប្រែជាសុំទាហាននិងស្បៀង ដើម្បីនឹងលើកទ័ពទៅវាយ**កងស៊ុនចាន**វិញ ដែល**អ្វនសៀវ**ពោលមកដូច្នេះ ជាការប្រមាថមើលងាយ យើងចង់លើកទ័ពទៅវាយស្រុកគីជីវចាប់**អ៊្វនសៀវ**សម្លាប់ចេញ តែនៅមានសេចក្តីបារម្ភព្រោះទាហានយើងតិចហើយកំពុងនឿយហត់ តើអ្នកទាំងឡាយនឹងយល់ឃើញដូចម្តេច? **គុយកែ**ឆ្លើយថា កាលព្រះចៅ**ហាន់កោចោ** និងព្រះចៅ**ឈប៉ាអង**ធ្វើសង្គ្រាមនឹងគ្នា ព្រះចៅ**ឈប៉ាអង**ខ្លាំងពូកែហើយមានសេនាទាហានច្រើន ខាងព្រះចៅ**ហាន់កោចោ**មានទាហានតិច តែជំនាញស្ទាត់ស្ទាញខាងកលសឹក គិតយកជ័យជម្នះព្រះចៅ**ឈប៉ាអង**បាន។ សេចក្តីទាំងប៉ុន្មានលោកក៏បានជ្រាបសព្វហើយ ដែល**អ៊្វនសៀវ**មានទាហានច្រើនក៏ពិតមែនហើយ តែថាមិនសូវប៉ិនប្រសប់វិះគិត លោកមិនត្រូវព្រួយនឹងទាហានតិចច្រើននោះឡើយ បើលោកទៅធ្វើការសឹកហើយ ខ្ញុំបាទ

យល់ឃើញថា លោកនឹងមានជ័យជម្នះ**អ៊្ហួនសៀវ**ដប់ប្រការ ឯ**អ៊្ហួនសៀវ**នឹងបរាជ័យដល់លោកដប់ប្រការ។

**ចូផ្ង**សួរថា យើងនឹងឈ្នះ**អ៊្ហួនសៀវ**ដប់ប្រការ **អ៊្ហួនសៀវ**នឹងចាញ់ដប់ប្រការនោះដូចម្ដេចខ្លះ? ចូរអ្នកនាំសេចក្ដីមកអធិប្បាយឲ្យពិស្ដារ យើងនឹងស្ដាប់ផងមើល។

**គុយកែ**ថា លោកនឹងឈ្នះដប់ប្រការនោះគឺ៖

១- លោកមិនបានកាន់ខ្លួន បើនឹងធ្វើការអ្វីៗ ទោះបីអ្នកតូចទទឹងទាស់នឹងលោកថា ខុសត្រូវ លោក៏រង់ចាំស្ដាប់។

២- ចិត្តរបស់លោកជាអ្នកមានអធ្យាស្រ័យស្រឡាញ់រាប់អានមនុស្សទាំងពួង ទោះបីធ្វើកិច្ចការណាៗ ក៏កៀកកាន់យកព្រះតម្រាស់ព្រះចៅ**ហៀនតេ**ជាប្រមាណ មនុស្សសព្វស្ថានក៏មានសេចក្ដីត្រេកអរស្រឡាញ់លោក។

៣- លោកនឹងនិយាយការអ្វីទៀងទាត់ មានឫទ្ធិអំណាច មនុស្សទាំងឡាយកោតខ្លាចជាច្រើន។

៤- លោកមានចិត្តសត្យពិតត្រង់ ទ្រទ្រង់សេនាទាហានឲ្យមានកិត្តិយសដោយយុត្តិធម៌ សូម្បីញាតិសាលោហិតមិត្តសំឡាញ់ធ្វើខុស ក៏មិនពោលប្រកាន់ខាងខុសជាត្រូវ។

៥- លោកនឹងគិតធ្វើការអ្វី ឃើញថាសេចក្ដីនោះប្រពៃល្អ ទាំងចិត្តក៏ផ្លុងផ្ដើមធ្វើឲ្យបានសម្រេច។

៦- លោកនឹងរាប់អានស្រឡាញ់អ្នកណា ក៏រាប់អានស្រឡាញ់ពេញដោយសុចរិត មិនមែនគិតល្បួងបញ្ឆោត។

៧- លោកចិញ្ចឹមមនុស្សដែលនៅជិតនឹងនៅឆ្ងាយ បើល្អហើយក៏ចិញ្ចឹមស្មើគ្នា។

៨- លោកគិតការអ្វីជាទម្ងន់ ត្រូវគិតឲ្យឆ្អែតឆ្អន់មាំមួនទើបធ្វើ។

៩- លោកនឹងចាប់ផ្ដើមធ្វើការអ្វី ក៏ធ្វើតាមទំនៀមទម្លាប់ពីបុរាណ។

១០- លោកជំនាញស្ទាញស្ទាត់ក្នុងកលឧបាយនៃក្បួនពិជ័យសង្គ្រាម ទោះកម្លាំងសត្រូវខ្លាំងជាងលោក ៗក៏គិតយកជ័យជម្នះបាន។

ឯ**អ៊្លួនសៀវ**ដែលនឹងចាញ់លោកដប់ប្រការនោះគឺ៖

១- **អ៊្លួនសៀវ**ជាមនុស្សប្រកាន់ឥស្សរិយយស មិនបានយល់ត្រូវនិងខុសតាមគំនិតអ្នកឯណា។

២- **អ៊្លួនសៀវ**ជាមនុស្សអាក្រក់ ធ្វើការលាមកដោយរោហារ។

៣- **អ៊្លួនសៀវ**នឹងនិយាយការអ្វីមិនមានអំណាចសោះ ព្រោះវាចារពោលមិនទៀងទាត់។

៤- **អ៊្លួនសៀវ**ឃើញតែញាតិសន្ដានបងប្អូនរបស់ខ្លួន មិនបានស្ទួនយកចិត្តអ្នកដទៃ និយាយទៅទាំងខុសទាំងត្រូវ។

៥- **អ៊្លួនសៀវ**គិតការអ្វី រមែងត្រឡប់ផ្លាស់ប្ដូរយកល្អជាអាក្រក់ មិនទុកចិត្តគំនិតខ្លួន។

៦- **អ៊្លួនសៀវ**នឹងចិញ្ចឹមរក្សាអ្នកឯណា មិនបានតាំងចិត្តចិញ្ចឹមជាប្រក្រតី ចំពោះមុខសរសើរថាល្អ កំបាំងមុខនិយាយបង្អាប់បង្អោនថាអាក្រក់។

៧- **អ៊ួនសៀវ**រមែងស្រឡាញ់មនុស្សទំនុកទុកចិត្ត ដែលគិតនឹងជួយផ្គងផ្ដើម បើអ្នកឯណាក្លៀវក្លាខ្លាំងពូកែបែរជាព្រងើយកន្តើយ សូម្បីត្រង់ល្អសុចរិតក៏មានចិត្តគិតស្អប់។

៨- **អ៊ួនសៀវ**ធ្វើសេចក្ដីខុសផ្សេងៗ រមែងស្ដាប់ពាក្យមនុស្សញុះញង់។

៩- **អ៊ួនសៀវ**នឹងធ្វើការអ្វី ក៏យកតែតាមអំពើចិត្តគំនិតរបស់ខ្លួន មិនបានធ្វើការឲ្យខ្ជាប់ខ្ជួនតាមទំនៀមទម្លាប់ច្បាប់ពីបុរាណ។

១០- **អ៊ួនសៀវ**មិនចេះមិនដឹងក្នុងកលឧបាយនៃក្បួនសឹកសង្គ្រាម មើលតែល្អមនឹងចិត្តមិនគិតថា សត្រូវនឹងបញ្ឆោតឲ្យចាញ់ ទោះបីនឹងឈ្នះវិញក៏មិនដឹងមិនយល់។

**ចូឆ្វូ**បានស្ដាប់ដូច្នោះសើចហើយថា អ្នកនិយាយដូច្នេះយើងក៏ដឹងច្បាស់ហើយ តែនៅបារម្ភក្រែងថានឹងធ្វើការសង្គ្រាមគ្រានេះនឹងមិនដូចពាក្យថា។ **ស៊ុនហុក**ជម្រាបចូឆ្វូថា ដែល**គុយកែ**និយាយថាលោកនឹងមានជ័យជម្នះ**អ៊ួនសៀវ**ដប់ប្រការនោះ ខ្ញុំបាទយល់ឃើញថាត្រូវផង ព្រោះ**អ៊ួនសៀវ**មិនជាអ្នកចេះគិតក្រវើន សូម្បីតែបើមានទាហានច្រើនជាងលោកប៉ុន្មាន ក៏មានតែសេចក្ដីចាញ់គំនិតលោកជាប្រាកដ។ **គុយកែ**ឆ្លើយថា ដែលលោកលើកតម្កើង**លីប៉ោ**ឲ្យធ្វើធំនោះ ខ្ញុំបាទគិតឃើញថា**លីប៉ោ**ជាមនុស្សអាក្រក់មិនជាអ្នកស្គាល់គុណអ្នកទាំងពួង សព្វថ្ងៃនេះ**លីប៉ោ**ប្រាថ្នានឹងគិតប្រទូសរ៉ាយដល់លោក ឥឡូវ**អ៊ួនសៀវ**លើកទៅវាយ**កងស៊ុនចាន** បើលោកនឹងលើកទ័ពទៅវាយស្រុក**អ៊ួនសៀវ**នឹងបានដោយងាយ តែក្រែង**លីប៉ោ**នឹងលើកទ័ពត្រឡប់មកវាយក្រុងហ៊ូតោវិញ ហេតុនេះសូមលោកលើកកងទ័ពទៅកម្ចាត់**លីប៉ោ**ដែលជាសត្រូវនៅទិសបូព៌ាឲ្យរាបទាបហើយ ទើបឆ្លងទៅវាយយកស្រុក**អ៊ួនសៀវ**

តែម្តង ទាន់**អ៊្លួនសៀវ**មិនទាន់ដឹង។ **ចូឆ្វ**យល់ឃើញត្រូវ ក៏ឲ្យទៅប្រមូលសេនាទាហានត្រៀមទុក នឹងលើកទៅវាយយកស្រុកឈីជីវ។

**ស៊ុនហុក**ជម្រាប**ចូឆ្វ**ថា ដែលលោកនឹងលើកទ័ពទៅនោះ សុំឲ្យមានសំបុត្រទៅប្រាប់**ឡៅពី**ឲ្យដឹងមុន ឲ្យ**ឡៅពី**គិតជួយកម្ចាត់**លីប៉ោ**ឲ្យបាន បើមានសំបុត្រ**ឡៅពី**ប្តឹងមកដល់លោកជាការមាំមួនប្រាកដហើយ សឹមលោកលើកកងទ័ពចេញទៅ។ **ចូឆ្វ**យល់ឃើញត្រូវក៏ធ្វើសំបុត្រតាមពាក្យ**ស៊ុនហុក**ថា ហើយឲ្យទាហានកាន់ទៅឲ្យ**ឡៅពី**ឯក្រុងសៀវផាយ ហើយតែងព្រះតម្រាស់ព្រះចៅ**ហៀនតេ**តាំងឲ្យ**អ៊្លួនសៀវ**ជាចៅហ្វាយស្រុកគីជីវ និងស្រុកបេងជីវ ស្រុកអីវជីវ ស្រុកសៀងជីវ បីតំបន់នេះឲ្យនៅក្នុងបង្គាប់បញ្ជា**អ៊្លួនសៀវ**ទាំងអស់ ព្រោះ**អ៊្លួនសៀវ**មានគុណបំណាច់ក្នុងរាជការ ហើយធ្វើសំបុត្រមួយច្បាប់ទៀតជាពាក្យ**ចូឆ្វ**ថា "ឲ្យ**អ៊្លួនសៀវ**លើកទ័ពទៅវាយ**កងស៊ុនចាន**ចុះ យើងនឹងលើកទ័ពមកជួយធ្វើការនោះ" លុះធ្វើសំបុត្រហើយ**ចូឆ្វ**ក៏ប្រើបម្រើកាន់ទៅឲ្យ**អ៊្លួនសៀវ**នៅស្រុកគីជីវ។ **អ៊្លួនសៀវ**ទទួលព្រះតម្រាស់និងសំបុត្រ**ចូឆ្វ**មើលដឹងសេចក្តីហើយ ក៏មានចិត្តសោមនស្សត្រេកអរជាទីបំផុត ទើបរៀបចាត់ការប្រមូលសេនាទាហានបានច្រើន ហើយលើកកងទ័ពទៅវាយ**កងស៊ុនចាន**ចៅហ្វាយស្រុកប៉ាក់ប៉េង។

ឯ**លីប៉ោ**ធ្វើចៅហ្វាយស្រុកឈីជីវនោះ ក៏មានសេចក្តីសុខក្សេមក្សាន្តសប្បាយទូលាយចិត្ត គិតតែរៀបតុលៀងអាហារសេនាទាហានជារឿយៗ។ ឯ**តាន់គុយ**និង**តាន់តេង**ក៏ក្លែងចរចាសរសើរ**លីប៉ោ**ថា មានបញ្ញាទាំងចិត្តថ្លើមក៏ជ្រះថ្លារាប់អានទាហានខ្ញុំរាជការនិងបណ្តារាស្ត្រទូទៅជាច្រើន។ **តាន់កុង**បានឮ**តាន់គុយ** និង**តាន់តេង**ក្លែងពោលលើកសរសើរ**លីប៉ោ**រឿយៗ ក៏មានសេចក្តីក្រោធខឹងជាខ្លាំង។

លុះនៅមកក្នុងថ្ងៃមួយនោះ **តាន់កុង**និយាយនឹង**លីប៉ោ**ថា ដែល**តាន់គុយ**និង**តាន់តេង**និយាយសរសើរលោកនោះ តែត្រឹមបបូរមាត់ក្រៅប៉ុណ្ណោះទេ ឯចិត្ត**តាន់គុយ**និង**តាន់តេង**តែងគិតរកឧបាយនឹងប្រទូសរ៉ាយដល់លោកជាដរាប លោកកុំគប្បីជឿស្តាប់ពាក្យវាទាំងអាពុកនឹងកូននោះឡើយ បើលោកចេះតែជឿវាហើយ អំណើះទៅមុខ លោកក៏នឹងមានទុក្ខភ័យអន្តរាយជាប្រាកដ សុំឲ្យលោករិះរវាំងឲ្យម៉ត់ចត់កុំធ្វេសប្រហែស។ **លីប៉ោ**ឮដូច្នោះក៏ស្រែកគំហកឲ្យ**តាន់កុង**ថា ខ្លួនឃើញថាយើងមានចិត្តអាណិតស្រឡាញ់**តាន់គុយ,តាន់តេង** បានជាខ្លួនឯងទាស់ចិត្តមកគិតឫស្យាញុះញង់ឲ្យយើងត្រឡប់ធ្វើទោសមនុស្សទៀងត្រង់កុំឲ្យនៅបាន។

**តាន់កុង**បានឮដូច្នោះ ក៏ក្រោកដើរចេញហើយដកដង្ហើមធំគិតថា “**លីប៉ោ**ជាមនុស្សល្ងង់អាប់ឥតប្រាជ្ញា ខ្លួនអញយល់ការថាដោយត្រង់ទៅជាខឹងថាអញអាក្រក់វិញ អំណើះទៅមុខគង់នឹងបានសេចក្តីអន្តរាយដោយទាំងអញផង តែថាបើអញនឹងលះបង់ចោល**លីប៉ោ** ដើរទៅរកទីពឹងពំនាក់ទៀត ក៏នឹងមានសេចក្តីគរហានិន្ទា” លុះយាត្រាទៅដល់គ្រឹះប៊ាស្ថាន ក៏គិតវិតក្កជាទុក្ខយូរថ្ងៃ។

ក្នុងថ្ងៃមួយនោះ **តាន់កុង**ក៏នាំបក្សពួកប្រហែលប្អូនប្រាំនាក់ជិះសេះ ទៅបរបាញ់សត្វក្នុងព្រៃជិតស្រុកសៀវផាយ ឃើញទាហានម្នាក់បំផាយសេះចេញពីស្រុកសៀវផាយទៅ **តាន់កុង**សង្ស័យក៏នាំបក្សពួកបំផាយសេះតាមស្ទាក់ពីមុខទាន់ ហើយសួរថា នរណាប្រើខ្លួនទៅណាមកណា ត្រូវការអ្វី? ទាហាននោះក៏ភ័យស្លុតចិត្តព្រោះចាំមុខបានថា **តាន់កុង**ជាទាហាន**លីប៉ោ** បម្រើកាន់សំបុត្រនោះក៏ឆ្លើយប្រាប់មិនរួច។ **តាន់កុង**ក៏ព្រួតគ្នាចាប់យកខ្លួនបានទាំងសំបុត្រមួយច្បាប់នាំទៅជូន**លីប៉ោ** ៗក៏ដណ្តឹងសួរថា នរណាឲ្យសំបុត្រនេះមកឯងកាន់យកទៅណា? ទាហាននោះខ្លាចមិនអាច

នឹងលាក់ទុកបានក៏ឆ្លើយតាមត្រង់ថា មហាឧបរាជប្រើខ្ញុំបាទកាន់សំបុត្រទៅឲ្យ**ឡៅពី**ឯស្រុកសៀវផាយ **ឡៅពី**តបសំបុត្រប្ដឹងទៅមហាឧបរាជវិញ សេចក្ដីសំបុត្រនោះនិយាយដូចម្ដេចខ្ញុំបាទមិនដឹងទេ។ **លីប៉ោ**ក៏ហែកស្រោមសំបុត្រនោះចេញមើលឃើញសេចក្ដីថា ខ្ញុំបាទ**ឡៅពី**បានដឹងក្នុងសេចក្ដីសំបុត្រមហាឧបរាជដែលបញ្ជូនទៅឲ្យខ្ញុំបាទ ឲ្យជួយរិះគិតកម្ចាត់**លីប៉ោ**ចេញនោះ ខ្លួនខ្ញុំបាទនឹងធ្វើការនោះមិនទាន់បាន ព្រោះកម្លាំងទាហានតិចជាង**លីប៉ោ** បើមហាឧបរាជលើកទ័ពមកកាលណាសឹមខ្ញុំបាទចេញជួយធ្វើការកម្ចាត់**លីប៉ោ**ចេញឲ្យបាន។

**លីប៉ោ**ដឹងក្នុងសំបុត្រដូច្នោះក៏ថា "**អាចូឆូ**នោះវាគិតនឹងធ្វើអញ ៗមិនបានកោតខ្លាចវាសោះ" ហើយបង្គាប់ឲ្យយកទាហាននោះទៅប្រហារជីវិតបង់។ **លីប៉ោ**ក៏ប្រើ**តាន់កុង**និង**ចុងប៉ា**ទៅបញ្ចុះបញ្ចូល**ស៊ុនគួន១, ង៉ទុន១, អ៊ុនឡេ១, សៀងហ៊ួ១** ដែលជានាយចោរនៅភ្នំថៃសានយកមកជាកម្លាំង ហើយឲ្យលើកទ័ពទៅវាយខាងទិសបូព៌ា រហូតដល់ស្រុកគុនជីវ ឲ្យ**កោស៊ុន** និង**តៀវលៀង**លើកទ័ពទៅវាយស្រុកសៀវផាយ ចាប់ខ្លួន**ឡៅពី**ឲ្យបាន ឲ្យ**ស៊ុនហៀន**និង**ងុយសុក**លើកទ័ពទៅទិសបស្ចិមវាយយកស្រុកយីអេង ទាហានទាំងបីកងនោះក៏លើកទៅតាមបង្គាប់**លីប៉ោ**។ ឯខ្លួន**លីប៉ោ**ក៏លើកទាហានជាក្បួនទ័ពធំទៅត្រៀមបម្រុងស្ដាប់ដំណើរទ័ពទាំងបីកង បើឮថាកងណាទន់ថយនឹងសត្រូវក៏នឹងបានលើកជាទ័ពណូនទៅជួយ។

បម្រើសេះដឹងថា **លីប៉ោ**ប្រើ**សោស៊ុន**និង**តៀវលៀង**លើកទៅវាយស្រុកសៀវផាយ ក៏នាំយកសេចក្ដីនេះទៅជម្រាប**ឡៅពី**ថា **លីប៉ោ**លើកទ័ពមកធ្វើអន្តរាយដល់លោកហើយ។ **ឡៅពី**ឮដូច្នោះក៏ភ័យស្លុតចិត្ត ទើបប្រឹក្សានឹងសេនាទាហានទាំងពួងថា ដែល**លីប៉ោ**ឲ្យលើកទ័ពមកនេះ អ្នកទាំងឡាយនឹងគិតឃើញប្រការម្ដេច

ខ្លះ? **ស៊ុនខៀន**ឆ្លើយថា សុំឱ្យលោកធ្វើសំបុត្រប្ដឹងចូលទៅសុំកងទ័ព**ចូឆ្វ**ឱ្យលើកមកជួយ។ **ឡៅ**ពីយល់ឃើញត្រូវក៏សួរថា នរណានឹងយកអាសានាំសំបុត្រទៅបាន? **តាន់យ៉ុង**ដែលទើបមកចូលធ្វើរាជការថ្មី ឆ្លើយសុំយកអាសានាំសំបុត្រទៅឱ្យ**ចូឆ្វ**។

# រឿង សាមកុក

## អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

## កណ្ឌទី ១៧

**ចារឹកឡើងវិញដោយ ៖ ឈុល ដារ៉ា**

*(តាំងពី**ឡៅពី**ធ្វើសំបុត្រ ចាត់បម្រើឲ្យទៅសុំកងទ័ព**ចូឆ្វូ**ឯក្រុងហ៊ូតោមកជួយច្បាំងនឹង**លីប៉ោ** រហូតដល់**តៀវហ៊ុយ**ចាប់**ឡាន់បេង**សេនា**លីប៉ោ**បាន នាំទៅឲ្យ**ឡៅពី**។)*

**ឡៅពី**ក៏សរសេរសំបុត្រថា "ឥឡូវនេះ**លីប៉ោ**ប្រើទាហានលើកទ័ពទៅច្បាំងយកស្រុកសៀវផាយហើយ ខ្ញុំបាទ**ឡៅពី**សុំកងទ័ពមហាឧបរាជឲ្យលើកទៅជួយ" លុះសរសេរចប់ ក៏ប្រគល់សំបុត្រនោះឲ្យ**តាន់យ៉ុង**នាំសំបុត្រនោះទៅក្រុងហ៊ូតោ ហើយ**ឡៅពី**ឲ្យជួសជុលបន្ទាយរាយចម្រូង ជីកស្នាមភ្លោះទម្លុះជាគូក្បែរជុំវិញកំពែងយ៉ាងមាំមួន ហើយចាត់ទាហានយាមល្បាតលើសើនបន្ទាយ រាយផ្លាស់ប្តូរវេនគ្នាទាំងយប់ថ្ងៃ ចាត់**តៀវហ៊ុយ**ឲ្យធំជាងគេថែរក្សាគយល្បាតក្រវែលខាងទិសបូព៌ា ចាត់ឲ្យ**គួនអ៊ូ**ថែរក្សាគយទិសឧត្តរ ចាត់ឲ្យ**ប៊ីតុក**ជាបងនាង**ប៊ីហង**ត្រូវជាបងថ្លៃ**ឡៅពី**នោះនៅត្រួតត្រារក្សាគ្រប់ក្រួ។

ឯ**កោស៊ុន**និង**តៀវលៀង** លើកទាហានចូលទៅតាំងភ្ជាប់នឹងជើងកំពែង **ឡៅពី**នៅលើសើនក្រឡេកឃើញក៏ស្រែកសួរ**កោស៊ុន**និង**តៀវលៀង**ថា យើងនិង**លីប៉ោ**មិនមានហេតុអ្វីជាទោសទាស់គ្នាសោះ ហេតុម្តេចបានជាលើកទ័ពមកខ្ទប់វាយស្រុកយើងដូច្នេះ? **កោស៊ុន**ឆ្លើយថា "ខ្លួនអ្នកឯងគិតគូរគ្នានឹង**ចូឆ្វូ**ផ្ញើសំបុត្រទៅវិញទៅមក ដើម្បីនឹងធ្វើសេចក្តីអន្តរាយដល់ចៅហ្វាយយើង រឿងទាំងអស់**លីប៉ោ**ដឹង

អស់ហើយ ហេតុម្ដេចខ្លួនហ៊ានថាមិនមានទោសទាស់ខុសវិញ?” ហើយ**កោស៊ុន**ក៏បរសេះដេញទាហានឲ្យចូលឡោមព័ទ្ធជុំវិញជើងកំពែង។ **ឡៅពី**ក៏ប្រើទាហានឲ្យត្រួតត្រារក្សាជើងបន្ទាយជាមាំមួន លុះពេលព្រឹកឡើង **តៀវលៀង**ក៏លើកទាហានចូលវាយគយខាងទិសបស្ចិម។

**គួនអ៊ូ**ឃើញរូប**តៀវលៀង**ស្អាតល្អគួរសមជានាហ្មឺនមុខមន្ត្រី ក៏ស្រែកសួរជាកលឧបាយថា ខ្លួនអ្នកមានពណ៌សម្បុរបរិបូរល្អព្រម យើងយល់ឃើញថាជាមនុស្សមានសតិបញ្ញានិងសេចក្ដីអៀនខ្មាស ហេតុម្ដេចមកនៅជាបាវព្រាវ**លីប៉ោ**ដែលជាមនុស្សចិត្តអាក្រក់? យើងឃើញមិនសមគួរសោះ។ **តៀវលៀង**បានឮដូច្នោះក៏មានសេចក្ដីខ្មាសណាស់ មិនមានឆ្លើយតបថាអ្វី។ **គួនអ៊ូ**ឃើញថា**តៀវលៀង**មានបញ្ញាហើយមានសេចក្ដីអៀនខ្មាស ក៏មិនបាននិយាយទ្រគោះបោកបោះមើលងាយទៅទៀត។ **តៀវលៀង**ក៏លើកទាហានថយទៅ ហើយលើកទៅវាយគយខាងទិសបូព៌ា។ **តៀវហ៊ុយ**ឃើញក៏នាំទាហានចេញតច្បាំងនឹង**តៀវលៀង**។ មានទាហានរត់ទៅប្រាប់**គួនអ៊ូ**ថា ឥឡូវ**តៀវលៀង**លើកចូលទៅវាយគយទិសបូព៌ា ហើយ**តៀវហ៊ុយ**ក៏លើកចេញត។ **គួនអ៊ូ**បានឮដូច្នោះក៏ស្រូតទៅប្រញាប់ ឃើញ**តៀវហ៊ុយ**លើកចេញពីទ្វារស្រុកទៅ។ **តៀវលៀង**ក្រឡេកឃើញ**តៀវហ៊ុយ**ចេញមក ក៏ឲ្យនឹករន្ធត់ភ័យខ្លាចមិនហ៊ាននឹងចូលតស៊ូបាន នាំទាហានទាំងអស់ថយទៅទៀត។ **តៀវហ៊ុយ**ឃើញបានការក៏បរពលចូលដេញពីក្រោយ។ **គួនអ៊ូ**ស្រែកឃាត់ថា កុំអាលដេញឲ្យត្រឡប់មកវិញសិន។ **តៀវហ៊ុយ**ឮក៏ប្រែត្រឡប់ទ័ពមកក្រោយ ហើយសួរ **គួនអ៊ូ**ថា សឹកសត្រូវត្រូវឱកាសស្រួលនឹងចូលយកជ័យជម្នះបាន ហេតុម្ដេចមកស្រែកឃាត់ឲ្យខូចការដូច្នេះវិញ? **គួនអ៊ូ**ក៏អធិប្បាយរាយរឿងឲ្យ**តៀវហ៊ុយ**ស្ដាប់ហើយថា ថ្វីដៃ ប្អូននិង

**តៀវលៀង**នេះ បើនឹងច្បាំងតស៊ូគ្នាក៏ល្មមកម្លាំងនឹងធ្វើបាន តែបងគិតស្មានថា**តៀវលៀង**នោះមានសតិបញ្ញាកិរិយាជាអ្នកអៀនខ្មាស បានជានាំទាហានត្រឡប់ប្រាសថយក្រោយទៅវិញពីរលើកហើយ។ បងឃើញថា**តៀវលៀង**មានគំនិតនឹងគិតបែកចិត្តចេញពី**លីប៉ោ** បានជាបងឃាត់ហាមដូច្នេះ។ **តៀវហ៊ុយ**ក៏សរសើរថា “បងគិតនេះប្រសើរណាស់ ព្រោះយល់ស្គាល់ឃើញចិត្តមនុស្សបាន” ហើយ**តៀវហ៊ុយ**ក៏លើកទាហានត្រឡប់ចូលក្នុងស្រុកវិញឲ្យត្រួតត្រារក្សាសើនបន្ទាយដូចដើម។

ឯ**តាន់យ៉ុង**ដែលកាន់សំបុត្រទៅប្ដឹង**ចូឆ្វ**នោះ លុះបានទៅដល់ហើយក៏ជូនសំបុត្រនោះទៅ**ចូឆ្វ** ៗដឹងសេចក្ដីក៏ប្រឹក្សានឹងសេនាទាហានថា **លីប៉ោ**លើកទ័ពទៅវាយស្រុកសៀវផាយនោះ ត្រូវតែយើងលើកទ័ពទៅជួយ**ឡៅពី**ជាប្រញាប់ ទោះបី**អ៊្វនសៀវ**នឹងលើកទ័ពមកខាងនេះយើងក៏មិនត្រូវវិតក្កព្រួយ ខ្លាចមួយតែ**ឡៅពៀវ**និង**តៀវស៊ីវ** ក្រែងលើកត្រឡប់មកពីក្រោយវាយយកស្រុកយើង។

**ស៊ុនហ៊ីវ**ជម្រាបថា ឯ**ឡៅពៀវ**និង**តៀវស៊ីវ**នោះ ទើបតែនឹងបរាជ័យចាញ់យើង បើទោះបីយ៉ាងណាក៏មិនអាចនឹងរិះគិតលើកមកក្នុងពេលនេះបានទេ ឯ**លីប៉ោ**នោះជាមនុស្សមានថ្វីដៃខ្លាំងពូកែ ទាំងចិត្តក៏ប្រែកំរើបតាំងខ្លួនជាធំ បើយើងនឹងសំងំទុកយូរទៅ មុខជា**លីប៉ោ**និង**អ៊្វនសុត**គប់គិតគ្នាជារូបមួយ កម្លាំងក៏រឹតតែមានច្រើនឡើង ឃើញថាយើងនឹងកម្ចាត់ចេញបានដោយលំបាកណាស់។

**គុយកែ**បានឮ**ស៊ុនហ៊ីវ**និយាយត្រូវនឹងគំនិតខ្លួនដូច្នោះ ទើបជម្រាប**ចូឆ្វ**ថា ដែល**ស៊ុនហ៊ីវ**និយាយនេះត្រូវណាស់ សុំឲ្យមហាឧបរាជលើកទ័ពទៅកម្ចាត់**លីប៉ោ**ជាប្រញាប់ចុះ ព្រោះពេលនេះកម្លាំងវានៅទន់ មុខជានឹងបានជ័យជម្នះដោយងាយ។ **ចូឆ្វ**យល់ឃើញត្រូវក៏តម្រូវឲ្យប្រុងប្រៀបរៀបកងទ័ព បង្គាប់**ហែហ្វទុន**,

**ហែហួអៀន, លីយ៉យ, លីតៀន** ទាំងបួននាយនេះឲ្យលើកទាហានដែលមានថ្វីដៃច្រើននាក់ជា កងហ្លួង លើកទៅជួយ**ឡៅពី**ឯស្រុកសៀវផាយ ឯ**តាន់យ៉ុង**ដែលកាន់សំបុត្រទៅនោះក៏ ត្រឡប់មកជាមួយនឹងកងទ័ព**ចូឆូ**។

បម្រើសេះ**កោស៊ុន**នាំសេចក្តីទៅប្រាប់**កោស៊ុន**ថា **ចូឆូ**ឲ្យ**ហែហួទុន**លើកកងទ័ពទៅជួយ**ឡៅពី**ជាច្រើន ឥឡូវលើកមកដល់ដែនស្រុកសៀវផាយហើយ។ **កោស៊ុន**ដឹងដូច្នោះក៏ភ័យស្លុតចិត្ត ទើបប្រើបម្រើសេះឲ្យនាំសេចក្តីនោះទៅប្រាប់**លីប៉ោ** ៗក៏ប្រើ**ហែហ៊ូឡេង១, ឡាន់បេង១, ចោសេង១,** និងទាហានសេះពីរយហាសិបនាក់លើកជាទ័ពណ្ហូនទៅជួយ**កោស៊ុន**ឯស្រុកសៀវផាយ។ ឯ**កោស៊ុន**មានកម្លាំងច្រើនឡើង ក៏ថយកងទ័ពចេញទៅតាំងបន្ទាយចាំទទួលកងទ័ព**ចូឆូ** ក្បែរព្រំដែនស្រុកសៀវផាយ ចម្ងាយផ្លូវប្រហែលមួយរយសិន (៤គ.ម)។ **ឡៅពី**ឃើញ**កោស៊ុន**ថយទ័ពទៅដូច្នោះ ក៏គិតឃើញថា **ចូឆូ**លើកកងទ័បមកដល់ហើយ **កោស៊ុន**បារម្ភខ្លាច**ចូឆូ**នឹងលើកទ័ពមកវាយខ្នប់ពីក្រោយបានជាថយទៅ។ **ឡៅពី**ក៏ប្រើ**ស៊ុនខៀន, ប៊ីតុក** និង**ប៊ីហាង** ឲ្យនៅរក្សាស្រុកសៀវផាយ ហើយនាំយក**គួនអ៊ូ, តៀវហ៊ុយ**និងទាហានទាំងពួងចេញទៅតាំងបន្ទាយក្រៅកំពែងស្រុកចាំទទួលទ័ព**ចូឆូ** និងបានរិះគិតគ្នាធ្វើការសង្គ្រាម តទៅ។

**ហែហួទុន**លើកទ័ពមកដល់ដែនស្រុកសៀវផាយ ក៏ប្រទះទល់ទ័ព**កោស៊ុន**។ **ហែហួទុន**ក៏បរសេះចូលតយុទ្ធនឹង**កោស៊ុន**បានហាសិបភ្លេង **កោស៊ុន**តទល់នឹង**ហែហួទុន**មិនបាន ក៏ញាក់សេះត្រឡប់ចូលបន្ទាយខ្មៅខ្លួល **ហែហ៊ូទុន**បានទំនងស្រួលក៏បរពលចូលតាមទៅ។ **ចោសេង**ឃើញ**ហែហួទុន**ដេញ**កោស៊ុន**មក ក៏លើកធ្នូបាញ់ត្រូវភ្នែក**ហែហួទុន**ខ្វាក់ ព្រួញក៏ធ្លាក់ដោតជាប់ក្នុងរង់ភ្នែក **ហែហួទុន**ស្រែកសន្ធាប់

ដោយសំឡេងខ្លាំង កន្ត្រាក់ដកយកព្រួញមកមើលឃើញកែវភ្នែកសណ្ដកជាប់នឹងចុងព្រួញចេញមក ក៏ស្រែកទៀតថា កែវភ្នែកនេះជាដួងកំណើតដ៏វិសេសមិនគួរនឹងបោះចោល **ហែហួទុន**ក៏ទំពារលេបស្រូបចូលទៅទាំងកែវភ្នែក ទាំងព្រួញបាត់ទៅក្នុងពោះ។

ឯ**ចោសេង**នោះក្រឡេកឃើញ**ហែហួទុន**ត្រូវព្រួញហើយ ក៏ធ្វេសប្រហែសគិតថា**ហែហួទុន**កាលណានឹងធ្វើការតទៅទៀតបាន ក៏មិនបានរវាំងខ្លួន **ហែហ៊ួទុន**ក៏បំផាយសេះចូលទៅលើកទួនចាក់ត្រូវ**ចោសេង**ធ្លាក់ពីលើសេះស្លាប់។ **ហែហួទុន**ក៏ត្រឡប់ចូលបន្ទាយ ទាហានទាំងឡាយក៏សរសើរ**ហែហួទុន**ថា មានថ្វីដៃខ្លាំងពូកែគ្មាននរណាស្មើបាន សត្រូវបាញ់ត្រូវភ្នែកហើយក៏នៅខំយកជ័យជម្នះបានទៀត គួរជាសេនាឯក។

**កោស៊ុន**ឃើញ**ហែហួទុន**ត្រូវព្រួញ ហើយត្រឡប់ចូលបន្ទាយដូច្នោះ ក៏លើកទ័ពត្រឡប់ដេញពីខាងក្រោយទៅ ចូលប្រកាប់ក្នុងកងទ័ព**ហែហួទុន**។ ទាហាន**ហែហួទុន**មិនដឹងខ្លួនក៏បាក់បែកខ្ចាត់ខ្ចាយ **ហែហួអៀន**ភ័យណាស់ក៏នាំ**ហែហួទុន**រត់ទម្លាយបន្ទាយចេញទៅ **លីយ៉យ**និង**លីទៀន**ក៏នាំទាហានរត់ទៅតាំងបន្ទាយនៅស្រុកចេប៉ាក។ **កោស៊ុន**ក៏លើកទ័ពដេញកាប់សម្លាប់កងទ័ព**ហែហួទុន**ស្លាប់ជាច្រើនហើយលើកទ័ពត្រឡប់ទៅវាយស្រុកសៀវផាយវិញ។ ទទួល**លីប៉ោ**លើកទ័ពមកជួបនឹង**កោស៊ុន** ៗក៏ថ្លែងព័ត៌មានដែល**ហែហួទុន**បែកទ័ពឲ្យ**លីប៉ោ**ស្ដាប់គ្រប់ប្រការ។ **លីប៉ោ**ក៏លើកទ័ពរួមគ្នានឹងទ័ព**កោស៊ុន**ទៅទល់នឹងកំពែងស្រុកសៀវផាយ ឃើញ**ឡៅពី**តាំងបន្ទាយនៅក្រៅកំពែងបីអន្លើ។ **លីប៉ោ**ក៏ប្រើ**កោស៊ុន**និង**តៀវលៀវ**លើក

ចូលទៅវាយបន្ទាយ**គួនអ៊ូ**។ ខ្លួន**លីប៉ោ**លើកចូលវាយបន្ទាយ**តៀវហ៊ុយ** ឯ**គួនអ៊ូ**និង**តៀវហ៊ុយ**ក៏លើកទាហានចេញតែសព្វខ្លួននៅមុខបន្ទាយ។

**លីប៉ោ**បែងទាហានលើកត្រឡប់ទៅខ្ទប់វាយពីក្រោយបន្ទាយ**គួនអ៊ូ** និង **តៀវហ៊ុយ** ៗមិនដឹងខ្លួន ហើយទាហានតិចជាង**លីប៉ោ**នឹងតស៊ូមិនបាន ក៏បែកខ្ចាត់ខ្ចាយចេញពីបន្ទាយអស់។

**ឡៅពី**ឃើញ**គួនអ៊ូ**, **តៀវហ៊ុយ**បែកបន្ទាយ ក៏នាំទាហានប្រមាណសាមសិបនាក់រត់ចេញពីបន្ទាយទៅដល់ទ្វារស្រុក ហើយ**ឡៅពី**ស្រែកឲ្យអ្នកចាំទ្វារបើកទ្វារទទួលៗ **លីប៉ោ**ដេញតាមមកទាន់**ឡៅពី** ទាហានទាំងសងខាងក៏លាយឡំគ្នា **ឡៅពី**រត់ចូលទៅក្នុងស្រុកបិទទ្វារមិនទាន់ **លីប៉ោ**ក៏បរពលចូលតាមទៅបាន ទាហានដែលនៅក្នុងស្រុកសៀវផាយក៏បែកខ្ចាត់ខ្ចាយអស់ទៅ។ **ឡៅពី**ឃើញទ័ព**លីប៉ោ**ដេញខ្លាន់ៗចូលមក នឹងតស៊ូមិនបានក៏លះចោលគ្រប់គ្រួភរិយាបុត្រ បរសេះរត់តាមទ្វារតទៅទិសឯលិច។ **លីប៉ោ**ក៏ដេញកាប់សម្លាប់ទាហាន**ឡៅពី**ស្លាប់វិនាសជាច្រើន។

ឯ**ប៊ីតុក**ដែលនៅរក្សាគ្រប់គ្រួ**ឡៅពី** ឃើញ**លីប៉ោ**ដេញកាប់សម្លាប់មនុស្សមកដល់មុខផ្ទះក៏ចេញទៅគោរពគំនាប់**លីប៉ោ**ថា ខ្ញុំបាទបានឮចាស់បុរាណពោលតៗមកថា អ្នកដែលនឹងតាំងខ្លួនជាធំតទៅបាននោះ ទោះនឹងវាយទ័ពចាប់យកស្រុកណា ក៏ប្រាថ្នាតែជ័យជម្នះ មនុស្សណាដែលជាគូសត្រូវក៏ធ្វើអន្តរាយតែអ្នកនោះ មិនបានធ្វើអន្តរាយទៅដល់គ្រប់គ្រួ និងភរិយាបុត្រនូវអាណាប្រជានុរាស្ត្រ ដែលឥតកំហុសនោះឡើយ។ ឥឡូវខ្លួនលោកក៏ប្រុងនឹងតាំងខ្លួនធ្វើធំ ឯគូសត្រូវលោកក៏គឺ**ចូឆូ**តែមួយប៉ុណ្ណោះ ដូច**ឡៅពី**នោះមិនមែនជាគូវិវាទនឹងលោកសោះឡើយ សព្វថ្ងៃនេះ**ឡៅពី**មានតែសចក្តីគិតដល់លោកជារឿយៗថា កាលគ្រា**អ៊ូនសុត**ប្រើ**គីឡេង**លើកទ័ពមក

វាយស្រុកសៀវផាយ បានលោកលើកទ័ពមកជួយ សួរដែលបាញ់ធ្នូនិងសំឡេងដែលនិយាយគ្នា ក៏ច្រឡំនាំឲ្យ**គីឡេង**ប្រែចិត្តគិតមេត្រីលើកទ័ពត្រឡប់ទៅវិញ **ឡៅពី**នោះមិញក៏បានសេចក្ដីសុខដរាបមក គុណលោកមានលើខ្លួន**ឡៅពី**មួយទៀត**ឡៅពី**និងលោកក៏មានឧបការៈទៅវិញទៅមក សុំកុំឲ្យលោកធ្វើអន្តរាយភរិយាបុត្រ**ឡៅពី**ឡើយ គុណរបស់លោកក៏នឹងមានលើ**ឡៅពី**ទៅមុខទៀត។

**លីប៉ោ**ឆ្លើយថា "អ្នកកុំបីវិតក្កជាទុក្ខឡើយ យើងនិង**ឡៅពី**ក៏ជាមិត្តវិស្សាសៈនឹងគ្នាមកពីដើម ឯគ្រប់គ្រួភរិយាបុត្រ**ឡៅពី**នោះ យើងមិនបានធ្វើអន្តរាយទេ" ថា ហើយក៏ឲ្យ**ប៊ីតុក**នាំភរិយា**ឡៅពី**ទៅទុកឯស្រុកគីជីវ។

**លីប៉ោ**ក៏ចាត់ចែងរៀបចំឲ្យ**កោស៊ុន** និង**តៀវលៀវ**នៅឈររក្សាស្រុកសៀវផាយ ឯ**លីប៉ោ**ក៏លើកទ័ពស្រូតចេញទៅទិសបូព៌ា ប្រាថ្នាដើម្បីនឹងវាយយកស្រុកគុនជីវ ទទួលជួបនឹង**តាន់កុង, ចុងប៉ា** ដែលមកពីបញ្ចុះបញ្ចូលពួកចោរនៅភ្នំថៃសាន់ **លីប៉ោ**ក៏ចាត់**តាន់កុង**និងនាយចោរទាំងបួននាក់ ឲ្យនៅរក្សាគយសៀវគួន ហើយ**លីប៉ោ**ក៏លើកទ័ពទៅវាយអាណាខេត្តខាងទិសបូព៌ា។

ឯ**គួនអ៊ូ**កាលរត់ពី**លីប៉ោ**ផុតពីបន្ទាយ ក៏បានជួបគ្នានឹង**តៀវហ៊ុយ**កណ្ដាលផ្លូវ **គួនអ៊ូ**សួរ**តៀវហ៊ុយ**ថា ប្អូនបានជួបប្រទះនឹង**ឡៅពី**ឬទេ? **តៀវហ៊ុយ**ប្រាប់ថា កាលខ្ញុំបែកមកនោះក៏ខ្ចាត់ខ្ចាយគ្នា មិនបានដឹងថា**ឡៅពី**នឹងរត់ទៅខាងតំបន់ណា។ **គួនអ៊ូ, តៀវហ៊ុយ**គិតដល់**ឡៅពី**ក៏កៀកកគ្នាយំ ហើយក៏នាំគ្នាទៅតាំងហ្វឹកហាត់សេនាទាហាននៅតំបន់ច្រកភ្នំមួយអន្លើ។

ឯ**ឡៅពី**រត់ចេញពីស្រុកសៀវផាយ បំផាយសេះទៅឆ្ងាយណាស់ចម្ងាយផ្លូវប្រហែលប្រាំរយសិន(២០គ.ម) ជួបប្រទះនឹង**ស៊ុនខៀន**ដែលឲ្យនៅរក្សាស្រុករត់ចេញ

ទៅមុន **ឡៅពីនិងស៊ុនខៀន**ក៏នាំគ្នាយំសោក ហើយ**ឡៅពី**សួរថា **គួនអ៊ូ, តៀវហ៊ុយ** ប្អូនយើងនឹងស្លាប់ឬរស់? រត់ទៅទីណាក៏មិនបានដឹងដំណឹងសោះ? ខ្លួនយើងពេលនេះអស់ទីពឹង ហើយដូចជាគេហែលទឹកកណ្តាលសមុទ្រ។ **ស៊ុនខៀន**ថា កើតហេតុទាំងនេះ ព្រោះលោកគប់គិតនឹងគេធ្វើអាក្រក់នឹង**លីប៉ោ** លោកទើបបានសេចក្តីលំបាកដូច្នេះ ឥឡូវនេះលោកគួរទៅរក**ចូវឆ្វ**ជាទីពឹងនឹងបានតាំងខ្លួនគិតការតទៅ។ **ឡៅពី**ឮ**ស៊ុនខៀន**ថាដូច្នោះ ក៏ធូរស្រាលក្នុងចិត្ត ទើបនាំ**ស៊ុនខៀន**គេចចូលទៅក្នុងព្រៃ ដើម្បីនឹងរក**ចូវឆ្វ**ឯក្រុងហ៊ូតោ។

កាល**ឡៅពីនិងស៊ុនខៀន**រត់ទៅនោះ អត់បាយអត់ទឹកលំបាកពេកណាស់ លុះដើរទៅដល់ភូមិតំបន់ណា ក៏បបួលគ្នាចូលទៅសំបាយគេអាស្រ័យ។ បណ្តារាស្ត្រទាំងពួងដឹងថាឈ្មោះ**ឡៅពី**ចាញ់ទ័ពគេរត់មក ក៏មានចិត្តអាណិតអាសូរពន់ប្រមាណ នាំញាតិសន្តានរៀបតុលៀងអាហារឲ្យ**ឡៅពី**បរិភោគគ្រប់ភូមិស្ថានរៀងទៅ។ វេលាល្ងាចថ្ងៃមួយនោះ **ឡៅពី**ក៏ដើរទៅផុតភូមិក្បែរព្រៃ ហើយប្រឹក្សានឹង**ស៊ុនខៀន**ថា យើងឃ្លាតចាកមកពីស្រុកជាច្រើនថ្ងៃហើយ មិនដែលខ្វះខាតចំណីអាហារបរិភោគសោះ ទើបតែថ្ងៃនេះនឹងរកទីសំណាក់អាស្រ័យពុំបាន បើដូច្នោះតើនឹងគិតធ្វើដូចម្តេច? កាល**ឡៅពីនិងស៊ុនខៀន**កំពុងប្រឹក្សាគ្នា ក៏ក្រឡេកមើលទៅឃើញផ្ទះមួយនៅក្នុងព្រៃ **ឡៅពី**អរណាស់នាំ**ស៊ុនខៀន**ចូលទៅសុំសំណាក់នៅផ្ទះនោះ។ ឯ**ឡៅអាន់**ម្ចាស់ផ្ទះក្រឡេកឃើញ**ឡៅពី** និង**ស៊ុនខៀន**ចូលមក ក៏មិនស្គាល់ថាជាអ្នកណាទេ ចេញមកទទួលហៅឡើងទៅលើផ្ទះ។

**ឡៅពី**សួរថា អ្នកឈ្មោះអ្វី? **ឡៅអាន់**ឆ្លើយថា “ខ្ញុំបាទឈ្មោះ**ឡៅអាន់**ជាមនុស្សក្រខ្សត់អនាថា នៅតែពីរនាក់នឹងភរិយាធ្វើចម្ការដាំបន្លែបង្ការនៅទីនេះ” រួច

ហើយ**ឡៅអាន់**ក៏សួរទៅវិញថា អ្នកទាំងពីរអញ្ជើញមកពីស្រុកណា? ហេតុម្ដេចក៏ស្វះស្វែងមកដល់ទីនេះតែពីរនាក់មិនឃើញមានបក្សពួកជូនមក? **ឡៅពី**ថ្លែងព័ត៌មានតាំងពីដើមដល់ចុងឲ្យ**ឡៅអាន់**ស្ដាប់ហើយថា យើងមកនេះដើម្បីនឹងរក**ចូវឆ្វ**តែឥឡូវជួនពេលក៏យប់ យើងសុំឈប់ស្នាក់មួយរាត្រី ដល់ថ្ងៃស្អែកនឹងលាចេញទៅទៀត។ **ឡៅអាន់**បានស្ដាប់ក៏មានចិត្តត្រេកអរ អញ្ជើញ**ឡៅពី**និង**ស៊ុនខៀន**ចូលទៅក្នុងផ្ទះ ហើយ**ឡៅអាន់**ក៏ចូលទៅក្នុងទីជើងក្រាន រិះគិតអាននឹងធ្វើអាហារជូន**ឡៅពី**បរិភោគ នឹងរិះរកវត្ថុអ្វីក៏គ្មានសោះ បើនឹងទៅរកឯណាក៏ជួនវេលាយប់ក្រែងមិនទាន់ការ **ឡៅអាន់**ក៏សម្លាប់ភរិយាខ្លួននោះ ហើយវះពន្លះយកសាច់ភ្លៅនៃភរិយានោះចៀនឆាខ្លះស្ងោខ្លះ រួចរហ័សលើកចេញមកជូន**ឡៅពី**និង**ស៊ុនខៀន**បរិភោគ។

**ឡៅពី**សួរថា នេះសាច់សត្វអ្វី? **ឡៅអាន់**ឆ្លើយថា សាច់នេះខ្ញុំរកបានពីព្រឹកមិញ។ **ឡៅពី**សម្គាល់ថាពិត ក៏នាំ**ស៊ុនខៀន**បរិភោគទាល់តែឆ្អែត។ លុះវេលាយប់**ឡៅអាន់**ក៏យកសេះរបស់**ឡៅពី**និង**ស៊ុនខៀន**ទៅចងទុកខាងក្រោយផ្ទះ ហើយរៀបដំណេកឲ្យ**ឡៅពី**និង**ស៊ុនខៀន**ដេកក្នុងផ្ទះ។ ព្រឹកឡើង**ឡៅពី**លា**ឡៅអាន់**ហើយចុះទៅស្រាយសេះក្រោយផ្ទះ ទទួលក្រឡេកទៅឃើញសពភរិយា**ឡៅអាន់**ចោលនៅខាងក្រោយផ្ទះ **ឡៅពី**ភ័យស្លុតក៏ពិនិត្យសួរ**ឡៅអាន់**ថា នេះសពអ្នកឯណាបានជាយកមកចោលនៅទីនេះ? **ឡៅអាន់**ឆ្លើយថា “សពនេះជាសពភរិយាខ្ញុំ” ហើយនិយាយរៀបរាប់តាមហេតុដំណើរត្រង់ជម្រាបឲ្យ**ឡៅពី**ស្ដាប់។ **ឡៅពី**បានឮដូច្នោះ ក៏គិតអាណិតខ្លោចចិត្តស្រក់ទឹកនេត្រាយំសោកានៅទីនោះ ហើយនិយាយថា “គុណូបការៈរបស់អ្នក មាននៅលើខ្លួនខ្ញុំនឹងរកទីបំផុតគ្មាន បើប្រសិនខ្ញុំមានជីវិតរស់នៅដរាបណា ខ្ញុំនឹងតបស្នងសងគុណអ្នកដរាបនោះ” ហើយ**ឡៅពី**ក៏ឡើងសេះលា**ឡៅអាន់**

ចេញពីភូមិនោះ ទៅចម្ងាយផ្លូវបីរយសិន (១២គ.ម) ឃើញកងទ័ពលើកមកជាច្រើន **ឡៅពី**ក្រឡេកមើលឃើញទង់ជ័យជាសម្គាល់ក៏ដឹងថាកងទ័ព**ចូឆ្លូ**លើកមក**ឡៅពី**ក៏ធូរស្រាលក្នុងចិត្តគិតត្រេកអរ ទើបនាំ**ស៊ុនខៀន**គេចពីផ្លូវតម្រង់ទៅជួបនឹង**ចូឆ្លូ** ហើយ**ឡៅពី**ជម្រាបថា "ស្រុកសៀវផាយអន្តរាយនឹង**លីប៉ោ**ទៅហើយ **គួនអ៊ូ, តៀវហ៊ុយ**ប្អូនខ្ញុំបាទនិងបុត្រភរិយាស្ម័គ្របក្សពួកទាំងឡាយ ក៏បែកបាក់ខ្ចាត់ខ្ចាយទៅអស់មិនដឹងជាស្លាប់ឬរស់នៅឯណាឡើយ" និយាយហើយក៏យំដំឱរា។ **ចូឆ្លូ**ឃើញកាលណាក៏មានចិត្តអាណិតអានាថខ្លោចផ្សាយំសោកានៅទីនោះ។ **ឡៅពី**ពណ៌នារឿងដែល**ឡៅអាន់**សម្លាប់ភរិយាអារយកសាច់ចម្អិនអាហារឲ្យ**ឡៅពី** និង**ស៊ុនខៀន**បរិភោគនោះឲ្យ**ចូឆ្លូ**ស្តាប់។ **ចូឆ្លូ**ក៏មានចិត្តគិតសរសើរថា នឹងរកអ្នកឯណាល្អស្មើគ្មាន ទើបយកមាសឲ្យ**ស៊ុនខៀន**មួយរយតម្លឹងនាំទៅឲ្យ**ឡៅអាន់**ដែលមានគុណនឹង**ឡៅពី** ហើយ**ចូឆ្លូ**ក៏នាំ**ឡៅពី**លើកទ័ពទៅដែនស្រុកចេប៉ាក់។

ឯ**ហែហ្គូអៀន**និង**ហែហ្គូទុន**ដែលនាំគ្នារត់ទៅនោះ ក៏បានជួបប្រទះនឹង**លីយ៉យ, លីតៀន** ហើយតាំងបញ្ចុះបញ្ចូលឲ្យប្រមូលសេនាទាហាននៅជាមួយគ្នានឹង**លីយ៉យ** លុះបានដឹងថា**ចូឆ្លូ**លើកទ័ពមកហើយ ក៏នាំគ្នាចេញទៅទទួល**ចូឆ្លូ** ហើយអញ្ជើញឲ្យចូលទៅក្នុងបន្ទាយអធិប្បាយរឿងឲ្យ**ចូឆ្លូ**ស្តាប់។ **ចូឆ្លូ**ក៏ចូលទៅសួរ**ហែហ្គូទុន**កំពុងដេកឈឺធ្ងន់ឃើញអាការៈមិនអន់ស្រន់ ក៏ចាត់ទាហាននាំខ្លួន**ហែហ្គូទុន**ចូលទៅក្រុងហ៊ូតោ ហើយចាត់ទាហានយាមល្បាតលាតក្រវែលស្តាប់ការឲ្យដឹងថា **លីប៉ោ**វេលានេះនឹងគិតប្រការម្តេច។ បម្រើសេះក៏ចេញទៅស្តាប់ការវិលមកវិញជម្រាប**ចូឆ្លូ**ថា **លីប៉ោ** និង**តាន់កុង, ចុងប៉ា** ទៅបញ្ចុះបញ្ចូលបានពួកចោរដែលតាំងនៅភ្នំថៃសាន់ជាច្រើន ឥឡូវលើកជាកងទ័ពទៅវាយយកអាណាខេត្តខាង

ទិសបូព៌ាបានជាច្រើនតំបន់ហើយ។ **ចូវឆ្វ**បានឮដូច្នោះ ក៏ចាត់ប្រើ**ចោយិន**លើកពលបីពាន់ទៅវាយស្រុកសៀវផាយ ខ្លួន**ចូវឆ្វ**ក៏នាំ**ឡៅពី**និងទាហានទាំងឡាយ លើកតាម**លីប៉ោ**ទៅដល់គយសៀវគួនជាដែនស្រុកខាងទិសបូព៌ា ក៏ជួបប្រទះនឹង**ស៊ុនគួន, ង៉ទុន, អ៊ុនឡេ, សៀងហ៊ូ** ដែលជានាយចោរនៅភ្នំថៃសាន់ លើកបក្សពួកប្រហែលបីម៉ឺនមកស្ទាក់ពីមុខទ័ព**ចូវឆ្វ** ៗក៏ប្រើ**ខៅធូ**ចេញច្បាំងនឹងពួកចោរ។ **ខៅធូ**និងពួកចោរបួននាយបានតច្បាំងគ្នាជាពន្លឹក តាំងពីព្រឹកទាល់ថ្ងៃត្រង់ នាយចោរទាំងបួននោះអស់កម្លាំងនឿយណាស់។ **ចូវឆ្វ**ក៏លើកទ័ពឈូនទៅជួយ**ខៅធូ**សម្លាប់ពួកចោរស្លាប់បែកទ័ពរត់ទៅរក**តាន់កុង**ដែលនៅចាំគយ។ **ចូវឆ្វ**លើកទាហានបណ្ដោយទៅតាំងបន្ទាយជាប់ជិតគ្នានឹងគយសៀវគួន។

**លីប៉ោ**ដឹងដំណឹងថា **ចូវឆ្វ**លើកទ័ពមកវាយពួកចោរបែក ក៏ឆ្ងល់ក្នុងចិត្តគិតក្រែង**ចូវឆ្វ**នឹងលើកទ័ពទៅវាយស្រុកឈីជីវ រួចប្រមូលសេនាទាហានបានច្រើនប្រុងនឹងលើកទៅវាយគយសៀវគួនវិញ។ **តាន់តេង**ដឹងការណ៍ដូច្នោះក៏ទៅជួបនឹង**តាន់គុយ**ជាបិតានិយាយថា ពីដើមកិច្ចការទាំងអម្បាលនេះ**លីប៉ោ**ផ្ទុកធុរៈដាក់ឲ្យយើងគិត ឥឡូវ**ចូវឆ្វ**លើកទ័ពមកជិតហើយ ឃើញថា**លីប៉ោ**នឹងមានសេចក្ដីថ្លោះការដោយ**ចូវឆ្វ**ជាប្រាកដ ព្រោះវេលានេះ**លីប៉ោ**ប្រុងនឹងលើកទ័ពទៅតច្បាំងនឹង**ចូវឆ្វ** បើ**លីប៉ោ**បែកទ័ពត្រឡប់ចូលមកស្រុកវិញ ត្រូវបិតានិង**ប៊ីតុក**បិទទ្វារទុកឲ្យមាំកុំឲ្យ**លីប៉ោ**ចូលមកបាន ខ្លួនខ្ញុំបាទនឹងទៅជាមួយនឹង**លីប៉ោ**ដើម្បីនឹងគិតការតទៅ។ **តាន់គុយ**និយាយថា កូននិយាយដូច្នោះក៏ត្រូវហើយ តែថាដែល**លីប៉ោ**នឹងឲ្យនៅរក្សាស្រុកនោះ មិនមែនតែយើងម្នាក់ឯងទេ ទាហានរបស់**លីប៉ោ**ក៏នៅជាមួយដោយច្រើន ឃើញថាយើងនឹងធ្វើការមិនសម្រេច។ **តាន់តេង**ឆ្លើយថា "បិតាកុំវិតក្កព្រួយ ខ្ញុំបាទ

នឹងរិះគិតឲ្យ**លីប៉ោ**បែងទាហានទៅទុកឯស្រុកដទៃ” និយាយហើយក៏លា**តាន់គុយ**ជាបិតាទៅជួបនឹង**លីប៉ោ**។

**លីប៉ោ**ក្រឡេកឃើញ**តាន់តេង**ចូលទៅ ក៏មានចិត្តត្រេកអរសាទរ ហើយបបួល**តាន់តេង**ថា យើងនឹងលើកទ័ពទៅច្បាំងនឹង**ចូឆ្វ**នៅគយសៀវគួន។ **តាន់តេង**ជម្រាបថា ដែលលោកនឹងលះចោលស្រុកឈីជីវឥឡូវនេះមិនស្រួលទេ ព្រោះខ្ញុំបាទយល់ថា ស្រុកនេះជាទីមុខសឹកខ្លាច**ចូឆ្វ**នឹងលើកទ័ពមកវាយខ្នប់ពីខាងក្រោយ ដោយយើងមិនទាន់ដឹងខ្លួនក៏បានទៅ**ចូឆ្វ** សុំឲ្យលោកចាត់ចែងស្បៀងអាហារ និងគ្រប់គ្រួឲ្យបែងរំលែកទៅទុកឯស្រុកហែហ្វីខ្លះ ទុកជាស្រុកនេះអន្តរាយ យើងក៏បានអាស្រ័យស្រុកហែហ្វីជាកម្លាំង។ **លីប៉ោ**មិនបានដឹងថា **តាន់តេង**នឹងគិតប្រទូសរ៉ាយដល់ខ្លួន ក៏បង្គាប់**សុងហៀន**និង**ង៉ុយសុក**ឲ្យឃុំនាំគ្រប់គ្រួនិងស្បៀងអាហារទៅទុកឯស្រុកហែហ្វីតាមពាក្យ**តាន់តេង** ហើយ**លីប៉ោ**នាំ**តាន់តេង**និងទាហានលើកទៅគយសៀវគួន។ លុះទៅដល់កណ្ដាលផ្លូវ **តាន់តេង**និយាយនឹង**លីប៉ា**ថា យើងនឹងលើកទ័ពទៅធ្វើសង្គ្រាមនឹង**ចូឆ្វ**គ្រានេះ មិនបានដឹងថា កម្លាំងសឹកនឹងច្រើនឬតិចដូចម្ដេចសោះឡើយ សុំឲ្យលោកតាំងបន្ទាយនៅតំបន់នេះសិនចុះ ខ្ញុំបាទនឹងសុំយកអាសាចេញទៅស្ដាប់មើលកម្លាំង**ចូឆ្វ** បើបានដឹងថាច្រើន ឬតិចហើយនឹងត្រឡប់មកជម្រាបលោកវិញ។ **លីប៉ោ**មិនបានដឹងដល់ក៏ឈប់ទ័ពតាំងនៅទីនោះ។

**តាន់តេង**លា**លីប៉ោ**ទៅត្រង់គយសៀវគួន ហើយក៏ចូលទៅជួបនឹង**តាន់កុង**ក្នុងទីគយនិយាយនឹង**តាន់កុង**ថា **លីប៉ោ**ដឹងរឿងថា **ចូឆ្វ**វាយនាយចោរទាំងបួននោះបែកហើយ ក៏លើកទ័ពមកតាំងភ្ជាប់គ្នានឹងគយសៀវគួននេះ **លីប៉ោ**ខឹងណាស់ថា អ្នកធ្វើការធ្វេសប្រហែសឲ្យចាញ់ប្រៀប**ចូឆ្វ** បានជា**លីប៉ោ**លើកទ័ពមកនឹងយកទោស

អ្នក។ **តាន់កុង**ឆ្លើយថា **ចូឆ្វ**លើកទ័ពមកគ្រានេះធំជាពន្លឹក យើងនឹងតស៊ូមិនបានទេ ត្រូវតែប្រុងប្រៀបរៀបចំទាហានរក្សាស្រុកទុកឲ្យមាំមួន ចូរអ្នកត្រឡប់ទៅជម្រាប **លីប៉ោ**ចុះ ថាយើងនឹងទប់ទល់ទ័ព**ចូឆ្វ**នោះ ឃើញទុញទាល់ណាស់ ឲ្យ**លីប៉ោ**លើកទ័ពទៅរក្សាស្រុកឈីជីវ និងចំណុះឲ្យមាំមួនចុះ ដើម្បីកុំឲ្យមានសេចក្ដីអន្តរាយ។ **តាន់តេង**បានស្ដាប់**តាន់កុង**ថាដូច្នោះ ក៏មិនឆ្លើយតបថាអ្វីសោះ ក្រោកឡើងទៅពិនិត្យមើលលើសើនបន្ទាយ ឃើញកងទ័ព**ចូឆ្វ**តាំងជាប់គ្នាជិតក្បែរបន្ទាយ លុះពេលយប់ **តាន់តេង** ក៏សរសេរសំបុត្របិទចងនៅចុងព្រួញ ហើយបាញ់ផ្ញើសំដៅទៅក្នុងកងទ័ព **ចូឆ្វ** សេចក្ដីក្នុងសំបុត្រនោះថា "ខ្ញុំបាទ**តាន់តេង**នឹងសុំយកអាសាជាកលសឹកខាងក្នុង ខ្ញុំបាទនឹងយកភ្លើងអុជឡើងជាសម្គាល់ សុំឲ្យមហាឧបរាជលើកចូលប្លន់បន្ទាយចុះ ខ្ញុំនឹងជួយធ្វើការឲ្យសម្រេច"។ លុះវេលាព្រឹក**តាន់តេង**ក៏លា**តាន់កុង**ត្រឡប់ទៅរក**លីប៉ោ**ហើយជម្រាបថា ខ្ញុំបាទឃើញ**ចូឆ្វ**មានកម្លាំងច្រើនណាស់ ទាំង**ស៊ុនគួន**និងនាយចោរទាំងពួងដែលលោកឲ្យនៅនឹង**តាន់កុង**នោះ ខ្ញុំបាទឃើញប្រែចិត្តទៅខាង**ចូឆ្វ**ហើយ ឥឡូវខ្ញុំបាទកំជាប់**តាន់កុង**ឲ្យប្រយ័ត្នរក្សាគយឲ្យមាំទាំទម្រាំតែលោកលើកទ័ពទៅដល់ **តាន់កុង**ក៏មានចិត្តព្រួយបារម្ភខ្លាំងណាស់ សូមលោកលើកទ័ពប្រញាប់ឲ្យដល់ទៅគយសៀវគួនក្នុងវេលាថ្ងៃនេះ នឹងបានជួយ**តាន់កុង**ធ្វើចម្បាំងវេលានេះ។

**លីប៉ោ**បានស្ដាប់ដូច្នោះ ក៏មានសេចក្ដីត្រេកអរពន់ពេក ហើយបាននិយាយនឹង**តាន់តេង**ថា ឥឡូវ**ចូឆ្វ**លើកចូលមកព័ទ្ធជុំកំពែងស្រុកហើយ បើនឹងនៅក្រែងចូលទៅបន្ទាយគយមិនបាន ឲ្យអ្នកឯងស្រួតទៅមុនដើម្បីនឹងប្រាប់**តាន់កុង**ថា យើងនឹងលើកទ័ពទៅដល់ក្នុងវេលាយប់នេះ ឲ្យចាំបើកទ្វារទទួលហើយអុជភ្លើងសញ្ញាឡើង

ហើយនឹងលើកពលពារទម្លាយទ័ព**ចូឆ្វ**ចូលទៅឲ្យបាន។ **តាន់តេង**ក៏លា**លីប៉ោ**ស្រូតទៅគយសៀវគួនជាមុន លុះដល់ហើយក៏ប្រាប់**តាន់កុង**ថា ខ្ញុំបាននាំដំណឹងទៅជម្រាប**លីប៉ោ** ៗក៏យល់ឃើញត្រូវដូចគំនិតខ្ញុំ ឥឡូវ**លីប៉ោ**ផ្ដាំមកថា កម្លាំងទ័ព**ចូឆ្វ**ខ្លាំងពន្លឹកណាស់ ឃើញថាលោកនឹងតទល់មិនបានទេ ព្រោះគយសៀវគួននេះមិនមែនជាទីសំខាន់ ឲ្យលើកទ័ពទៅស្រុកឈើជីវនឹងបានជួយ**លីប៉ោ**គិតគូរគ្នាការពារស្រុក។ **តាន់កុង**មិនដឹងក្នុងកល**តាន់តេង** ក៏សម្គាល់ថា មែន លុះពេលយប់ក៏នាំទាហានរត់ចោលបន្ទាយគយនោះទៅ មិនបានប្រាប់នាយចោរទាំងបួនឲ្យដឹង។ ខណៈកាល**តាន់កុង**លើកពលរត់ទៅនោះ **តាន់តេង**ក៏លបដុតភ្លើងឆេះឡើងក្នុងបន្ទាយ ទទួល**លីប៉ោ**លើកទ័ពមកដល់ក្រឡេកឃើញពន្លឺភ្លើងភ្លឺឡើង ក៏សម្គាល់ថា**តាន់កុង**អុជទទួល ក៏បង្ហំបរពលចូលទៅជួបនឹង**តាន់កុង**ដែលកំពុងរត់ចេញមក។ **លីប៉ោ**សម្គាល់ថាកងទ័ព**ចូឆ្វ**ក៏ដេញទាហានចូលប្រកាប់ជាប់ដៃគ្នា ខាង**តាន់កុង**មិនដឹងថា**លីប៉ោ**សម្គាល់ថា ទ័ព**ចូឆ្វ**លើកចូលមកស្ទាក់ពីមុខ ក៏ដេញពលចូលគ្រលុកដើម្បីនឹងទម្លាយចេញទៅ ទាហានទាំងសងខាងក៏ចាក់កាប់សម្លាប់គ្នាស្លាប់ជាច្រើនណាស់។

ឯ**ចូឆ្វ**ឃើញភ្លើងឆេះក្នុងបន្ទាយដូចសំបុត្រ**តាន់តេង** ក៏ដេញពលចូលទៅពារទម្លាយបន្ទាយ នាយចោរទាំងបួននាក់ដែលនៅរក្សាគយនោះ មិនបានដឹងការណ៍ថាយ៉ាងម៉េច ក៏ប្រមូលទាហានចេញទៅតច្បាំងគ្នានឹងកងទ័ព**ចូឆ្វ**ជាពន្លឹក។ ពួកចោរនោះមានទាហានតិចតស៊ូនឹងកងទ័ព**ចូឆ្វ**មិនបាន ក៏បាក់បែកខ្ចាត់ខ្ចាយរត់យកតែខ្លួន។ **ចូឆ្វ**ក៏លើកពលចូលទៅតាំងនៅក្នុងគយសៀវគួនបាន។

ឯ**លីប៉ោ**និង**តាន់កុង**វង្វេងច្រឡំចាក់កាប់សម្លាប់គ្នាត្រាតែថ្ងៃរះ ទាហានទាំងសងខាងក៏ក្រឡេកឃើញមុខគ្នាស្គាល់ច្បាស់ជាទ័ពគ្នាឯង ក៏ឈប់ប្រកាប់គ្នា **តាន់កុង**ម្នីម្នាចូលទៅជួបនឹង**លីប៉ោ** ពណ៌នារាយរឿងឲ្យ**លីប៉ោ**ស្តាប់គ្រប់ប្រការ **លីប៉ោ**និង**តាន់កុង**ក៏ដឹងច្បាស់ថា ហេតុដែលកើតចលាចលដូច្នេះដោយសារឧបាយកល**តាន់តេង**។ **លីប៉ោ**ក៏នាំសេនាទាហានទាំងអស់ស្រូតត្រឡប់ទៅស្រុកឈីជីវ លុះដល់ជើងកំពែង**លីប៉ោ**ក៏ហៅសេនាទាហានដែលយាមល្បាតឲ្យបើកទ្វារទទួល។

ឯ**ប៊ីតុក**ឃើញកងទ័ព**លីប៉ោ**លើកចូលមកស្រែកឲ្យបើកទ្វារ ក៏បង្គាប់ឲ្យទាហានដែលនៅលើសើនលើកធ្នូបាញ់ចម្រុះចុះទៅ ហើយ**ប៊ីតុក**ស្រែកប្រាប់**លីប៉ោ**ថា ស្រុកឈីជីវនេះមិនមែនជារបស់**លីប៉ោ**ឯងទេ គឺជាស្រុក**ឡៅពី**ចៅហ្វាយយើងកាលពីមុននោះឯងបានមកដណ្តើមយក ឥឡូវយើងមកដណ្តើមយកវិញ ចូរឯងលើកទាហានត្រឡប់ទៅវិញចុះ។

**លីប៉ោ**ភ័យស្លុតចិត្តក៏ស្រែកសួរ**ប៊ីតុក**ថា **តាន់គុយ**ដែលយើងឲ្យនៅរក្សាស្រុកនេះឥឡូវទៅឯណាបាត់ទៅហើយ? **ប៊ីតុក**ឆ្លើយថា **តាន់គុយ**នោះយើងចាប់ខ្លួនសម្លាប់ទៅហើយ។ **លីប៉ោ**បានឮដូច្នោះទើបងាកមកសួរ**តាន់កុង**ថា **តាន់តេង**បានមកជាមួយដែរឬទេ? **តាន់កុង**ឆ្លើយកាត់ថា ហេតុដូចម្តេចលោកនៅសួររកឈ្មោះអាស្រូវនោះទៀត? **លីប៉ោ**ក៏ឲ្យត្រួតពិនិត្យមើលក្នុងពួកទាហានមិនឃើញ**តាន់តេង**សោះ។ **តាន់កុង**និយាយនឹង**លីប៉ោ**ថា ដែលយើងនឹងលើកចូលកាប់ទម្លាយយកស្រុកឈីជីវនេះ ជាការទុញទាល់ហើយ សុំឲ្យលោកលើកទាហានទៅស្រុកសៀវផាយចុះ នឹងបានរិះគិតគ្នានឹង**កោស៊ុន, តៀវលៀវ** ហើយលើកទ័ពត្រឡប់មកយកស្រុកយើងឲ្យបានវិញ។ **លីប៉ោ**យល់ឃើញត្រូវក៏លើកទ័ពទៅស្រុកសៀវផាយ។

ឯ**តាន់តេង** កាលលបដុតភ្លើងឆេះឡើងក្នុងបន្ទាយគយសៀវគួនហើយ ក្រឡេកមើលទៅឃើញទាហាន**លីប៉ោ** និងទាហាន**តាន់កុង**វង្វេងកាប់សម្លាប់គ្នាជាពន្លឹកដូច្នោះ **តាន់តេង**ក៏លបចេញពីក្នុងបន្ទាយសៀវគួនស្រូតរូតទៅស្រុកសៀវផាយ ប្រាប់**កោស៊ុន, តៀវលៀវ**ថា ម្សិលមិញ**ចូឆូ**លើកទ័ពមកឡោមព័ទ្ធ**លីប៉ោ** ៗតស៊ូនឹង**ចូឆូ**មិនបាន ក៏ប្រើខ្ញុំឲ្យមករកអ្នក ដើម្បីឲ្យអ្នកលើកទាហានទៅជួយ។ **កោស៊ុន, តៀវលៀវ**ភ័យស្លុតចិត្ត សម្គាល់ថាពិតប្រាកដ ក៏លើកទាហានចេញពីស្រុកសៀវផាយចេញទៅជួយ**លីប៉ោ**។ **តាន់តេង**ក៏ចេញទៅរក**ចោយិន** ហើយនាំយកកងទ័ពទៅតាំងនៅក្នុងស្រុកសៀវផាយ។

**កោស៊ុន, តៀវលៀវ**ជម្រាបលីប៉ោថា **តាន់តេង**ជាបុត្រ**តាន់គុយ**ទៅប្រាប់ខ្ញុំបាទថា **ចូឆូ**ឡោមព័ទ្ធលោកជាប់ ហើយឲ្យខ្ញុំបាទប្រញាប់លើកទ័ពទៅជួយ ដែលខ្ញុំបាទចេញចោលស្រុកមកដូច្នេះ ទោសខ្ញុំបាទខុសជាទម្ងន់ណាស់។ **តាន់កុង**ក៏និយាយនឹង**លីប៉ោ**ថា ដែល**តាន់តេង**វាគិតប្រទូសរ៉ាយដល់លោកគ្រានេះ លោកនឹងគិតដូចម្ដេច? **លីប៉ោ**ឆ្លើយថា “អ្នកកុំវិតក្កឡើយ ដែល**តាន់តេង**វាទុរយសដល់យើងដូច្នេះ យើងត្រូវតែតាមសងសឹកកាត់ក្បាលវាឲ្យបាន” ហើយនាំ**កោស៊ុន, តៀវលៀវ**និងសេនាទាហានទាំងពួង លើកចូលទៅស្រុកសៀវផាយ ឃើញទាហាននៅត្រួតត្រារក្សាសើនបន្ទាយមាំមួនណាស់ មានទង់ជ័យដោយនៅមុខបន្ទាយជាទង់ជ័យរបស់**ចូឆូ** **លីប៉ោ**ខឹងណាស់ក៏បំផាយសេះចូលទៅដល់ជើងកំពែង ហើយស្រែកជេរ**តាន់តេង**ថា អាចោរអាពុកនិងកូនពីរនាក់ អញស្រឡាញ់រាប់អានតម្កើងឲ្យធ្វើធំ គួរឬអាឯងមកទុរយសក្បត់ចិត្តអញ ៗនឹងកាត់ក្បាលអាឯងឲ្យបាន។

**តាន់តេង**ឈរនៅលើសេីន លើកដៃចង្អុលមុខ**លីប៉ោ**ហើយស្រែកតបមកថា ខ្លួនកុំព្រហើនចរថា យើងនេះជាខ្ញុំរាជការព្រះចៅ**ហៀនតេ**ផ្សេងទេ កាលគ្រា**អ៊្វិនសុត**លើកទ័ពមកវាយយកស្រុកឈីជីវនោះ មិនពីព្រោះគំនិតអញនិងបិតាអញទេតើ បានជាខ្លួនឯងរួចចាកសេចក្ដីស្លាប់ ឥឡូវម្ដេចត្រឡប់ថាអញប្រទូសរ៉ាយនឹងឯងវិញ? **លីប៉ោ**ខឹងណាស់ ក៏បរពលចូលនឹងហែកបន្ទាយទម្លាយកំពែងស្រុកសៀវផាយ។ ទទួល**តៀវហ៊ុយ**ដែលបែកទ័ពទៅតាំងហ្វឹកហាត់ទាហាននៅភ្នំបងយ៉ុងនោះ បានដឹងថា **លីប៉ោ**បែកខ្ញែកទ័ពដោយកលឧបាយរបស់**តាន់តេង**ហើយ ក៏ស្រូតរូតប្រញាប់លើកទ័ពតម្រង់ទៅស្រុកសៀវផាយ។ **លីប៉ោ**ឃើញក៏ថយទាហានចេញមក ហើយប្រើ**កោស៊ុន**ចេញតយុទ្ធនឹង**តៀវហ៊ុយ**បានប្រាំភ្លែង **លីប៉ោ**ឃើញកម្លាំង**កោស៊ុន**តស៊ូនឹង**តៀវហ៊ុយ**មិនបាន ក៏បរសេះចូលជួយ**កោស៊ុន**ប្រយុទ្ធគ្នានឹង**តៀវហ៊ុយ**។

ខណៈនោះ**ចូឆ្វ**ដឹងថា**លីប៉ោ**ខូចស្រុកនឹង**ប៊ីតុក, តាន់គុយ**ហើយក៏លើកកងទ័ពតម្រង់ទៅស្រុកសៀវផាយ ឃើញ**លីប៉ោ**និង**តៀវហ៊ុយ**ច្បាំងជាប់ដៃ **ចូឆ្វ**ក៏ឲ្យទាហានចោមព័ទ្ធជុំវិញ។ **លីប៉ោ**ឃើញដូច្នោះក៏ដោះខ្លួនចេញពី**តៀវហ៊ុយ** បំផាយសេះទម្លាយកងទ័ព**ចូឆ្វ**ចេញទៅបាន។ **តៀវហ៊ុយ**ក៏បំផាយសេះទន្រ្ទានទៅទៀត។

ឯ**គួនអ៊ូ**កាលបែកទ័ពទៅ បានទៅតាំងហាត់សមសេនាទាហាននៅស្រុកហៃជីវ លុះបានដឹងថា **លីប៉ោ**ចាញ់ឧបាយកល**តាន់តេង** ក៏ស្រូតលើកទាហានតម្រង់ទៅស្រុកសៀវផាយ ប្រទះនឹង**លីប៉ោ**កណ្ដាលផ្លូវ **គួនអ៊ូ**ក៏ស្រែកសួរថា អា**លីប៉ោ** អាឯងរត់ទៅណា? **លីប៉ោ**ខឹងណាស់ក៏បរសេះចូលប្រយុទ្ធគ្នានឹង**គួនអ៊ូ** ទទួល**តៀវហ៊ុយ**តាមមកទាន់ **លីប៉ោ**ភ័យតក់ស្លុតក៏បំផាយសេះរត់ចូលទៅក្នុងស្រុកហៃហ្វី ហើយចាត់ចែងទាហានឲ្យឡើងយាមល្បាតជុំវិញសើនបន្ទាយ។

**តៀវហ៊ុយ**ដេញ**លីប៉ោ**មកប្រទះនឹង**គួនអ៊ូ** ៗប្រាប់**តៀវហ៊ុយ**ថា កាលយើងពីរនាក់បងប្អូនបែកព្រាត់គ្នាទៅច្រកភ្នំនោះ បងបានទៅនៅហ្វឹកហាត់ទាហាននៅស្រុកហៃជីវ។ **តៀវហ៊ុយ**ប្រាប់ថា កាលខ្ញុំព្រាត់គ្នានៅច្រកភ្នំនោះខ្ញុំបានទៅហ្វឹកហាត់ទាហាននៅភ្នំបងយ៉ុង លុះដឹងថា**លីប៉ោ**បែកខ្វែកកងពល ខ្ញុំក៏លើកត្រឡប់មកស្ទាក់ច្បាំងនឹង**លីប៉ោ**។ **ឡៅពី**បងយើងឥឡូវបានចូលទៅនៅនឹង**ចូឆូ**ហើយ។ **គួនអ៊ូ**បានស្តាប់ដូច្នោះក៏មានចិត្តសោមនស្សត្រេកអរពន់ប្រមាណ ទើបនាំ**តៀវហ៊ុយ**ចូលទៅរក**ឡៅពី**ក្នុងកងទ័ព**ចូឆូ**។ **ឡៅពី**ឃើញ**គួនអ៊ូ**, **តៀវហ៊ុយ**ទៅដល់ក៏សប្បាយចិត្តណាស់ ស្ទុះចេញមកទទួល ហើយអធិប្បាយរាយរឿងកម្សត់ពិបាក កាលបែកបាក់ព្រាត់គ្នាទៅនោះ ឲ្យ**គួនអ៊ូ**, **តៀវហ៊ុយ**ស្តាប់ ហើយក៏នាំចូលទៅគំនាប់**ចូឆូ** ៗក៏នាំ**ឡៅពី**, **ចោយិន**, **តាន់តេង** លើកទាហានចូលទៅស្រុកឈីជីវ។ **ប៊ីតុក**ដឹងថា**ចូឆូ**លើកទ័ពមក ក៏ចេញទៅទទួលនាំចូលទៅក្នុងស្រុក ហើយ**ប៊ីតុក**ទៅគំនាប់**ឡៅពី**ពណ៌នារឿងឲ្យ**ឡៅពី**ស្តាប់ **ឡៅពី**ដឹងថាមិនមានសេចក្តីអន្តរាយក៏ត្រេកអរណាស់។

ឯ**តាន់តេង**កាលចូលទៅដល់ស្រុកឈីជីវហើយ ក៏ចូលទៅជួបនឹង**តាន់គុយ**ជាបិតា ដំណាលរឿងហេតុឲ្យបិតាស្តាប់ ហើយនាំគ្នាទៅគំនាប់**ចូឆូ** ៗក៏ឲ្យរៀបតុលៀងអាហារអញ្ជើញ**តាន់គុយ**, **តាន់តេង** និងបណ្តានាហ្មឺនសេនាទាហានទាំងពួងឲ្យបរិភោគ ហើយ**ចូឆូ**ក៏សួរប្រាស្រ័យនឹង**តាន់គុយ**, **តាន់តេង**ថា “អ្នកធ្វើការបានសម្រេចដូចគំនិតដែលបានគិតទុកមកនោះ ឃើញថាបានសេចក្តីគាប់ប្រសើរដល់យើងជាអនេកណាស់” ថាហើយក៏លើកអាណាខេត្តខាងបូព៌ាទិសដប់មណ្ឌល ឲ្យនាំស្លួយសារអាករឡើង**តាន់គុយ**គ្រប់រដូវ ហើយតាំង**តាន់តេង**ជា **ហុកតោជៀងគុន** គឺនាយទាហានធំ។

កាល**ចូឆូ**បានស្រុកឈីជីវហើយ ក៏តាំងស្តាប់ដំណឹងនិងប្រៀបប្រុងសេនាទាហានឲ្យមានកម្លាំងព្រមព្រៀងគ្នា រួចបង្គាប់ទាហានថា យើងត្រូវលើកទ័ពទៅតាមចាប់**លីប៉ោ**ឯស្រុកហែហ្វីទៀត។ **ជៀយ៉ុក**ទីប្រឹក្សាឆ្លើយថា ដែលមហាឧបរាជនឹងលើកទៅវាយស្រុកហែហ្វីគ្រានេះ ខ្ញុំយល់ថា**លីប៉ោ**នោះប្រៀបដូចសុនខទាល់ច្រក ក៏នឹងស៊ូច្បាំងត្រាតែអស់តម្រិះនិងកម្លាំង ប្រសិន**លីប៉ោ**រត់ចេញទៅបាន មុខជានឹងទៅរក**អ៊ួនសុត** បើ**លីប៉ោ**និង**អ៊ួនសុត**គប់គិតគ្នាជាពួកមួយហើយ ក៏នឹងបានជាកងទ័ពធំ បើដូច្នេះសូមឲ្យមហាឧបរាជចាត់ទាហានដែលមានថ្វីដៃ លើកទ័ពមួយប៉ែកទៅចាំស្កាត់ផ្លូវនៅទីមាត់កំពង់ស្រុកហួយណាំ បើ**លីប៉ោ**នឹងរត់ទៅរក**អ៊ួនសុត**វេលាណា គង់តម្រង់ត្រង់ទៅលើទីនោះ យើងនឹងបានស្កាត់ទុកកុំឲ្យចេញទៅបាន ប្រសិនបើ**អ៊ួនសុត**នឹងលើកទ័ពមកជួយ**លីប៉ោ**វិញក៏គង់នឹងមកមិនរួច មួយយ៉ាងទៀត **ស៊ុនគួន, អ៊ុនឡេ, ង៉ទុន, សៀងហ៊ូ** ដែលជាមេចោរបែកទ័ពពីតាន់សៀនគួនទៅនោះ ក៏មិនបានដឹងប្រាកដជាទៅតាំងនៅតំបន់ណា ខ្លាចក្រែងវាលើកមកជួប**លីប៉ោ** ដូច្នេះ សុំឲ្យមហាឧបរាជលើកទៅកម្ចាត់ពួកចោរចេញសិន។

**ចូឆូ**ថា យើងនឹងឲ្យ**ឡៅពី**ទៅចាំស្ទាក់**អ៊ួនសុត**នៅកំពង់ហួយណាំ តាមផ្លូវដែលពួកចោរនឹងលើកគ្នាមកជួយ**លីប៉ោ**នោះ អ្នកកុំវិតក្កឡើយ យើងនឹងទទួលធានាគិតរឿងនេះឲ្យបានស្រួល។

**ឡៅពី**បានឮ**ចូឆូ**ថាដូច្នេះក៏ទទួលថា ដែលនឹងទៅចាំស្ទាក់**លីប៉ោ**និង**អ៊ួនសុត** ខ្ញុំនឹងសុំទទួលយកអាសា។ **ចូឆូ**ក៏ទទួលយល់ព្រម។ លុះវេលាព្រឹកឡើង **ឡៅពី**ក៏ចាត់ឲ្យ**ប៊ីតុក**និង**កាន់យ៉ុង**នៅរក្សាគ្រប់គ្រួ ខ្លួន**ឡៅពី, គួនអ៊ូ, តៀវហ៊ុយ** និង**ស៊ុនខៀន**ក៏

លើកទាហានទៅតាំងទ័ពនៅកំពង់ស្រុកហ្លួយណាំ ឯ**ចូវឆូ**លើកទ័ពទៅវាយស្រុកហែហ្វី។

កាល**លីប៉ោ**ទៅតាំងទ័ពនៅស្រុកហែហ្វីនោះ ស្បៀងអាហារក៏បរិបូរគ្រប់គ្រាន់ គូស្នាមភ្លោះជុំវិញស្រុកក៏ជ្រៅទឹកដក់ពេញ កាលដឹងថា **ចូវឆូ**លើកទ័ពតាមមក **លីប៉ោ**មិនបានគិតនឹងចេញតច្បាំងនឹង**ចូវឆូ** គ្រាន់តែប្រុងប្រៀបរៀបសេនាទាហាន និងគ្រឿងសាស្ត្រាវុធ ឡើងយាមលើសើនបន្ទាយជាមាំមួន។ **តាន់កុង**និយាយនឹង**លីប៉ោ**ថា ឥឡូវ**ចូវឆូ**លើកទ័ពមក មិនទាន់បានទីស្នាក់ជាមាំមួនទេ ហេតុម្តេចក៏លោកនៅស្ងៀមមិនចេញទៅច្បាំងនឹង**ចូវឆូ** បើបង្អង់ឲ្យ**ចូវឆូ**តាំងបន្ទាយជាមាំមួនហើយ យើងក៏ធ្វើការលំបាក។ **លីប៉ោ**ថា យើងធ្វើសង្គ្រាមចាញ់ប្រៀប**ចូវឆូ**ច្រើនក្តារហើយ គ្រានេះយើងត្រូវបង្អង់តាំងខ្លួនឲ្យខ្ជាប់ខ្ជួននៅក្នុងស្រុកសិន ចាំកាលណា**ចូវឆូ**លើកទាហានឆ្លងគូចូលមកដល់ជើងកំពែង សឹមយើងចេញតទល់ គង់តែ**ចូវឆូ**នឹងចាញ់ប្រៀបយើងជាប្រាកដ។

កាល**ចូវឆូ**លើកទ័ពមកដល់ស្រុកហែហ្វី ក៏តាំងទ័ពនៅជិតកំពែងស្រុកប្រហែលដប់សិន(៤០០ម) **ចូវឆូ**ក៏ឡើងជិះសេះឆ្លងគូឆ្លងចូលទៅដល់ជើងកំពែង ហើយស្រែកហៅ**លីប៉ោ**ថា កាលគ្រា**តាំងតុះ**ប្រែចិត្តក្បត់ផែនដី អ្នកឯងរិះគិតនឹងសម្លាប់**តាំងតុះ**ចេញ គ្រានេះឈ្មោះអ្នកឯងមានសេចក្តីគាប់ប្រសើរល្អនឹងរាជការច្រើន ឥឡូវអ្នកឯងត្រឡប់មកចូលគំនិតនឹង**អ៊្វីនសុត** ដែលជាមនុស្សក្បត់ផែនដីវិញ កិត្តិសព្ទក៏ជ្រួតជ្រាបទៅដល់ព្រះសោតព្រះកាណ៌នៃព្រះចៅ**ហៀនតេ** បានជាទ្រង់ព្រះពិរោធត្រាស់ប្រើយើងឲ្យលើកទ័ពមក បើវេលានេះអ្នកឯងលះបង់មិនទៅចូលគំនិតនឹង**អ៊្វីនសុត**ទេ គឺមានចិត្តសុចរិតត្រង់នឹងផែនដីវិញ ក៏ចូរប្រញាប់ចេញមករកយើង

ដោយស្រួល យើងនឹងបានជួយកែខែក្រាបពិតទូលព្រះចៅ**ហៀនតេ**ឲ្យទ្រង់អនុញ្ញាតទោស ហើយចិញ្ចឹមឲ្យធ្វើជានាហ្មឺនតទៅ បើអ្នកឯងមិនចេញមករកយើងដោយស្រួលទេ តែយើងវាយយកស្រុកនេះបានហើយ អ្នកឯងត្រូវដឹងខ្លួនជាប្រាកដក្នុងទោសជាមហន្ត ដែលខ្លួនបានធ្វើទុកមកពីមុននេះ។

**លីប៉ោ**ស្រែកតបថា បើប្រសិនមហាឧបរាជមានសេចក្ដីករុណាដល់ខ្លួនខ្ញុំមែន ឲ្យលើកទ័ពថយទៅវិញឲ្យអស់សិនចុះ ខ្ញុំនឹងបានជួបជុំពិគ្រោះនឹងទីប្រឹក្សាជាក្រោយ។

កាល**ចូអ្នូ**និង**លីប៉ោ**ពិគ្រោះគ្នានោះ **តាន់កុង**ឈរពីក្រោយខ្នង**លីប៉ោ**បានឮ ក៏ខឹងច្រឡោតលើកធ្នូចង្កុលមក**ចូអ្នូ**ហើយបាញ់តម្រង់ទៅ ព្រួញក៏ត្រូវចំមួក**ចូអ្នូ** ៗ ក្រឡេកឃើញ**តាន់កុង**ឈរពីក្រោយខ្នង**លីប៉ោ** ក៏ស្រែកថា “អញសម្លាប់អាឯងឲ្យបាន អាឯងមិនរួចពីដៃអញទេ” ហើយក៏បំផាយសេះវិលមកដេញទាហានឲ្យលើកសង្កុញចូលទៅព័ទ្ធស្រុកហែហ្វីជុំវិញ។ **តាន់កុង**និយាយនឹង**លីប៉ោ**ថា **ចូអ្នូ**លើកកងទ័ពមកពីស្រុកហ៊្វតោច្រើនខែហើយ ទាហានវាក៏មានសេចក្ដីនឿយហត់ណាស់ សុំឲ្យលោកបែងរំលែកទាហានយើងចេញទៅក្រៅស្រុក ខ្លួនខ្ញុំបាទនឹងទទួលនៅរក្សាត្រួតត្រាខាងក្នុង បើ**ចូអ្នូ**លើកទ័ពមកវាយស្រុកវេលាណា ត្រូវលោកព្រួតវាយខ្នប់ពីខាងក្រោយទ័ព**ចូអ្នូ** ខ្ញុំបាទនឹងតទល់ពីខាងមុខ បើ**ចូអ្នូ**ប្រែទៅតទល់នឹងលោកវិញ ខ្ញុំបាទនឹងលើកទាហានវាយសង្កុញពីខាងក្រោយទៅ សេចក្ដីដែលយើងធ្វើកលបញ្ឆោតយ៉ាងនេះ គង់តែ**ចូអ្នូ**នឹងរារែកបែកខ្ញែកកងទ័ពត្រឡប់ជាដាច់ស្បៀងអាហារ គង់នឹងបរាជ័យមិនខាន។ **លីប៉ោ**យល់ត្រូវផង ក៏ចាត់ចែងសេនាទាហាន

ទុកព្រម ហើយចូលទៅនិយាយនឹងនាង**ងៀមស៊ី**ជាភរិយា ពណ៌នារឿងរ៉ាវឲ្យស្ដាប់តាមគំនិត ដែល**តាន់កុង**គិតនោះគ្រប់ប្រការ។

នាង**ងៀមស៊ី**ឆ្លើយថា ដែលលោកនឹងលើកទ័ពចេញទៅក្រៅស្រុកនោះ ប្រសិនជាអន្តរាយ ធ្វើម្ដេចខ្ញុំនឹងបានព្យាបាលរក្សាលោក។ **លីប៉ោ**បានស្ដាប់ភរិយាថាដូច្នោះ ក៏ទន់ចិត្តអាណិតភរិយាបុត្រមិនដឹងជាគិតប្រការម្ដេច ក៏មិនបានចេញនិយាយការរាជការដល់បីថ្ងៃ។ **តាន់កុង**ក៏ចូលទៅជួបនឹង**លីប៉ោ**និយាយថា **ចូឆ្វ**លើកទ័ពរុករានទន្ទ្រានចូលមកដល់ជើងកំពែងហើយ ម្ដេចឡើយក៏លោកមិនអើពើនៅស្ងៀមដូច្នេះ ស្រុកនេះមិនអន្តរាយដោយ**ចូឆ្វ**ទេឬ? **លីប៉ោ**ថា ដែលយើងគិតការទុកនោះយើងនាំឲ្យព្រួយទទេទៅ ត្រូវតែយើងរិះគិតរក្សាស្រុកទុកឲ្យមាំមួនទៅចុះឃើញស្រួលជាជាង។ **តាន់កុង**ថា ខ្ញុំបាទបានឮថាស្បៀងអាហារក្នុងកងទ័ព**ចូឆ្វ**នៅស្តើងណាស់ទៅហើយ ឥឡូវ**ចូឆ្វ**ប្រើបម្រើទៅនាំស្បៀងពីក្រុងហ៊ូតោទៀត សុំឲ្យលោកលើទៅចាំស្កាត់ដណ្ដើមស្បៀង**ចូឆ្វ** ឃើញនឹងខូចការដោយស្នាដៃរបស់យើង។ **លីប៉ោ**យល់ត្រូវក៏ចូលទៅប្រឹក្សានឹងនាង**ងៀមស៊ី**ទៀត។ នាង**ងៀមស៊ី**ឆ្លើយថា "ដែលលោកទុកចិត្ត**តាន់កុង**ឲ្យនៅរក្សាស្រុកនោះ ខ្ញុំយល់ថា**តាន់កុង**តស៊ូនឹង**ចូឆ្វ**មិនបានទេ បើលោកទៅហើយ កិច្ចការដែលនឹងរក្សាស្រុកខាងក្រោយគង់នឹងអន្តរាយ ខ្ញុំនឹងបែរមុខទៅសង្ឃឹមអ្នកឯណា កាលគ្រាលោកចោលខ្ញុំទុកក្នុងស្រុកទៀងអាន់នោះ កុំតែបាន**បាំងស៊ី**ជួយរិះគិតបញ្ជូនខ្ញុំឲ្យចេញមកដល់លោក ក៏ខ្ញុំមិនរួចខ្លួន ឥឡូវខ្ញុំមិនបានឃើញអ្នកឯណាដែលនឹងទីពឹងបាន បើលោកលើកទ័ពចេញទៅគ្រានេះ នោះនឹងបានលាភសក្ការៈប៉ុន្មានក៏ត្រូវលោកគិតដល់ទ្រូងខ្ញុំ ដែលជាគូកម្សត់កម្រនឹងគ្នានោះសិនចុះ" និយាយហើយក៏សោកាពិលាបឱបបាទា**លីប៉ោ** ៗក៏មានចិត្តអាណិតអាណាថ

ពន់ប្រមាណណាស់ មិនដឹងបើនឹងរិះគិតកែប្រែយ៉ាងណា ក៏ចូលទៅរកនាង**តៀវសៀន**ដែលជាភរិយាបន្ទាប់ ហើយអធិប្បាយរាយរឿងឲ្យនាង**តៀវសៀន**ស្ដាប់។ នាង**តៀវសៀន**ក៏ហាមឃាត់អង្វរករ**លីប៉ោ** ដូចនាង**ងៀមស៊ី**គ្រប់ប្រការ។ នាង**តៀវសៀន**បឱបបាទា**លីប៉ោ**សោកាទួញយំ។ **លីប៉ោ**ក៏បបោសអង្អែលថា "នាងកុំវិតក្កជាទុក្ខព្រួយឡើយ ទោះបីយ៉ាងណាបងមិនចោលប្អូនឲ្យមានសេចក្ដីអន្តរាយទេ នឹងខ្លាចថ្វីដំណូចប៉ុន**ចូឆូ**នោះ ទួននិងសេះបងក៏មានកម្លាំងច្រើន បងនឹងតាំងត្រួតត្រារក្សាស្រុកនេះឲ្យមាំមួនមិនឲ្យ**ចូឆូ**ចូលមកបាន" ហើយ**លីប៉ោ**ក៏ត្រឡប់ចេញមកនិយាយនឹង**តាន់កុង**ថា ដែល**ចូឆូ**ប្រើទាហានចូលទៅនាំយកស្បៀងអាហារពីក្រុងហ៊ូតោនោះ គឺវាធ្វើបញ្ឆោតយើងជាកលឧបាយ ឲ្យយើងលើកទ័ពទៅចាំដណ្ដើមស្បៀងបើកាលណាយើងទៅឯណោះ វានឹងលើកកងទ័ពមកវាយយកស្រុកឯណេះនឹងបានដោយងាយ ហេតុនេះខ្ញុំយល់ថានឹងលើកទ័ពទៅតាមពាក្យអ្នកនោះ ក៏គង់នឹងថ្លោះការជាប្រាកដ។

**តាន់កុង**ឮ**លីប៉ោ**ថាដូច្នោះ ក៏មិនមានតបឆ្លើយថាដូចម្ដេច ក្រោកដើរចេញទៅក្រៅហើយនិយាយប្រាប់សេនាទាហានទាំងពួងថា យើងទាំងឡាយរាល់គ្នាក្នុងវេលានេះ ឃើញនឹងដល់នូវសេចក្ដីវិនាសអន្តរាយក្ស័យអាយុជីវិតប្រាកដហើយ ព្រោះ**លីប៉ោ**គិតការខុសពុំបានយកតាមគំនិតប្រាជ្ញាអ្នកឯណាសោះ **លីប៉ោ**មិនបានគិតនឹងចេញតតាំងច្បាំងនឹង**ចូឆូ**ទេ ចេះតែនាំនាង**ងៀមស៊ី** នាង**តៀវសៀន**ផឹកស្រាជាអចិន្ត្រៃយ៍ព្រឹកល្ងាច ប្រាថ្នានឹងឲ្យរសាយសេចក្ដីទុក្ខលំបាក។

ឯ**ខៅគី, អងកាយ**ទីប្រឹក្សាឃើញ**លីប៉ោ**មិនបានគិតការសង្គ្រាមដូច្នោះ ក៏នាំគ្នាចូលទៅរំឭកថា ដែលលោកនៅស្ងៀមព្រងើយកន្តើយដូច្នេះ ស្រុកហែហ្វីនឹង

អន្តរាយអសារឥតការដោយថ្វីដៃ**ចូឆ្វ**ជាប្រាកដហើយ សព្វថ្ងៃនេះ**អ៊ួនសុត**នៅស្រុកហ្លួយណាំក៏មានសេនាទាហានជាច្រើន សូមឲ្យលោកចាត់បម្រើទៅនិយាយនឹង**អ៊ួនសុត**ថា លោកនឹងលើកកូនក្រមុំឲ្យជាភរិយាកូន**អ៊ួនសុត** ឲ្យ**អ៊ួនសុត**លើកកងទ័ពមកជួយវាយខ្ទប់កងទ័ព**ចូឆ្វ** ៗក៏គង់នឹងបែកខ្ញែកចេញមិនខាន។ **លីប៉ោ**យល់ឃើញត្រូវក៏ធ្វើសំបុត្រឲ្យ**ខៅគី, អងកាយ**កាន់ចេញទៅឲ្យ**អ៊ួនសុត**។ **ខៅគី**ជម្រាបថា ខ្ញុំបាទនឹងសុំទាហានចេញជូនដំណើរទៅឲ្យផុតកងទ័ព**ចូឆ្វ**សិន។ **លីប៉ោ**ក៏ចាត់ប្រើ**តៀវលៀវ**ជានាយទ័ពមុខ ប្រើ**ឡាន់បេង**ជានាយទ័ពក្រោយលើកទាហានមួយពាន់ចេញទៅ។ លុះពេលយាមបីយប់ **ខៅគី, អងកាយ** ក៏លា**លីប៉ោ**ចេញពីស្រុកហែហ្វី។ **តៀវលៀវ**និង**ឡាន់បេង, ខៅគី**ទៅដល់ដែនហ្លួយណាំ។ **ឡាន់បេង**បែងចែកទាហានប្រាំរយទៅជាមួយ**ខៅគី, អងកាយ** ឲ្យ**តៀវលៀវ**នាំទាហានប្រាំរយត្រឡប់មកស្រុកហែហ្វីវិញ។ ហើយ**ខៅគី, អងកាយ, ឡាន់បេង**ក៏លើកចូលទៅក្នុងស្រុកហ្លួយណាំចូលទៅជួបនឹង**អ៊ួនសុត** យកសំបុត្រ**លីប៉ោ**ជូនឲ្យ**អ៊ួនសុត** ៗលាមើលឃើញសេចក្ដីថា "ខ្ញុំ**លីប៉ោ**សូមគំនាប់មក**អ៊ួនសុត** ដ្បិតអ្នកឲ្យអ្នកបម្រើមកសុំកូនក្រមុំខ្ញុំ នឹងនាំទៅឲ្យកូនអ្នកនោះ ខ្ញុំនៅមិនទាន់រៀបមង្គលការ ព្រោះ**ចូឆ្វ**លើកទ័ពមកជាច្រើនណាស់ លើសកម្លាំងដែលនឹងចេញតទល់ ហេតុនេះ ខ្ញុំសុំឲ្យអ្នកលើកកងទ័ពមកជួយវាយខ្ទប់ពីក្រោយ ដោយផ្លូវមេត្រីរាប់អានគ្នាតទៅ"។

**អ៊ួនសុត**មើលសំបុត្រហើយក៏ថា **លីប៉ោ**នេះជាមនុស្សនិយាយមិនមានពាក្យសត្យពិតត្រង់ៗណាសោះ កាលគ្រាមុននោះយើងឲ្យសំបុត្រទៅសុំកូនក្រមុំ **លីប៉ោ**ទទួលថាព្រមឲ្យដល់យើង ឲ្យយើងរៀបទៅទទួលនាំយកតាមទំនៀម **លីប៉ោ**ក៏

ត្រឡប់កែប្រែទៀត។ ឥឡូវ**ចូវឆ្វ**លើកទ័ពមកព័ទ្ធស្រុក ហេតុម្តេចមិនពឹងប្រស្រ័យ**ចូវឆ្វ** ក៏ត្រឡប់បែរមុខមកពឹងយើងជាគូសត្រូវទៅវិញ?

**ខៅគី**បានឮដូច្នោះ ក៏ឆ្លើយតបថា **លីប៉ោ**ថៅហ្វាយខ្ញុំបាទនឹងបានគិតប្រទូសរ៉ាយនឹងលោកដូច្នោះក៏ទេ កាលលោកប្រើ**ហាន់អ៊ិន**ទៅសុំកូនក្រមុំនោះ **លីប៉ោ**មានសេចក្តីត្រេកអរណាស់ ព្រមលើកកូនក្រមុំឲ្យបម្រើលោកនាំមកជូនលោកជាពិត ដែលថាវេលានោះ**ចូវឆ្វ**ប្រើកលឧបាយផ្សេងៗទើបការនោះប្រែត្រឡប់ខុសទៅ ឥឡូវ**លីប៉ោ**ផ្តាំមកជម្រាបលោកថា ម្តងនេះព្រមជូនកូនក្រមុំមកលោកជាប្រាកដហើយ។

**អ៊ួនសុត**តបថា ឥឡូវ**លីប៉ោ**ប្រហែលតស៊ូនឹង**ចូវឆ្វ**មិនបានហើយឬ? បានជាលើកកូនក្រមុំឲ្យយើង បើប្រសិនម្តងនេះជាការពិតមែន ក៏ត្រូវតែ**លីប៉ោ**បញ្ជូនកូនក្រមុំមកឲ្យយើងសិន ទើបយើងនឹងលើកកងទ័ពទៅជួយ ដែលនឹងឲ្យយើងលើកទៅជួយជាមុននោះ យើងមិនទុកចិត្តជាប្រាកដទេ ព្រោះ**លីប៉ោ**ធ្វើឲ្យយើងរង្កៀសចិត្តម្តងទៅហើយ។ **ខៅគី**បានស្តាប់ក៏មិនបានឆ្លើយតបថាម្តេច ទើបលា**អ៊ួនសុត**នាំគ្នាចេញពីស្រុកហួយណាំមកវិញ លុះមកដល់ប្រទល់ដែនឃើញបន្ទាយ**ឡៅពី**តាំងស្កាត់ទទឹងផ្លូវ។ **ខៅគី** និង**អងកាយ**ក៏និយាយនឹង**ឡាន់បេង**ថា យើងជាអ្នកកាន់សំបុត្រខ្លួនអ្នកជាសេនា**លីប៉ោ** ៗប្រើឲ្យមកជួយការពារយើងមិនឲ្យមានសេចក្តីអន្តរាយ វេលាយប់នេះយើងនឹងលបចេញទៅឲ្យផុតបន្ទាយ**ឡៅពី**ចុះ អ្នកចូរនាំពលទាហានជួយការពារពីក្រោយឲ្យមាំមួន។ **ឡាន់បេង**ទទួលពាក្យពេចន៍ស្រេចហើយ លុះដល់ពេលយប់ **ខៅគី** និង**អងកាយ**ក៏លបចេញទៅផុតបន្ទាយ**ឡៅពី**។ **ឡាន់បេង**ក៏នាំទាហានការពារពីក្រោយ។

**តៀវហ៊ុយ**នៅក្នុងបន្ទាយ បានឮសូរជើងមនុស្សដើរសន្ធឹកណាស់ក៏នឹកសង្ស័យនាំទាហានចេញទៅមើល ឃើញ**ឡាន់បេង**លើកទាហានពារបន្ទាយឆ្លងទៅ **តៀវហ៊ុយ**ក៏បំផាយសេះដេញ**ឡាន់បេង**ពីក្រោយ **ឡាន់បេង**ក៏ទាញសេះបែរមកតនឹង **តៀវហ៊ុយ**បានមួយភ្លែង **តៀវហ៊ុយ**ចាប់ខ្លួន**ឡាន់បេង**បាន ឯទាហានប្រាំរយក៏រត់បែកព្រាត់ព្រាយអស់ទៅ។ **តៀវហ៊ុយ**ក៏នាំខ្លួន**ឡាន់បេង**ទៅជូន**ឡៅពី** ៗសួរសាកដឹងសេចក្ដីសព្វគ្រប់ហើយ ក៏ឲ្យបម្រើឃុំនាំខ្លួន**ឡាន់បេង**ទៅឲ្យ**ច្វូឆ្វូ** ៗសួរ**ឡាន់បេង**ថាខ្លួនឯងទៅណាមកណា? **ឡាន់បេង**ក៏ឆ្លើយជម្រាបតាមដំណើរពិតឲ្យ**ច្វូឆ្វូ**ស្ដាប់។

ចប់សៀវភៅទីពីរ

សូមរង់ចាំអានសៀវភៅទីបីបន្តទៀត។

សូមអរគុណ។

ណុល ដារ៉ា